# រដ្ឋធម្មនុញ្ញទាំងឡាយ

# នៃ

# កម្ពុជា

រៀបចំចងក្រង និងបោះពុម្ពដោយអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
ខែ កញ្ញា ឆ្នាំ ២០១១

**អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ :**

- អគ្គលេខាធិការ ទូរស័ព្ទ : ០១២ ៨១៩ ៨៧៨
- អគ្គលេខាធិការរង ទូរស័ព្ទ : ០១១ ៨៩៣ ៩៨២

- ទូរស័ព្ទ : (៨៥៥)២៣-៧២៦ ០៣១ /២៣-៧២០ ៩១២ / ២៣-៧២៦ ០៣៤
- ហ្វាក់ : (៨៥៥)២៣-៧២៦ ០៣១ / ២៣-៧២០ ៩១២
- អ៊ីមែល : **sgccc@online.com.kh** / **info@ccc.gov.kh**
- **Website : http://www.ccc.gov.kh**
- ប្រអប់សំបុត្រលេខ : ២៤៨៣ សង្កាត់បឹងព្រលឹត , ភ្នំពេញ

# អារម្ភកថា

តាមមតិណែនាំដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **ឯក សំអុល** ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ អាណត្តិបីឆ្នាំ លើកទី ៥ (២០១០-២០១៣) និងការដែលឯកឧត្តមប្រធានបានផ្តល់ឯកសាររដ្ឋធម្មនុញ្ញគ្រប់សម័យកាលជារបស់ផ្ទាល់ខ្លួន ដែលឯកឧត្តមបានស្រាវជ្រាវ រក្សាទុកជាច្រើនឆ្នាំមកហើយ ឱ្យដល់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញធ្វើការរៀបចំចងក្រងបោះពុម្ពផ្សាយ ដើម្បីជាគុណប្រយោជន៍សម្រាប់ជនរួមជាតិសិក្សាស្រាវជ្រាវអំពីប្រធានបទ "រដ្ឋធម្មនុញ្ញនៃកម្ពុជា" ចាប់ពីការកកើត រហូតមកដល់សព្វថ្ងៃ។

រដ្ឋធម្មនុញ្ញ ជាច្បាប់កំពូល ដែលច្បាប់ និងឯកសារគតិយុត្តទាំងអស់នៅក្នុងប្រទេសនីមួយៗត្រូវអនុលោមឱ្យស្របតាម បើពុំនោះទេ ច្បាប់ និងឯកសារគតិយុត្តទាំងនោះនឹងអធម្មនុញ្ញភាព។ តាមទ្រឹស្តីស្តីពី រដ្ឋធម្មនុញ្ញ គេឃើញមានទស្សនៈយល់ដឹងប្លែកៗគ្នា មានជាអាទិ៍ ÷ រដ្ឋធម្មនុញ្ញជាកិច្ចសន្យានៃសង្គម រដ្ឋធម្មនុញ្ញជាលក្ខន្តិកៈនៃអំណាច រដ្ឋធម្មនុញ្ញជាលក្ខណៈនៃទស្សនវិជ្ជានយោបាយ និងរដ្ឋធម្មនុញ្ញជាលក្ខន្តិកៈសម្រាប់អ្នកដែលគ្រប់គ្រងគេ។

ចាប់តាំងពីឆ្នាំ ១៩៤៧ រហូតមកដល់បច្ចុប្បន្ន ប្រទេសកម្ពុជាមានរដ្ឋធម្មនុញ្ញចំនួន ០៦ ដែលផ្លាស់ប្តូរទៅតាមរបបនយោបាយ រួមមាន ÷

១- រដ្ឋធម្មនុញ្ញប្រទេសកម្ពុជា (ឆ្នាំ ១៩៤៧)

២- រដ្ឋធម្មនុញ្ញសាធារណរដ្ឋខ្មែរ

៣- រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ

៤- រដ្ឋធម្មនុញ្ញ នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា

៥- រដ្ឋធម្មនុញ្ញ នៃរដ្ឋកម្ពុជា

៦- រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ( ឆ្នាំ ១៩៩៣)

អគ្គលេខាធិការដ្ឋានបានរៀបចំចងក្រង និងបោះពុម្ពផ្សាយរដ្ឋធម្មនុញ្ញទាំង ០៦ របស់ប្រទេសកម្ពុជាបញ្ចូលគ្នាធ្វើជាសៀវភៅតែមួយ ដោយគោរពតាមច្បាប់ដើមទាំងស្រុង ដែលទទួលបានពីឯកឧត្តមប្រធានក្រុមប្រឹក្សាធម្មនុញ្ញ។

អគ្គលេខាធិការដ្ឋានសង្ឃឹមថា ការប្រមូលចងក្រងរដ្ឋធម្មនុញ្ញទាំងអស់នេះនឹងរួមចំណែករក្សាទុកនូវឯកសាររដ្ឋធម្មនុញ្ញដែលមានកន្លងមក និងដើម្បីជាមូលដ្ឋានគ្រឹះ ប្រគេនព្រះសង្ឃ ថ្វាយសម្តេច ព្រះអង្គម្ចាស់ និងជូន សម្តេច ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ សិស្ស និស្សិត និង ជនរួមជាតិខ្មែរ ធ្វើការសិក្សាស្រាវជ្រាវអំពីការវិវត្តនៃរបបនយោបាយ លទ្ធិប្រជាធិបតេយ្យ ការគោរពសិទ្ធិមនុស្ស និងការវិវត្តនៃអក្ខរាវិរុទ្ធនៃភាសាខ្មែរ នៅក្នុងមាតុភូមិនៃយើង។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១១

**អគ្គលេខាធិការ**

**ចាន់ រ៉ាស៊ី**

# មាតិកា

**ទំព័រ**

**I. រដ្ឋធម្មនុញ្ញប្រទេសកម្ពុជា ១៩៤៧** ............................................................. ១-៤២

- ចំពូក ១ : ធម្មជាតិ នឹងសណ្ឋានរបស់រដ្ឋ
  មាត្រា ១ ដល់ មាត្រា ២............................................................. ៣
- ចំពូក ២ : សេរីភាព សិទ្ធិ នឹង ករណីយកិច្ច របស់ខេមរជន
  មាត្រា ៣ ដល់ មាត្រា ១៦............................................................ ៤
- ចំពូក ៣ : អំពីច្បាប់នឹងអំណាច
  មាត្រា ១៧ ដល់ មាត្រា ២៤........................................................... ៧
- ចំពូក ៤ : អំពីព្រះមហាក្សត្រិយ៍
  មាត្រា ២៥ ដល់ មាត្រា ៤៧........................................................... ៩
- ចំពូក ៥ : អំពីរដ្ឋសភា
  មាត្រា ៤៨ ដល់ មាត្រា ៦៩ ....................................................... ១៤
- ចំពូក ៦ : អំពីក្រុមប្រឹក្សាព្រះរាជអាណាចក្រ
  មាត្រា ៧0 ដល់ មាត្រា ៧៨ ....................................................... ១៩
- ចំពូក ៧ : អំពីរដ្ឋមន្ត្រី
  មាត្រា ៧៩ ដល់ មាត្រា ៩៤ .......................................................២២
- ចំពូក ៨ : អំពីអំណាចតុលាការ
  មាត្រា ៩៥ ដល់ មាត្រា ៩៦ .......................................................២៦
- ចំពូក ៩ : បញ្ញត្តិទូទៅ
  មាត្រា ៩៧ ដល់ មាត្រា ១០៣....................................................២៧

- ចំពូក ១០ : អន្តរបញ្ញត្តិ
មាត្រា ១០៤ ដល់ មាត្រា ១០៧ ........................................ ២៩
- សេចក្តីអធិប្បាយពាក្យខ្លះក្នុងរដ្ឋធម្មនុញ្ញ ........................................ ៣១

**រដ្ឋធម្មនុញ្ញប្រទេសកម្ពុជា** ( បោះពុម្ពឆ្នាំ ១៩៦៩)........................................ ៤៣-៨៤
- ចំពូក ១ : ធម្មជាតិ នឹងសណ្ឋានរបស់រដ្ឋ
មាត្រា ១ ដល់ មាត្រា ២........................................ ៤៥
- ចំពូក ២ : សេរីភាព-សិទ្ធិនឹងករណីយកិច្ច របស់ខេមរជន
មាត្រា ៣ ដល់ មាត្រា ១៦........................................ ៤៥
- ចំពូក ៣ : អំពីច្បាប់ នឹងអំណាច
មាត្រា ១៧ ដល់ មាត្រា ២៤........................................៤៩
- ចំពូក ៤ : អំពីព្រះមហាក្សត្រិយ៍
មាត្រា ២៥ ដល់ មាត្រា ៤៨........................................ ៥១
- ចំពូក ៥ : អំពីរដ្ឋសភា
មាត្រា ៤៩ ដល់ មាត្រា ៧៣........................................ ៥៨
- ចំពូក ៦ : អំពីក្រុមប្រឹក្សាព្រះរាជអាណាចក្រ
មាត្រា ៧៤ ដល់ មាត្រា ៨៣ ........................................ ៦៤
- ចំពូក ៧ : អំពីសភាប្រជារាស្ត្រប្រចាំខែត្រ និង ប្រចាំរាជធានី
មាត្រា ៨៤ ដល់ មាត្រា ៩១ ........................................ ៦៨
- ចំពូក ៨ : អំពីសមាជជាតិ
មាត្រា ៩២ ដល់ មាត្រា ៩៥........................................៧១
- ចំពូក ៩ : អំពីរដ្ឋមន្ត្រី

មាត្រា ៩៦ ដល់ មាត្រា ១១២ ....................................................... ៧២

- ចំពូក ១០ : អំពីអំណាចតុលាការ

មាត្រា ១១៣ ដល់ មាត្រា ១១៤ ....................................................... ៧៧

- ចំពូក ១១ : បញ្ញត្តិទូទៅ

មាត្រា ១១៥ ដល់ មាត្រា ១២១ ....................................................... ៧៨

- ចំពូក ១២ : បទបញ្ញត្តិពិសេស

មាត្រា ១២២ ....................................................... ៨០

**II. រដ្ឋធម្មនុញ្ញសាធារណរដ្ឋខ្មែរ** ....................................................... ៨៥-១៣៣

- ជំពូក ១ : បទបញ្ញត្តិជាគ្រឹះ

មាត្រា ១ ដល់ មាត្រា ៤ ....................................................... ៨៩

- ជំពូក ២ : សិទ្ធិ និង ករណីយកិច្ច នៃពលរដ្ឋ

មាត្រា ៥ ដល់ មាត្រា ២២ ....................................................... ៩០

- ជំពូក ៣ : ប្រធានាធិបតី នៃសាធារណរដ្ឋ

មាត្រា ២៣ ដល់ មាត្រា ៤២ ....................................................... ៩៥

- ជំពូក ៤ : រដ្ឋាភិបាល

មាត្រា ៤៣ ដល់ មាត្រា ៤៥ ....................................................... ១០២

- ជំពូក ៥ : សហសភា

មាត្រា ៤៦ ដល់ មាត្រា ៦៤ ....................................................... ១០៣

- ជំពូក ៦ : ការទាក់ទងរវាងសហសភា និង រដ្ឋាភិបាល

មាត្រា ៦៥ ដល់ ៧៩ ....................................................... ១០៨

- ជំពូក ៧ : អំណាចតុលាការ

មាត្រា ៨០ ដល់ មាត្រា ៩២........................................................ ១១៣
- ជំពូក ៨ : ស្ថាប័នដទៃទៀតនៃសាធារណរដ្ឋ
មាត្រា ៩៣ ដល់ មាត្រា ១១៣................................................. ១១៦
- ជំពូក ៩ : សមូហភាព ដែនដី
មាត្រា ១១៤ .........................................................................១២១
- ជំពូក ១០ : ការពិនិត្យ និង វិសោធនកម្ម
មាត្រា ១១៥ ដល់ មាត្រា ១១៧...............................................១២២
- ជំពូក ១១ : អន្តរប្បញ្ញត្តិ
មាត្រា ១១៨ ដល់ មាត្រា ១២១...............................................១២២

**III. រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ** .................................................... ១៣៤-១៤៦
- ជំពូក ១ : អំពីរបបរដ្ឋ
មាត្រា ១ ................................................................................ ១៣៧
- ជំពូក ២ : អំពីរបបសេដ្ឋកិច្ច
មាត្រា ២ ................................................................................ ១៣៨
- ជំពូក ៣ : អំពីរបបវប្បធម៌
មាត្រា ៣ ................................................................................ ១៣៨
- ជំពូក ៤ : អំពីរបបដឹកនាំ និងធ្វើការងារ
មាត្រា ៤ ................................................................................ ១៣៨
- ជំពូក ៥ : អំពីអំណាចធ្វើច្បាប់
មាត្រា ៥ ដល់ មាត្រា ៧ .........................................................១៣៩
- ជំពូក ៦ : អំពីអង្គការអនុវត្តច្បាប់

មាត្រា ៨........................................................................ ១៤០
- ជំពូក ៧ : អំពីតុលាការ
មាត្រា ៩ ដល់ មាត្រា ១០ ...................................................... ១៤០
- ជំពូក ៨ : អំពីគណៈប្រធានរដ្ឋ
មាត្រា ១១........................................................................ ១៤១
- ជំពូក ៩ : អំពីសិទ្ធិ និងករណីយកិច្ចរបស់ប្រជាជនកម្ពុជាម្នាក់ៗ
មាត្រា ១២ ដល់ មាត្រា ១៤ .................................................... ១៤២
- ជំពូក ១០ : អំពីរដ្ឋធានី
មាត្រា ១៥ ........................................................................ ១៤៣
- ជំពូក ១១ : អំពីទង់ជាតិ
មាត្រា ១៦........................................................................ ១៤៣
- ជំពូក ១២ : អំពីសញ្ញាជាតិ
មាត្រា ១៧........................................................................ ១៤៤
- ជំពូក ១៣ : អំពីភ្លេងជាតិ
មាត្រា ១៨ ........................................................................ ១៤៤
- ជំពូក ១៤ : អំពីកងទ័ពបដិវត្តកម្ពុជា
មាត្រា ១៩ ........................................................................ ១៤៤
- ជំពូក ១៥ : អំពីសិទ្ធិខាងជំនឿ និងសាសនា
មាត្រា ២០........................................................................ ១៤៥
- ជំពូក ១៦ : អំពីនយោបាយក្រៅប្រទេស
មាត្រា ២១........................................................................ ១៤៥

**IV. រដ្ឋធម្មនុញ្ញ នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា** ........ ១៤៧-១៨៩

- ជំពូកទី ១ : របបនយោបាយ
  មាត្រា ១ ដល់ មាត្រា ១០........ ១៥៥
- ជំពូកទី២ : របបសេដ្ឋកិច្ច និងគោលនយោបាយ វប្បធម៌ - សង្គមកិច្ច
  មាត្រា ១១ ដល់ មាត្រា ២៩........ ១៥៩
- ជំពូកទី ៣ : សិទ្ធិ និង ករណីយកិច្ចរបស់ពលរដ្ឋ
  មាត្រា ៣០ ដល់ មាត្រា ៤៤........ ១៦៥
- ជំពូកទី ៤ : រដ្ឋសភា
  មាត្រា ៤៥ ដល់ មាត្រា ៥៨ ........ ១៧០
- ជំពូកទី ៥ : ក្រុមប្រឹក្សារដ្ឋ
  មាត្រា ៥៩ ដល់ មាត្រា ៦៣........ ១៧៥
- ជំពូកទី ៦ : ក្រុមប្រឹក្សារដ្ឋមន្ត្រី
  មាត្រា ៦៤ ដល់ មាត្រា ៧០........ ១៧៨
- ជំពូកទី ៧ : គណៈកម្មាធិការប្រជាជនបដិវត្តមូលដ្ឋាន
  មាត្រា ៧១ ដល់ មាត្រា ៧៨........ ១៨១
- ជំពូកទី ៨ : សាលាជំរះក្តី និង អយ្យការ
  មាត្រា ៧៩ ដល់ មាត្រា ៨៦........ ១៨៤
- ជំពូកទី ៩ : សញ្ញាជាតិ ទង់ជាតិ ភ្លេងជាតិ និង រដ្ឋធានី
  មាត្រា ៨៧ ដល់ មាត្រា ៩០........ ១៨៦
- ជំពូកទី ១០ : អានុភាពនៃរដ្ឋធម្មនុញ្ញ និងការកែប្រែរដ្ឋធម្មនុញ្ញ

មាត្រា ៩១ ដល់ មាត្រា ៩៣ .................................................... ១៨៧

**V. រដ្ឋធម្មនុញ្ញ នៃរដ្ឋកម្ពុជា** ........................................................................ ១៩០-២៣៣

- ជំពូកទី ១ : របបនយោបាយ
  មាត្រា ១ ដល់ មាត្រា ១០ ........................................................ ១៩៦
- ជំពូកទី ២ : របបសេដ្ឋកិច្ច និងគោលនយោបាយ វប្បធម៌-សង្គមកិច្ច
  មាត្រា ១១ ដល់ មាត្រា ២៩ ...................................................... ២០០
- ជំពូកទី ៣ : សិទ្ធិ និង ករណីយកិច្ចរបស់ពលរដ្ឋ
  មាត្រា ៣០ ដល់ មាត្រា ៤៤ ...................................................... ២០៦
- ជំពូកទី ៤ : រដ្ឋសភា
  មាត្រា ៤៥ ដល់ មាត្រា ៥៨ ...................................................... ២១១
- ជំពូកទី ៥ : ក្រុមប្រឹក្សារដ្ឋ
  មាត្រា ៥៩ ដល់ មាត្រា ៦៣ ...................................................... ២១៨
- ជំពូកទី ៦ : ក្រុមប្រឹក្សារដ្ឋមន្ត្រី
  មាត្រា ៦៤ ដល់ មាត្រា ៧០ ...................................................... ២២១
- ជំពូកទី ៧ : គណៈកម្មាធិការប្រជាជនមូលដ្ឋាន
  មាត្រា ៧១ ដល់ មាត្រា ៧៨ ...................................................... ២២៥
- ជំពូកទី ៨ : សាលាជម្រះក្តី និង អយ្យការ
  មាត្រា ៧៩ ដល់ មាត្រា ៨៦ ...................................................... ២២៨
- ជំពូកទី ៩ : សញ្ញាជាតិ ទង់ជាតិ ភ្លេងជាតិ និង រដ្ឋធានី
  មាត្រា ៨៧ ដល់ មាត្រា ៩០ ...................................................... ២៣០

- ជំពូកទី ១០៖ អានុភាពនៃរដ្ឋធម្មនុញ្ញ និងការកែប្រែរដ្ឋធម្មនុញ្ញ
មាត្រា ៩១ ដល់ មាត្រា ៩៣ ........................................ ២៣១

**VI. រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា**........................................២៣៤-៣២៦

- ជំពូកទី ១ ៖ អំពីអធិបតេយ្យ
មាត្រា ១ ដល់ មាត្រា ៦........................................ ២៣៦

- ជំពូកទី ២ ៖ អំពីព្រះមហាក្សត្រ
មាត្រា ៧ ដល់ មាត្រា ៣០ ថ្មី ........................................ ២៣៧

- ជំពូកទី ៣ ៖ អំពីសិទ្ធិ និង ករណីយកិច្ចរបស់ប្រជាពលរដ្ឋខ្មែរ
មាត្រា ៣១ ដល់ មាត្រា ៥០........................................ ២៤៤

- ជំពូកទី ៤ ៖ អំពីរបបនយោបាយ
មាត្រា ៥១ ដល់ មាត្រា ៥៥........................................ ២៥១

- ជំពូកទី ៥ ៖ អំពីសេដ្ឋកិច្ច
មាត្រា ៥៦ ដល់ មាត្រា ៦៤........................................ ២៥៣

- ជំពូកទី ៦ ៖ អំពីអប់រំ វប្បធម៌ និង សង្គមកិច្ច
មាត្រា ៦៥ ដល់ មាត្រា ៧៥ ........................................ ២៥៦

- ជំពូកទី ៧ ៖ អំពីរដ្ឋសភា
មាត្រា ៧៦ ដល់ មាត្រា ៩៨ ថ្មី........................................ ២៥៨

- ជំពូកទី ៨ ថ្មី ៖ អំពីព្រឹទ្ធសភា
មាត្រា ៩៩ ថ្មី ដល់ មាត្រា ១១៥ ថ្មី........................................ ២៦៨

- ជំពូកទី ៩ ថ្មី : អំពីសមាជរដ្ឋសភា និង ព្រឹទ្ធសភា

មាត្រា ១១៦ ថ្មី ដល់ មាត្រា ១១៧ ថ្មី........................................២៧៦

- ជំពូកទី ១០ ថ្មី : អំពីរាជរដ្ឋាភិបាល

មាត្រា ១១៨ ថ្មី ដល់ មាត្រា ១២៧ ថ្មី........................................២៧៧

- ជំពូកទី ១១ ថ្មី : អំពីអំណាចតុលាការ

មាត្រា ១២៨ ថ្មី ដល់ មាត្រា ១៣៥ ថ្មី........................................ ២៧៩

- ជំពូកទី ១២ ថ្មី : អំពីក្រុមប្រឹក្សាធម្មនុញ្ញ

មាត្រា ១៣៦ ថ្មី ដល់ មាត្រា ១៤៤ ថ្មី........................................២៨២

- ជំពូកទី ១៣ ថ្មី : អំពីការគ្រប់គ្រងរដ្ឋបាល

មាត្រា ១៤៥ ថ្មី (មួយ) ដល់ មាត្រា ១៤៦ ថ្មី (មួយ) ................ ២៨៤

- ជំពូកទី ១៤ ថ្មី : អំពីសមាជជាតិ

មាត្រា ១៤៧ ថ្មី ដល់ មាត្រា ១៤៩ ថ្មី........................................ ២៨៥

- ជំពូកទី ១៥ ថ្មី : អំពីអានុភាព ការសើរើ និង វិសោធនកម្មរដ្ឋធម្មនុញ្ញ

មាត្រា ១៥០ ថ្មី ដល់ មាត្រា ១៥៣ ថ្មី........................................ ២៨៦

- ជំពូកទី ១៦ ថ្មី : អំពីអន្តរប្បញ្ញត្តិ

មាត្រា ១៥៤ ថ្មី ដល់ មាត្រា ១៥៨ ថ្មី........................................២៨៧

- ឧបសម្ព័ន្ធទី១ : ទង់ជាតិ........................................................................................ ២៨៩

- ឧបសម្ព័ន្ធទី២ : ភ្លេងជាតិ នគររាជ.....................................................................២៩០

- ឧបសម្ព័ន្ធទី៣ : សញ្ញាជាតិ................................................................................. ២៩២

- ឧបសម្ព័ន្ធទី៤ : សច្ចាប្រណិធាន ( ព្រះមហាក្សត្រ) ..........................................២៩៣
- ឧបសម្ព័ន្ធទី៥ : សច្ចាប្រណិធាន ( រដ្ឋសភា) ....................................................២៩៤
- ឧបសម្ព័ន្ធទី៦ : សច្ចាប្រណិធាន ( រាជរដ្ឋាភិបាល) ........................................... ២៩៧
- ឧបសម្ព័ន្ធទី៧ : សច្ចាប្រណិធាន ( ព្រឹទ្ធសភា) ................................................ ៣០០
- គណៈកម្មការអចិន្ត្រៃយ៍រៀបរៀងរដ្ឋធម្មនុញ្ញ..................................................... ៣០៣
- ព្រះរាជក្រមចុះថ្ងៃទី ២៤ ខែ កញ្ញា គ.ស ១៩៩៣................................................ ៣០៥
- ច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១
ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០០៤.................................................................... ៣០៦
- កំណត់សម្គាល់.................................................................................................. ៣១២
- ព្រះរាជក្រម ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ១៩៩៤ ................................................... ៣១៤
- ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១
ចុះថ្ងៃទី ៨ ខែ មីនា ឆ្នាំ១៩៩៩......................................................................... ៣១៦
- ព្រះរាជក្រមលេខ នស/រកម/០៧០១/១១
ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ២០០១ .................................................................. ៣១៨

- ព្រះរាជក្រមលេខ នស/រកម/០៦០៥/០១៨
ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ២០០៥............................................................................៣២០
- ព្រះរាជក្រមលេខ នស/រកម/០៣០៦/០០៦
ចុះថ្ងៃទី ៩ ខែ មីនា ឆ្នាំ២០០៦................................................................................ ៣២២
- ព្រះរាជក្រមលេខ នស/រកម/០២០៨/០០៨
ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០០៨............................................................................៣២៥

# រដ្ឋធម្មនុញ្ញ

# ប្រទេសកម្ពុជា

# ១៩៤៧



# រដ្ឋធម្មនុញ្ញ
# ប្រទេសកម្ពុជា
# ឆ្នាំ ១៩៤៧

# រដ្ឋធម្មនុញ្ញប្រទេសកម្ពុជា

# ព្រះបាទសម្ដេចព្រះនរោត្ដម សីហនុ វរ្ម័ន រាជហរិវង្ស
# ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្ដម
# ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
# ព្រះចៅក្រុងកម្ពុជាធិបតី

រដ្ឋឯករាជ ជាភាគមួយក្នុងសហភាពបារាំងក្នុងឋានៈជាសមាគតរដ្ឋ

ទ្រង់ប្រោសព្រះរាជទានដល់ប្រជារាស្ត្ររបស់ព្រះអង្គ ក្នុងក្របខណ្ឌសីមានៃសន្ធិសញ្ញាទាំងឡាយ ដែលមានរវាងប្រទេសខ្មែរនឹងប្រទេសបារាំង នូវរដ្ឋធម្មនុញ្ញដូចមានសេចក្ដីតទៅនេះ ÷

## ចំពូក ១
## ធម្មជាតិនឹងសណ្ឋានរបស់រដ្ឋ

មាត្រា ១- ប្រទេសកម្ពុជា ជាប្រជាជាតិមួយមានព្រះមហាក្សត្រិយ៍សោយរាជ្យ ។

មាត្រា ២- ភាសាដែលប្រើជាផ្លូវការ គឺភាសាខ្មែរ ។

ភាសាបារាំង ជាភាសាផ្លូវការ សំរាប់ប្រើក្នុងការដែលទាក់ទងនឹងសហភាពបារាំង ហើយនឹងយកមកប្រើក្នុងការក្រៅពីនោះផងក៏បានដែរ ទំរាំភាសាខ្មែរមានពាក្យបរិបូណ៌គ្រប់គ្រាន់នឹងប្រើការសំរាប់ប្រជាជាតិសម័យថ្មី ។

## ជំពូក ២

## សេរីភាព សិទ្ធិ និង ករណីយកិច្ចរបស់ខេមរជន

មាត្រា ៣- សេរីភាពជាដំណើរអាចធ្វើអ្វីបានគ្រប់យ៉ាង កុំឱ្យតែប៉ះពាល់ឱ្យខូចសិទ្ធិអ្នកដទៃ ។ លក្ខខណ្ឌនៃការប្រើសេរីភាពមានត្រាទុកក្នុងច្បាប់ ។

អ្វីដែលច្បាប់មិនបង្គាប់ឱ្យធ្វើទេ ជនណាក៏ដោយមិនអាចត្រូវគេបង្ខំឱ្យធ្វើបានឡើយ ។

មាត្រា ៤- នឹងចោទចាប់ឬឃុំឃាំងជនណាមួយបាន លុះតែជននោះប្រព្រឹត្តបទដែលមានត្រាទុកក្នុងច្បាប់ ឯអ្នកចោទ-អ្នកចាប់ឬអ្នកឃុំឃាំងត្រូវប្រតិបត្តិតាមរបៀបដែលច្បាប់បានបញ្ញត្តទុក ។

នឹងឃុំឃាំងជនណាទុកបាន លុះតែមានចៅក្រមពិនិត្យការឃុំឃាំងនោះឃើញថាត្រឹមត្រូវតាមច្បាប់ ហើយយល់ព្រមផង ដោយចង្អុលហេតុផលក្នុងរយៈវេលាដែលមានកំណត់ទុកក្នុងច្បាប់ ។

ទារុណកម្ម ឬការបង្ខំដែលឥតប្រយោជន៏ក្នុងខណៈចាប់ជនណាមួយ ការសង្កត់សង្កិនចិត្ត ឬការធ្វើបាបដល់រាងកាយចំពោះអ្នកជាប់ឃុំណាមួយ ការប្រព្រឹត្តដែលបណ្តាលឱ្យធ្ងន់ថែមទៅលើទណ្ឌកម្មដែលតុលាការបានតម្រូវតាមច្បាប់ទៅលើអ្នក មានទោសណាមួយស្រេចហើយនោះច្បាប់ហាមមិនឱ្យប្រព្រឹត្ត ហើយក្នុងបទទាំងនេះអ្នកដៃដល់ អ្នកមេគំនិត ឬអ្នកសមគំនិតត្រូវទទួលខុសត្រូវផ្ទាល់ខ្លួន ។

មាត្រា ៥- ដរាបណាតុលាការមិនទាន់ប្រកាស ថាអ្នកត្រូវចោទមានទោសទេ ដរាបនោះត្រូវទុកអ្នកត្រូវចោទជាមនុស្សឥតទោស ។

ទណ្ឌកម្មដែលបំបាត់ ឬបន្ថយសេរីភាពដល់អ្នកប្រព្រឹត្តខុស ត្រូវដាក់ដោយញ៉ាំងឱ្យកែខ្លួនបានល្អឡើងវិញ ។

**មាត្រា ៦-** ខេមរជនមិនអាចត្រូវនិរទេសពីដែនខ្មែរបានឡើយ ។ ការហាមខេមរជនមិនឱ្យនៅក្នុងកន្លែងណាមួយ ឬការបង្ខំឱ្យនៅក្នុងកន្លែងណាមួយ ត្រូវធ្វើតែក្នុងករណីដែលមានបញ្ញត្តទុកក្នុងច្បាប់ ។

**មាត្រា ៧-** កម្មសិទ្ធិឋិតនៅក្នុងការឃុំគ្រងនៃច្បាប់ ។ ដែលនឹងដកហូតកម្មសិទ្ធិអំពីជនណាមួយបាននោះ ក៏ដោយហេតុជាសាធារណប្រយោជន៍ក្នុងករណីដែលច្បាប់បានបញ្ញត្តទុក ហើយត្រូវឱ្យសោហ៊ុយជួសជុលជាមុនដោយយុត្តិធម៌ ។

**មាត្រា ៨-** សេរីភាពខាងជំនឿត្រូវបើកឱ្យមានដោយបរិបូណ៌ ។ សេរីភាពក្នុងការប្រតិបត្តិខាងផ្លូវសាសនា ក៏ត្រូវបើកឱ្យមានដូច្នោះដែរ បើនឹងបន្ថយខ្លះបាន តែត្រង់ណាដែលវៀរពុំបាន ដើម្បីកុំឱ្យខូចសេចក្តីស្ងប់រៀបរយដល់មហាជន ។

ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ ។

**មាត្រា ៩-** ខេមរជនមានសេរីភាពក្នុងការនិយាយ - សរសេរ បោះពុម្ព នឹងការផ្សាយដល់មហាជន ។ ខេមរជនអាចសំដែង ផ្សាយឬការពារមតិគ្រប់យ៉ាង តាមផ្លូវកាសែតក្តី តាមវិធីណាឯទៀតក្តី កុំឱ្យតែប្រើសិទ្ធិនេះដោយរំលោភ ហើយកុំឱ្យតែញ៉ាំងឱ្យខូចសេចក្តីស្ងប់រៀបរយដល់មហាជន ។

មិនត្រូវបង្ខំ ឬបង្គាប់នរណាឱ្យសំដែងមតិថាដូច្នេះឬដូច្នោះបានឡើយ ។

**មាត្រា ១០-** ខេមរជនទាំងពួង មានសិទ្ធិរួបរួមគ្នាជាសមាគមដោយសេរី, កុំឱ្យតែ

សមាគមនោះធ្វើឱ្យខូចឬញុំាងឱ្យខូចសេរីភាពទាំងឡាយ ដែលរដ្ឋធម្មនុញ្ញនេះធានាអះអាងឱ្យមាន ។

ត្រូវបើកឱ្យមានសេរីភាពក្នុងការប្រជុំផងដែរ ។

**មាត្រា ១១-** ទីលំនៅមិនត្រូវនរណាចូលទៅរុករានបានឡើយ ។ នឹងចូលទៅក្នុងទីលំនៅគេបាន តែក្នុងករណីដែលច្បាប់បានបញ្ញត្តទុក ហើយឱ្យត្រូវតាមរបៀបច្បាប់ផង ។

**មាត្រា ១២-** សំបុត្រដែលផ្ញើទៅមករកគ្នា មិនត្រូវនរណាបើកមើលបានឡើយ វៀរលែងតែមានច្បាប់អនុញ្ញាតដោយដាក់ស្តែងជាបណ្តោះអាសន្នឱ្យបើក ក្នុងវេលាដែលប្រយោជន៍យ៉ាងធំរបស់ប្រជាជាតិបង្គាប់ឱ្យធ្វើដោយខានពុំបាន ។

**មាត្រា ១៣-** ខេមរជនទាំងពួងត្រូវទទួលតំណែងរាជការបានដូចគ្នា ។ ក្រៅអំពីគុណសម្បត្តិ នឹងសមត្ថភាពរបស់សាមីខ្លួន គ្មានអ្វីជាហេតុបណ្តាលឱ្យជននេះទទួលបាន ឱ្យជននោះទទួលពុំបានទេ ។

**មាត្រា ១៤-** ខេមរជននិមួយៗ មានសិទ្ធិចូលពាក្យប្តឹងសុំទៅអ្នកកាន់អំណាចសាធារណៈបាន ដើម្បីនាំឱ្យមានការពិចារណាបញ្ហាទាំងឡាយ ដែលមានផលប្រយោជន៍ចំពោះបុគ្គលឬដល់មហាជន ។

**មាត្រា ១៥-** ការប្រើសិទ្ធិទាំងឡាយ ដែលរដ្ឋធម្មនុញ្ញនេះធានាអះអាង មិនត្រូវបង្អាក់បង្អានបានឡើយ ។ ប៉ុន្តែបើប្រជាជាតិត្រូវប្រកាសថានៅក្នុងភយន្តរាយ នោះសិទ្ធិដែលមានពណ៌នាក្នុងមាត្រា ៤ - ៩ (វគ្គទី ១). ១០ (វគ្គទី ២) នឹង ១២ អាចត្រូវបង្អាក់ឱ្យឈប់ប្រើសិនបាន តាមកំរិតនឹងរបៀបដែលមានបញ្ញត្តទុកក្នុងច្បាប់ ។

ការបង្អាក់បង្ខាននេះ មិនត្រូវឱ្យយូរលើសពីប្រាំមួយខែ ប៉ុន្តែនឹងបន្តជាថ្មីទៀត តាមរបៀបដដែលក៏បាន ។

ជនណារំលោភប្រើការបង្អាក់បង្ខាននេះ ដើម្បីធ្វើតាមទំនើងចិត្តឱ្យខូចសិទ្ធិអ្នកដទៃខាងភោគទ្រព្យក្តី ខាងផ្លូវចិត្តក្តី ជននោះត្រូវទទួលខុសត្រូវក្នុងបទនេះ ដោយផ្ទាល់ខ្លួន ។

ដល់ផុតពេលបង្អាក់បង្ខាននេះហើយ ជនណាយល់ថាខ្លួនត្រូវគេធ្វើតាមទំនើងចិត្តឱ្យឈឺចាប់ដល់រាងកាយក្តី ឱ្យខូចខាតដល់ភោគទ្រព្យក្តីជននោះអាចប្តឹងសាលាជំរះក្តី សុំឱ្យជួសជុលខាងផ្លូវចិត្តឬខាងធនធានបាន ។

**មាត្រា ១៦-** ខេមរជននីមួយៗ ត្រូវមានចិត្តស្មោះត្រង់ចំពោះព្រះមហាក្សត្រិយ៍ ។ ត្រូវមានករណីយកិច្ចគោរពប្រតិបត្តិច្បាប់ ការពារប្រទេស ហើយជួយរដ្ឋាភិបាលដោយបង់ពន្ធដារនឹងដោយវិធីគ្រប់យ៉ាងដែលមានបញ្ញត្តិទុកក្នុងច្បាប់ ។

## ចំពូក ៣
## អំពីច្បាប់នឹងអំណាច

**មាត្រា ១៧-** ច្បាប់ជាសេចក្តីសំដែងឆន្ទៈរបស់ប្រជាជាតិ ។ ច្បាប់ត្រូវប្រើទៅលើជនទាំងអស់ បើទោះជាច្បាប់នោះរក្សាការពារក្តី ផ្តន្ទាទោសក្តី បង្ខិតបង្ខំក្តី ។

ច្បាប់ធានាអះអាងឱ្យខេមរជនទាំងពួងប្រើសេរីភាពនឹងសិទ្ធិទាំងឡាយ ដូចមានរៀបរាប់នៅក្នុងចំពូកមុននេះ បើទោះជាដូចម្តេចក៏ដោយច្បាប់មិនអាចធ្វើឱ្យខូចសេរីភាពនឹងសិទ្ធិទាំងនោះបានឡើយ ។

**មាត្រា ១៨-** ច្បាប់ធានាអះអាងឱ្យមនុស្សទាំងពួងមានសិទ្ធិឱ្យតុលាការទទួលជំនុំជំរះ ។ សេចក្តីខ្វះខាតធនធានមិនគ្រប់គ្រាន់ មិនអាចជាឧបសគ្គក្នុងការឱ្យតុលាការទទួលជំនុំជំរះបានឡើយ ។

**មាត្រា ១៩-** វៀរលែងតែមានបញ្ញត្តិពិសេសដោយជាក់ច្បាស់ក្នុងច្បាប់ ច្បាប់មិនត្រូវយកទៅប្រើលើអំពើដែលកន្លងទៅហើយមុនពេលឱ្យប្រតិបត្តិតាមនោះទេ ។

ប៉ុន្តែជនណាក៏ដោយ នឹងអាចត្រូវតុលាការជំនុំជំរះនឹងដាក់ទណ្ឌកម្មបាន លុះតែជននោះបានប្រព្រឹត្តបទល្មើសមានក្នុងច្បាប់ណាមួយដែលបានប្រកាសឱ្យប្រើហើយ ហើយដែលត្រូវប្រើមុនមានបទល្មើសនោះ ។

**មាត្រា ២០-** ច្បាប់ត្រូវប្រតិបត្តិតាម ÷

- នៅភ្នំពេញ កំណត់មួយថ្ងៃគត់ ក្រោយដែលបានចុះច្បាប់នោះក្នុងរាជកិច្ច ។
- នៅទីឯទៀតគឺក្នុងដែនស្រុកនីមួយៗ កំណត់ប្រាំថ្ងៃគត់ ក្រោយរាជកិច្ចដែលមានចុះច្បាប់នោះ ទៅដល់សាលាស្រុក ។

ប៉ុន្តែ បើច្បាប់បានសំដែងថាជាការប្រញាប់ ច្បាប់នោះត្រូវប្រើភ្លាម ៗ នៅក្រុងភ្នំពេញក្រោយដែលបានយកទៅបិទនៅសាលាក្រុង ហើយនៅក្នុងស្រុកនីមួយ ៗ ក្រោយដែលបានយកទៅបិទនៅសាលាស្រុក ។

**មាត្រា ២១-** អំណាចគ្រប់យ៉ាងមកពីព្រះមហាក្សត្រិយ៍ ។ អំណាចទាំងនោះត្រូវប្រើទៅតាមបទបញ្ញត្តិនៃរដ្ឋធម្មនុញ្ញនេះ ។

**មាត្រា ២២-** រដ្ឋសភាជាអ្នកប្រើអំណាចនីតិបញ្ញត្តិក្នុងព្រះបរមនាមនៃព្រះមហាក្សត្រិយ៍ ។

អ្នកដែលមានសិទ្ធិផ្ដើមគំនិតតែងច្បាប់នោះ គឺព្រះមហាក្សត្រិយ៍ គណៈរដ្ឋមន្ត្រី សមាជិកនៃរដ្ឋសភា នឹងសមាជិកនៃក្រុមប្រឹក្សាព្រះរាជអាណាចក្រ ។

**មាត្រា ២៣-** គណៈរដ្ឋមន្ត្រីជាអ្នកប្រើអំណាចនីតិប្រតិបត្តិក្នុងព្រះបរមនាមនៃព្រះមហាក្សត្រិយ៍ ។

**មាត្រា ២៤-** សាលាជំរះក្ដីគ្រប់ជាន់ គ្រប់ប៉ែក ជាអ្នកប្រើអំណាចតុលាការ ក្នុងព្រះបរមនាមនៃព្រះមហាក្សត្រិយ៍ ។

## ចំពូក ៤
## អំពីព្រះមហាក្សត្រិយ៍

**មាត្រា ២៥-** រាជសម្បត្តិប្រទេសកម្ពុជា ជាមតិករបស់ក្សត្រាទាំងឡាយដែលជាតំណពីព្រះបាទសម្ដេចព្រះហរិរក្សរាមាធិបតីព្រះអង្គដួង ។

**មាត្រា ២៦-** ព្រះមហាក្សត្រិយ៍ទ្រង់នូវព្រះរាជអំណាចចាត់តាំងព្រះរជ្ជទាយាទ នឹងព្រះរាជអំណាចដកព្រះរជ្ជទាយាទពីតំណែងបាន ដោយបានទ្រង់ប្រជុំក្រុមប្រឹក្សារាជសម្បត្តិពីគ្រោះជាមុនហើយ ។

**មាត្រា ២៧-** កាលបើរាជសម្បត្តិទំនេរ ប្រសិនបើព្រះមហាក្សត្រិយ៍ពុំបានចាត់តាំងព្រះរជ្ជទាយាទដូចខាងលើនេះទេ នោះក្រុមប្រឹក្សារាជសម្បត្តិចាត់តាំងព្រះមហាក្សត្រិយ៍អង្គថ្មី ដោយយកតាមមតិនៃភាគច្រើនក្នុងទីប្រជុំ បើមតិនៃទីប្រជុំចែកជាពីរភាគស្មើគ្នានោះត្រូវយកតាមមតិនៃប្រធាន ។

**មាត្រា ២៨-** ក្រុមប្រឹក្សារាជសម្បត្តិមានសមាជិកដូចតទៅនេះ :

- អធិបតីនៃក្រុមសង្ឃហព្រះរាជវង្សានុវង្ស
- នាយករដ្ឋមន្ត្រី
- ប្រធានរដ្ឋសភា
- ប្រធានក្រុមប្រឹក្សាព្រះរាជអាណាចក្រ
- ព្រះសង្ឃនាយកទាំងពីរគណៈ
- ចាងហ្វាងសាលាតុលាការជាន់ខ្ពស់

អធិបតីក្រុមសង្ឃហព្រះរាជវង្សានុវង្ស ជាប្រធាននៃក្រុមប្រឹក្សារាជសម្បត្តិ ។

**មាត្រា ២៩-** នីតិភាពនៃព្រះមហាក្សត្រិយ៍ ត្រូវកំណត់តាំងពីព្រះជន្មាយុដប់ប្រាំបីព្រះវស្សា ។ បើប្រសិនជាព្រះមហាក្សត្រិយ៍ឋិតនៅក្នុងអនីតិភាព ឬគ្មានសមត្ថភាពនឹងទ្រង់ប្រើព្រះរាជសិទ្ធិទេ នោះព្រះរាជសិទ្ធិនោះត្រូវជាភារៈរបស់ព្រះរាជានុសិទ្ធមួយព្រះអង្គ ។

ក្រុមប្រឹក្សារាជសម្បត្តិជាអ្នកវិនិច្ឆ័យថា ព្រះមហាក្សត្រិយ៍គ្មានសមត្ថភាព ហើយបើមានករណីដូច្នោះ ក្រុមប្រឹក្សារាជសម្បត្តិត្រូវចាត់តាំងក្សត្រាមួយព្រះអង្គក្នុងព្រះរាជវង្សានុវង្ស ជាព្រះរាជានុសិទ្ធ ។

**មាត្រា ៣០-** កាលបើរាជសម្បត្តិទំនេរ ហើយប្រសិនបើព្រះមហាក្សត្រិយ៍ពុំបានចាត់តាំងព្រះរជ្ជទាយាទទេ ក្រុមប្រឹក្សារាជសម្បត្តិត្រូវតែប្រជុំក្នុងរវាងបីថ្ងៃក្រោយព្រឹត្តិការណ៍ ដែលធ្វើឱ្យរាជសម្បត្តិទំនេរ ដើម្បីចាត់តាំងព្រះមហាក្សត្រិយ៍អង្គថ្មីព្រមទាំងរាជានុសិទ្ធ បើព្រះមហាក្សត្រិយ៍អង្គថ្មីឋិតនៅក្នុងអនីតិភាព ។

ការប្រជុំក្រុមប្រឹក្សារាជសម្បត្តិត្រូវធ្វើដោយប្រធានអញ្ជើញ ឬបើប្រធានមិនបាន

អញ្ជើញទេ ត្រូវប្រជុំនៅថ្ងៃទីបីនៃរយៈវេលាដែលមានកំណត់ក្នុងវគ្គមុននេះ ។

បើត្រូវវិនិច្ឆ័យថាព្រះមហាក្សត្រិយ៍ក្នុងរាជសម្បត្តិគ្មានសមត្ថភាព នោះត្រូវប្រធានក្រុមប្រឹក្សារាជសម្បត្តិ អញ្ជើញសមាជិកមកប្រជុំដោយត៏រិះព្រះអង្គឯងក៏បាន ដោយសេចក្តីសុំនៃសមាជិកយ៉ាងតិចត្រឹមពីរនាក់ក៏បាន ដើម្បីនឹងវិនិច្ឆ័យថាព្រះមហាក្សត្រិយ៍មានសមត្ថភាពឬទេ ហើយបើព្រះមហាក្សត្រិយ៍គ្មានសមត្ថភាពទេ ក្រុមប្រឹក្សារាជសម្បត្តិត្រូវចាត់តាំងព្រះរាជានុសិទ្ធមួយអង្គឡើង ។

**មាត្រា ៣១-** ក្នុងរវាង ៨ ថ្ងៃក្រោយវេលាផ្លាស់ប្តូររជ្ជកាល រដ្ឋសភាត្រូវប្រជុំដោយខានពុំបាន ដើម្បីទទួលសច្ចាប្រណិធានអំពីព្រះមហាក្សត្រិយ៍ ឬ អំពីព្រះរាជានុសិទ្ធ ។

**មាត្រា ៣២-** មុននឹងទទួលព្រះរាជអំណាច ព្រះមហាក្សត្រិយ៍ទ្រង់ថ្លែងសច្ចាប្រណិធានក្នុងទីប្រជុំរដ្ឋសភា មានជាសេចក្តីដូចតទៅនេះ ÷

"ខ្ញុំតាំងសច្ចាថា នឹងប្រព្រឹត្តតាមរដ្ឋធម្មនុញ្ញ នឹងច្បាប់ទាំងឡាយនៃព្រះរាជអាណាចក្រ ហើយនឹងតាំងចិត្តធ្វើផលប្រយោជន៍ដល់រដ្ឋនឹងប្រជារាស្ត្រ" ។

**មាត្រា ៣៣-** មុននឹងទទួលតំណែង ព្រះរាជានុសិទ្ធ ត្រូវថ្លែងសច្ចាប្រណិធានក្នុងទីប្រជុំរដ្ឋសភា មានជាសេចក្តីដូចក្នុងមាត្រាខាងលើនេះ

ហើយបន្ថែមពាក្យថា "ខ្ញុំតាំងសច្ចាថាខ្ញុំមានចិត្តស្មោះត្រងចំពោះព្រះមហាក្សត្រិយ៍" ។

**មាត្រា ៣៤-** ចាប់ផ្តើមតាំងពីវេលាដែលរាជសម្បត្តិទំនេរ រហូតដល់វេលាដែលព្រះមហាក្សត្រិយ៍អង្គថ្មី ឬព្រះរាជានុសិទ្ធថ្លែងសច្ចាប្រណិធាន ក្នុងរវាងវេលានោះប្រធានរដ្ឋសភាប្រើអំណាចជាប្រមុខរបស់រដ្ឋស្នងព្រះអង្គដោយទទួលសេចក្តីខុសត្រូវលើខ្លួន ។

ក្នុងពេលដែលព្រះមហាក្សត្រិយ៍មិនបានគង់នៅក្នុងប្រទេសកម្ពុជា ឬពុំអាចទ្រង់ទទួលព្រះរាជភារៈបាន ព្រះមហាក្សត្រិយ៍ទ្រង់ប្រគល់ព្រះរាជភារៈនោះ ទៅក្រុមប្រឹក្សាមួយក្រុមជាបណ្តោះអាសន្ន ព្រះមហាក្សត្រិយ៍ទ្រង់តាំងអធិបតី នឹងសមាជិកនៃក្រុមប្រឹក្សានោះ ដោយចាត់តាំងយកក្រៅពីសមាជិកនៃរដ្ឋាភិបាល ។

**មាត្រា ៣៥-** ព្រះមហាក្សត្រិយ៍ទ្រង់ជាអគ្គប្រមុខនៃរដ្ឋ ។ អង្គព្រះមហាក្សត្រិយ៍ជាទីគោរពសក្ការៈ នរណានឹងល្មើសពុំបាន ។

**មាត្រា ៣៦-** ព្រះមហាក្សត្រិយ៍ទ្រង់ប្រកាសឱ្យប្រើច្បាប់ទាំងឡាយតាមមាត្រា ៧៨ នៃរដ្ឋធម្មនុញ្ញនេះ ។

ក្នុងរយៈវេលាដែលមានកំណត់សំរាប់ការប្រកាសឱ្យប្រើនេះ ព្រះមហាក្សត្រិយ៍អាចផ្ញើព្រះរាជសារទៅឱ្យរដ្ឋសភានឹងក្រុមប្រឹក្សាព្រះរាជអាណាចក្រ ពិចារណាច្បាប់នោះជាថ្មីទៀត ឯរដ្ឋសភានឹងក្រុមប្រឹក្សាព្រះរាជអាណាចក្រ ត្រូវតែព្រមតាមព្រះរាជឱង្ការ ។

**មាត្រា ៣៧-** ព្រះមហាក្សត្រិយ៍ទ្រង់ប្រស្រ័យនឹងរដ្ឋសភា ហើយនឹងក្រុមប្រឹក្សាព្រះរាជអាណាចក្រ ដោយព្រះរាជសារ ។

**មាត្រា ៣៨-** ព្រះមហាក្សត្រិយ៍ទ្រង់ហៅប្រជុំរដ្ឋសភា តាមបទបញ្ញត្តិនៃមាត្រា ៥៨ នឹង ៥៩ នៃរដ្ឋធម្មនុញ្ញនេះ ។ ព្រះអង្គទ្រង់នូវព្រះរាជសិទ្ធិរំលាយរដ្ឋសភាបាន តាមសេចក្តីណែនាំគណៈរដ្ឋមន្ត្រី ។ ព្រះមហាក្សត្រិយ៍ទ្រង់រំលាយរដ្ឋសភាបានតែមួយដងដោយហេតុដដែល ។ បើមានការរំលាយរដ្ឋសភាដូចខាងលើនេះ ការជ្រើសតាំងជាថ្មីត្រូវឱ្យមានក្នុងរយៈវេលាពីរខែយ៉ាងយូរ ។

មាត្រា ៣៩- ព្រះមហាក្សត្រិយ៍ទ្រង់ ជ្រើសយកនាយករដ្ឋមន្ត្រី ហើយទ្រង់តែងតាំងនាយករដ្ឋមន្ត្រី ព្រមទាំងរដ្ឋមន្ត្រី ដែលនាយកនោះក្រាបបង្គំទូលសុំឱ្យតាំង។

មាត្រា ៤០- ព្រះមហាក្សត្រិយ៍ទ្រង់នូវព្រះរាជសិទ្ធិជាអធិបតីទីប្រជុំគណៈរដ្ឋមន្ត្រី ។ សេចក្តីកត់ហេតុទាំងឡាយនៃពេលប្រជុំគណៈរដ្ឋមន្ត្រីត្រូវនាំយកទៅក្រាបបង្គំថ្វាយព្រះ-មហាក្សត្រិយ៍ ។

មាត្រា ៤១- ព្រះរាជលិខិតទាំងពួង វៀរលែងតែព្រះរាជលិខិតណាដែលទាក់ទងនឹងការខាងក្នុងព្រះបរមរាជវាំង ត្រូវឱ្យមាននាយករដ្ឋមន្ត្រីនឹងរដ្ឋមន្ត្រីមួយនាក់ ឬច្រើននាក់ចុះហត្ថលេខាទទួលព្រះបរមរាជឱង្ការ ។

មាត្រា ៤២- ព្រះមហាក្សត្រិយ៍ទ្រង់បង្កើត ព្រមទាំងទ្រង់ព្រះរាជទានឋានន្តរស័ក្តិខាងស៊ីវិល នឹងខាងទាហាន ។

ព្រះមហាក្សត្រិយ៍ទ្រង់ជាអធិបតីធំបំផុតនៃក្រុមឥស្សរិយយសហើយទ្រង់ព្រះរាជទានគ្រឿងឥស្សរិយាករណ៍ ។

មាត្រា ៤៣- ព្រះមហាក្សត្រិយ៍ទ្រង់តែងតាំងចៅក្រមទាំងឡាយតាមសេចក្តីសុំរបស់ក្រុមប្រឹក្សាជាន់ខ្ពស់នៃតុលាការ ។

មាត្រា ៤៤- ព្រះមហាក្សត្រិយ៍ទ្រង់នូវព្រះរាជសិទ្ធិលើកលែងទោសនឹងបន្ថយទោស ។

មាត្រា ៤៥- ព្រះមហាក្សត្រិយ៍ទ្រង់ជាអគ្គសេនាប្រមុខលើកំឡាំងទាហានទាំងឡាយនៃព្រះរាជអាណាចក្រ ។

មាត្រា ៤៦- ព្រះមហាក្សត្រិយ៍ទ្រង់ចុះព្រះរាជហត្ថលេខាក្នុងសន្ធិសញ្ញាទាំងឡាយ

ដែលធ្វើនឹងប្រទេសបារាំងហើយនឹងសមាគតរដ្ឋឯទៀតក្នុងសហភាពបារាំង ហើយទ្រង់ព្រះរាជទានសច្ចាប័នដល់សន្ធិសញ្ញាទាំងនោះ ដោយអាស្រ័យអនុម័តិនៃរដ្ឋសភា ។

ព្រះមហាក្សត្រិយ៍ទ្រង់ចាត់តាំងតស្សរជនឱ្យកាន់តំណែងឬទទួលបំរើខាងផ្លូវទូតទៅប្រទេសក្រៅ ។

**មាត្រា ៤៧-** ព្រះមហាក្សត្រិយ៍ទ្រង់នូវព្រះរាជសិទ្ធិរំលែកព្រះរាជអំណាចក្នុងការព្រះរាជទានឋានន្តរស័ក្តិខាងស៊ីវិលនឹងទាហាន ហើយក្នុងការចុះព្រះរាជហត្ថលេខាក្នុងលិខិតទាំងឡាយ ។

## ចំពូក ៥

## អំពីរដ្ឋសភា

**មាត្រា ៤៨-** អ្នកដែលមានសិទ្ធិជ្រើសតាំងអ្នកតំណាងរាស្ត្រ គឺ ពលរដ្ឋខ្មែរ ភេទបុរសអាយុ ២០ ឆ្នាំបរិបូណ៌ឡើងទៅ វៀរលែងតែបុរសនោះប្រាសចាកសិទ្ធិរបស់ពលរដ្ឋ ហើយបុរសនោះត្រូវប្រកបដោយលក្ខណសម្បត្តិតាមច្បាប់ស្តីអំពីការជ្រើសតាំងអ្នកតំណាងរាស្ត្រ ។

ទាហានក្នុងតំណែងគ្មានសិទ្ធិជ្រើសតាំងអ្នកតំណាងរាស្ត្រ ហើយគ្មានទាំងសិទ្ធិឈរឈ្មោះ ឱ្យគេជ្រើសតាំងខ្លួនជាអ្នកតំណាងរាស្ត្រទៀតផង ។ បព្វជិតក៏គ្មានសិទ្ធិដូចខាងលើនេះដែរ ព្រោះទើសទាល់នឹងធម៌វិន័យព្រះពុទ្ធសាសនា ។

**មាត្រា ៤៩-** អ្នកដែលមានសិទ្ធិឈរឈ្មោះឱ្យគេជ្រើសតាំងជាអ្នកតំណាងរាស្ត្របាននោះ គឺបុរសដែលមានសិទ្ធិជ្រើសតាំងអ្នកតំណាងរាស្ត្រទាំងឡាយ មានអាយុយ៉ាងតិចម្ភៃប្រាំ

ឆ្នាំ ។ ច្បាប់ស្ដីអំពីការជ្រើសតាំងអ្នកតំណាងរាស្ដ្រមានកំណត់អំពីបុរស ដែលគ្មានសិទ្ធិឈរឈ្មោះឱ្យគេជ្រើសតាំងខ្លួនជាអ្នកតំណាងរាស្ដ្រ ។

ជនមួយនាក់នឹងធ្វើជាអ្នករាជការកាន់កាប់តំណែងផង ហើយធ្វើជាអ្នកតំណាងរាស្ដ្រផងពុំបាន ។

**មាត្រា ៥០-** អ្នកតំណាងរាស្ដ្រនៅក្នុងតំណែងត្រឹមបួនឆ្នាំ ដោយបានទទួលជ្រើសតាមវិធីបោះឆ្នោតសាកលដោយចំពោះ ។

រដ្ឋសភាក្នុងមួយលើក១ អស់អំណាចនៅវេលាដែលរដ្ឋសភាលើកថ្មីចូលទទួលការ ។ ក្នុងវេលាដែលផុតនីតិកាលនីមួយ ៗ បើមានហេតុបណ្ដាលមិនឱ្យមានការជ្រើសតាំងជាថ្មីទៀតបានទេ ព្រោះមហាក្សត្រិយ៍អាចបន្តនីតិកាលឱ្យវែងទៅបានម្ដងមួយឆ្នាំ ។

បើកាលណាមានអ្នកតំណាងរាស្ដ្រទទួលអនិច្ចកម្ម លាលែងឬត្រូវបណ្ដេញ នោះត្រូវជ្រើសតាំងជំនួសឡើង តាមបញ្ញត្តិច្បាប់ស្ដីអំពីការជ្រើសតាំងអ្នកតំណាងរាស្ដ្រ ។

**មាត្រា ៥១-** មុននឹងចាប់ផ្ដើមធ្វើការ រដ្ឋសភាត្រូវពិនិត្យដោយខានពុំបាននូវការតាំងសមាជិកដែលគួរតាំង ឱ្យបានជាអ្នកតំណាងរាស្ដ្រពេញទី ។

**មាត្រា ៥២-** នៅពេលដំបូងនៃនីតិកាលនីមួយ ៗ ហើយមុននឹងចូលកាន់តំណែងសមាជិកនៃរដ្ឋសភា ដែលបានទទួលតាំងជាអ្នកតំណាងរាស្ដ្រពេញទីហើយ តាំងសច្ចាប្រណិធានក្នុងទីប្រជុំចំពោះព្រះភ័ក្ត្រព្រះមហាក្សត្រិយ៍ ជាសេចក្ដីដូចតទៅនេះ ÷

"ខ្ញុំសូមតាំងសច្ចាថាមានចិត្តស្មោះត្រង់ចំពោះព្រះមហាក្សត្រិយ៍ ហើយនឹងរដ្ឋធម្មនុញ្ញ ហើយថានឹងខំប្រឹងធ្វើការដោយពេញកំឡាំងដើម្បីជាផលប្រយោជន៍ដល់ប្រទេសជាតិ " ។

អ្នកតំណាងរាស្ត្រណាដែលគេជ្រើសតាំងក្នុងរយៈវេលានីតិកាល ហើយដែលរដ្ឋសភាបានតាំងជាអ្នកតំណាងរាស្ត្រពេញទីហើយ ត្រូវតាំងសច្ចាប្រណិធានចំពោះព្រះភ័ក្ត្រព្រះមហាក្សត្រិយ៍ក្នុងឱកាសព្រះរាជពិធីចំរើនព្រះជន្មវស្សា ( តាំងតុ ) ដែលតបន្ទាប់ពីពេលនោះ មួយអន្លើនឹងអ្នករាជការទាំងឡាយ ។

**មាត្រា ៥៣-** សមាជិកទាំងឡាយនៃរដ្ឋសភា ជាអ្នកតំណាងរបស់ប្រជាជាតិខ្មែរទាំងមូល ពុំមែនត្រឹមតែជាអ្នកតំណាងរបស់ជនដែលជ្រើសតាំងខ្លួនប៉ុណ្ណោះទេ ។ អ្នកតំណាងរាស្ត្រមិនត្រូវជំពាក់ទាក់ទិន ដោយអាណត្តិដាច់ខាតណាមួយឡើយ ។

**មាត្រា ៥៤-** អ្នកតំណាងរាស្ត្រមិនអាចត្រូវគេចោទប្រកាន់រកខ្លួន ចាប់ខ្លួនឃុំឃាំងឬជំនុំជំរះដោយហេតុថា អ្នកតំណាងរាស្ត្រនោះបានសំដែងយោបល់ឬបញ្ចេញមតិថាដូច្នេះដូច្នោះក្នុងមុខក្រសួងរបស់ខ្លួនឡើយ ។

សេចក្តីខាងលើនេះ ជាអភ័យឯកសិទ្ធិរបស់សមាជិករដ្ឋសភា ។

**មាត្រា ៥៥-** នៅវេលាដែលឋិតក្នុងសមាជិកភាព ហើយវៀរលែងតែបានប្រព្រឹត្តបទល្មើស ដែលគេបានទាន់ឃើញជាក់ស្តែង អ្នកតំណាងរាស្ត្របើនឹងត្រូវគេចោទប្រកាន់ឬចាប់ខ្លួនបាន ដោយបទឧក្រិដ្ឋឬមជ្ឈិម នោះលុះត្រាតែមានអនុញ្ញាតពីរដ្ឋសភាជាមុនសិន។ ការឃុំឃាំងឬការចោទប្រកាន់អ្នកតំណាងរាស្ត្រណាមួយត្រូវបង្អង់សិន បើរដ្ឋសភាបញ្ចេញមតិសុំដោយមានភាគច្រើនដល់បួនក្នុងប្រាំ ( ៤/៥ ) នៃចំនួនសមាជិក ។

**មាត្រា ៥៦-** នៅវេលាដែលឋិតក្នុងតំណែង បើអ្នកតំណាងរាស្ត្រណាមួយត្រូវទណ្ឌកម្ម ដែលនាំឱ្យបុគ្គលឈរឈ្មោះជាបេក្ខជនពុំបាន អ្នកតំណាងរាស្ត្រនោះធ្លាក់ចាកសមាជិកភាពរដ្ឋសភា ។

ការទំលាក់ចាកសមាជិកភាពនេះ គឺរដ្ឋសភាជាអ្នកវិនិច្ឆ័យ ។

**មាត្រា ៥៧-** អ្នកតំណាងរាស្ត្រ ត្រូវទទួលប្រាក់បំណាច់មានកំណត់ដោយប្រៀបស្មើទៅនឹងប្រាក់បៀវត្សនៃអ្នករាជការ ថ្នាក់ណាមួយ ។

**មាត្រា ៥៨-** រដ្ឋសភាមានសម័យប្រជុំសាមញ្ញយ៉ាងតិចពីរក្នុងមួយឆ្នាំ ។ សម័យប្រជុំនិមួយ ៗ មានកំណត់យ៉ាងតិចបីខែ ។ ក្នុងសម័យប្រជុំសាមញ្ញពីរនេះ សម័យប្រជុំមួយត្រូវចាប់ផ្តើមក្នុងខែកញ្ញា ( សេបតម ) ។

ព្រះមហាក្សត្រីយ៍ទ្រង់ត្រាស់ហៅរដ្ឋសភាប្រជុំជាសម័យប្រជុំសាមញ្ញ ។

**មាត្រា ៥៩-** ក្រុមអភិបាលរដ្ឋសភា ជាអ្នកហៅសមាជិកប្រជុំជាសម័យប្រជុំវិសាមញ្ញដោយបានទទួលព្រះរាជបញ្ជាក្តី ដោយសេចក្តីណែនាំនៃគណៈរដ្ឋមន្ត្រីក្តី ឬដោយសេចក្តីសុំរបស់ភាគមួយក្នុងបី ( ១/៣) យ៉ាងតិចនៃចំនួនអ្នកតំណាងរាស្ត្រទាំងពួងក្តី ។

របៀបវារៈនៃសម័យប្រជុំវិសាមញ្ញនេះ ត្រូវផ្សាយដល់មហាជនព្រមជាមួយនឹងថ្ងៃណាត់ប្រជុំ ។

**មាត្រា ៦០-** រដ្ឋសភាប្រជុំក្នុងរាជធានីនៃព្រះរាជអាណាចក្រ ក្នុងមន្ទីរមួយដែលបានរៀបចំប្រចាំការ វៀរលែងតែមានបញ្ជាក់ជាពិសេសក្នុងសំបុត្រហៅប្រជុំ ដោយមានហេតុផ្សេងៗ ។

**មាត្រា ៦១-** វៀរលែងតែក្នុងករណីដែលមាត្រាទាំងឡាយមុននេះបានបញ្ញត្តទុក ការប្រជុំនៃរដ្ឋសភា ក្រៅពីកន្លែងដែលមានកំណត់នឹងក្រៅពីវេលាត្រឹមត្រូវតាមច្បាប់ ទុកជាខុសនឹងច្បាប់ហើយអសារសូន្យទៅឯង ។

**មាត្រា ៦២-** ក្នុងពេលបើកសម័យប្រជុំម្តងៗព្រះមហាក្សត្រិយ៍ទ្រង់អានព្រះរាជសារកាន់រដ្ឋសភាដោយព្រះអង្គឯង ឬដោយអ្នកតំណាងព្រះអង្គ ។

**មាត្រា ៦៣-** រដ្ឋសភាតាំងបទបញ្ជាមួយសម្រាប់ប្រើការ ។

**មាត្រា ៦៤-** មានតែរដ្ឋសភាប៉ុណ្ណោះទេ ដែលមានសិទ្ធិបញ្ចេញមតិតាំងច្បាប់ ។ សិទ្ធិនេះរដ្ឋសភាមិនអាចប្រគល់ឱ្យទៅនរណាបានឡើយ ។

**មាត្រា ៦៥-** ការលុបលាងទោស ត្រូវឱ្យមានច្បាប់មួយសំរេចទើបបាន ។

**មាត្រា ៦៦-** ថវិការបស់ជាតិ ត្រូវរដ្ឋសភាអនុម័តិទើបប្រើបាន ហើយឯបញ្ជីចំណូលចំណាយ ក៏ត្រូវឱ្យរដ្ឋសភាយល់ព្រមផង ។ កិច្ចចងការប្រាក់របស់ជាតិ ក៏ត្រូវទទួលអនុម័តិអំពីរដ្ឋសភាដែរ ។

ប៉ុន្តែការផ្តើមគំនិតកំណត់ចំនួនប្រាក់ចំណាយសំរាប់បៀវត្សអ្នករាជការ ជាភារៈតែលើរដ្ឋាភិបាល ។ មួយទៀតរដ្ឋសភាគ្មានសិទ្ធិដដែកពីចំនួនប្រាក់កំណត់ទុកក្នុងថវិការបស់ជាតិ ដែលសំរាប់បញ្ចូលជាអំណោយទៅក្នុងថវិការាជសម្បត្តិ ។

**មាត្រា ៦៧-** ការពិភាក្សានៃរដ្ឋសភានឹងយកជាការបាន លុះត្រាតែមានភាគពីរក្នុងបី (២/៣) នៃចំនួនសមាជិកមកប្រជុំ ។

**មាត្រា ៦៨-** ការពិភាក្សានៃរដ្ឋសភាជាការបើកចំហដល់មហាជន ប៉ុន្តែបើមាន

សេចក្តីសុំអំពីរដ្ឋាភិបាលក្តី អំពីប្រធានរដ្ឋសភាក្តី អំពីសមាជិកយ៉ាងតិចប្រាំនាក់ក្តី រដ្ឋសភាអាចបញ្ចេញមតិឱ្យប្រជុំជាសម្ងាត់បាន ។

ក្នុងពាក្យរាយការណ៍នៃការពិភាក្សាក្នុងពេលប្រជុំចំហ ត្រូវចុះក្នុងរាជកិច្ច ។

**មាត្រា ៦៩-** ក្នុងរយៈវេលាដប់ប្រាំបីខែ បើរដ្ឋាភិបាលរលំពីរដង ដូចមានលក្ខខណ្ឌដែលបានកំណត់ទុកក្នុងមាត្រា ៨៤ នឹង ៨៥ ខាងក្រោយនេះគណៈរដ្ឋមន្ត្រីអាចប្រជុំសំរេចឱ្យរំលាយរដ្ឋសភាបាន ក្រោយដែលបានទទួលសេចក្តីយល់អំពីប្រធានរដ្ឋសភា ។ ព្រះមហាក្សត្រិយ៍ក៏ទ្រង់ប្រកាសរំលាយរដ្ឋសភា តាមសេចក្តីសំរេចនោះ ។

បទបញ្ញត្តិដែលមានក្នុងវគ្គខាងលើនេះ នឹងយកមកប្រើបាន លុះត្រាតែរយៈវេលាដប់ប្រាំបីខែដំបូងនៃនីតិកាលបានកន្លងផុតទៅហើយ ។

## ជំពូក ៦

## អំពីក្រុមប្រឹក្សាព្រះរាជអាណាចក្រ

**មាត្រា ៧០-** ក្រុមប្រឹក្សាព្រះរាជអាណាចក្រ មានសមាជិកដែលត្រូវចាត់តាំងខ្លះនឹងសមាជិកដែលត្រូវជ្រើសតាំងដោយបោះឆ្នោតអសាកលខ្លះ ។ សមាជិកទាំងនោះត្រូវមានអាយុ ៤០ ឆ្នាំយ៉ាងតិច ។

ជនមួយនាក់នឹងធ្វើជាទីប្រឹក្សាព្រះរាជអាណាចក្រផង ហើយធ្វើជាអ្នកតំណាងរាស្ត្រផង ពុំបាន ។

**មាត្រា ៧១-** សមាជិកដែលត្រូវចាត់តាំង មានចំនួនពីររូប ។ ព្រះមហាក្សត្រិយ៍ទ្រង់ចាត់តាំង ក្នុងបណ្តាព្រះរាជវង្សានុវង្ស ។

**មាត្រា ៧២-** សមាជិកពីររូបត្រូវរដ្ឋសភាជ្រើសតាំង តាមភាគច្រើនដោយប្រៀបយកក្រៅពីអ្នកតំណាងរាស្ត្រ ។

**មាត្រា ៧៣-** សមាជិកប្រាំបីរូប រូបនិមួយ ៗ ជាអ្នកតំណាងភូមិភាគមួយ ឬក្រុងភ្នំពេញ ត្រូវជ្រើសតាំងដោយបោះឆ្នោតអសាកល មិនចំពោះ ទីប្រឹក្សាខេត្តជាអ្នកជ្រើសតាំងអ្នកតំណាងភូមិភាគ ហើយមេសង្កាត់នឹងទីប្រឹក្សាក្រុង ជាអ្នកជ្រើសតាំងអ្នកតំណាងក្រុងភ្នំពេញ ។

ភូមិភាគទាំងប្រាំពីរ ដែលត្រូវជ្រើសតាំងអ្នកតំណាងមួយរូបសំរាប់ភូមិភាគមួយនោះមានដូចតទៅនេះ ÷

ភូមិភាគទី ១- ខេត្តបាត់ដំបងនឹងសៀមរាប

— ២- ខេត្តពោធិ៍សាត់នឹងកំពង់ឆ្នាំង

— ៣- ខេត្តកំពង់ធំនឹងកំពង់ចាម

— ៤- ខេត្តក្រចេះនឹងស្ទឹងត្រែង

— ៥- ខេត្តព្រៃវែងនឹងស្វាយរៀង

— ៦- ខេត្តកណ្តាលនឹងកំពង់ស្ពឺ

— ៧- ខេត្តតាកែវនឹងកំពត

**មាត្រា ៧៤-** សមាជិកប្រាំបីរូប ជាអ្នកតំណាងវិជ្ជាជីវៈផ្សេង១ត្រូវគេជ្រើសតាំងដោយបោះឆ្នោតចំពោះនឹងតាមសំបុត្រ ។

ឯសមាជិកបួនរូបជាអ្នកតំណាងអ្នករាជការក៏ដូច្នោះដែរ ។

**មាត្រា ៧៥-** ការរៀបចំនៃក្រុមប្រឹក្សាព្រះរាជអាណាចក្រ បែបផែននឹងលក្ខខណ្ឌនៃការចាត់តាំង នឹងការជ្រើសតាំងសមាជិកក្រុមនេះ នឹងមានកំណត់ទុកក្នុងច្បាប់ពិសេសមួយ ។

**មាត្រា ៧៦-** អាណត្តិនៃទីប្រឹក្សាព្រះរាជអាណាចក្រ មានកំណត់បួនឆ្នាំ ។

ក្រុមប្រឹក្សាព្រះរាជអាណាចក្រត្រូវហៅប្រជុំ ហើយត្រូវប្រជុំក្នុងពេលជាមួយគ្នានឹងរដ្ឋសភា ។

**មាត្រា ៧៧-** មាត្រា ៤៩ ( វគ្គទី ២ ) - ៥១ - ៥២ - ៥៤ - ៥៥ - ៥៦- ៥៧, - ៦៣ នឹង ៦៨ នៃរដ្ឋធម្មនុញ្ញនេះ ត្រូវយកមកប្រើសំរាប់ក្រុមប្រឹក្សាព្រះរាជអាណាចក្រផង ។

**មាត្រា ៧៨-** ក្រុមប្រឹក្សាព្រះរាជអាណាចក្រពិនិត្យហើយឱ្យយោបល់អំពីសេចក្ដីព្រាងនឹងសេចក្ដីស្នើច្បាប់ ដែលរដ្ឋសភាបានបញ្ចេញមតិយល់ព្រមមួយលើកដំបូងរួចហើយ ព្រមទាំងអំពីបញ្ហាទាំងពួងដែលរដ្ឋាភិបាលបានដាក់ឱ្យពិនិត្យ ។

អំពីសេចក្ដីព្រាង នឹងសេចក្ដីស្នើច្បាប់ ហើយនឹងអំពីច្បាប់ថវិកា ក្រុមប្រឹក្សាព្រះរាជ-អាណាចក្រត្រូវឱ្យយោបល់កំណត់មួយខែយ៉ាងយូរ ។ បើជាការប្រញាប់ កំណត់វេលានោះត្រូវបន្ថយមកនៅត្រឹមតែប្រាំថ្ងៃ ។

បើក្រុមប្រឹក្សាព្រះរាជអាណាចក្របានឱ្យយោបល់យល់ព្រម ឬពុំបានឱ្យយោបល់សោះក្នុងវេលាដែលមានកំណត់ទុកហើយនោះទេ ច្បាប់ដែលរដ្ឋសភាបានបញ្ចេញមតិយល់ព្រមហើយនោះ ត្រូវប្រកាសឱ្យប្រើក្នុងកំណត់ដប់ថ្ងៃ ។ បើជាការប្រញាប់ កំណត់វេលានោះត្រូវ

បន្ថយមកនៅត្រឹមតែពីរថ្ងៃ ។

បើក្រុមប្រឹក្សាព្រះរាជអាណាចក្រ សូមឱ្យកែសម្រួលសេចក្តីព្រាង ឬសេចក្តីស្នើច្បាប់ នោះរដ្ឋសភាត្រូវយកមកពិចារណាភ្លាមជាលើកទី២ ។

បើក្រុមប្រឹក្សាព្រះរាជអាណាចក្របដិសេធសេចក្តីព្រាង ឬសេចក្តីស្នើច្បាប់នោះ រដ្ឋសភាមិនអាចយកមកពិចារណាជាលើកទី ២ មុនកំណត់ពេលមួយខែទេ ។

ការពិនិត្យសេចក្តីព្រាង ឬសេចក្តីស្នើច្បាប់ជាលើកទីពីរនេះ រដ្ឋសភាត្រូវបញ្ចេញមតិ ដោយវិធីបោះឆ្នោតចំហ យកតាមភាគច្រើនដោយដាច់ខាត នៃសមាជិករដ្ឋសភា ។ សេចក្តីព្រាង ឬសេចក្តីស្នើច្បាប់ណា ដែលបានធ្វើសម្រេចដូចខាងលើនេះ ហើយត្រូវប្រកាសឱ្យប្រើក្នុងកំណត់ដប់ថ្ងៃ ។

## ជំពូក ៧
## អំពីរដ្ឋមន្ត្រី

**មាត្រា ៧៩-** គណៈរដ្ឋមន្ត្រីជារដ្ឋាភិបាលនៃព្រះមហាក្សត្រិយ៍ ។ គណៈរដ្ឋមន្ត្រី មានសមាជិកយ៉ាងច្រើនត្រឹមដប់ពីររូប រាប់បញ្ចូលទាំងរដ្ឋលេខាធិការផង ។

ជនម្នាក់អាចទទួលតំណែងជាអ្នកតំណាងរាស្ត្រឬទីប្រឹក្សាព្រះរាជអាណាចក្រផង ហើយជារដ្ឋមន្ត្រីផងបាន ។ នឹងយកសមាជិកនៃរដ្ឋសភានឹងក្រុមប្រឹក្សាព្រះរាជអាណាចក្រ ឬជនដែលពុំមែនជាសមាជិកនៃសភាទាំងពីរនេះ មកធ្វើជារដ្ឋមន្ត្រី ក៏បាន ។

**មាត្រា ៨០-** ក្នុងវេលាដំបូងនៃនីតិកាលនីមួយៗ ឬកាលគណៈរដ្ឋមន្ត្រីលាឈប់ ព្រះមហាក្សត្រិយ៍ទ្រង់ប្រឹក្សានឹងប្រធានរដ្ឋសភា នឹងប្រធានក្រុមប្រឹក្សាព្រះរាជអាណាចក្រ

ហើយនឹងមេគណបក្សទាំងឡាយ រួចទ្រង់ចាត់ជនមួយនាក់ជានាយករដ្ឋមន្ត្រីឱ្យជ្រើសរដ្ឋមន្ត្រីឯទៀត ។

រដ្ឋមន្ត្រីទាំងឡាយនឹងទទួលតែងតាំង ហើយនឹងចូលកាន់មុខក្រសួងបាន លុះត្រាតែរដ្ឋសភាបានបញ្ចេញមតិទុកចិត្តជាមុន ដោយវិធីបោះឆ្នោតចំហ ហើយយកតាមភាគច្រើនដោយដាច់ខាត ។

**មាត្រា ៨១-** រដ្ឋមន្ត្រីទាំងឡាយទទួលខុសត្រូវរួមគ្នាចំពោះរដ្ឋសភាអំពីនយោបាយទូទៅនៃគណៈរដ្ឋមន្ត្រី ហើយរដ្ឋមន្ត្រីមួយរូបៗ ទទួលខុសត្រូវរៀងខ្លួនចំពោះនាយករដ្ឋមន្ត្រីអំពីការដែលខ្លួនបានប្រព្រឹត្ត ។

**មាត្រា ៨២-** រដ្ឋមន្ត្រីទាំងឡាយមិនអាចអាងសេចក្តីបង្គាប់ ដោយលាយលក្ខណ៍អក្សរ ឬដោយវាចាអំពីនរណាក៏ដោយ ដើម្បីដោះសាឱ្យរួចខ្លួន ពីការទទួលខុសត្រូវលើខ្លួនបានឡើយ ។

**មាត្រា ៨៣-** បើមានអ្នកតំណាងរាស្ត្រមួយនាក់ ឬច្រើននាក់ តាំងសំនួរដោយវាចាក្តី តាំងសំនួរដោយលាយលក្ខណ៍អក្សរក្តី តាំងសំនួរដេញដោលក្តី ដើម្បីសុំឱ្យរដ្ឋមន្ត្រីឆ្លើយដោះសាអំពីការប្រព្រឹត្តក្នុងមុខក្រសួងរបស់ខ្លួន នោះរដ្ឋមន្ត្រីត្រូវរាយការណ៍តាមសេចក្តីសុំជូនរដ្ឋសភា ។

**មាត្រា ៨៤-** លុះតែបានពិភាក្សាព្រមព្រៀងគ្នាជាមុនស្រេចហើយ ទើបគណៈរដ្ឋមន្ត្រីអាចសុំឱ្យរដ្ឋសភាបញ្ចេញ មតិអំពី សេចក្តីទុកចិត្តក្នុងគណៈរដ្ឋមន្ត្រីបាន ។

ការសុំឱ្យរដ្ឋសភាបញ្ចេញមតិដូចខាងលើនេះ ជាភារៈរបស់នាយករដ្ឋមន្ត្រីតែម្នាក់ឯង ។

កាលបើនាយករដ្ឋមន្ត្រីសុំឱ្យរដ្ឋសភាបញ្ចេញមតិអំពីសេចក្តីទុកចិត្តនោះត្រូវបង្អង់វេលាយ៉ាងតិចមួយថ្ងៃគត់ គិតតាំងពីពេលសុំនោះមក ទើបរដ្ឋសភាបញ្ចេញមតិអំពីរឿងនេះបាន ។ ការបញ្ចេញមតិនេះត្រូវធ្វើដោយវិធីបោះឆ្នោតចំហ ។

រដ្ឋសភានឹងបញ្ចេញមតិ ថាមិនទុកចិត្តក្នុងគណៈរដ្ឋមន្ត្រីបាន លុះតែមានភាគច្រើនដោយដាច់ខាតនៃចំនួនសមាជិករដ្ឋសភា យល់ព្រមផង ។

សេចក្តីមិនព្រមទុកចិត្តនេះ នាំឱ្យរដ្ឋមន្ត្រីលាឈប់ទាំងគណៈ ។

**មាត្រា ៨៥-** កាលបើរដ្ឋសភាបញ្ចេញមតិតាំងញត្តិបន្ទោសគណៈរដ្ឋមន្ត្រី នោះរដ្ឋមន្ត្រីត្រូវលាឈប់ទាំងគណៈ ។

កាលបើមានអ្នកតំណាងរាស្ត្រ សុំឱ្យរដ្ឋសភាបញ្ចេញមតិតាំងញត្តិបន្ទោសគណៈរដ្ឋមន្ត្រី នោះរដ្ឋសភាត្រូវបង្អង់វេលាមួយថ្ងៃគត់ គិតតាំងពីថ្ងៃជូនសេចក្តីសុំតាំងញត្តិ ទើបបញ្ចេញមតិពីរឿងនេះបាន ។ ការបញ្ចេញមតិនេះ ត្រូវធ្វើទៅដោយវិធីបោះឆ្នោតចំហ ។

ការតាំងញត្តិបន្ទោសគណៈរដ្ឋមន្ត្រីនឹងយកជាការបាន លុះតែមានភាគច្រើនដោយដាច់ខាតនៃសមាជិករដ្ឋសភាយល់ព្រមផង ។

**មាត្រា ៨៦-** គណៈរដ្ឋមន្ត្រីត្រូវប្រជុំរាល់សប្តាហ៍ ជួនកាលជាពេលប្រជុំធំដោយមានព្រះមហាក្សត្រិយ៍ឬនាយករដ្ឋមន្ត្រីជាប្រធាន ជួនកាលជាពេលប្រជុំតូច ។

**មាត្រា ៨៧-** រដ្ឋមន្ត្រីទាំងឡាយ អាចចូលនិយាយការក្នុងទីប្រជុំនៃសភាទាំងពីរ

នឹងក្នុងទីប្រជុំគណកម្មការទាំងឡាយនៃសភាទាំងនោះបាន ។ បើរដ្ឋមន្ត្រីទាំងនោះសុំនិយាយការ ត្រូវតែបើកឱកាសឱ្យនិយាយ ។

ក្នុងការពិភាក្សានៃសភាណាមួយ ៗ រដ្ឋមន្ត្រីអាចចាត់តាំងអ្នកស្នងរាជការ ឱ្យជួយនិយាយការផងបាន ។

**មាត្រា ៨៨-** នាយករដ្ឋមន្ត្រី អាចរំលែកអំណាចរបស់ខ្លួនឱ្យទៅរដ្ឋមន្ត្រីណាមួយបាន។

**មាត្រា ៨៩-** បើតំណែងនាយករដ្ឋមន្ត្រីទំនេរ ត្រូវតែងតាំងគណៈរដ្ឋមន្ត្រីមួយជាថ្មីតាមលក្ខខណ្ឌដែលមានចែងទុកក្នុងរដ្ឋធម្មនុញ្ញនេះ បើការទំនេរនេះជាដាច់ខាត ឬត្រូវចាត់តាំងនាយករដ្ឋមន្ត្រីជាបណ្ដោះអាសន្ន បើការទំនេរនេះជាមួយកាលមួយគ្រាទេ ។

**មាត្រា ៩០-** បើមានការរំលាយរដ្ឋសភា នោះនាយករដ្ឋមន្ត្រីនឹងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវឈប់ធ្វើការសិន រដ្ឋមន្ត្រីឯទៀតគង់នៅក្នុងតំណែងទាំងអស់គ្នា ដើម្បីសម្រេចកិច្ចការសាមញ្ញ ។

ក្នុងខណៈនោះ ព្រះមហាក្សត្រិយ៍ទ្រង់ប្រទានភារៈទៅលើប្រធានរដ្ឋសភាឱ្យកាន់តំណែងនាយករដ្ឋមន្ត្រីជាបណ្ដោះអាសន្ន ។ ប្រធានរដ្ឋសភាចាត់តាំងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃជាថ្មី ដោយសេចក្ដីយល់ព្រមនៃក្រុមអភិបាលរដ្ឋសភា ។

**មាត្រា ៩១-** រដ្ឋមន្ត្រីដែលពុំមែនជាសមាជិកនៃរដ្ឋសភាឬក្រុមប្រឹក្សាព្រះរាជអាណាចក្រទេ ត្រូវទទួលផលប្រយោជន៍ដែលមានចែងទុកក្នុងមាត្រា៥៤ នឹង ៥៥ នៃរដ្ឋធម្មនុញ្ញនេះ ។

**មាត្រា ៩២-** រដ្ឋមន្ត្រីត្រូវទទួលទណ្ឌកម្មអំពីបទឧក្រិដ្ឋនឹងបទមជ្ឈិម ដែលបានប្រព្រឹត្តក្នុងវេលាធ្វើការមុខក្រសួងរបស់ខ្លួន ។

ក្នុងករណីនេះ នឹងករណីធ្វើខុសជាទម្ងន់ក្នុងវេលាធ្វើការមុខក្រសួងរបស់ខ្លួន រដ្ឋសភាអាចសម្រេចប្តឹងផ្តល់សាលាតុលាការជាន់ខ្ពស់ ។

រដ្ឋសភាសម្រេចក្នុងរឿងនេះ ដោយវិធីបោះឆ្នោតសម្ងាត់យកតាមភាគច្រើនដោយដាច់ខាតនៃសមាជិករបស់ខ្លួន លើកតែសមាជិកណាដែលត្រូវចាត់ទៅឱ្យចោទប្រកាន់ ស៊ើបសួរ ឬជំនុំជំរះកាត់សេចក្តី ។

**មាត្រា ៩៣-** សាលាតុលាការជាន់ខ្ពស់មានសមាជិកប្រាំរូប ក្នុងចំនួននេះមានចៅក្រមជាន់ខ្ពស់ពីររូបសមាជិកមួយរូបដែលរដ្ឋសភាជ្រើសតាំង នឹងសមាជិកពីររូប ដែលក្រុមប្រឹក្សាព្រះរាជអាណាចក្រជ្រើសតាំង ។

ការជ្រើសតាំងនោះ ត្រូវធ្វើក្នុងពេលដំបូងនៃនីតិកាលនីមួយៗ ហើយសំរាប់រយៈវេលានីតិកាលនេះ ។

**មាត្រា ៩៤-** វិធីចាត់តាំងនឹងរយៈវេលានៃអាណ័ត្តិរបស់ចៅក្រមជាន់ខ្ពស់ពីររូបដែលជាសមាជិកនៃសាលាតុលាការជាន់ខ្ពស់ ការរៀបចំសាលានេះ នឹងរបៀបប្តឹងផ្តល់សាលានេះ មានបញ្ញត្តិទុកក្នុងច្បាប់ពិសេសមួយ ។

## ចំពូក ៨
## អំពីអំណាចតុលាការ

**មាត្រា ៩៥-** ការរៀបចំនៃភារៈតុលាការមានបញ្ញត្តិទុកក្នុងច្បាប់ពិសេសមួយ ។

**មាត្រា ៩៦-** ក្រុមប្រឹក្សាជាន់ខ្ពស់នៃតុលាការ ត្រូវប្រព្រឹត្តតាមបញ្ញត្តិច្បាប់ ដើម្បី

ឱ្យចៅក្រមទាំងឡាយរក្សាវិន័យនឹងប្រតិបត្តិការជាឯកច្ឆន្ទបាន ។

ក្រុមប្រឹក្សាជាន់ខ្ពស់នៃតុលាការ មានសមាជិកដូចតទៅនេះ

- រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ជាអធិបតី
- សមាជិកពីររូបដែលព្រះមហាក្សត្រិយ៍ទ្រង់ចាត់តាំង
- សមាជិកពីររូបដែលរដ្ឋសភាជ្រើសតាំង
- សមាជិកពីររូបដែលតុលាការទាំងឡាយជ្រើសតាំង ។

ក្រុមប្រឹក្សាជាន់ខ្ពស់នៃតុលាការសម្រេចសេចក្តីតាមមតិនៃភាគច្រើនរបស់សមាជិកទាំងនេះ បើមានមតិចែកជាពីរភាគស្មើគ្នា នោះត្រូវយកតាមមតិនៃអធិបតី ។

ការរៀបចំក្រុមប្រឹក្សានេះ មានបញ្ញត្តទុកក្នុងច្បាប់ពិសេសមួយ ។

## ជំពូក ៩
## បញ្ញត្តិទូទៅ

**មាត្រា ៩៧-** បទបញ្ញត្តិទាំងឡាយ ដែលស្តីអំពីរបៀបគ្រប់គ្រង ដោយមានព្រះមហាក្សត្រិយ៍ជាអគ្គប្រមុខរបស់រដ្ឋនេះ ១ អំពីរបៀបគ្រប់គ្រងដោយអាស្រ័យអ្នកតំណាងរបស់ប្រជារាស្ត្រនេះ ១ អំពីគោលចារិកនៃសេរីភាពនឹងសមភាពដែលរដ្ឋធម្មនុញ្ញនេះធានាអះអាងឱ្យមាននេះ ១ មិនត្រូវសុំកែប្រែសោះឡើយ ។

**មាត្រា ៩៨-** ហាមមិនឱ្យកែប្រែរដ្ឋធម្មនុញ្ញ ដើម្បីនឹងបន្ថយព្រះរាជសិទ្ធិទាំងឡាយដែលមានត្រាទុកជាស្រេចហើយ ។

**មាត្រា ៩៩-** អ្នកដែលមានសិទ្ធិផ្ដើមគំនិតកែប្រែរដ្ឋធម្មនុញ្ញនោះគឺព្រះមហាក្សត្រិយ៍ នាយករដ្ឋមន្ត្រី ប្រធានរដ្ឋសភា នឹងប្រធានក្រុមប្រឹក្សាព្រះរាជអាណាចក្រ ឯប្រធានទាំងពីរនេះត្រូវធ្វើទៅដោយសេចក្ដីអនុម័តិនៃសភារបស់ខ្លួន ដែលបានបញ្ចេញមតិ ដោយមានចំនួនសមាជិកយ៉ាងតិចភាគមួយក្នុងបួន ( ១/៤ ) សុំ ។

**មាត្រា ១០០-** របៀបកែប្រែរដ្ឋធម្មនុញ្ញដូចគ្នានឹងរបៀបដែលមានត្រាទុកសំរាប់បញ្ចេញមតិតាំងច្បាប់ធម្មតា ។ ប៉ុន្តែត្រូវមានភាគច្រើនដល់បីក្នុងបួន ( ៣/៤ ) នៃរដ្ឋសភាយល់ព្រមផង ទើបយកជាការបាន ហើយមិនអាចប្រកាសថាជាការប្រញាប់បានទេ ។

**មាត្រា ១០១-** រដ្ឋសភាមានសិទ្ធិបកស្រាយសេចក្ដីបទរដ្ឋធម្មនុញ្ញនេះជាដាច់ខាត ។

**មាត្រា ១០២-** ដើម្បីនឹងកំណត់ភាគច្រើនដោយដាច់ខាតក្នុងចំនួនសមាជិកនៃសភានីមួយៗ ត្រូវគិតចំនួនសមាជិកនៃសភានោះដោយឥតរាប់បញ្ចូល ÷

- សមាជិកណាដែលទទួលអនិច្ចកម្មទៅហើយ
- សមាជិកណា ដែលផុតចាកសមាជិកភាព ដោយលាលែងក្ដី ដោយត្រូវបណ្ដេញក្ដី ឬដោយមិនបានទទួលតាំងជាសមាជិកពេញទីក្ដី
- សមាជិកណា ដែលទទួលតំណែងក្នុងរដ្ឋាភិបាលឬត្រូវបញ្ជូនទៅប្រតិបត្តិការឯណាក្ដី ។

**មាត្រា ១០៣-** បទបញ្ញត្តិទាំងពួង ដែលត្រឹមត្រូវតាមច្បាប់ មិនផ្ទុយសេចក្ដីគ្នានឹងរដ្ឋធម្មនុញ្ញនេះត្រូវដឹកលំទុកប្រតិបត្តិតទៅ ។

## ជំពូក ១០

## អន្តរបញ្ញត្តិ

**មាត្រា ១០៤-** រហូតដល់វេលាដែលអង្គការថ្មីទាំងឡាយ ដូចមានបញ្ញត្តិទុកក្នុងរដ្ឋធម្មនុញ្ញនេះ អាចប្រតិបត្តិការបានត្រឹមត្រូវតាមច្បាប់, បទបញ្ញត្តិទាំងឡាយដែលកំណត់មុខក្រសួងនៃអង្គការទាំងនោះ ក៏យកមកប្រើពុំទាន់បានដែរ, ហេតុនេះរបៀបចាស់ដែលប្រើសព្វថ្ងៃត្រូវប្រើតទៅទៀត ដោយអនុលោមតាមត្រូវការទៅតាមមាត្រាណានៃរដ្ឋធម្មនុញ្ញដែលយកមកប្រើបានតាំងពីឥឡូវនេះទៅ ហើយដែលកែប្រែ ឬបញ្ជាក់របៀបចាស់នោះ ។

**មាត្រា ១០៥-** ដោយអនុលោមតាមវិធានទូទៅ ដែលមានកំណត់ទុកក្នុងមាត្រាមុននេះ ហើយក្នុងរយៈវេលាដូចមានខាងលើ ដោយចំពោះ ÷

បើរាជសម្បត្តិទំនេរ ចាប់តាំងពីថ្ងៃដែលទំនេរនោះទៅទល់នឹងថ្ងៃចាត់តាំងព្រះមហាក្សត្រិយ៍អង្គថ្មីឬព្រះរាជានុសិទ្ធ អំណាចនៃប្រមុខរបស់រដ្ឋត្រូវប្រគល់ទៅនាយករដ្ឋមន្ត្រី ;

សិទ្ធិបកស្រាយបទបញ្ញត្តិរដ្ឋធម្មនុញ្ញជាភារៈ នៃព្រះមហាក្សត្រិយ៍ក្នុងពេលប្រជុំគណៈរដ្ឋមន្ត្រី ;

**មាត្រា ១០៦-** ព្រោះហេតុថា បើនឹងយករបៀបគ្រប់គ្រងដោយអាស្រ័យសភាទាំងពីរជាពេញទីមកប្រើតាមបទបញ្ញត្តិរដ្ឋធម្មនុញ្ញនេះភ្លាមទៅ នឹងអាចបណ្តាលឱ្យកើតការទើសទាស់មិនស្រួលឡើង ព្រះមហាក្សត្រិយ៍ទ្រង់នូវព្រះរាជអំណាចបង្អាក់ពុំទ្រង់ប្រកាសឱ្យប្រើច្បាប់ណាក៏ដោយ ដែលរដ្ឋសភាបានបញ្ចេញមតិតាំងឡើង នឹងទ្រង់ព្រះរាជអំណាចកែប្រែបទបញ្ញត្តិនៃច្បាប់នោះបាន ដោយសេចក្តីសុំនៃគណៈរដ្ឋមន្ត្រី ។ ព្រះមហាក្សត្រិយ៍ទ្រង់

នូវព្រះរាជអំណាចនេះ ចាប់តាំងពីពេលដែលរដ្ឋសភានឹងក្រុមប្រឹក្សាព្រះរាជអាណាចក្រអាច ប្រតិបត្តិមុខក្រសួងរបស់ខ្លួនបាន រហូតដល់ថ្ងៃដែលនឹងមានកំណត់ទុកក្នុងច្បាប់ពិសេសមួយ ដែលគណៈរដ្ឋមន្ត្រីសុំឱ្យតាំង ។

ព្រះមហាក្សត្រិយ៍នឹងទ្រង់ប្រើព្រះរាជអំណាចដូច្នេះបាន លុះត្រាតែទ្រង់បានដាក់ឱ្យ សភាទាំងពីរ ពិចារណាច្បាប់នោះជាថ្មីទៀត ដូចមានបញ្ញត្តិទុកក្នុងមាត្រា ៣៦ នៃរដ្ឋធម្មនុញ្ញ នេះ ។

រយៈវេលាប្រើបទបញ្ញត្តិដែលមានត្រាទុកក្នុងវគ្គទាំងពីរមុននេះត្រូវកំណត់យ៉ាង តិចប្រាំមួយខែ តែមិនឱ្យយូរហួសពីអវសានវេលាធម្មតានៃនីតិកាលដំបូងនោះទេ ។

**មាត្រា ១០៧-** ក្នុងរយៈវេលាដូចបានពោលក្នុងមាត្រាខាងលើនេះ ឥស្សរជនណា ដែលព្រះមហាក្សត្រិយ៍ទ្រង់បានតម្រូវឱ្យតាំងគណៈរដ្ឋមន្ត្រីថ្មី នឹងធ្វើបញ្ជីរាយឈ្មោះសមាជិកនៃ គណៈរដ្ឋមន្ត្រីនោះយកជាស្រេចដើម្បីនឹងនាំខ្លួនទៅបង្ហាញរដ្ឋសភាបាន លុះតែព្រះមហា-ក្សត្រិយ៍សព្វព្រះរាជហឫទ័យនឹងនាមដែលមានក្នុងបញ្ជីនោះជាមុនសិន ។

ធ្វើក្នុងព្រះបរមរាជវាំងក្រុងភ្នំពេញ នៅថ្ងៃអង្គារ ២ រោច ខែ ពិសាខ ឆ្នាំកុរនព្វស័ក ព្រះពុទ្ធសករាជ ២៤៩០ ត្រូវនឹងថ្ងៃ ៦ ខែ ឧសភា (ម៉េ) គ្រិស្តសករាជ ១៩៤៧ ។

ព្រះបរមរាជហត្ថលេខា ÷

**ន.សីហនុ**

ទទួលព្រះរាជឱង្ការ
នូវព្រះបន្ទូលសូរសីហនាទដំកល់លើត្បូង
ប្រធានរដ្ឋសភា

ហត្ថលេខា ÷ **អៀវ កើស**

---

# សេចក្ដីអធិប្បាយពាក្យខ្លះក្នុងរដ្ឋធម្មនុញ្ញ

# សេចក្ដីអធិប្បាយពាក្យ

លោក អៀវ-កើសប្រធានរដ្ឋសភាបណ្ដោះអាសន្ន បានរៀបរៀងដោយបានប្រឹក្សាព្រមព្រៀងនឹងគណៈកម្មការវប្បធម៌ ។

**ករណី** — ការដែលកើតឡើង ហេតុដែលបណ្ដាលឡើង រឿងដែលមានឡើង (cas) ។

**ករណីយកិច្ច** — អ្វីដែលយើងត្រូវធ្វើ, ដូចជាសេចក្ដីគោរពជាករណីយកិច្ចនៃបុត្រចំពោះបិតាមាតា ប្រែសេចក្ដីថា បុត្រត្រូវតែគោរពបិតាមាតា ។ ការបង់ពន្ធជូនរាជការជាករណីយកិច្ចនៃពលរដ្ឋទាំងឡាយ (devoir) ។

**ក្រុមប្រឹក្សាព្រះរាជអាណាចក្រ** — ទីប្រជុំឬសភាមួយ ទំនងប្រហែលគ្នានឹងរដ្ឋសភាដែរ តែរដ្ឋសភាកាន់អំណាចនីតិបញ្ញត្តិ ឯសភានេះមិនកាន់អំណាចនីតិបញ្ញត្តិទេ គ្រាន់តែពិនិត្យច្បាប់ដែលរដ្ឋសភាបានបញ្ចេញមតិតាំងហើយ នឹងបញ្ហាដែលរដ្ឋសភាបញ្ជូនមកឱ្យពិនិត្យ ។

**ក្រុមឥស្សរិយយស** — ក្រុមឬពួកជនដែលមានកេរ្តិ៍ឈ្មោះ ។ ក្រុមទាំងនេះគេបង្កើតឡើងដើម្បីជាបំណាច់ដល់ជនដែលបានប្រព្រឹត្តល្អ បានធ្វើប្រយោជន៍ដល់រាជការ ដល់ជាតិ ។ នៅប្រទេសខ្មែរមានក្រុមឥស្សរិយយសកម្ពុជា (Ordre Royal du Cambodge), ក្រុមឥស្សរិយសបំណាច់ខាងក្សេត្រាធិការសុវត្ថារា (Ordre du Mérite Agricole), ក្រុមឥស្សរិយយសមុនីសារភណ្ឌ (Ordre du Mérite Historique, Litèraire et

Scientifique) ក្រុមឥស្សរិយយសព្រះករុណាទ្រង់រាជ្យ (Ordre du Règne) ក្រុមឥស្សរិយយសស្ត្រីវឌ្ឍនា (Ordre du Mérite Féminin) ក្រុមឥស្សរិយយសកីឡាឫទ្ធិ (Ordre du Mérite Sportif) ។ ក្នុងក្រុមឥស្សរិយយសនិមួយ ៗ មានថ្នាក់ផ្សេង ៗ ដូចជា អស្សឫទ្ធិ (chevalier) សេនា (officier) ធិបឌិន (commandeur) វរសេនា (Gand officier) មហាសិរីវឌ្ឍ (grand croix) ទាំងអស់៥ថ្នាក់ ។ ក្រុមឥស្សរិយយសខ្លះមានតែ២ ឬ ៣ ថ្នាក់ ។ មនុស្សក្នុងថ្នាក់និមួយ ៗ នៃក្រុមឥស្សរិយយសមានគ្រឿងឥស្សរិយាភរណ៍ពាក់ជាសំគាល់ ។ គ្រឿងឥស្សរិយាភរណ៍ ហៅថា តាមពាក្យសាមញ្ញថា "មេដាយ" ។

គណៈរដ្ឋមន្ត្រី — ក្រុមរដ្ឋមន្ត្រីទាំងអស់គ្នា រួមបញ្ចូលទាំងរដ្ឋលេខាធិការផង ។

ឆន្ទៈ — សេចក្តីប្រាថ្នា បំណងយ៉ាងមុតមាំ (volonté) ។

ញត្តិ (motion) — ពាក្យដែលសូត្រប្រកាសក្នុងទីប្រជុំ ។ សេចក្តីណែនាំដែលសមាជិកថ្លែងក្នុងទីប្រជុំ ។

ឋានន្តរសក្តិ (ម. "ឋាន" កន្លែង ថ្នាក់ + សំ. ម. "អន្តរ" ចន្លោះ រយៈ លំដាប់ + សំ."សក្តិ" ) បណ្តាសក្តិធំតូចតាមមុខងារ ។

ថវិកា — ប្រែតាមសព្ទថា ថង់ ត្រង់នឹងពាក្យបារាំងប៊ុតសេ (budget) ការគ្រោងប្រាក់ចំណូលចំណាយ ។

ទារុណកម្ម — អំពើកាច, អំពើអាក្រក់ ។ ក្នុងទីនេះបានដល់ការដាក់កំដៅតឹងតែង ។

នាយករដ្ឋមន្ត្រី — រដ្ឋមន្ត្រីដែលធំជាងរដ្ឋមន្ត្រីឯទៀត ដែលជានាយនៃរដ្ឋមន្ត្រីឯទៀត ។ ត្រង់នឹងពាក្យ "អគ្គមហាសេនា" ដែលប្រើក្នុងសម័យមុន ។

នីតិកាល — រយៈវេលានៃរដ្ឋសភារាប់តាំងពីពេលប្រជុំដំបូងរហូតដល់ពេលដែលត្រូវរំលាយ ដើម្បីឱ្យប្រជារាស្ត្រជ្រើសតាំងជាថ្មី ។ តាមធម្មតា នីតិកាលនៃរដ្ឋសភាខ្មែរមានកំណត់ ៤ ឆ្នាំ ។

នីតិភាព — ភាវៈនៃជនដែលមានអាយុពេញការតាមច្បាប់ហើយ, អាយុដែលជនអាចប្រើសិទ្ធិរបស់ខ្លួនដោយពេញបរិបូណ៌ គឺអាយុ ២០ ឆ្នាំសំរាប់ជនជាតិខ្មែរ ។

បញ្ជា — បង្គាប់, តែអ្នកបញ្ជា ច្រើននៅក្នុងឋានៈខ្ពស់ជាងអ្នកបង្គាប់ ។

បេក្ខជន — អ្នកឈរឈ្មោះឱ្យគេជ្រើសតាំងខ្លួន ។ អ្នកឈរឈ្មោះឱ្យរាស្ត្របោះឆ្នោត (candidat) ។

ប្រជុំសាមញ្ញ — ប្រជុំធម្មតា ។ រដ្ឋសភាមានសម័យប្រជុំសាមញ្ញ ២ ក្នុងមួយឆ្នាំ ។ សម័យប្រជុំសាមញ្ញនីមួយៗ មានកំណត់វេលាយ៉ាងតិច ៣ ខែ ។ ដល់ផុតសម័យប្រជុំសាមញ្ញនីមួយ ៗ អ្នកតំណាងរាស្ត្រឈប់សំរាកទៅទីលំនៅរៀងខ្លួន ។ ពេលឈប់សម្រាកនេះ ហៅថាវិស្សមកាល (vacances) ។ បើក្នុងវិស្សមកាលនេះមានសារចំឡែក ត្រូវហៅរដ្ឋសភាមកប្រជុំជាសម័យប្រជុំខុសធម្មតា សម័យប្រជុំនេះហៅថាសម័យ ប្រជុំវិសាមញ្ញ ។

ប្រធាន — អ្នកដែលធំជាងគេក្នុងទីប្រជុំ ។ ជួនកាលហៅថាអធិបតីក៏បាន ។

ប្រមុខ — ក្នុងទីនេះ ប្រើជានាមនាម មេលើគេ អ្នកធំជាងគេ ជាឯក ជាទី ១ ។

ពលរដ្ឋ — សមាជិករបស់រដ្ឋ ជនដែលមានសិទ្ធិពេញ ។ ក្នុងប្រទេសខ្មែរ ជនជាតិខ្មែរ នឹងជនដែលរាប់ជាខ្មែរ ដូចជាចាម គួយ ព្នង... នឹងជនដែលចូលជាតិជាខ្មែរ ជាពលរដ្ឋខ្មែរ។ ឯជនជាតិក្រៅដែលនៅក្នុងព្រះរាជអាណាចក្រដូចជាចិន យួន មិនមែនជាពលរដ្ឋខ្មែរទេ ។ ជនទាំងនេះគ្មានសិទ្ធិពេញដូចខ្មែរ គ្មានសិទ្ធិបោះឆ្នោតជ្រើសតាំងអ្នកតំណាងរាស្ត្រជាដើម (citoyen) ។

ពិសេស — ប្លែក, ដោយឡែក (spécial) ។

ព្រឹត្តិការណ៍ — ហេតុដែលបណ្ដាលកើតឡើងក្នុងលោក ហេតុដែលគួរសំគាល់បាន (évènement)

ភូមិភាគ — ដែនដីជាភាគមួយ ឬចំណែកមួយនៃប្រទេស មិនមែនជាប្រទេសទាំងមូល (région) ។

មតិ — សេចក្ដីយល់, យោបល់ ។

មហាផ្ទៃ — មហា =ធំ : ផ្ទៃ = ខាងក្នុង, ផ្ទាំងផែនដី ។ ឧ. ផ្ទៃពោះ ផ្ទៃសំពត់ ផ្ទៃវាំង ផ្ទៃក្រោម ។ ពាក្យមហាផ្ទៃ ជាពាក្យខ្មែរ ប្រើពីបូរាណមក ។ សៀមខ្ចីទៅប្រើ ជាមហាតថៃ ។ យើងហៅក្លាយទៅជា មហាថៃ រួចយើងលែងប្រើទៅ ប្រើពាក្យរដ្ឋាធិការជំនួស ។ រដ្ឋសភាបានបញ្ចេញមតិឱ្យយកពាក្យដើមមហាផ្ទៃមកប្រើវិញ ដាក់ក្នុងរដ្ឋធម្មនុញ្ញ។ ហេតុនេះត្រូវប្រើតែពាក្យមហាផ្ទៃតទៅ កុំឱ្យប្រើពាក្យមហាថៃ ឬរដ្ឋាធិការទៀត ។

រជ្ជកាល — រយៈវេលាដែលព្រះមហាក្សត្រិយ៍ឋិតនៅក្នុងរាជសម្បត្តិ ។

**រជ្ជទាយាទ** — បុរសដែលត្រូវទទួលរាជសម្បត្តិជាមតិក, ក្សត្រិយ៍ដែលនឹងបំរុងបានសោយរាជ្យជាតំណអំពីព្រះមហាក្សត្រិយ៍ដែលគង់ក្នុងរាជសម្បត្តិ ។

**រដ្ឋ** — ក្នុងទីនេះបានដល់ប្រទេសដែលមានតាំងជារដ្ឋាភិបាលសំរាប់គ្រប់គ្រង ។ ប្រទេសកូស័ងស៊ីនមុនពេលផុតសង្គ្រាមលោកលើកក្រោយនេះមិនមែនជារដ្ឋទេ ព្រោះគ្មានរដ្ឋាភិបាល គឺជាផែនដី ជាអាណានិគម (colonie) បារាំង ។

តាមន័យរដ្ឋធម្មសាស្ត្រ (au point de vue du droit constitutionnel) មនុស្សទាំងឡាយដែលរួមគ្នាជាស័ង្គមមួយនៅក្រោមអំណាចរាជការតែមួយដូចគ្នា ហើយត្រូវប្រតិបត្តិតាមច្បាប់ទូទៅទាំងឡាយតែមួយយ៉ាងដូចគ្នាជា ប្រជាជាតិមួយ (nation) ។

គេអាចទុកប្រជាជាតិដូចជាបុគ្គលម្នាក់ចេះមានសម្បត្តិទ្រព្យ ចេះជំពាក់គេ ចេះឱ្យគេជំពាក់ខ្លួន មានអំណាចបង្គាប់បញ្ជា ។ បុគ្គលនេះគ្មានរូបគ្មានអង្គទេ ហៅថា នីតិបុគ្គល (personne morale) នីតិបុគ្គលនេះហើយ ដែលជារដ្ឋ (Etat) ។

**រដ្ឋមន្ត្រី** — អ្នកកាន់អំណាចនីតិប្រតិបត្តិ ត្រង់នឹងពាក្យសេនាបតីក្នុងសម័យមុន ។

**រដ្ឋលេខាធិការ** — ដូចជារដ្ឋមន្ត្រីដែរ តែកាន់ការដែលមានសារៈសំខាន់តិចជាង (sécrétaire Etat) ។

**រដ្ឋាភិបាល** — នាយករដ្ឋមន្ត្រី នឹងរដ្ឋមន្ត្រីទាំងឡាយព្រមទាំងរដ្ឋលេខាធិការ រួមគ្នាទាំងអស់ជារដ្ឋាភិបាល ។

**រាជកិច្ច** — បារាំងហៅថា (Journal officiel) ប្រែថា "កាសែតរាជការ" ។ ក្នុង

ទីនេះ ជាសៀវភៅដែលរាជការបោះពុម្ពចុះកិច្ចការការផ្សេងៗ ដូចជាច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសំរេច បទបញ្ជា ។ ល ។ ដើម្បីផ្សាយដល់មហាជន ។

**រាជានុសិទ្ធ** — បុរសដែលទទួលព្រះរាជភារៈគ្រងរាជ្យជួសព្រះមហាក្សត្រិយ៍ជាបណ្តោះអាសន្ន (régent) ។

**លក្ខណសម្បត្តិ** — ត្រង់នឹងពាក្យបារាំង (conditions) ប្រើចំពោះលក្ខណៈដែលបុគ្គលត្រូវមានដើម្បីមានសិទ្ធិជ្រើសតាំង ឬដើម្បីឈរឈ្មោះជាបេក្ខជន ។

លក្ខណសម្បត្តិដែលបុគ្គលត្រូវមាន ដើម្បីជ្រើសតាំងអ្នកតំណាងរាស្ត្របាននោះ គឺជាពលរដ្ឋខ្មែរភេទបុរស អាយុយ៉ាងតិច ២០ ឆ្នាំបរិបូណ៌ ពុំមែនជាទាហាន ពុំមែនជាបព្វជិត ពុំមែនជាបុរសដែលបានទទួលទណ្ឌកម្មបទឧក្រិដ្ឋធម្មតា ពុំមែនជាមនុស្សវិកលចរិត ។ ល ។

ពាក្យ (conditions) ក្នុងទីឯទៀតមានប្រែថាលក្ខខណ្ឌ ។

**លក្ខខណ្ឌ** — កំរិត កំណត់ (Condition) ។

**លិខិតសញ្ញា** — សំបុត្រសន្យា ។

**វិជ្ជាជីវៈ** (ម. វិជ្ជា + អាជីវៈ) អាជីវៈគឺរបរមុខការរកស៊ី (Métier) វិជ្ជាជីវៈ (Profession) គឺអាជីវៈ ដែលត្រូវប្រើវិជ្ជា បានដល់របរដែលមានចំណេះផងទើបធ្វើបាន ដូចជាធ្វើពេទ្យ ធ្វើអាចារ្យជាដើម្បី ។

**វិធាន** — វិធី បែប ក្បួន (règle) ។

**វិន័យ** — ច្បាប់ទាំងពួងដែលមនុស្សក្នុងពួក ឬក្នុងក្រុមជាមួយគ្នាត្រូវធ្វើតាមដូចគ្នា (discipline) ។

**សច្ចាប័ន —** ការបញ្ជាក់ត្រឹមត្រូវតាមរបៀបច្បាប់នូវរបស់ដែលបានធ្វើហើយ ឬដែលបានសន្យាហើយ (ratification) ។

**សន្ធិសញ្ញា —** (សំ.ម "សន្ធិ" ការត ការភ្ជាប់ + ម. "សញ្ញា" ) លិខិតសញ្ញាដែលប្រទេសមួយធ្វើនឹងប្រទេសមួយទៀត ដើម្បីឱ្យមានការទាក់ទងភ្ជាប់គ្នាទៅវិញទៅមក ។ សន្ធិសញ្ញា (traité) ជាលិខិតសញ្ញាដែលមានសារៈសំខាន់ជាងលិខិតសញ្ញាឯទៀត ។ ប្រទេសខ្មែរបានធ្វើសន្ធិសញ្ញាមួយនឹងប្រទេសបារាំងនៅ គ.ស. ១៨៦៣ ។

លិខិតសញ្ញាដែលមានសារៈសំខាន់តិចបន្ទាប់មកហៅថា អនុសញ្ញា (convention) ។ ប្រទេសយើងបានធ្វើអនុសញ្ញាមួយនឹងប្រទេសបារាំងនៅ គ.ស. ១៨៨៤ ។

លិខិតសញ្ញាដែលមានសារៈសំខាន់តិចមកទៀត ហៅថា កិច្ចព្រមព្រៀង (accord) ។ តាំងពីផុតមហាសង្គ្រាមលើកក្រោយនេះមក ប្រទេសយើងបានធ្វើកិច្ចព្រមព្រៀងនឹងប្រទេសបារាំងទាំងអស់ ៩ កិច្ច ។

**សមត្ថភាព —** ភាពនៃបុគ្គលដែលអាចធ្វើបាន (capacité) ។

ឧ. ខ្ញុំចេះធ្វើទូមួយបាន ហើយខ្ញុំមានកំឡាំងនឹងគ្រឿងប្រដាប់ល្មមនឹងធ្វើទូនោះកើត គេថាខ្ញុំមានសមត្ថភាពធ្វើទូនោះបាន ។ បើខ្ញុំធ្វើមិនកើត គេថាខ្ញុំគ្មានសមត្ថភាពទេ ។

**សមភាព —** ភាពស្មើគ្នា ។ ខេមរជនមានសមភាព ប្រែសេចក្ដីថា ខេមរជនមានសិទ្ធិស្មើគ្នា គ្មាននរណាមានសិទ្ធិច្រើនជាងនរណាទេ (égalité) ។

**សមាគតរដ្ឋ —** មើលក្នុង "សហភាព" ។ (Etat associé)

សមាជិក — (សំ.ម. "សមាជិ" ទីប្រជុំ ក្រុម សមាគម + "អិក" បច្ច័យ) អ្នកចូលក្នុងសមាគម ក្នុងក្រុមណាមួយ ។ ក្នុងគ្រួសារមួយ ឧបមាថាមានគ្នា ៧ នាក់ ជីតា ជីដូន ឪពុក ម្ដាយ នឹងកូន ៣ នាក់ ។ មនុស្សទាំង ៧ នាក់នេះ ជាសមាជិកនៃគ្រួសារនោះ ។ ជីតាជាសមាជិកមួយ ជីដូនជាសមាជិកមួយ ឪពុកជាសមាជិកមួយ ។ល។ អ្នកដំណាងរាស្ត្រ ជាសមាជិកនៃរដ្ឋសភា ។

សមាជិកភាព — ភារៈនៃជនដែលជាសមាជិក ។ សមាជិកភាពនៃរដ្ឋសភា គឺ ភារៈជាអ្នកតំណាងរាស្ត្រ ។ ធ្លាក់ចាកសមាជិកភាពរដ្ឋសភា គឺលែងអ្នកជាតំណាងរាស្ត្រ ។

សហភាព — (សំ.ម. "សហ" ជាមួយ + "ភាវ" = ភាព) - ភាពជាមួយគ្នា ការ រួបរួមរបស់ផ្សេងៗ ឱ្យទៅជារបស់តែមួយ ។ ប្រទេសបារាំងនៅអឺរ៉ុប ខេត្តបារាំង នឹងដែនដី បារាំងឯនាយសមុទ្រ នេះប៉ែកមួយដែនដីសមាគត នឹង រដ្ឋសមាគត ឬ សមាគតរដ្ឋ នេះជា ប៉ែកមួយទៀតរួមគ្នាទៅជា សហភាពបារាំង (Union Française) ។

ខេត្តបារាំងឯនាយសមុទ្របានដល់ដែនដីខ្លះ ដូចជា អាល់សេរ អូរ៉ង់ នឹងកុងស្តង់ទីន ។ ខេត្តទាំងបីនេះរួមគ្នាហៅថា អាល់សេរី ។

- ដែនដីបារាំងឯនាយសមុទ្របានដល់កោះឡារ៉េអ៊ុយញ៉ុង ដែនដីសេណេកាល ដែនដី ប៉ុងឌីសេរី ជាដើម ។

សមាគតរដ្ឋ គឺរដ្ឋដែលនៅក្នុងសហភាពបារាំង ។ សហភាពបារាំង ទុកដូចក្រុមហ៊ុនមួយ ឬសមាគមមួយ ។ រដ្ឋដែលនៅក្នុងសហភាពបារាំង ដូចជាអ្នកចូលហ៊ុនក្នុងសមាគមនោះ ទើប

ហៅថា សមាគតរដ្ឋ ។ ពាក្យ "សមាគត" (associé) មកពីពាក្យ "សមាគម" (associété) ដែលអាចប្រែថា "ក្រុមហ៊ុន" នោះឯង ។

- ដែនដីសមាគត ក៏ប្រហែលគ្នានឹងសមាគតរដ្ឋដែរ តែជាស័ង្គមតូចជាង ហើយគ្មានរដ្ឋាភិបាលគ្រប់គ្រងដូចជារដ្ឋ ។ អ្នកស្រុកក្នុងខេត្តនឹងដែនដីបារាំងឯនាយសមុទ្រ មានសិទ្ធិជាពលរដ្ឋបារាំង (citoyens français) ដូចអ្នកស្រុកក្នុងប្រទេសបារាំងដែរ ឯអ្នកស្រុកក្នុងដែនដីសមាគត នឹងក្នុងសមាគតរដ្ឋ មិនមែនជាពលរដ្ឋបារាំងទេ គ្រាន់តែជាពលរដ្ឋនៃសហភាពបារាំង (citoyens de l'Union Française)

សាកល — ទាំងអស់ ទាំងមូល ។ បោះឆ្នោតសាកល គឺបោះឆ្នោតទាំងអស់គ្នា ÷ ពលរដ្ឋគ្រប់រូបអាចបោះឆ្នោតបានទាំងអស់គ្នា ឱ្យតែមានលក្ខណសម្បត្តិគ្រប់គ្រាន់ (universel) ។

សិទ្ធិ — ដំណើរអាចធ្វើអ្វីមួយបាន (droit) ។ ឧទាហរណ៍ ÷ ខ្ញុំទិញសំបុត្រមើលកុន ខ្ញុំមានសិទ្ធិចូលទៅក្នុងរោងកុន ហើយអង្គុយមើលក្នុងទីណាមួយបាន ។

ស្វ័យរាជ្យ — (សំ. "ស្វយម" ខ្លួនឯង + "រាជ្យ" ការគ្រប់គ្រងដែនដី) ការគ្រប់គ្រងប្រទេសដោយខ្លួនឯង ។ រដ្ឋឯករាជ ជារដ្ឋដែលមានអំណាចអធិបតេយ្យពេញទី គឺអំណាចអធិបតេយ្យខាងក្នុងប្រទេស នឹងអំណាចអធិបតេយ្យខាងក្រៅប្រទេស ។ រដ្ឋស្វ័យរាជ មានតែអំណាចអធិបតេយ្យខាងក្នុងប្រទេស ឯអំណាចអធិបតេយ្យខាងក្រៅប្រទេសត្រូវប្រគល់ទៅឱ្យរដ្ឋមួយផ្សេងទៀតដែលជារដ្ឋឯករាជ្យ ។ ប្រទេសកម្ពុជាជារដ្ឋស្វ័យរាជ ប្រែសេចក្តី

ជា ខ្មែរគ្រប់គ្រងខ្លួនឯងដោយអាស្រ័យច្បាប់ដែលខ្មែរតាំងឡើងខ្លួនឯង ។ តាមន័យមួយទៀត ជាកិច្ចការក្នុងប្រទេសខ្មែរស្រេចតែលើខ្មែរ ។ ឯកិច្ចការក្រៅប្រទេស គឺកិច្ចការដែលទាក់ទងនឹងប្រទេសក្រៅ ជាភារៈលើបារាំង (អាន ស្វៃ- យ: (Autonomie) ។

អគ្គសេនាប្រមុខ — (ម. "អគ្គ" កំពូល ចុងខាងលើ + សំ.ម. "សេនា" ពួកទាហាន ទ័ព + សំ. "ប្រមុខ") នាយឬមេទាហានធំបំផុត ។

អនីតិភាព — ភាវៈនៃក្មេងដែលមានអាយុមិនទាន់ពេញការតាមកំណត់ច្បាប់ ។

អនុម័តិ — (សំ. ម. "អនុ" តាម + "មតិ" យោបល់) - សេចក្តីយល់ព្រមតាម ។ ប្រើជាកិរិយាសព្ទក៏បាន យល់ព្រមតាម ។

អនុលោម — (សំ.ម. "អនុ" តាម បណ្តោយ + "លោម" រោម ) បណ្តោយរោម បណ្តោយតាម ។

អភ័យឯកសិទ្ធិ — សិទ្ធិដែលជនខ្លះមានចំពោះខ្លួនម្នាក់ៗ មិនឱ្យមានភ័យ មានទោសដល់ខ្លួន ដូចជាមិនឱ្យគេចោទ គេចាប់ គេឃុំឃាំងជាដើម ។

អវសាន — ទីបំផុត ទីចប់ ទីអស់ ។

អសាកល — មិនមែនទាំងអស់ មិនមែនទាំងមូល បោះឆ្នោតអសាកលគឺបោះឆ្នោតមិនទាំងអស់គ្នា ជនខ្លះមានសិទ្ធិបោះឆ្នោត ជនខ្លះគ្មាន ។ ដូចជាក្នុងការជ្រើសតាំងទីប្រឹក្សាព្រះរាជអាណាចក្រមួយនាក់ដែលជាអ្នកតំណាងអ្នកជំនួញស្រូវ មានតែអ្នកជំនួញស្រូវតែប៉ុណ្ណោះដែលមានសិទ្ធិបោះឆ្នោតបាន ។ ឯជនដែលមិនធ្វើជំនួញស្រូវ ធ្វើតែជំនួញឯ

ទៀត ឬមិនធ្វើជំនួញទេ នោះគ្មានសិទ្ធិបោះឆ្នោតជ្រើសតាំង ទីប្រឹក្សាព្រះរាជអាណាចក្រនេះទេ ។ (suffrage restreint)

អាណត្តិ — សេចក្តីបង្គាប់ ។ ក្នុងទីនេះ គឺសិទ្ធិដែលប្រជារាស្ត្រប្រគល់ទៅជនណាមួយឱ្យនិយាយការជួសខ្លួន ។ (mandat)

ឧបសគ្គ — គ្រឿងទើសទាក់, គ្រឿងជំទាស់, គ្រឿងរារាំង (obstacle) ។

អំណាចតុលាការ — អំណាចជំរះកាត់សេចក្តី ។

អំណាចនីតិបញ្ញត្តិ - (សំ.ម. "នីតិ" ច្បាប់ + ម "បញ្ញត្តិ" (សេចក្តីតាំងទុក, រៀបចំទុក) អំណាចធ្វើច្បាប់ តាំងច្បាប់ ។

អំណាចនីតិប្រតិបត្តិ — អំណាចប្រើច្បាប់ដែលតាំងទុកមកហើយ អំណាចយកច្បាប់ទៅដាក់ឱ្យប្រតិបត្តិតាម ។

# រដ្ឋធម្មនុញ្ញ
# ប្រទេសកម្ពុជា

Constitution
du
ROYAUME DU CAMBODGE




តាមលិខិតអនុញ្ញាតរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ លេខ ១.០៤២ ក.ទ.ទ. ចុះថ្ងៃទី ១៦ ខែ កក្កដា ១៩៥៩ បានអនុញ្ញាតឱ្យសហជីវិន ទ្រិញ វ៉ាញ អ្នកដំណាងរាស្ត្រ រៀបចំរដ្ឋធម្មនុញ្ញ ឱ្យបានត្រឹមត្រូវតាមការកែប្រែពីរដ្ឋសភា

រោងពុម្ព គីម គី បណ្ណាគារលេខ ៩៥
វិថី យុគន្ធរ ភ្នំពេញ ១៩៦៩ បោះពុម្ពលើកទី ២

# រដ្ឋធម្មនុញ្ញ

# ប្រទេសកម្ពុជា

# រដ្ឋធម្មនុញ្ញប្រទេសកម្ពុជា

ព្រះបាទសម្តេច **ព្រះនរោត្តម សីហនុ វរ្ម័ន** រាជហរិវង្ស ឧភតោ សុជាត វិសុទ្ធិពង្ស

អគ្គមហាបុរសរតន៍ និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

រដ្ឋឯករាជ្យ ពេញដោយអធិបតេយ្យភាព

ទ្រង់ប្រោសព្រះរាជទាន

ដល់ប្រជារាស្ត្ររបស់ព្រះអង្គនូវរដ្ឋធម្មនុញ្ញ ដូចមានសេចក្តីតទៅនេះ ÷

## ជំពូក ១

## ធម្មជាតិ នឹងសណ្ឋានរបស់រដ្ឋ

មាត្រា ១.- ប្រទេសកម្ពុជា ជាប្រជាជាតិមួយមានព្រះមហាក្សត្រិយ៍សោយរាជ្យ ។

មាត្រា ២.- (កែប្រែ) ភាសាដែលប្រើជាផ្លូវការគឺភាសាខ្មែរ ។

## ជំពូក ២

## សេរីភាព សិទ្ធិនឹងករណីយកិច្ច របស់ខេមរជន

មាត្រា ៣.- សេរីភាព ជាដំណើរអាចធ្វើអ្វីបានគ្រប់យ៉ាង កុំឱ្យតែប៉ះពាល់ឱ្យខូចសិទ្ធិអ្នកដទៃ ។ លក្ខខណ្ឌនៃការប្រើសេរីភាពមានត្រាទុកក្នុងច្បាប់ ។

អ្វីដែលច្បាប់មិនបង្គាប់ឱ្យធ្វើទេ ជនណាក៏ដោយមិនអាចត្រូវគេបង្ខំឱ្យធ្វើបានឡើយ ។

មាត្រា ៤.- នឹងចោទចាប់ ឬឃុំឃាំងជនណាមួយបាន លុះតែជននោះប្រព្រឹត្តបទដែលមានត្រាទុកក្នុងច្បាប់ ឯអ្នកចោទ-អ្នកចាប់ ឬអ្នកឃុំឃាំង ត្រូវប្រតិបត្តិតាមរបៀបដែលច្បាប់បានបញ្ញត្តទុក ។

នឹងឃុំឃាំងជនណាទុកបាន លុះតែមានចៅក្រមពិនិត្យការឃុំឃាំងនោះឃើញជាត្រឹមត្រូវតាមច្បាប់ហើយយល់ព្រមផង ដោយចង្អុលហេតុផលក្នុងរយៈវេលាដែលមានកំណត់ទុកក្នុងច្បាប់ ។

ទារុណកម្មឬការបង្ខំដែលឥតប្រយោជន៍ក្នុងខណៈចាប់ជនណាមួយ ការសង្កត់សង្កិនចិត្ត ឬការធ្វើបាបដល់រាងកាយចំពោះអ្នកជាប់ឃុំណាមួយ ការប្រព្រឹត្តដែលបណ្ដាលឱ្យធ្ងន់ថែមទៅលើទណ្ឌកម្ម ដែលតុលាការបានតម្រូវតាមច្បាប់ទៅលើអ្នកមានទោសណាមួយស្រេចហើយ នោះច្បាប់ហាមមិនឱ្យប្រព្រឹត្ត ហើយក្នុងបទទាំងនេះ អ្នកដៃដល់ អ្នកមេគំនិត ឬអ្នកសមគំនិតត្រូវទទួលខុសត្រូវផ្ទាល់ខ្លួន ។

មាត្រា ៥.- ដរាបណាតុលាការមិនទាន់ប្រកាសថាអ្នកត្រូវចោទមានទោសទេ ដរាបនោះ ត្រូវទុកអ្នកត្រូវចោទជាមនុស្សឥតទោស ។

ទណ្ឌកម្មដែលបំបាត់ឬបន្ថយសេរីភាពដល់អ្នកប្រព្រឹត្តខុស ត្រូវដាក់ដោយញ៉ាំងឱ្យកែខ្លួនបានល្អឡើងវិញ ។

មាត្រា ៦.- ខេមរជនមិនអាចត្រូវនិរទេសពីដែនខ្មែរបានឡើយ ។ ការហាមខេមរ-ជនមិនឱ្យនៅក្នុងកន្លែងណាមួយ ឬការបង្ខំឱ្យនៅក្នុងកន្លែងណាមួយ ត្រូវធ្វើតែក្នុងករណីដែល

មានបញ្ញត្តទុកក្នុងច្បាប់ ។

មាត្រា ៧.- កម្មសិទ្ធិឋិតនៅក្នុងការឃុំគ្រងនៃច្បាប់ ។ ដែលនឹងដកហូតកម្មសិទ្ធិអំពីជនណាមួយបាននោះក៏ដោយហេតុជាសាធារណៈប្រយោជន៍ក្នុងករណីដែលច្បាប់បានបញ្ញត្តទុក ហើយត្រូវឱ្យសោហ៊ុយជួសជុលជាមុន ដោយយុត្តិធម៌ ។

មាត្រា ៨.- សេរីភាពខាងជំនឿត្រូវបើកឱ្យមានដោយបរិបូរណ៍ ។ សេរីភាពក្នុងការប្រតិបត្តិខាងផ្លូវសាសនា ក៏ត្រូវបើកឱ្យមានដូច្នោះដែរបើនឹងបន្ថយខ្លះបាន តែត្រង់ណាដែលវៀរពុំបាន ដើម្បីកុំឱ្យខូចសេចក្ដីស្ងប់រៀបរយដល់មហាជន ។

ព្រះពុទ្ធសាសនា ជាសាសនារបស់រដ្ឋ ។

មាត្រា ៩.- ខេមរជន មានសេរីភាពក្នុងការនិយាយ, សរសេរ, បោះពុម្ពនឹងការផ្សាយដល់មហាជន ។ ខេមរជនអាចសំដែងផ្សាយឬការពារមតិគ្រប់យ៉ាងតាមផ្លូវកាសែតក្ដី តាមវិធីណាឯទៀតក្ដី កុំឱ្យតែប្រើសិទ្ធិនេះដោយរំលោភ ហើយកុំឱ្យតែញុំាងឱ្យខូចសេចក្ដីស្ងប់រៀបរយដល់មហាជន ។

មិនត្រូវបង្ខំ ឬបង្គាប់នរណាឱ្យសំដែងមតិថាដូច្នេះ ឬ ដូច្នោះបានឡើយ ។

មាត្រា ១០.- ខេមរជនទាំងពួង មានសិទ្ធិរួបរួមជាសមាគមដោយសេរី កុំឱ្យតែសមាគមនោះធ្វើឱ្យខូច ឬ ញុំាងឱ្យខូចសេរីភាពទាំងឡាយ ដែលរដ្ឋធម្មនុញ្ញនេះធានាអះអាងឱ្យមាន ។

ត្រូវបើកឱ្យមានសេរីភាពក្នុងការប្រជុំផងដែរ ។

មាត្រា ១១.- ទីលំនៅមិនត្រូវនរណាចូលទៅរុករានបានឡើយ ។ នឹងចូលទៅក្នុង

លំនៅគេបាន តែក្នុងករណីដែលច្បាប់បានបញ្ញត្តទុក ហើយឱ្យត្រូវតាមរបៀបច្បាប់ផង ។

មាត្រា ១២.- សំបុត្រដែលផ្ញើទៅមករកគ្នា មិនត្រូវនរណាបើកមើលបានឡើយ វៀរលែងតែមានច្បាប់អនុញ្ញាតដោយជាក់ស្តែងជាបណ្តោះអាសន្នឱ្យបើក ក្នុងវេលាដែលប្រយោជន៍យ៉ាងធំរបស់ប្រជាជាតិបង្គាប់ឱ្យធ្វើដោយខានពុំបាន ។

មាត្រា ១៣.- ខេមរជនទាំងពួង ត្រូវទទួលតំណែងរាជកាបានដូចគ្នា។ ក្រៅអំពីគុណសម្បត្តិនឹងសមត្ថភាពរបស់សាមីខ្លួន គ្មានអ្វីជាហេតុបណ្តាលឱ្យជននេះទទួលបាន ឱ្យជននោះទទួលពុំបានទេ ។

មាត្រា ១៤.- ខេមរជននីមួយៗ មានសិទ្ធិចូលពាក្យប្តឹងសុំទៅអ្នកកាន់អំណាចសាធារណៈបាន ដើម្បីនាំឱ្យមានការពិចារណាបញ្ហាទាំងឡាយ ដែលមានផលប្រយោជន៍ចំពោះបុគ្គល ឬ ដល់មហាជន ។

មាត្រា ១៥.- ការប្រើសិទ្ធិទាំងឡាយដែលរដ្ឋធម្មនុញ្ញនេះធានាអះអាង មិនត្រូវបង្អាក់បង្អានបានឡើយ ។ ប៉ុន្តែបើប្រជាជាតិត្រូវប្រកាសថានៅក្នុងភយន្តរាយ នោះសិទ្ធិដែលមានពណ៌នាក្នុងមាត្រា ៤-៩ (វគ្គទី ១) -១០ (វគ្គទី ២) និង ១២ អាចត្រូវបង្គាប់ឱ្យឈប់ប្រើសិនបានតាមកិរិតនឹងរបៀបដែលមានបញ្ញត្តទុកក្នុងច្បាប់ ។

ការបង្អាក់បង្អាននេះ មិនត្រូវឱ្យយូរលើសពីប្រាំមួយខែ ប៉ុន្តែនឹងបន្តជាថ្មីទៀត តាមរបៀបដដែលក៏បាន ។

ជនណារលោភប្រើការបង្អាក់បង្អាននេះ ដើម្បីធ្វើតាមទំនើងចិត្តឱ្យខូចសិទ្ធិអ្នកដទៃខាងភោគទ្រព្យក្តី ខាងផ្លូវចិត្តក្តី ជននោះត្រូវទទួលខុសត្រូវក្នុងបទនេះ ដោយផ្ទាល់ខ្លួន ។

ដល់ផុតពេលបង្អាក់បង្អាននេះហើយ ជនណាយល់ថាខ្លួនត្រូវគេធ្វើតាមទំនើងចិត្ត ឱ្យឈឺចាប់ដល់រាងកាយក្តី ឱ្យខូចខាតដល់ភោគទ្រព្យក្តី ជននោះអាចប្តឹងសាលាជំរះក្តី សុំឱ្យជួសជុលខាងផ្លូវចិត្ត ឬខាងធនធានបាន ។

មាត្រា ១៦.- ខេមរជននីមួយៗត្រូវឱ្យមានចិត្តស្មោះត្រង់ចំពោះព្រះមហាក្សត្រិយ៍ ។ ត្រូវមានករណីយកិច្ច ប្រតិបត្តិច្បាប់ការពារប្រទេស ហើយជួយរដ្ឋាភិបាល ដោយបង់ពន្ធដារ និងដោយវិធីគ្រប់យ៉ាង ដែលមានបញ្ញត្តទុកក្នុងច្បាប់ ។

## ចំពូក ៣
## អំពីច្បាប់ នឹងអំណាច

មាត្រា ១៧.- ច្បាប់ជាសេចក្តីសំដែងឆន្ទៈរបស់ប្រជាជាតិ ។ ច្បាប់ត្រូវប្រើទៅលើជនទាំងអស់ បើទោះជាច្បាប់នោះរក្សាការពារក្តី ផ្តន្ទាទោសក្តី បង្ខិតបង្ខំក្តី ។

ច្បាប់ធានាអះអាងឱ្យខេមរជនទាំងពួង ប្រើសេរីភាពនឹងសិទ្ធិទាំងឡាយ ដូចមានរៀបរាប់នៅក្នុងចំពូកមុននេះ បើទោះជាដូចម្តេចក៏ដោយច្បាប់មិនអាចធ្វើឱ្យខូចសេរីភាពនឹងសិទ្ធិទាំងនោះបានឡើយ ។

មាត្រា ១៨.- ច្បាប់ធានាអះអាងឱ្យមនុស្សទាំងពួងមានសិទ្ធិឱ្យតុលាការទទួលជំនុំជំរះ ។ សេចក្តីខ្វះខាតធនធានមិនគ្រប់គ្រាន់ មិនអាចជាឧបសគ្គក្នុងការឱ្យតុលាការទទួលជំនុំជំរះបានឡើយ ។

មាត្រា១៩.- វៀរលែងតែមានបញ្ញត្តិពិសេសដោយជាក់ច្បាស់ក្នុងច្បាប់ ច្បាប់មិន

ត្រូវយកទៅប្រើលើអំពើដែលកន្លងទៅហើយ មុនពេលឱ្យប្រតិបត្តិតាមនោះទេ ។

ប៉ុន្តែជនណាក៏ដោយ នឹងអាចត្រូវតុលាការជំនុំជំរះ នឹងដាក់ទណ្ឌកម្មបាន លុះតែជននោះ បានប្រព្រឹត្តបទល្មើសមានក្នុងច្បាប់ណាមួយ ដែលមានប្រកាសឱ្យប្រើហើយ ហើយដែលត្រូវប្រើមុនមានបទល្មើសនោះ ។

មាត្រា ២០.- ច្បាប់ត្រូវប្រតិបត្តិតាម ÷

- នៅភ្នំពេញ កំណត់មួយថ្ងៃគត់ ក្រោយដែលបានចុះច្បាប់នោះក្នុងរាជកិច្ច ។
- នៅទីឯទៀត គឺក្នុងដែនស្រុកនីមួយៗកំណត់ប្រាំថ្ងៃគត់ ក្រោយរាជកិច្ចដែលមានចុះច្បាប់នោះ ទៅដល់សាលាស្រុក ។

ប៉ុន្តែ បើច្បាប់បានសំដែងថាជាការប្រញាប់ ច្បាប់នោះត្រូវប្រើភ្លាមៗ នៅក្រុងភ្នំពេញ ក្រោយដែលបានយកទៅបិទនៅសាលាក្រុង ហើយនៅក្នុងស្រុកនិមួយៗ ក្រោយដែលបានយកទៅបិទនៅសាលាស្រុក ។

មាត្រា ២១.- អំណាចគ្រប់យ៉ាងមកពីព្រះមហាក្សត្រិយ៍ ។ អំណាចទាំងនោះ ត្រូវប្រើទៅតាមបទបញ្ញត្តិ នៃរដ្ឋធម្មនុញ្ញនេះ ។

មាត្រា ២២.- រដ្ឋសភាជាអ្នកប្រើអំណាចនីតិបញ្ញត្តិ ក្នុងព្រះបរមនាមនៃព្រះមហាក្សត្រិយ៍ ។

អ្នកដែល សិទ្ធិផ្តើមគំនិតតែងច្បាប់នោះ គឺព្រះមហាក្សត្រិយ៍ គណៈរដ្ឋមន្ត្រី សមាជិកនៃរដ្ឋសភា នឹងសមាជិកនៃក្រុមប្រឹក្សាព្រះរាជអាណាចក្រ ។

មាត្រា ២៣.- គណៈរដ្ឋមន្ត្រីជាអ្នកប្រើអំណាចនីតិប្រតិបត្តិ ក្នុងព្រះបរមនាមនៃ

ព្រះមហាក្សត្រិយ៍ ។

មាត្រា ២៤.- សាលាជំរះក្ដីគ្រប់ជាន់-គ្រប់ថ្នាក់ ជាអ្នកប្រើអំណាចតុលាការក្នុងព្រះបរមនាមនៃព្រះមហាក្សត្រិយ៍ ។

## ជំពូក ៤
## អំពីព្រះមហាក្សត្រិយ៍

មាត្រា ២៥.- រាជសម្បត្តិប្រទេសកម្ពុជា ជាមត៌ករបស់ក្សត្រាទាំងឡាយ ដែលជាតំណពីព្រះបាទសម្ដេចព្រះហរិរក្សរាមាធិបតីព្រះអង្គដួង ។

មាត្រា ២៦.- ព្រះមហាក្សត្រិយ៍ទ្រង់នូវព្រះរាជអំណាចចាត់តាំងព្រះរជ្ជទាយាទ និងព្រះរាជអំណាចដកព្រះរជ្ជទាយាទពីតំណែងបាន ដោយបានទ្រង់ប្រជុំក្រុមប្រឹក្សារាជសម្បត្តិពិគ្រោះជាមុនហើយ ។

មាត្រា ២៧.- កាលបើរាជសម្បត្តិទំនេរ ប្រសិនបើព្រះមហាក្សត្រិយ៍ពុំបានចាត់តាំងព្រះរជ្ជទាយាទដូចខាងលើនេះទេ នោះក្រុមប្រឹក្សារាជសម្បត្តិ ចាត់តាំងព្រះមហាក្សត្រិយ៍អង្គថ្មី ដោយយកតាមមតិនៃភាគច្រើនក្នុងទីប្រជុំ បើមតិនៃទីប្រជុំចែកជាពីរភាគស្មើគ្នា នោះត្រូវយកតាមមតិនៃប្រធាន ។

មាត្រា ២៨.- ក្រុមប្រឹក្សារាជសម្បត្តិមានសមាជិកដូចតទៅនេះ ÷

- អធិបតីនៃក្រុមសង្គហព្រះរាជវង្សានុវង្ស

- ប្រធានរដ្ឋសភា
- នាយករដ្ឋមន្ត្រី,
- ព្រះសង្ឃនាយកទាំងពីរគណៈ ។

អធិបតីក្រុមសង្គហៈព្រះរាជវង្សានុវង្ស ជាប្រធាននៃក្រុមប្រឹក្សារាជសម្បត្តិ ។

មាត្រា ២៩.- នីតិភាពនៃព្រះមហាក្សត្រិយ៍ ត្រូវកំណត់តាំងព្រះជន្មាយុដប់ប្រាំបីព្រះវស្សា ។ បើប្រសិនជាព្រះមហាក្សត្រិយ៍ ឋិតនៅក្នុងអនីតិភាព ឬ គ្មានសមត្ថភាពនឹងទ្រង់ប្រើព្រះរាជសិទ្ធិទេនោះ ព្រះរាជសិទ្ធិនោះត្រូវជាភារៈរបស់ព្រះរាជានុសិទ្ធមួយព្រះអង្គ ។

ក្រុមប្រឹក្សារាជសម្បត្តិ ជាអ្នកវិនិច្ឆ័យថា ព្រះមហាក្សត្រិយ៍គ្មានសមត្ថភាព ហើយបើមានករណីដូច្នោះ ក្រុមប្រឹក្សារាជសម្បត្តិ ត្រូវចាត់តាំងក្សត្រាមួយព្រះអង្គក្នុងព្រះរាជវង្សានុវង្ស ជាព្រះរាជានុសិទ្ធ ។

មាត្រា ៣០.- កាលបើរាជសម្បត្តិទំនេរ ហើយប្រសិនបើព្រះមហាក្សត្រិយ៍ ពុំបានចាត់តាំងព្រះរាជទាយាទទេ ក្រុមប្រឹក្សារាជសម្បត្តិត្រូវតែប្រជុំក្នុងរវាងបីថ្ងៃ ក្រោយព្រឹត្តិការណ៍ដែលធ្វើឱ្យរាជសម្បត្តិទំនេរដើម្បីចាត់តាំងព្រះមហាក្សត្រិយ៍អង្គថ្មី ព្រមទាំងរាជានុសិទ្ធ បើព្រះមហាក្សត្រិយ៍អង្គថ្មី ឋិតនៅអនីតិភាព ។

ការប្រជុំក្រុមប្រឹក្សារាជសម្បត្តិ ត្រូវធ្វើដោយប្រធានអញ្ជើញ ឬ បើប្រធានមិនបានអញ្ជើញទេ ត្រូវប្រជុំនៅថ្ងៃទីបីនៃរយៈវេលា ដែលមានកំណត់ក្នុងវគ្គមុននេះ ។

បើត្រូវវិនិច្ឆ័យថា ព្រះមហាក្សត្រិយ៍ក្នុងរាជសម្បត្តិគ្មានសមត្ថភាពនោះត្រូវប្រធានក្រុមប្រឹក្សារាជសម្បត្តិអញ្ជើញសមាជិកមកប្រជុំ ដោយតំរិះព្រះអង្គឯងក៏បាន ដោយសេចក្តី

សុំនៃសមាជិកយ៉ាងតិចត្រឹមពីរនាក់ក៏បាន ដើម្បីនឹងវិនិច្ឆ័យថាព្រះមហាក្សត្រិយ៍មានសមត្ថភាពឬទេ ហើយបើព្រះមហាក្សត្រិយ៍គ្មានសមត្ថភាពទេ ក្រុមប្រឹក្សារាជសម្បត្តិត្រូវចាត់តាំងព្រះរាជានុសិទ្ធមួយអង្គឡើង ។

មាត្រា ៣០ (ស្ទួន).- ដោយមានហេតុផលនៃវដ្តតម្រូវ ក្នុងករណីដែលកាលៈទេសៈពុំអាចឱ្យចាត់តាំងបាននូវព្រះមហាក្សត្រិយ៍អង្គថ្មី ក្រុមប្រឹក្សារាជសម្បត្តិ ក្នុងរយៈវេលាដដែល ដូចមានក្នុងមាត្រាខាងលើ ត្រូវចាត់ការចាត់តាំងក្រុមប្រឹក្សារាជានុសិទ្ធមួយ ដែលត្រូវបំពេញជាបណ្តោះអាសន្ន នូវព្រះរាជបុព្វសិទ្ធិ ក្នុងល័ក្ខខ័ណ្ឌទាំងឡាយដូចមានកំណត់ក្នុងរដ្ឋធម្មនុញ្ញនេះ ។

ក្រុមប្រឹក្សារាជានុសិទ្ធនេះ មានសមាជិកបីរូប ដែលប្រធានត្រូវជាសមាជិកមួយរូបនៃព្រះរាជវង្សានុវង្សជាការចាំបាច់ ។

ក្រុមប្រឹក្សារាជានុសិទ្ធ ចេញសេចក្តីសំរេចទាំងឡាយ ដោយមតិជាឯកច្ឆន្ទ ហើយលើកិច្ចទាំងអស់ដែលត្រូវព្រះរាជាទ្រង់ឡាយព្រះហស្តលេខានោះ ត្រូវសមាជិកទាំងអស់ចុះហត្ថលេខា ។

ក្រុមប្រឹក្សារាជសម្បត្តិ ត្រូវជ្រើសរើសដទៃទៀតនូវសមាជិកជំនួយពីររូប សំរាប់ជំនួសសមាជិកសាមីជនទាំងឡាយ នៅពេលពុំនៅ ឬ មានធុរៈ ។ ក្នុងករណីដែលប្រធានពុំនៅ ឬមានធុរៈ នោះត្រូវសមាជិកសាមីជនមួយរូប ដែលយកតាមរបៀបការតែងតាំង ជំនួសជាបណ្តោះអាសន្ន ។ សមាជិកសាមីជននេះ ត្រូវសមាជិកជំនួយមួយរូបជំនួសជាបណ្តោះអាសន្នក្នុងក្រុមប្រឹក្សា សមាជិកជំនួយនេះ ត្រូវយកតាមរបៀបការតែងតាំង ។

នៅដំបូងនីតិកាលនីមួយៗ ក្រុមប្រឹក្សារាជសម្បត្តិ ត្រូវសម្រេចអំពីការបន្ត ឬ អំពីការកែប្រែក្រុមប្រឹក្សារាជានុសិទ្ធ ប្រសិនបើដោយមានហេតុផលនៃរដ្ឋជាដរាបដែរ យល់ឃើញថា មិនអាចចាត់ការចាត់តាំងនូវព្រះមហាក្សត្រិយ៍អង្គថ្មីទេ។

ក៏ប៉ុន្តែ ក្នុងករណីដែលប្រធានសាមីជន ស្រាប់តែកាន់កាប់មុខតំណែងរបស់ខ្លួនឥតកើតជាស្ថាពរ នោះក្រុមប្រឹក្សារាជសម្បត្តិ ត្រូវចាត់ការដើម្បីជំនួសប្រធាននោះ ក្នុងបីថ្ងៃបន្ទាប់ពីព្រឹត្តិការណ៍មក។

មាត្រា ៣១.- (កែប្រែ) ក្នុងប្រាំបីថ្ងៃ តពីការផ្លាស់ប្តូររជ្ជកាលមួយៗ រដ្ឋសភាត្រូវប្រជុំជាកាតព្វកិច្ច ដើម្បីទទួលតាមករណី នូវសច្ចាប្រណិធានរបស់ព្រះមហាក្សត្រិយ៍របស់រាជានុសិទ្ធ ឬ របស់ក្រុមប្រឹក្សារាជានុសិទ្ធ។

មាត្រា ៣២.- មុននឹងទទួលព្រះរាជអំណាច, ព្រះមហាក្សត្រិយ៍ទ្រង់ថ្លែងសច្ចាប្រណិធានក្នុងទីប្រជុំរដ្ឋសភា មានជាសេចក្តីដូចតទៅនេះ ÷

"ខ្ញុំតាំងសច្ចាថានឹងប្រព្រឹត្តតាមរដ្ឋធម្មនុញ្ញ និង ច្បាប់ទាំងឡាយនៃព្រះរាជអាណាចក្រ ហើយនឹងតាំងចិត្តធ្វើផលប្រយោជន៍ដល់រដ្ឋ និង ប្រជារាស្ត្រ "។

មាត្រា ៣៣. (កែប្រែ) រាជានុសិទ្ធនឹងចូលកាន់តំណែងបានតែនៅពេលបន្ទាប់ពីបានថ្លែងនៅក្នុងរដ្ឋសភា នូវសច្ចាប្រណិធាន ដូចមានកំណត់ក្នុងមាត្រាខាងលើ ដោយ បន្ថែមសេចក្តីថា "... ហើយមានសេចក្តីភក្តីចំពោះព្រះមហាក្សត្រិយ៍"។

ក្រុមប្រឹក្សារាជានុសិទ្ធ នឹងចូលកាន់តំណែងបានតែនៅពេលបន្ទាប់ពីបានថ្លែងនៅក្នុងរដ្ឋសភា នូវសច្ចាប្រណិធាន ដូចមានកំណត់ក្នុងមាត្រាខាងលើ ដោយបន្ថែមសេចក្តីថា : "... ហើយមានសេចក្តីភក្តីចំពោះព្រះរាជបល្ល័ង្ក"។

ប្រធាន ហើយនិង សមាជិកទាំងឡាយ នៃក្រុមប្រឹក្សារាជានុសិទ្ធ គ្មានសិទ្ធិទទួល បៀវត្សរ៍ ហើយនិងអ្វីដទៃទៀត ដូចជាអត្ថប្រយោជន៍ និង តាវកាលិកធម្មជាតិ ដែលថ្វាយ ចំពោះព្រះមហាក្សត្រិយ៍ ព្រមទាំងនិវាសដ្ឋាននៅក្នុងព្រះបរមរាជវាំង។ ក៏ប៉ុន្តែ សមាជិក ទាំងនេះ ក្នុងករណីដ៏គួរអាចទទួលនូវតាវលិកធម្មជាតិ និង អំណាចពិសេស ដែលនឹងកំណត់ ដោយច្បាប់មួយ។

មាត្រា ៣៤.- ចាប់ផ្តើមតាំងពីវេលាដែលរាជសម្បត្តិទំនេររហូតដល់វេលាដែល ព្រះមហាក្សត្រិយ៍អង្គថ្មី ឬ ព្រះរាជានុសិទ្ធ ថ្លែងសច្ចាប្រណិធាន ក្នុងរវាងវេលានោះ ប្រធាន រដ្ឋសភា ប្រើអំណាចជាប្រមុខរបស់រដ្ឋស្នងព្រះអង្គ ដោយទទួលសេចក្តីខុសត្រូវលើខ្លួន។

ក្នុងពេលដែលព្រះមហាក្សត្រិយ៍ មិនបានគង់នៅក្នុងប្រទេសកម្ពុជា ឬ ពុំអាចទ្រង់ ទទួលព្រះរាជភារៈបាន ព្រះមហាក្សត្រិយ៍ទ្រង់ប្រគល់ព្រះរាជភារៈនោះទៅក្រុមប្រឹក្សាមួយ ក្រុមជាបណ្តោះអាសន្ន, ព្រះមហាក្សត្រិយ៍ទ្រង់តាំងអធិបតី និង សមាជិកនៃក្រុមប្រឹក្សានោះ ដោយចាត់តាំងយកក្រៅពីសមាជិកនៃរដ្ឋាភិបាល។

មាត្រា ៣៥.- ព្រះមហាក្សត្រិយ៍ ទ្រង់ជាអគ្គប្រមុខនៃរដ្ឋ។ អង្គព្រះមហាក្សត្រិយ៍ជាទីគោរពសក្ការៈ នរណានឹងល្មើសពុំបាន។

មាត្រា ៣៦.- ព្រះមហាក្សត្រិយ៍ ទ្រង់ប្រកាសឱ្យប្រើច្បាប់ទាំងឡាយ តាមមាត្រា ៨៣ នៃរដ្ឋធម្មនុញ្ញនេះ។

ក្នុងរយៈវេលាដែលមានកំណត់សម្រាប់ការប្រកាសឱ្យប្រើនេះ ព្រះមហាក្សត្រិយ៍ អាចផ្ញើព្រះរាជសារ ទៅឱ្យរដ្ឋសភា និង ក្រុមប្រឹក្សាព្រះរាជអាណាចក្រ ពិចារណាច្បាប់នោះ

ជាថ្មីទៀត ឯរដ្ឋសភា និង ក្រុមប្រឹក្សាព្រះរាជអាណាចក្រ ត្រូវតែព្រមតាមព្រះរាជឱង្ការ ។

មាត្រា ៣៧.- (កែប្រែ) ព្រះមហាក្សត្រិយ៍ ទ្រង់ប្រាស្រ័យនឹងរដ្ឋសភា និង ក្រុមប្រឹក្សាព្រះរាជអាណាចក្រ ហើយនិងសភាប្រជារាស្ត្រប្រចាំខេត្ត និង រាជធានី ដោយព្រះរាជសាសន៍ ។

ព្រះមហាក្សត្រិយ៍ ទ្រង់ត្រាស់បញ្ជាឱ្យវរជននានា ចូលទៅកាន់រដ្ឋសភា ក្រុមប្រឹក្សាព្រះរាជអាណាចក្រ និង សភាប្រជារាស្ត្រប្រចាំខែត្រ និង រាជធានី ដើម្បីថ្លែងយោបល់ ឬថ្លែងការណ៍ដ៏សំខាន់ពិសេសជំរាបសភា និង ក្រុមខាងលើនេះ បានតាមសព្វព្រះរាជហឫទ័យ ។

មាត្រា ៣៨.- ព្រះមហាក្សត្រិយ៍ ទ្រង់ហៅប្រជុំរដ្ឋសភា តាមបទបញ្ញត្តិនៃមាត្រា ៥៩ និង ៦០ នៃរដ្ឋធម្មនុញ្ញនេះ ។ ព្រះអង្គទ្រង់នូវព្រះរាជសិទ្ធិរំលាយរដ្ឋសភាបាន តាមសេចក្ដីណែនាំនៃគណៈរដ្ឋមន្ត្រី ។ ព្រះមហាក្សត្រិយ៍ ទ្រង់រំលាយរដ្ឋសភាបានតែមួយដង ដោយហេតុដដែល ។ បើមានការរំលាយរដ្ឋសភាដូចខាងលើនេះ, ការជ្រើសតាំងជាថ្មីត្រូវឱ្យមានក្នុងរយៈវេលាពីរខែយ៉ាងយូរ ។

មាត្រា ៣៩.- ព្រះមហាក្សត្រិយ៍ ទ្រង់ជ្រើសយកនាយករដ្ឋមន្ត្រី ហើយទ្រង់តែងតាំងនាយករដ្ឋមន្ត្រី ព្រមទាំងរដ្ឋមន្ត្រី ដែលនាយកនោះក្រាបបង្គំទូលសុំឱ្យតាំង ។

មាត្រា៤០.- ព្រះមហាក្សត្រិយ៍ ទ្រង់នូវព្រះរាជសិទ្ធិជាអធិបតីទីប្រជុំគណៈរដ្ឋមន្ត្រី ។ សេចក្ដីកត់ហេតុទាំងឡាយ នៃពេលប្រជុំគណៈរដ្ឋមន្ត្រី ត្រូវនាំយកទៅក្រាបបង្គំថ្វាយព្រះមហាក្សត្រិយ៍ ។

មាត្រា ៤១. - ព្រះរាជលិខិតទាំងពួង វៀរលែងតែព្រះរាជលិខិតណាដែលទាក់ទង

នឹងការខាងក្នុងព្រះបរមរាជវាំង ត្រូវឱ្យមាននាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីមួយនាក់ ឬ ច្រើននាក់ចុះហត្ថលេខាទទួលព្រះបរមរាជឱង្ការ ។

មាត្រា ៤២.- ព្រះមហាក្សត្រិយ៍ ទ្រង់បង្កើត ព្រមទាំងទ្រង់ព្រះរាជទានឋានន្តរស័ក្តិខាងស៊ីវិល និង ទាហាន ។

ព្រះមហាក្សត្រិយ៍ ទ្រង់ជាអធិបតីធំបំផុត នៃក្រុមឥស្សរិយយស ហើយទ្រង់ព្រះរាជទានគ្រឿងឥស្សរិយាករណ៍ ។

មាត្រា ៤៣.- ព្រះមហាក្សត្រិយ៍ ទ្រង់តែងតាំងចៅក្រមទាំងឡាយ តាមសេចក្តីសុំរបស់ក្រុមប្រឹក្សាជាន់ខ្ពស់នៃតុលាការ ។

មាត្រា ៤៤.- ព្រះមហាក្សត្រិយ៍ ទ្រង់នូវព្រះរាជសិទ្ធិលើកលែងទោស និង បន្ធូរទោស ។

មាត្រា ៤៥.- ព្រះមហាក្សត្រិយ៍ ទ្រង់ជាអគ្គសេនាប្រមុខលើកំឡាំងទាហានទាំងឡាយ នៃព្រះរាជអាណាចក្រ ។

មាត្រា ៤៦.- (កែប្រែ) ព្រះមហាក្សត្រិយ៍ ទ្រង់ឡាយព្រះហស្ថលេខា ក្នុងសន្ធិសញ្ញា ឬ អនុសញ្ញាទាំងឡាយ ដែលធ្វើជាមួយនឹងបរទេសនានា ហើយទ្រង់ព្រះរាជទានសច្ចាប័ន ដល់សន្ធិសញ្ញា និង អនុញ្ញាទាំងនោះ ដោយអាស្រ័យការអនុម័តិ នៃរដ្ឋសភា ។

មាត្រា ៤៧.- (ថ្មី) ព្រះមហាក្សត្រិយ៍ ទ្រង់ចាត់តាំងឯកអគ្គរាជទូត និង ប្រេសិត-វិសាមញ្ញ ខាងបរទេស ត្រូវបរទេសតែងតាំងឱ្យមកនៅប្របព្រះអង្គ ។

មាត្រា ៤៨. - (មាត្រា ៤៧ ចាស់) ព្រះមហាក្សត្រិយ៍ ទ្រង់នូវព្រះរាជសិទ្ធិរំលែក

ព្រះរាជអំណាច ក្នុងការព្រះរាជទានឋានន្តរស័ក្តិខាងស៊ីវិល និង ទាហាន ហើយក្នុងការចុះព្រះរាជហត្ថលេខា ក្នុងលិខិតទាំងឡាយ ។

## ចំពូក ៥
## អំពីរដ្ឋសភា

មាត្រា ៤៩.- ( មាត្រា ៤៨ ចាស់ ) អ្នកដែលមានសិទ្ធិជ្រើសតាំងអ្នកតំណាងរាស្ត្រ គឺពលរដ្ឋខ្មែរទាំងពីរភេទអាយុ ២០ ឆ្នាំបរិបូណ៌ឡើងទៅ, វៀរលែងតែជននោះ ប្រាសចាកសិទ្ធិពលរដ្ឋ ហើយត្រូវប្រកបដោយលក្ខណសម្បត្តិ តាមច្បាប់ស្ដីអំពីការជ្រើសតាំងអ្នកតំណាង-រាស្ត្រ ។

ទាហានក្នុងតំណែង គ្មានសិទ្ធិជ្រើសតាំងអ្នកតំណាងរាស្ត្រ ហើយគ្មានទាំងសិទ្ធិឈរឈ្មោះឱ្យគេជ្រើសតាំងខ្លួន ជាអ្នកតំណាងរាស្ត្រទៀតផង ។

បព្វជិត គ្មានសិទ្ធិដូចខាងលើនេះដែរ ព្រោះទើសទាស់នឹងធម៌វិន័យ ។

មាត្រា ៥០.- ( មាត្រា ៤៩ ចាស់ ) អ្នកដែលមានសិទ្ធិឈរឈ្មោះឱ្យគេជ្រើសតាំងជាអ្នកតំណាងរាស្ត្របាននោះ គឺពលរដ្ឋខ្មែរទាំងពីរភេទដែលមានសិទ្ធិជ្រើសតាំងអ្នកតំណាង-រាស្ត្រទាំងឡាយមានអាយុយ៉ាងតិច ២៥ ឆ្នាំ។ អំពីអ្នកដែលគ្មានសិទ្ធិឈរឈ្មោះឱ្យគេជ្រើសខ្លួនជាអ្នកតំណាងរាស្ត្រនោះ នឹងមានសម្ដែងក្នុងច្បាប់បោះឆ្នោត ។

ជនមួយនាក់ នឹងធ្វើជាអ្នករាជការកាន់កាប់តំណែងផង ហើយធ្វើជាអ្នកតំណាង-រាស្ត្រផងពុំបាន ។

មាត្រា ៥១.- (មាត្រា ៥០ ចាស់) អ្នកតំណាងរាស្ត្រ នៅក្នុងតំណែងត្រឹម ៤ ឆ្នាំ ដោយបានទទួលជ្រើសតាមវិធីបោះឆ្នោតសាកលដោយចំពោះ។

រដ្ឋសភាក្នុងមួយលើក១ អស់អំណាចនៅវេលាដែលរដ្ឋសភាលើកថ្មីចូលទទួលការ។ ក្នុងវេលាដែលផុតនីតិកាលនីមួយ១ បើមានហេតុបណ្តាលមិនឱ្យមានការជ្រើសតាំងជាថ្មីទៀតបានទេ ព្រះមហាក្សត្រិយ៍អាចបន្តនីតិកាលឱ្យវែងទៅបានម្តងមួយឆ្នាំ។

បើកាលណាមានអ្នកតំណាងរាស្ត្រ ទទួលអនិច្ចកម្ម, លាលែងឬត្រូវបណ្តេញ នោះត្រូវជ្រើសតាំងជំនួសឡើងតាមបញ្ញត្តិច្បាប់ ស្តីអំពីការជ្រើសតាំងអ្នកតំណាងរាស្ត្រ។

ល្គឹកណាតែមានពលរដ្ឋភាគច្រើនដោយដាច់ខាតក្នុងមណ្ឌលណាមួយ បានថ្វាយពាក្យដល់ព្រះមហាក្សត្រិយ៍ សុំឱ្យបញ្ឈប់តំណាងខ្លួនពីរដ្ឋសភា នោះត្រូវឱ្យតាក់តែងរើសតំណាងបំពេញរូបឡើងវិញ បើការអង្កេតនៃរដ្ឋាភិបាល និង តំណាងរាស្ត្រ ៤ រូប ដែលចាត់ពីរដ្ឋសភាបានចង្អុលឱ្យឃើញច្បាស់ប្រាកដថា ពាក្យដែលសុំបញ្ឈប់តំណាងរាស្ត្រនោះពិតជារបស់ពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតក្នុងមណ្ឌលនោះ មានចំនួនគ្រប់គ្រាន់ពេញបរិបូណ៌មែនហើយ។

មាត្រា ៥២. - (មាត្រា ៥១ ចាស់) មុននឹងចាប់ផ្តើមធ្វើការ រដ្ឋសភាត្រូវពិនិត្យដោយខានពុំបាន នូវការតាំងសមាជិកដែលគួរតាំង ឱ្យបានជាអ្នកតំណាងរាស្ត្រពេញទី។

មាត្រា ៥៣.- (មាត្រា ៥២ ចាស់) នៅពេលដំបូងនៃនីតិកាលនីមួយ១ ហើយមុននឹងចូលកាន់តំណែង សមាជិកនៃរដ្ឋសភាដែលបានទទួលតាំងជាអ្នកតំណាងរាស្ត្រពេញទីហើយ តាំងសច្ចាប្រណិធានក្នុងទីប្រជុំ ចំពោះព្រះភក្ត្រព្រះមហាក្សត្រិយ៍ ជាសេចក្តីដូចតទៅនេះ ÷

" ខ្ញុំសូមតាំងសច្ចាថា មានចិត្តស្មោះត្រង់ ចំពោះព្រះមហាក្សត្រិយ៍ ហើយនឹងរដ្ឋធម្មនុញ្ញ

ហើយថានឹងខំប្រឹងធ្វើការដោយពេញកម្លាំង ដើម្បីជាផលប្រយោជន៍ដល់ប្រទេសជាតិ "។

អ្នកតំណាងរាស្ត្រណា ដែលគេជ្រើសតាំងក្នុងរយៈវេលានីតិកាល ហើយដែលរដ្ឋសភាបានតាំងជាអ្នកតំណាងរាស្ត្រពេញទីហើយ ត្រូវតាំងសច្ចាប្រណិធាន ចំពោះព្រះភក្ត្រព្រះមហាក្សត្រិយ៍ ក្នុងឱកាសព្រះរាជពិធីចំរើនព្រះជន្មវស្សា (តាំងតុ) ដែលតបន្ទាប់ពីពេលនោះ មួយអន្លើនឹងអ្នករាជការទាំងឡាយ ។

មាត្រា ៥៤.- (មាត្រា ៥៣ ចាស់) សមាជិកទាំងឡាយនៃរដ្ឋសភា ជាអ្នកតំណាងរបស់ប្រជាជាតិខ្មែរទាំងមូល ពុំមែនត្រឹមតែជាអ្នកតំណាងរបស់ជនដែលជ្រើសតាំងខ្លួនប៉ុណ្ណោះទេ។ អ្នកតំណាងរាស្ត្រ មិនត្រូវជំពាក់ទាក់ទិន ដោយអាណត្តិដាច់ខាតណាមួយឡើយ ។

មាត្រា ៥៥.- (មាត្រា ៥៤ ចាស់) អ្នកតំណាងរាស្ត្រ មិនអាចត្រូវគេចោទប្រកាន់រកខ្លួន ចាប់ខ្លួនឃុំឃាំង ឬ ជំនុំជំរះ ដោយហេតុថា អ្នកតំណាងរាស្ត្រនោះ បានសំដែងយោបល់ ឬ បញ្ចេញមតិថា ដូច្នេះ ដូច្នោះក្នុងក្រសួងរបស់ខ្លួនឡើយ ។

សេចក្តីខាងលើនេះ ជាអភ័យឯកសិទ្ធិរបស់សមាជិករដ្ឋសភា។

មាត្រា ៥៦.- (មាត្រា ៥៥ ចាស់) នៅវេលាដែលឋិតក្នុងសមាជិកភាព ហើយវៀរលែងតែបានប្រព្រឹត្តបទល្មើស ដែលគេបានទាន់ឃើញជាក់ស្តែង, អ្នកតំណាងរាស្ត្រ បើនឹងត្រូវគេចោទប្រកាន់ ឬ ចាប់ខ្លួនបានដោយបទឧក្រិដ្ឋ ឬ មជ្ឈិមនោះ លុះត្រាតែមានអនុញ្ញាតពីរដ្ឋសភាជាមុនសិន។ ការឃុំឃាំង ឬ ការចោទប្រកាន់អ្នកតំណាងរាស្ត្រណាមួយ ត្រូវបង្អង់សិន បើរដ្ឋសភាបញ្ចេញមតិសុំដោយមានភាគច្រើនដល់បួនក្នុងប្រាំ (៤/៥) នៃចំនួនសមាជិក។

មាត្រា ៥៧.- (មាត្រា ៥៦ ចាស់) នៅវេលាដែលឋិតក្នុងតំណែង បើអ្នកតំណាងរាស្ត្រណាមួយត្រូវទណ្ឌកម្ម ដែលនាំឱ្យបុគ្គលឈរឈ្មោះជាបេក្ខជនពុំបាន អ្នកតំណាងរាស្ត្រនោះ ធ្លាក់

ចាកសមាជិកភាពរដ្ឋសភា។

ការទំលាក់ចាកសមាជិកភាពនេះ គឺរដ្ឋសភាជាអ្នកវិនិច្ឆ័យ។

មាត្រា ៥៨.-（មាត្រា ៥៧ ចាស់）អ្នកតំណាងរាស្ត្រ ត្រូវទទួលប្រាក់បំណាច់មានកំណត់ ដោយប្រៀបស្មើ ទៅនឹងប្រាក់បៀវត្សនៃអ្នករាជការថ្នាក់ណាមួយ នៃក្របខណ្ឌជាន់ខ្ពស់។

មាត្រា ៥៩.-（មាត្រា ៥៨ ចាស់）រដ្ឋសភា មានសម័យប្រជុំសាមញ្ញយ៉ាងតិច ពីរលើក ក្នុងមួយឆ្នាំ។ សម័យប្រជុំនីមួយៗ មានកំណត់យ៉ាងតិចបីខែ។

ព្រះមហាក្សត្រិយ៍ ទ្រង់ត្រាស់ហៅរដ្ឋសភាប្រជុំជាសម័យប្រជុំសាមញ្ញ។

មាត្រា ៦០.-（មាត្រា ៥៩ ចាស់）ក្រុមអភិបាលរដ្ឋសភា ជាអ្នកហៅសមាជិកប្រជុំជាសម័យប្រជុំវិសាមញ្ញ ដោយបានទទួលព្រះរាជបញ្ជាក្តី ដោយសេចក្តីណែនាំនៃគណៈរដ្ឋមន្ត្រីក្តី, ឬ ដោយសេចក្តីសុំរបស់ភាគមួយក្នុងបី（១/៣）យ៉ាងតិចនៃចំនួនអ្នកតំណាងរាស្ត្រទាំងពួងក្តី។

របៀបវារៈនៃសម័យប្រជុំវិសាមញ្ញនេះ ត្រូវផ្សាយដល់មហាជនព្រមជាមួយនឹងថ្ងៃណាត់ប្រជុំ។

មាត្រា ៦១.-（មាត្រា ៦០ ចាស់）រដ្ឋសភា ប្រជុំក្នុងរាជធានីព្រះរាជអាណាចក្រក្នុងមន្ទីរមួយ ដែលបានរៀបចំប្រចាំការ វៀរលែងតែមានបញ្ជាក់ជាពិសេសក្នុងសំបុត្រហៅប្រជុំ ដោយមានហេតុផ្សេងៗ។

មាត្រា ៦២.-（មាត្រា ៦១ ចាស់）វៀរលែងតែក្នុងករណី ដែលមាត្រាទាំងឡាយមុននេះបានបញ្ញត្តទុក, ការប្រជុំនៃរដ្ឋសភា ក្រៅពីកន្លែងដែលមានកំណត់ និង ក្រៅវេលាត្រឹមត្រូវតាមច្បាប់ ទុកជាខុសនឹងច្បាប់ ហើយអសារសូន្យទៅឯង។

មាត្រា ៦៣.-（មាត្រា ៦២ ចាស់）ក្នុងពេលបើកសម័យប្រជុំម្តងៗ ព្រះមហាក្សត្រិយ៍

ទ្រង់អានព្រះរាជសារកាន់រដ្ឋសភាដោយព្រះអង្គឯង ឬ ដោយអ្នកតំណាងព្រះអង្គ ។

មាត្រា ៦៤.- ( មាត្រា ៦៣ ចាស់ ) រដ្ឋសភា តាំងបទបញ្ជាមួយសម្រាប់ប្រើការ ។

មាត្រា ៦៥.- ( មាត្រា ៦៤ ចាស់ ) មានតែរដ្ឋសភាប៉ុណ្ណោះទេដែលមានសិទ្ធិបញ្ចេញមតិតាំងច្បាប់ ។ សិទ្ធិនេះ រដ្ឋសភាមិនអាចប្រគល់ឱ្យទៅនរណាបានឡើយ ។

មាត្រា ៦៦.- ( មាត្រា ៦៥ ចាស់ ) ការលុបលាងទោសត្រូវឱ្យមានច្បាប់មួយសំរេចទើបបាន ។

មាត្រា ៦៧.- ( មាត្រា ៦៦ ចាស់ ) ថវិការបស់ជាតិ ត្រូវរដ្ឋសភាអនុម័តទើបប្រើប្រាស់បាន ឯបញ្ជីស្រង់ប្រាក់ចំណូលចំណាយផ្តាច់ឆ្នាំក៏ត្រូវឱ្យរដ្ឋសភាយល់ព្រមផងដែរ ក្រោយដែលសភាប្រជារាស្ត្រប្រចាំខេត្ត និង រាជធានី បានពិនិត្យហើយជូនយោបល់មករដ្ឋសភា ។

កិច្ចចងការប្រាក់របស់ជាតិ ក៏ត្រូវទទួលអនុម័តិអំពីរដ្ឋសភាដែរ ក្រោយដែលសភាខាងលើនេះ បានពិនិត្យហើយជូនយោបល់ផង ។

ប៉ុន្តែការផ្តើមគំនិតកំណត់ចំនួនប្រាក់ចំណាយ សំរាប់បៀវត្សអ្នករាជការ ជាភារៈតែលើរដ្ឋាភិបាល ។ មួយទៀត រដ្ឋសភា គ្មានសិទ្ធិជជែកពីចំនួនប្រាក់កំណត់ទុកក្នុងថវិការបស់ជាតិ ដែលសំរាប់បញ្ចូលជាអំណោយទៅក្នុងថវិការាជសម្បត្តិទេ ។

មាត្រា ៦៨.- ( ថ្មី ) បើជាមានសមាជិកចំនួនពាក់កណ្តាលយ៉ាងតិចបានស្នើសុំ នោះរដ្ឋសភាអាចនឹងអញ្ជើញវរជនណាមួយឱ្យមកបំភ្លឺ ដោយយោបល់អំពីបញ្ហាសំខាន់ពិសេសណាមួយបាន ។

មាត្រា ៦៩.- ( ថ្មី )( លុបដោយព្រះរាជក្រមលេខ ១៦៦ ប.រ. ចុះថ្ងៃទី ១៣/១/៦៤ ) រដ្ឋសភា ត្រូវមានភារៈជួយសំអាតការរាជការដោយប្រតិបត្តិតាមបញ្ញត្តិចំពូក ៧ ។

បើមានសេចក្តីស្នើសុំពីសភាប្រជារាស្ត្រ ឬ ពីសមាជិករដ្ឋសភាចំនួនភាគមួយក្នុងបួននោះ រដ្ឋសភា អាចទទួលចាត់ចែងជំរះនូវរឿងមន្ត្រីណាមួយ ដែលបានប្រព្រឹត្តខុសក្នុងមុខក្រសួង បណ្តាលជាហេតុនាំឱ្យខូចប្រយោជន៍ដល់ជាតិ ។

មាត្រា ៧០.- (ថ្មី) (លុបដោយព្រះរាជក្រមលេខ ១៦៦ ប.រ. ចុះថ្ងៃទី ១៣/១/៦៤) រដ្ឋសភា អាចនឹងសម្រេចទណ្ឌកម្មដែលតម្រូវឱ្យរដ្ឋាភិបាលផ្តន្ទាដល់មន្ត្រីដែលមានរឿងនោះ បើបានបញ្ចេញមតិដោយភាគច្រើនជាដាច់ខាត ។ សេចក្តីសម្រេចនៃរដ្ឋសភានេះ នឹងទុកជាស្រេចបាន លុះណាតែក្រុមប្រឹក្សារាជអាណាចក្រ អនុម័តិយល់ស្របតាមរដ្ឋសភា ដោយភាគច្រើនជាដាច់ខាតនៃចំនួនសមាជិក ។

មាត្រា ៧១.- (មាត្រា ៦៧ ចាស់) ការពិភាក្សានៃរដ្ឋសភា នឹងយកជាការបាន លុះត្រាតែមានភាគពីរក្នុងបី (២/៣) នៃចំនួនសមាជិករដ្ឋសភាមកប្រជុំ ។

មាត្រា ៧២.- (មាត្រា ៦៨ ចាស់) ការពិភាក្សានៃរដ្ឋសភាជាការបើកចំហដល់មហាជន, ប៉ុន្តែ បើមានសេចក្តីសុំអំពីរដ្ឋាភិបាលក្តី អំពីប្រធានរដ្ឋសភាក្តី អំពីសមាជិកយ៉ាងតិចប្រាំនាក់ក្តី រដ្ឋសភាអាចបញ្ចេញមតិឱ្យប្រជុំជាសម្ងាត់បាន ។

ពាក្យរាយការណ៍ នៃការពិភាក្សាក្នុងពេលប្រជុំចំហ ត្រូវចុះក្នុងរាជកិច្ច ។

មាត្រា ៧៣.- (មាត្រា ៦៩ ចាស់) ក្នុងរយៈវេលាដប់ប្រាំបីខែ បើរដ្ឋាភិបាលរលំពីរដងដូចមានលក្ខខណ្ឌដែលបានកំណត់ទុកក្នុងមាត្រា ១០១ និង ១០២ ខាងក្រោយនេះ, គណៈរដ្ឋមន្ត្រីអាចប្រជុំសម្រេចឱ្យរំលាយរដ្ឋសភាបាន ក្រោយដែលបានទទួលសេចក្តីយល់អំពីប្រធានរដ្ឋសភា ។ ព្រះមហាក្សត្រិយ៍ ក៏ទ្រង់ប្រកាសរំលាយរដ្ឋសភា តាមសេចក្តីសម្រេចនោះ ។

បទបញ្ញត្តិដែលមានក្នុងវគ្គខាងលើនេះ នឹងយកមកប្រើបាន លុះត្រាតែរយៈវេលាដប់ប្រាំបីខែដំបូងនៃនីតិកាលបានកន្លងផុតទៅហើយ ។

## ជំពូក ៦

## អំពីក្រុមប្រឹក្សាព្រះរាជអាណាចក្រ

មាត្រា ៧៤.- (មាត្រា ៧០ ចាស់) ក្រុមប្រឹក្សាព្រះរាជអាណាចក្រ មានសមាជិកដែលត្រូវចាត់តាំងខ្លះ និង សមាជិកដែលត្រូវជ្រើសតាំងដោយបោះឆ្នោតអសាកលខ្លះ ។ សមាជិកទាំងនោះត្រូវមានអាយុ ៤០ ឆ្នាំយ៉ាងតិច ។

ជនមួយនាក់ នឹងធ្វើជាទីប្រឹក្សាព្រះរាជអាណាចក្រផង ហើយធ្វើជាអ្នកតំណាងរាស្ត្រផងពុំបាន ។

មាត្រា ៧៥.- (មាត្រា ៧១ ចាស់) សមាជិកដែលត្រូវចាត់តាំងមានចំនួនពីររូប ។ ព្រះមហាក្សត្រិយ៍ ទ្រង់ចាត់តាំងក្នុងបណ្តាព្រះរាជវង្សានុវង្ស ។

មាត្រា ៧៦.- (មាត្រា ៧២ ចាស់) សមាជិកពីររូប ត្រូវរដ្ឋសភាជ្រើសតាំងតាមភាគច្រើនដោយប្រៀប យកក្រៅពីអ្នកតំណាងរាស្ត្រ ។

មាត្រា ៧៧.- (ថ្មី) (មាត្រា ៧៣ ចាស់កែប្រែ) ត្រូវជ្រើសតាំងដោយបោះឆ្នោតអសាកល មិនចំពោះ នូវសមាជិកដប់ (១០) រូបជាអតិបរមា, រូបនីមួយៗ ជាអ្នកតំណាងភូមិភាគមួយ ឬ ក្រុងភ្នំពេញ ។

ចំនួននៃភូមិភាគ ព្រមទាំងលក្ខខណ្ឌនៃការបោះឆ្នោតនេះ ត្រូវកំណត់ដោយច្បាប់មួយ ។

មាត្រា ៧៨.- (ថ្មី) (មាត្រា ៧៤ ចាស់កែប្រែ) សមាជិកដប់រូប ជាអតិបរមា ជាអ្នកតំណាងវិជ្ជាជីវៈផ្សេងៗ ត្រូវជ្រើសតាំងដោយបោះឆ្នោតចំពោះ ។

លក្ខខណ្ឌពីការបោះឆ្នោតនេះ នឹងត្រូវសម្រេចតាមអត្ថបទច្បាប់ ។

ឯអ្នកតំណាងអ្នករាជការបួនរូប ក៏ត្រូវសម្រេចតាមន័យនេះដែរ ។

មាត្រា ៧៩.- (មាត្រា ៧៥ ចាស់) ការរៀបចំនៃក្រុមប្រឹក្សាព្រះរាជអាណាចក្រ, បែបផែន និង លក្ខខណ្ឌនៃការចាត់តាំង និង ការជ្រើសតាំងសមាជិកក្រុមនេះ នឹងមានកំណត់ទុកក្នុងច្បាប់ពិសេសមួយ ។

មាត្រា ៨០.- (មាត្រា ៧៦ ចាស់) អាណត្តិនៃទីប្រឹក្សាព្រះរាជអាណាចក្រមានកំណត់បួនឆ្នាំ ។

ក្រុមប្រឹក្សាព្រះរាជអាណាចក្រ ត្រូវហៅប្រជុំ ហើយត្រូវប្រជុំក្នុងពេលជាមួយគ្នានឹងរដ្ឋសភា ។

មាត្រា ៨១.- (មាត្រា ៧៧ ចាស់កែប្រែ) មាត្រា ៤៩ (វគ្គទី ២) ៥០ (វគ្គទី២) ៥១ (វគ្គទី ២ និង ទី ៣) ៥២-៥៣-៥៥-៥៦-៥៧-៥៨-៥៩-៦១-៦៤-៦៨-៧១ និង ៧២ នៃរដ្ឋធម្មនុញ្ញត្រូវយកមកប្រើសំរាប់ក្រុមប្រឹក្សាព្រះរាជអាណាចក្រផង ។

លុះត្រាតែ មានអ្នកបោះឆ្នោតឱ្យខ្លួនភាគច្រើនដោយដាច់ខាតដែលមានឈ្មោះក្នុងបញ្ជី កាលក្នុងពេលបោះឆ្នោតនោះ បានថ្វាយពាក្យដល់ព្រះមហាក្សត្រិយ៍ សុំឱ្យបញ្ឈប់តំណាងខ្លួនពីក្រុមប្រឹក្សាព្រះរាជអាណាចក្រ នោះត្រូវឱ្យតាក់តែងរើសតំណាងបំពេញរូបនេះឡើងវិញ បើការអង្កេតនៃរដ្ឋាភិបាល និង សមាជិក ៤ រូបនៃក្រុមប្រឹក្សាព្រះរាជអាណា-

ចក្រដែលអង្គការនេះចាត់ទៅ បានចង្អុលឱ្យឃើញច្បាស់ប្រាកដថាពាក្យសុំបញ្ឈប់តំណាងនោះ សមហេតុផលពីអ្នកបោះឆ្នោត មានចំនួនគ្រប់គ្រាន់ពេញបរិបូរណ៍មែនហើយ ។

មាត្រា ៨២.- (ថ្មី)(លុបដោយព្រះរាជក្រមលេខ ១៦៦ ប.រ. ចុះថ្ងៃទី ១៣-១-៦៤) ក្រុមប្រឹក្សាព្រះរាជអាណាចក្រ ត្រូវមានភារៈជួយសំអាតការរាជការ ដោយប្រតិបត្តិតាមបញ្ញត្តិចំពូក ៧ ដែលចែងអំពីសភាប្រជារាស្ត្រប្រចាំខេត្ត និង រាជធានី និង តាមបញ្ញត្តិមាត្រា ៦៩ និង ៧០ ដែលចែងអំពីអំណាចនៃរដ្ឋសភា ។

មាត្រា ៨៣.- (មាត្រា ៧៨ ចាស់) ក្រុមប្រឹក្សាព្រះរាជអាណាចក្រពិនិត្យ ហើយឱ្យយោបល់ អំពីសេចក្តីព្រាង និង សេចក្តីស្នើច្បាប់ ដែលរដ្ឋសភាបានបញ្ចេញមតិយល់ព្រមមួយលើកដំបូងរួចហើយ ព្រមទាំង អំពីបញ្ហាទាំងពួង ដែលរដ្ឋាភិបាលបានដាក់ឱ្យពិនិត្យ ។

អំពីសេចក្តីព្រាង និង សេចក្តីស្នើច្បាប់ ហើយនឹង អំពីច្បាប់ថវិកាក្រុមប្រឹក្សាព្រះរាជអាណាចក្រ ត្រូវឱ្យយោបល់ក្នុងកំណត់មួយខែយ៉ាងយូរ ។ បើជាការប្រញាប់ កំណត់វេលានោះ ត្រូវបន្ថយមកនៅត្រឹមតែប្រាំថ្ងៃ ។

បើក្រុមប្រឹក្សាព្រះរាជអាណាចក្រ បានឱ្យយោបល់យល់ព្រម ឬ ពុំបានឱ្យយោបល់សោះ ក្នុងវេលាដែលមានកំណត់ទុកហើយនោះទេ ច្បាប់ដែលរដ្ឋសភាបានបញ្ចេញមតិយល់ព្រមហើយនោះ ត្រូវប្រកាសឱ្យប្រើក្នុងកំណត់ដប់ថ្ងៃ, បើជាការប្រញាប់ កំណត់វេលានោះ ត្រូវបន្ថយមកនៅត្រឹមតែពីរថ្ងៃ ។

បើក្រុមប្រឹក្សាព្រះរាជអាណាចក្រ សុំឱ្យកែសម្រួលសេចក្តីព្រាង ឬ សេចក្តីស្នើច្បាប់នោះ រដ្ឋសភាត្រូវយកមកពិចារណាភ្លាម ជាលើកទី២ ។ រដ្ឋសភា ត្រូវសំរេចតែត្រង់បទឯណា

ដែលក្រុមប្រឹក្សាព្រះរាជអាណាចក្រ សុំឱ្យកែសម្រួល ដោយបដិសេធចោលទាំងមូល ឬ ទុកយកជាការខ្លះ ។

ការដែលបង្វិលទៅបង្វិលមករវាងសភាទាំងពីរនេះ ត្រូវធ្វើតែក្នុងកំណត់មួយខែ (កំណត់នេះ ត្រូវបន្ថយមកត្រឹមដប់ប្រាំថ្ងៃ បើថាត្រូវពិនិត្យសម្រេចពីច្បាប់ថវិកាជាតិ និង ច្បាប់ហិរញ្ញវត្ថុ ហើយមកត្រឹមតែពីរថ្ងៃ បើជាការប្រញាប់) ។

បើរដ្ឋសភា ទុកឱ្យហួសកំណត់ ឬ ពន្យារពេល ដែលកំណត់ទុកសំរាប់ពិនិត្យនោះ, កំណត់ដែលលក្ខខ័ណ្ឌ ជាគោលសំរាប់សភាទាំងពីរនោះ ត្រូវបន្ថែមឱ្យស្មើគ្នាដែរ ។

បើក្រុមប្រឹក្សាព្រះរាជអាណាចក្រ បដិសេធសេចក្តីព្រាង ឬ សេចក្តីស្នើច្បាប់នោះជាអសារបង់, រដ្ឋសភា មិនអាចនឹងយកមកពិចារណាជាលើកទី២ បានមុនកំណត់ ពេលពីរខែទេ (កំណត់នេះ ត្រូវបន្ថយមកត្រឹមមួយខែ បើពិនិត្យពីច្បាប់ថវិកាជាតិ និង ច្បាប់ហិរញ្ញវត្ថុ ហើយមកត្រឹមតែបួនថ្ងៃបើជាការប្រញាប់) ។

ការពិនិត្យសេចក្តីព្រាងច្បាប់ឬសេចក្តីស្នើច្បាប់ជាលើកទី២នេះ រដ្ឋសភាត្រូវបញ្ចេញមតិ ដោយវិធីបោះឆ្នោតចំហ យកតាមភាគច្រើនដោយដាច់ខាត នៃសមាជិករដ្ឋសភា។ សេចក្តីព្រាង ឬ សេចក្តីស្នើច្បាប់ ណាដែលបានធ្វើសម្រេចដូចខាងលើនេះហើយ ត្រូវប្រកាសឱ្យប្រើក្នុងកំណត់ដប់ថ្ងៃ ។ ឯកំណត់នេះ នឹងបន្ថយមកត្រឹមតែពីរថ្ងៃ បើជាការប្រញាប់ ។

## ជំពូក ៧
## អំពីសភាប្រជារាស្ត្រប្រចាំខេត្ត និង ប្រចាំរាជធានី

(ព្រះរាជក្រមលេខ ១៨១-ប.រ ចុះថ្ងៃទី ៣១-៣-៦៤ ស្តីអំពីការផ្អាកបណ្តោះអាសន្ន នូវការប្រព្រឹត្តិទៅនៃសភាប្រជារាស្ត្រប្រចាំខេត្ត និង ប្រចាំរាជធានី)

មាត្រា ៨៤.- (ថ្មី) ត្រូវបង្កើតឱ្យមានសភាប្រជារាស្ត្រមួយនៅគ្រប់ទីប្រជុំខេត្តនីមួយៗ ឬ ជាតំណាងសង្កាត់ក្នុងរាជធានី។

ឯសមាជិកនៃសភានេះ ត្រូវជ្រើសតាំងតាមវិធីបោះឆ្នោតសាកល ដោយចំពោះ។ អ្នកដែលមានសិទ្ធិបោះឆ្នោតនោះ គឺពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុយ៉ាងតិចម្ភៃឆ្នាំបរិបូណ៌ ហើយមានទីលំនៅ នៅក្នុងស្រុក ឬ នៅក្នុងសង្កាត់នោះ។

សភាទាំងនេះ ត្រូវប្រជុំនៅទីប្រជុំខេត្ត ឬ នៅរាជធានី ក្នុងមន្ទីរមួយដែលបានរៀបចំប្រចាំការ, ឯលក្ខខណ្ឌទីប្រជុំ ដូចមានត្រាទុកក្នុងមាត្រា ៦១។

មាត្រា ៨៥.- (កែប្រែ) អ្នកដែលមានសិទ្ធិឈរឈ្មោះជាបេក្ខជនឱ្យគេបោះឆ្នោតជ្រើសតាំងជាសមាជិកសភាប្រជារាស្ត្របាននោះ គឺពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុយ៉ាងតិចម្ភៃប្រាំឆ្នាំបរិបូណ៌ឡើងទៅ។

សមាជិកសភាប្រជារាស្ត្រ ត្រូវជ្រើសតាំងសម្រាប់ពីរឆ្នាំ។ កំណត់ពេលនេះ នឹងបដិសេធចោលមុនបាន ដោយប្រតិបត្តិតាមលក្ខខណ្ឌនៃមាត្រា ៥១។

មាត្រា ៨៦.- (ថ្មី) សមាជិកនៃសភាប្រជារាស្ត្រប្រចាំខេត្ត និងរាជធានី ត្រូវបំពេញលក្ខណសម្បត្តិ ដូចដំណាងរាស្ត្ររដ្ឋសភាដែរ ហើយត្រូវមានសិទ្ធិក៏ដូចគ្នា មានអភ័យឯកសិទ្ធិ

ជាដើម តែត្រូវទទួលប្រាក់បំណាច់ តិចជាងប្រាក់បំណាច់សមាជិករដ្ឋសភា។ ប្រាក់បំណាច់នេះត្រូវកំណត់តាមច្បាប់ដោយប្រៀបស្មើ ទៅនឹងប្រាក់បៀវត្សអ្នករាជការថ្នាក់ណាមួយនៃក្របខណ្ឌបន្ទាប់។

មាត្រា ៨៧.- (កែប្រែ) សមាសភាព នៃសភាប្រជារាស្ត្រប្រចាំខេត្ត និង រាជធានី ត្រូវកំរិតតាមច្បាប់មួយ ដែលបញ្ញត្តអំពីបែបបទដំណើរការ នៃសភានេះផង។

មាត្រា ៤៩ (វគ្គទី ២) ៥០ (វគ្គទី ២) ៥១ (វគ្គទី ២, ៣ និង ៤) ៥៣-៥៥-៥៦-៥៧ ៦៤-៦៨ ៧១ និង ៧២ នៃរដ្ឋធម្មនុញ្ញ ត្រូវយកមកអនុវត្តលើសភាប្រជារាស្ត្រប្រចាំខេត្ត និង រាជធានីនេះដែរ។

មាត្រា ៨៨.- (ថ្មី) សភាប្រជារាស្ត្រប្រចាំខេត្ត និង រាជធានី ត្រូវមានភារៈបញ្ចេញមតិជូនយោបល់ ចំពោះការអនុម័តិនូវថវិកាជាតិ ចំពោះបញ្ជីស្រង់ប្រាក់ចំណូលចំណាយផ្តាច់ឆ្នាំ និង សេចក្តីព្រាងកិច្ចចងការប្រាក់នៃរដ្ឋាភិបាល។ ឯសន្ធិសញ្ញា ដែលត្រូវធ្វើនឹងបរទេស ក៏ត្រូវដាក់ឱ្យសភានេះជូនយោបល់ផងដែរ។

សភាប្រជារាស្ត្រ ត្រូវជូនយោបល់ទៅរដ្ឋសភាក្នុងកំណត់មួយខែយ៉ាងយូរ ចាប់តាំងពីថ្ងៃដែលបានទទួលសំណុំរឿងនោះមក ។ តែបើរដ្ឋសភាបញ្ចេញមតិ ថាទុកជាការប្រញាប់ កំណត់ខាងលើនេះ ត្រូវបន្ថយត្រឹមបីថ្ងៃពេញ លើកតែរឿងបញ្ជីចំណូលចំណាយចេញ។

មាត្រា ៨៩.- (ថ្មី) សភាប្រជារាស្ត្រប្រចាំខេត្ត និង រាជធានី ត្រូវអនុម័តិចំពោះថវិកាខេត្ត និង ថវិការាជធានី ព្រមទាំង ថវិកាឃុំដែលនៅក្នុងដែនចំណុះរបស់ខ្លួន ហើយអនុម័តចំពោះបញ្ជីស្រង់ប្រាក់ចំណូលចំណាយផ្តាច់ឆ្នាំ នៃសមូហភាពទាំងនេះ។

សភាទាំងនេះ ត្រូវសំរេចពីការបង្កើត ឬ ការលុបពន្ធអាករសម្រាប់ខេត្ត ឬ រាជធានី ក្នុងដែនចំណុះរបស់ខ្លួនក្នុងក្របខណ្ឌនៃច្បាប់ទាំងឡាយ ដែលរដ្ឋសភាបានអនុម័តហើយ។

មាត្រា ៩០.- (ថ្មី) សភាប្រជារាស្ត្រមានសិទ្ធិ នឹងធ្វើជាញត្តិជូនដល់រដ្ឋសភា ឬ រដ្ឋាភិបាល អំពីការចាត់ចែង នៃរាជការសាធារណៈក្នុងផែនការជាតិ។

សភាទាំងនេះ ត្រូវតាមពិនិត្យមើលរាជការចាត់ចែងការសាធារណៈក្នុងខេត្ត ឬ រាជធានី។

មាត្រា ៩១.- (ថ្មី) (លុបដោយព្រះរាជក្រមលេខ ១៦៦ ប.រ. ចុះ ថ្ងៃទី ១៣/១/៦៤) សភាប្រជារាស្ត្រ ត្រូវមានសិទ្ធិសួរដេញដោលដល់អ្នករាជការនានា។

បើសភាប្រជារាស្ត្រ បានបញ្ចេញមតិ ដោយមានភាគបីក្នុងបួននៃចំនួនសមាជិក មិនទុកចិត្តលើចៅហ្វាយខេត្ត ចៅហ្វាយក្រុង ឬ ចាងហ្វាងសាលាដំបូងក្នុងដែនចំណុះរបស់ខ្លួន សេចក្ដីសំរេចនេះ ត្រូវបញ្ជូនទៅក្រុមប្រឹក្សាព្រះរាជអាណាចក្រ ពិនិត្យថែមទៀត។ ក្រុមប្រឹក្សាព្រះរាជអាណាចក្រ ត្រូវពិនិត្យរឿងនេះ ក្នុងកំណត់មួយខែយ៉ាងយូរ គិតពីថ្ងៃដែលបានទទួលសំណុំរឿង។ បើក្រុមប្រឹក្សាព្រះរាជអាណាចក្របញ្ចេញមតិមិនទុកចិត្តលើអ្នករាជការនោះដែរ ដោយមានភាគបីក្នុងបួនក្នុងចំនួនសមាជិក, រដ្ឋាភិបាលត្រូវផ្លាស់ដោយស្វ័យប្រវត្តិនូវអ្នករាជការនោះឱ្យចេញផុតពីដែនខេត្ត ឬ រាជធានី។

ចំពោះលើអ្នករាជការក្រៅពីនោះ រដ្ឋាភិបាលត្រូវសំរេចដោយស្វ័យប្រវត្តិ ផ្លាស់ចេញពីខេត្ត ឬ រាជធានី, បើសភាប្រជារាស្ត្រ ប្រចាំខេត្ត ឬ រាជធានី បានបញ្ចេញមតិ មិនទុកចិត្តដោយមានភាគបីក្នុងបួន ហើយបើក្រុមប្រឹក្សាព្រះរាជអាណាចក្រ បានបញ្ចេញមតិយល់ព្រម

ដោយមានភាគច្រើនដាច់ខាតផង ក្នុងចំនួននៃសមាជិក ។

កាលបើមានអ្នករាជការណាបានទទួលផ្លាស់៣ដង ដោយស្វ័យប្រវត្តិ ដូចបានថ្លែងមកខាងលើ ក្នុងកំឡុងសកម្មភាពពីរឆ្នាំ នោះត្រូវលើករឿងនេះជូនទៅរដ្ឋសភាវិនិច្ឆ័យ ថាតើគួរបណ្តេញអ្នករាជការនោះចោល ឬ ទេ។ រដ្ឋសភា នឹងសំរេចថាត្រូវឱ្យបណ្តេញចោល លុះត្រាតែបានបញ្ចេញមតិយល់ព្រម, ដោយមានភាគច្រើនដាច់ខាត បើពុំបានភាគច្រើនដោយដាច់ខាតទេ, រដ្ឋាភិបាល ត្រូវតែធ្វើទណ្ឌកម្ម ដោយស្វ័យប្រវត្តិ បន្ថយស័ក្តិអ្នករាជការដែលមានរឿងនោះ ។

## ជំពូក ៨
## អំពីសមាជជាតិ

មាត្រា ៩២.- (ថ្មី) សមាជជាតិ បើកឱ្យប្រជារាស្ត្រជ្រាបបានដោយចំពោះ នូវកិច្ចការផ្សេងៗ ដែលជាប្រយោជន៍ជាតិ ។

ពលរដ្ឋខ្មែរទាំងពីរភេទ អាចចូលទៅរួបរួមក្នុងសមាជជាតិបាន ។

មាត្រា ៩៣.- (ថ្មី) សមាជជាតិ ប្រជុំយ៉ាងតិចពីរដងក្នុងមួយឆ្នាំ ការប្រជុំនេះ ត្រូវធ្វើឡើងតាមសេចក្តីអញ្ជើញ នៃនាយករដ្ឋមន្ត្រី ។

សមាជជាតិ ត្រូវតាំងប្រធានរបស់ខ្លួន ។

មាត្រា ៩៤.- (ថ្មី) សមាជជាតិ អនុម័តសច្ចាធិដ្ឋានជូនចំពោះរដ្ឋាភិបាល ហើយអនុម័តសេចក្តីសំរេចជូនចំពោះរដ្ឋសភា ។

ការរៀបចំធ្វើ និង ការប្រព្រឹត្តិទៅនៃសមាជ ត្រូវកំណត់ដោយជាក់លាក់ទុកក្នុងច្បាប់ណាមួយ ។

មាត្រា ៩៥.- (ថ្មី) រដ្ឋសភា អាចចាត់ចែងធ្វើប្រជាមតិបានចំពោះបញ្ហាណាដែលជាសេចក្ដីសំរេចនៃសមាជ ។

# ចំពូក ៩

# អំពីរដ្ឋមន្ត្រី

មាត្រា ៩៦.- (ថ្មី) (មាត្រា ៧៩ ចាស់កែប្រែ) គណៈរដ្ឋមន្ត្រីជារាជរដ្ឋាភិបាល ។ គណៈរដ្ឋមន្ត្រី មានសមាជិកចំនួនដប់ប្រាំមួយរូបជាអតិបរមា រាប់បញ្ចូលទាំងរដ្ឋលេខាធិការផង ។

គ្មានវិសមិតភាពណាមួយទេ រវាងអាណត្តិសភា និង ភារៈនៃសមាជិករដ្ឋាភិបាល ។ នឹងយកសមាជិកនៃរដ្ឋសភា និង ក្រុមប្រឹក្សាព្រះរាជអាណាចក្រ ឬ ជនដែលពុំមែនជាសមាជិកនៃសភាទាំងពីរនេះ មកធ្វើជាសមាជិកនៃរដ្ឋាភិបាលក៏បាន ។

ភារៈរបស់សមាជិករដ្ឋាភិបាលមានវិសមិតភាព ជាមួយនឹងសកម្មភាពខាងវិជ្ជាជីវៈ, ពាណិជ្ជកម្ម ឬ ឧស្សាហកម្មណាមួយ ហើយជាមួយនឹងការកាន់តំណែងណាមួយជាសាធារណៈផងដែរ ។

មាត្រា ៩៧.- (មាត្រា ៨០ ចាស់) ក្នុងវេលាដំបូង នៃនីតិកាលនីមួយៗ ឬ កាលគណៈរដ្ឋមន្ត្រីលាឈប់, ព្រះមហាក្សត្រ ទ្រង់ប្រឹក្សានឹងប្រធានរដ្ឋសភា នឹងប្រធានក្រុមប្រឹក្សាព្រះរាជអាណាចក្រ ហើយនឹងមេគណៈបក្សទាំងឡាយ ដែលមានតំណាងនៅក្នុងរដ្ឋសភា ឬ

ក្រុមប្រឹក្សាព្រះរាជអាណាចក្រ រួចទ្រង់ចាត់វរជនមួយរូប ជានាយករដ្ឋមន្ត្រីឱ្យជ្រើសរដ្ឋមន្ត្រីឯទៀត។

រដ្ឋមន្ត្រីទាំងឡាយ នឹងទទួលតែងតាំង ហើយនឹងចូលកាន់មុខក្រសួងបាន លុះត្រាតែរដ្ឋសភាបានបញ្ចេញមតិទុកចិត្តជាមុន ដោយវិធីបោះឆ្នោតចំហ ហើយយកតាមភាគច្រើនដោយដាច់ខាត។

មាត្រា ៩៨.- (មាត្រា ៨១ ចាស់) រដ្ឋមន្ត្រីទាំងឡាយ ទទួលខុសត្រូវរួមគ្នាចំពោះរដ្ឋសភា អំពីនយោបាយទូទៅនៃគណៈរដ្ឋមន្ត្រី ហើយរដ្ឋមន្ត្រីមួយរូបៗ ទទួលខុសត្រូវរៀងខ្លួនចំពោះនាយករដ្ឋមន្ត្រី អំពីការដែលខ្លួនបានប្រព្រឹត្ត។

មាត្រា ៩៩.- (មាត្រា ៨២ ចាស់) រដ្ឋមន្ត្រីទាំងឡាយ មិនអាចអាងសេចក្តីបង្គាប់ដោយលាយលក្ខណ៍អក្សរ ឬ ដោយវាចា អំពីនរណាក៏ដោយ ដើម្បីដោះសារឱ្យរួចខ្លួន ពីការទទួលខុសត្រូវលើខ្លួនបានឡើយ។

មាត្រា ១០០.- (មាត្រា ៨៣ ចាស់) បើមានអ្នកតំណាងរាស្ត្រមួយនាក់ ឬ ច្រើននាក់ តាំងសំនួរដោយវាចាក្តី តាំងសំនួរដោយលាយលក្ខណ៍អក្សរក្តី តាំងសំនួរដេញដោលក្តីដើម្បីសុំឱ្យរដ្ឋមន្ត្រីឆ្លើយដោះសាអំពីការប្រព្រឹត្តិក្នុងមុខក្រសួងរបស់ខ្លួន នោះរដ្ឋមន្ត្រីត្រូវរាយការណ៍តាមសេចក្តីសុំ ជូនរដ្ឋសភា។

មាត្រា ១០១.- (មាត្រា ៨៤ ចាស់) លុះតែបានពិភាក្សាព្រមព្រៀងគ្នាជា មុនស្រេចហើយ ទើបគណៈរដ្ឋមន្ត្រី អាចសុំឱ្យរដ្ឋសភាបញ្ចេញមតិ អំពីសេចក្តីទុកចិត្តក្នុងគណៈ-រដ្ឋមន្ត្រីបាន។

ការសុំឱ្យរដ្ឋសភាបញ្ចេញមតិដូចខាងលើនេះ ជាភារៈរបស់នាយករដ្ឋមន្ត្រីតែម្នាក់ឯង។

កាលបើនាយករដ្ឋមន្ត្រី សុំឱ្យរដ្ឋសភាបញ្ចេញមតិ អំពីសេចក្ដីទុកចិត្ត នោះត្រូវបង្អង់វេលាយ៉ាងតិចមួយថ្ងៃគត់ គិតតាំងពីពេលសុំនោះមក ទើបរដ្ឋសភាបញ្ចេញមតិអំពីរឿងនេះបាន។ ការបញ្ចេញមតិនេះត្រូវធ្វើដោយវិធីបោះឆ្នោតចំហ។

រដ្ឋសភា នឹងបញ្ចេញមតិ ថាមិនទុកចិត្តក្នុងគណៈរដ្ឋមន្ត្រីបាន លុះតែមានភាគច្រើនដោយដាច់ខាតនៃចំនួនសមាជិករដ្ឋសភាយល់ព្រមផង។

សេចក្ដីមិនព្រមទុកចិត្តនេះ នាំឱ្យរដ្ឋមន្ត្រីលាឈប់ទាំងគណៈ។

មាត្រា ១០២.-(មាត្រា ៨៥ ចាស់) កាលបើរដ្ឋសភាបញ្ចេញមតិតាំងញត្តិបន្ទោសគណៈរដ្ឋមន្ត្រី នោះរដ្ឋមន្ត្រីត្រូវលាឈប់ទាំងគណៈ។

កាលបើមានអ្នកតំណាងរាស្ត្រ សុំឱ្យរដ្ឋសភាបញ្ចេញមតិតាំងញត្តិបន្ទោសគណៈរដ្ឋមន្ត្រី នោះរដ្ឋសភាត្រូវបង្អង់វេលាមួយថ្ងៃគត់ គិតតាងពីថ្ងៃជូនសេចក្ដីសុំតាំងញត្តិ ទើបបញ្ចេញមតិពីរឿងនេះបាន។ ការបញ្ចេញមតិនេះ ត្រូវធ្វើទៅដោយវិធីបោះឆ្នោតចំហ។

ការតាំងញត្តិបន្ទោសគណៈរដ្ឋមន្ត្រី នឹងយកជាការបាន លុះតែមានភាគច្រើនដោយដាច់ខាត នៃសមាជិករដ្ឋសភាយល់ព្រមផង។

មាត្រា ១០៣.(ថ្មី) ដោយអនុវត្តន៍ក្រៅពីមាត្រា ៩៨-១០១ និង ១០២, រដ្ឋសភាអាចដកសេចក្ដីទុកចិត្ត ចំពោះតែលើរូបរដ្ឋមន្ត្រី ឬ រដ្ឋលេខាធិការណាមួយក៏បាន ឬ បញ្ចេញមតិបន្ទោសចំពោះតែលើរូបរដ្ឋមន្ត្រីឬរដ្ឋលេខាធិការណាមួយក៏បាន។ ដោយអាស្រ័យហេតុណាមួយដូចថ្លែងមកនេះ រដ្ឋមន្ត្រី ឬ រដ្ឋលេខាធិការ ដែលមានរឿងនោះ ត្រូវដកខ្លួនចេញពី

គណៈរដ្ឋមន្ត្រី ។ បើនាយករដ្ឋមន្ត្រីជំទាស់មិនព្រមឱ្យរដ្ឋមន្ត្រី ឬរដ្ឋលេខាធិការនោះឈប់ពីតំណែង នាយករដ្ឋមន្ត្រី ត្រូវសុំឱ្យរដ្ឋសភាបញ្ចេញមតិអំពីសេចក្ដីទុកចិត្ត ចំពោះគណៈរដ្ឋមន្ត្រីទាំងមូល ។

មាត្រា ១០៤.- (មាត្រា ៨៦ ចាស់) គណៈរដ្ឋមន្ត្រី ត្រូវប្រជុំរាល់សប្ដាហ៍ ជួនកាលជាពេលប្រជុំធំ ដោយមានព្រះមហាក្សត្រិយ៍ ឬនាយករដ្ឋមន្ត្រីជាប្រធាន ជួនកាលប្រជុំតូច ។

មាត្រា ១០៥.- (ថ្មី) (មាត្រា ៨៧ ចាស់កែប្រែ) សមាជិកទាំងឡាយនៃរដ្ឋាភិបាល អញ្ជើញចូលបានទៅក្នុងរដ្ឋសភា និង ក្រុមប្រឹក្សាព្រះរាជអាណាចក្រ ហើយនិងក្នុងគណៈកម្មការទាំងពួងនៃសភាទាំងនេះ ។ បើសមាជិករដ្ឋាភិបាលសុំនិយាយ នោះត្រូវតែបើកឱកាសឱ្យនិយាយ វៀរលែងតែក្នុងករណី ដែលសភារួមប្រជុំ ជាពេលប្រជុំបោះឆ្នោតតពីការដាក់ញត្តិបន្ទោស ។

សមាជិករដ្ឋាភិបាល អាចឱ្យអ្នកស្នងការដែលត្រូវចាត់តាំងសម្រាប់ការណាមួយឱ្យជួយនិយាយការនោះផងបាន ។

មាត្រា ១០៦.- (មាត្រា ៨៨ ចាស់) នាយករដ្ឋមន្ត្រី អាចរំលែកអំណាចរបស់ខ្លួនឱ្យទៅរដ្ឋមន្ត្រីណាមួយបាន ។

មាត្រា ១០៧.- (មាត្រា ៨៩ ចាស់) បើតំណែងនាយករដ្ឋមន្ត្រីទំនេរ ត្រូវតែងតាំងគណៈរដ្ឋមន្ត្រីមួយជាថ្មី តាមលក្ខខណ្ឌដែលមានត្រាទុកក្នុងរដ្ឋធម្មនុញ្ញនេះ បើការទំនេរជាដាច់ខាត, ឬ ត្រូវចាត់តាំងនាយករដ្ឋមន្ត្រីជាបណ្ដោះអាសន្ន បើការទំនេរនេះជាមួយកាលមួយគ្រាទេ ។

មាត្រា ១០៨.- ( មាត្រា ៩០ ចាស់) បើមានការរំលាយរដ្ឋសភា នោះនាយករដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវឈប់ធ្វើការសិន, រដ្ឋមន្ត្រីឯទៀត គង់នៅក្នុងតំណែងទាំងអស់គ្នា ដើម្បីសម្រេចកិច្ចការសាមញ្ញ។

ក្នុងខណៈនោះ ព្រះមហាក្សត្រិយ៍ ទ្រង់ប្រទានភារៈទៅលើប្រធានរដ្ឋសភា ឱ្យកាន់តំណែងនាយករដ្ឋមន្ត្រីជាបណ្តោះអាសន្ន។ ប្រធានរដ្ឋសភា ចាត់តាំងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃជាថ្មី ដោយសេចក្តីយល់ព្រមនៃក្រុមអភិបាលរដ្ឋសភា។

មាត្រា ១០៩.- ( មាត្រា ៩១ ចាស់) រដ្ឋមន្ត្រីដែលពុំមែនជាសមាជិកនៃរដ្ឋសភា ឬក្រុមប្រឹក្សាព្រះរាជអាណាចក្រទេ ត្រូវទទួលផលប្រយោជន៍ដែលមានត្រាទុកក្នុងមាត្រា ៥៥ និង ៥៦ នៃរដ្ឋធម្មនុញ្ញនេះ។

មាត្រា ១១០.- (ថ្មី) ( មាត្រា ៩២ ចាស់) រដ្ឋមន្ត្រី ត្រូវទទួលទណ្ឌកម្មអំពីបទឧក្រិដ្ឋ និង បទមជ្ឈិម ដែលបានប្រព្រឹត្តក្នុងវេលាធ្វើការមុខក្រសួងរបស់ខ្លួន។

ក្នុងករណីនេះ និង ករណីធ្វើខុសជាទម្ងន់ក្នុងវេលាធ្វើការមុខក្រសួងរបស់ខ្លួន, រដ្ឋសភា អាចសម្រេចប្តឹងផ្តល់តុលាការរាស្ត្រ។

រដ្ឋសភា សម្រេចក្នុងរឿងនេះ ដោយវិធីបោះឆ្នោតសម្ងាត់ យកតាមភាគច្រើនដោយដាច់ខាត នៃសមាជិករបស់ខ្លួន។

មាត្រា ១១១.- (ថ្មី) ( មាត្រា៩៣ចាស់) ការបង្កើត, ការរៀបចំ, ការប្រព្រឹត្តិទៅ, សមាសភាព, ការចាត់តាំង ហើយនិងថិរវេលានៃអាណត្តិ របស់សមាជិកនៃតុលាការរាស្ត្រ ត្រូវកំណត់ឡើងដោយច្បាប់ពិសេសមួយ។

មាត្រា ១១២.- (ថ្មី) (មាត្រា៩៤ចាស់) នីតិក្រមដែលត្រូវប្រតិបត្តិនៅសាលានីតិ-កម្មនេះ ក៏ត្រូវកំណត់ឡើងដោយច្បាប់ពិសេសដែរ ។

## ជំពូក ១០

## អំពីអំណាចតុលាការ

មាត្រា ១១៣.- (មាត្រា ៩៥ ចាស់) ការរៀបចំនៃតុលាការមានបញ្ញត្តិទុកក្នុងច្បាប់ពិសេសមួយ ។

មាត្រា ១១៤.- (មាត្រា ៩៦ ចាស់កែប្រែ) ក្រុមប្រឹក្សាជាន់ខ្ពស់នៃតុលាការ ដោយអនុលោមតាមច្បាប់ ត្រូវធានារ៉ាប់រងចំពោះវិន័យ និង ឥស្សរភាពនៃចៅក្រម ។

ក្រុមប្រឹក្សានេះ ត្រូវនៅក្រោមអធិបតិភាពនៃព្រះករុណាជាអម្ចាស់ជីវិតលើត្បូង មានសមាសភាពដូចតទៅនេះ ÷

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ .............................................. ជាអនុប្រធាន

សមាជិក ២ រូបចាត់តាំងដោយព្រះមហាក្សត្រិយ៍

សមាជិក ២ រូបជ្រើសតាំងដោយរដ្ឋសភា

សមាជិក ២ រូបជ្រើសតាំងដោយចៅក្រមទាំងឡាយ

កាលបើព្រះមហាក្សត្រិយ មិនសព្វព្រះរាជហឫទ័យ ប្រោសព្រះរាជទានព្រះរាជា-ធិបតិភាពក្នុងការប្រជុំនៃក្រុមប្រឹក្សាជាន់ខ្ពស់ទេ ឬ មិនប្រោសព្រះរាជទានចាត់តាំងដោយជាក់ស្តែង នូវសមាជិកឧត្តមក្រុមប្រឹក្សាអមព្រះអង្គមួយរូប ធ្វើជាអធិបតីក្នុងពេលប្រជុំនោះ

ទេ អនុប្រធាននឹងទទួលធ្វើជាអធិបតី ។

សេចក្តីសំរេចនៃក្រុមប្រឹក្សាជាន់ខ្ពស់នៃតុលាការ ត្រូវយកតាមមតិភាគច្រើនដោយវិធីបោះឆ្នោត ។ ក្នុងករណីមានបែកសំឡេងជា ២ ភាគស្មើគ្នា នោះត្រូវយកតាមសំឡេងនៃអធិបតី ។

ច្បាប់ពិសេសមួយ នឹងកំណត់អំពីការរៀបចំនៃក្រុមប្រឹក្សាជាន់ខ្ពស់នេះ ។

## ជំពូក ១១
## បញ្ញត្តិទូទៅ

មាត្រា ១១៥ (មាត្រា ៩៧ ចាស់) បទបញ្ញត្តិទាំងឡាយដែលស្តីអំពីរបៀបគ្រប់គ្រង ដោយមានព្រះមហាក្សត្រិយ៍ជាអគ្គប្រមុខរបស់រដ្ឋនេះ ១, អំពីរបៀបគ្រប់គ្រងដោយអាស្រ័យអ្នកតំណាងរបស់ប្រជារាស្ត្រនេះ ១ អំពីគោលចារឹកនៃសេរីភាព និង សមភាពដែលរដ្ឋធម្មនុញ្ញនេះធានាអះអាងឱ្យមាន ១, មិនត្រូវសុំកែប្រែសោះឡើយ ។

មាត្រា ១១៦.- (មាត្រា ៩៨ ចាស់) ហាមមិនឱ្យកែប្រែរដ្ឋធម្មនុញ្ញ ដើម្បីនឹងបន្ថយព្រះរាជសិទ្ធិទាំងឡាយដែលមានត្រាទុកជាស្រេចហើយ ។

មាត្រា ១១៧.- (ថ្មី) (មាត្រា ៩៩ ចាស់) អ្នកដែលមានសិទ្ធិផ្តើមគំនិតកែប្រែរដ្ឋធម្មនុញ្ញគឺ : ព្រះមហាក្សត្រិយ៍, នាយករដ្ឋមន្ត្រី, ប្រធានក្រុមប្រឹក្សាព្រះរាជអាណាចក្រ និង ប្រធានរដ្ឋសភា, អ្នកណាមួយក្នុងបណ្តាអ្នកទាំងពីរខាងក្រោយនេះ ត្រូវធ្វើទៅតាមសេចក្តីអនុម័តិនៃសភាដែលខ្លួនជាប្រធាន ដោយមានសមាជិកចំនួនភាគមួយក្នុងបួន (១/៤)

យ៉ាងតិចធ្វើពាក្យសុំ ។

មាត្រា ១១៨.- ( មាត្រា ១០០ ចាស់) របៀបកែប្រែរដ្ឋធម្មនុញ្ញដូចគ្នានឹងរបៀប ដែលមានត្រាទុកសំរាប់បញ្ចេញមតិតាំងច្បាប់ធម្មតា ។ ប៉ុន្តែ, ត្រូវមានភាគច្រើនដល់បីក្នុងបួន (៣/៤) នៃរដ្ឋសភា យល់ព្រមផង ទើបយកជាការបាន ហើយមិនអាចប្រកាសថាជាការ ប្រញាប់បានទេ ។

មាត្រា ១១៩.- ( មាត្រា ១០១ ចាស់) រដ្ឋសភា មានសិទ្ធិមកស្រាយសេចក្តីបទ រដ្ឋធម្មនុញ្ញនេះជាដាច់ខាត ។

មាត្រា ១២០.- ( មាត្រា ១០២) ដើម្បីនឹងកំណត់ភាគច្រើនដោយដាច់ខាត ក្នុង ចំនួនសមាជិកនៃសភានីមួយៗ ត្រូវគិតចំនួនសមាជិកនៃសភានោះ ដោយឥតរាប់បញ្ចូល ÷

សមាជិកណា ដែលទទួលអនិច្ចកម្មទៅហើយ ។

សមាជិកណា ដែលផុតចាកសមាជិកភាព ដោយលាលែងក្តី ដោយត្រូវបណ្តេញក្តី ឬ ដោយមិនបានទទួលតាំងជាសមាជិកពេញទីក្តី ។

សមាជិកណា ដែលទទួលតំណែងក្នុងរដ្ឋាភិបាល ឬ ត្រូវបញ្ជូនទៅប្រតិបត្តិការ ឯណាក្តី ។

មាត្រា ១២១.- ( មាត្រា ១០៣ ចាស់) បទបញ្ញត្តិទាំងពួងដែលត្រឹមត្រូវតាមច្បាប់ មិនផ្ទុយសេចក្តីគ្នានឹងរដ្ឋធម្មនុញ្ញនេះ ត្រូវដំកល់ទុកប្រតិបត្តិតទៅ ។

# ជំពូក ១២
# បទបញ្ញត្តិពិសេស

មាត្រា ១២២.- ក្នុងករណីដែលកាលៈទេសៈ ពុំអនុញ្ញាតឱ្យចាត់តាំង ទាំងព្រះមហាក្សត្រអង្គថ្មី ទាំងក្រុមប្រឹក្សារាជានុសិទ្ធ ដោយអនុលោមទៅតាមបទបញ្ញត្តិមាត្រា ៣០ និង ៣០ ស្ទួន នៃរដ្ឋធម្មនុញ្ញនេះ, សភាទាំងពីរត្រូវរួមប្រជុំគ្នា ដោយសេចក្តីអញ្ជើញនៃប្រធានរដ្ឋសភា និងក្រោមអធិបតីភាពនៃប្រធាននេះ ដោយអនុលោមទៅតាមឆន្ទៈដែលប្រជារាស្ត្របានសំដែងហើយ, សភាទាំងពីរនេះ អាចលើកអំណាច និង បុព្វសិទ្ធិទាំងឡាយរបស់ប្រមុខរដ្ឋប្រគល់ទៅឥស្សរជនមួយរូបដែលប្រជាពលរដ្ឋស្រឡាញ់ទុកចិត្ត ហើយបានបញ្ចេញមតិចង្អុលដ៏ជាក់ច្បាស់។ មុននឹងទទួលតំណែង ប្រមុខរដ្ឋត្រូវថ្លែងសច្ចាប្រណិធានក្នុងទីប្រជុំរដ្ឋសភាមានជាសេចក្តីដូចក្នុងមាត្រា ៣៤ នៃរដ្ឋធម្មនុញ្ញ ហើយបន្ថែមពាក្យថា "ហើយខ្ញុំមានចិត្តស្មោះត្រង់ចំពោះព្រះរាជបល្ល័ង្ក"។ ប្រសិនបើប្រមុខរដ្ឋ ពុំបានស្ថិតនៅក្នុងកម្ពុជរដ្ឋមួយដងមួយគ្រា ឬ ពុំអាចទទួលភារៈបានក្នុងមួយដងមួយគ្រា ប្រមុខរដ្ឋប្រគល់ភារៈនេះទៅប្រធានរដ្ឋសភា, ប្រធានរដ្ឋសភាកាន់កាប់ភារៈទាំងនេះដោយទទួលខុសត្រូវផ្ទាល់ខ្លួន។

## គួរចំណាំទុកជាពិសេស

- ព្រះបាទសម្តេចព្រះនរោត្តម សីហនុ វរ្ម័ន ព្រះចៅក្រុងកម្ពុជា ទ្រង់ប្រោស ព្រះរាជទានរដ្ឋធម្មនុញ្ញដល់ព្រះរាជារាស្ត្រខ្មែរ នៅថ្ងៃទី ៦ ខែ ឧសភា គ.ស.១៩៤៧។

- ព្រះរាជក្រមលេខ ៤៦៤ ន.ស. ចុះថ្ងៃទី ៦-៩-៤៨ បានប្រកាសទុកថ្ងៃទី ៦ ខែ ឧសភារៀងរាល់ឆ្នាំ ជាថ្ងៃបុណ្យជាតិ ព្រោះជាកាលបរិច្ឆេទនៃការប្រកាសឱ្យប្រើរដ្ឋធម្មនុញ្ញ ព្រះរាជអាណាចក្រ។

- រដ្ឋធម្មនុញ្ញនេះបានទទួលការកែប្រែ និងបន្ថែមតាមច្បាប់ដែលរដ្ឋសភាទី ៣ បានអនុម័តជាលើកទី ២ ពីថ្ងៃទី ៦ ខែធ្នូ គ.ស. ១៩៥៥ ហើយដែលមាន ព្រះរាជក្រមលេខ ៦៥ ន.ស. ចុះថ្ងៃទី ១៤-១-៥៦ ប្រកាសឱ្យប្រើ។

មាត្រា ៨១. នៃរដ្ឋធម្មនុញ្ញនេះ បានទទួលការកែប្រែ និង បន្ថែមតាមច្បាប់ដែល រដ្ឋសភាទី ៤ បានអនុម័តពីថ្ងៃទី ២០ មករា ១៩៥៩ ហើយដែលមានព្រះរាជក្រមលេខ ២៩៧ ន.ស. ចុះថ្ងៃទី ១៣-២-៥៩ ប្រកាសឱ្យប្រើ។

មាត្រា ៨៥.- បានទទួលការកែប្រែតាមច្បាប់ ដែលរដ្ឋសភាទី ៤ បានអនុម័ត កាលពីថ្ងៃទី ១៦-៦-៥៩ ហើយដែលមានព្រះរាជក្រមលេខ ៣២៨ ន.ស. ចុះថ្ងៃទី ២៨ កក្កដា ១៩៥៩ ប្រកាសឱ្យប្រើ។

មាត្រា ៨៧- បានទទួលការកែប្រែ និង បន្ថែមតាមច្បាប់ដែលរដ្ឋសភាទី ៣ បាន អនុម័តជាលើកទី ២ ពីថ្ងៃទី ៣០ មករា ១៩៥៧ ហើយដែលមានព្រះរាជក្រមលេខ ១៦៩ ន.ស ចុះថ្ងៃទី ៨-៣-៥៧ ប្រកាសឱ្យប្រើ។

- ព្រះរាជក្រមលេខ ២៨២ ន.ស. ចុះថ្ងៃទី ៧-១-៥៨ បានប្រកាសឱ្យប្រើច្បាប់ដែលរដ្ឋសភាទី ៣ បានអនុម័តជាលើកទី ២ កាលពីថ្ងៃទី ១៨-១២-៥៧ ស្តីពីបញ្ចូលសមាជជាតិទៅក្នុងរដ្ឋធម្មនុញ្ញ ត្រង់ចំពូក ៨ មាន ៤ មាត្រា ( មាត្រា ៩២-៩៣-៩៤ និង ៩៥) ។

មាត្រា ៩៦.- បានទទួលការកែប្រែតាមច្បាប់ ដែលរដ្ឋសភាទី ៤ បានអនុម័តពីថ្ងៃទី ១៩ មេសា ១៩៥៨ ហើយដែលមានព្រះរាជក្រមលេខ ២៦៦ ន.ស ចុះថ្ងៃទី ៣០-៤-៥៨ ប្រកាសឱ្យប្រើ ។

មាត្រា ១១៤.- បានទទួលការកែប្រែតាមច្បាប់ដែលរដ្ឋសភាទី ៤ បានអនុម័តពីថ្ងៃទី ២០-១-៥៩ ហើយដែលមានព្រះរាជក្រមលេខ ៣៣៥ ន.ស. ចុះថ្ងៃទី ២១ សីហា ១៩៥៩ ប្រកាសឱ្យប្រើ ។

- ក្រមលេខ ៣៨៤ ចុះថ្ងៃទី ៥-៤-៦០ បានប្រកាសឱ្យប្រើនូវច្បាប់ដែលរដ្ឋសភាទី ៤ បានអនុម័តជាលើកទី ១ កាលពីថ្ងៃទី ៤-៤-៦០ ស្តីអំពីការកែសម្រួលនូវចំពូក ៤ នៃរដ្ឋធម្មនុញ្ញព្រះរាជអាណាចក្រ ។

- ក្រមលេខ ៣៩០ ចុះថ្ងៃទី ១៤-៦-៦០ បានប្រកាសឱ្យប្រើច្បាប់ដែលរដ្ឋសភាទី ៤ បានអនុម័តជាលើកទី ១ កាលពីថ្ងៃទី ១៣-៦-៦០ ស្តីពីការបន្ថែមបទបញ្ញត្តិពិសេស ក្នុងរដ្ឋធម្មនុញ្ញព្រះរាជអាណាចក្រ ។

- ព្រះរាជក្រមលេខ ១៦៦ ប.រ. ចុះថ្ងៃទី ១៣-១-៦៤ បានប្រកាសឱ្យប្រើច្បាប់ដែលរដ្ឋសភាទី ៥ បានអនុម័តជាលើកទី ១ កាលពីថ្ងៃទី ៣-១-៦៤ ដែលថា :

មាត្រា ២៨.- ត្រូវកែប្រែ,

មាត្រា ១១០,១១១ និង ១១២ ត្រូវទុកជាមោឃៈ ហើយត្រូវយកបទបញ្ញត្តិថ្មីមកជំនួសវិញ,

មាត្រា ៦៩, ៧០, ៨២ និង ៩១ ត្រូវលុបចោល។

- ការប្រព្រឹត្តិទៅនៃសភាប្រជារាស្ត្រប្រចាំខែត្រ និង ប្រចាំរាជធានី ដែលមានចែងក្នុងជំពូកទី ៧ នៃរដ្ឋធម្មនុញ្ញព្រះរាជអាណាចក្រ បានត្រូវទទួលការផ្អាកជាបណ្ដោះអាសន្ន ពុំមានកំណត់កាល ដោយអនុលោមតាមប្រជាមតិចុះថ្ងៃទី ២៩ ខែ វិច្ឆិកាឆ្នាំ ១៩៥៩ និងតាមច្បាប់ដែលរដ្ឋសភាទី ៥ បានអនុម័តជាលើកទី ២ កាលពីថ្ងៃទី ៣០ មីនា ១៩៦៤ បានប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ ១៨១ ប រ. ចុះថ្ងៃទី ៣១ មីនា ១៩៦៤។

មាត្រា ៧៧, ៧៨, ៩៦, ១០៥ និង ១១៧ ត្រូវលុបចោល ហើយត្រូវយកមកជំនួសវិញនូវបទបញ្ញត្តិថ្មី តាមច្បាប់ដែលរដ្ឋសភាទី ៥ បានអនុម័តជាលើកទី ២ កាលពីថ្ងៃទី ៤-២-៦៤ បានប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ ១៨២ ប.រ. ចុះថ្ងៃទី ៣១ មីនា ១៩៦៤។

# កាលបរិច្ឆេទនៃការបោះឆ្នោត
# សំរាប់

| | | | | |
|---|---|---|---|---|
| - រដ្ឋសភាបណ្ដោះអាសន្ន | : ថ្ងៃទី | ១ | កញ្ញា | ១៩៤៦ |
| - រដ្ឋសភាទី ១ | : - | ២១ | ធ្នូ | ១៩៤៧ |
| - រដ្ឋសភាទី ២ | : ថ្ងៃទី | ៩ | កញ្ញា | ១៩៥១ |
| - -,,- ៣ | : - | ១១ | កញ្ញា | ១៩៥៥ |
| - -,,- ៤ | : - | ២៣ | មីនា | ១៩៥៨ |
| - -,,- ៥ | : - | ១០ | មិថុនា | ១៩៦២ |
| - -,,- ៦ | : - | ១១ | កញ្ញា | ១៩៦៦ |

# រដ្ឋធម្មនុញ្ញ

# សាធារណរដ្ឋខ្មែរ

## នាថ្ងៃ ១០ ឧសភា ១៩៧២

# បញ្ញត្តិលេខ ១៩/៧២-បសខ

## ប្រធានាធិបតី នៃ សាធារណរដ្ឋខ្មែរ

បានឃើញច្បាប់រដ្ឋធម្មនុញ្ញលេខ ៤៤២ - ៧០ - បរ ចុះថ្ងៃទី ៨ ខែតុលា ១៩៧០ ដែលប្រកាសសាធារណរដ្ឋខ្មែរ ហើយតម្កល់ទុកឱ្យអនុវត្តនូវរដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៤៧ លើកលែងតែបទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីគំនិត និង របបសាធារណរដ្ឋ។

បានឃើញ បញ្ញត្តិលេខ ១ - ៧១ - បរ ចុះថ្ងៃទី ១៨ ខែតុលា ១៩៧១ គ្រប់គ្រងបញ្ហាទាំងឡាយណាដែលស្ថិតនៅក្រោមវិស័យច្បាប់។

បានឃើញ បញ្ញត្តិលេខ ១៧ - ៧២ - បរ ចុះថ្ងៃទី ១២ ខែមិនា គ.ស. ១៩៧២ ដែលប្រគល់អំណាចទាំងឡាយ នៃរដ្ឋាភិបាល ជូនទៅប្រធានាធិបតី នៃ សាធារណរដ្ឋខ្មែរ។

បានឃើញ លទ្ធផលនៃប្រជាមតិ ចុះថ្ងៃទី ៣០ ខែមេសា គ.ស. ១៩៧២ លើសេចក្តីព្រាងរដ្ឋធម្មនុញ្ញ នៃសាធារណរដ្ឋខ្មែរ។

គណៈ រដ្ឋមន្ត្រី បានយល់ព្រមផង។

## បញ្ញត្តិដូចមានខាងក្រោមនេះ

**មាត្រា ១.** ត្រូវប្រកាសឱ្យប្រើរដ្ឋធម្មនុញ្ញ នៃ សាធារណរដ្ឋខ្មែរ ដែលប្រជារាស្ត្រខ្មែរ បានទទួលយល់ព្រមដោយប្រជាមតិ នាថ្ងៃទី ៣០ ខែមេសា គ.ស. ១៩៧២ ហើយដែលមានអត្ថបទភ្ជាប់ជាឧបសម្ពន្ធនៃបច្ចុប្បន្នបញ្ញត្តិនេះ។

**មាត្រា ២.-** បច្ចុប្បន្នរដ្ឋធម្មនុញ្ញនេះ នឹងចូលជាធរមាន នៅថ្ងៃទី ១២ ខែឧសភា គ.ស. ១៩៧២ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី ១០ ខែឧសភា គ.ស. ១៩៧២

ហត្ថលេខា : លន់ នល់

# រដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋខ្មែរ

## បុព្វកថា

**យើងប្រជារាស្ត្រខ្មែរ** ធ្លាប់មានអារ្យធម៌មួយ ក្នុងបណ្ដាអារ្យធម៌ល្បីល្បាញ ហើយចាស់ជាងគេក្នុងពិភពលោក គឺអារ្យធម៌ខ្មែរ-មន បានភប់ប្រទះនូវវិបល្លាសនៃប្រវត្តិ-សាស្ត្រយើង ដែលនាំមកនូវទុក្ខវេទនាជារឿយៗ តាំងពីសម័យក្រោយអង្គរ រហូតមកទល់នឹងព្រឹត្តិការណ៍នាថ្ងៃទី ១៨ មីនា គ.ស. ១៩៧០។

## ប្ដេជ្ញាចិត្តថា :

- ជំរុញឱ្យវប្បធម៌ជាតិរីកសាយឡើងវិញ ព្រមទាំងប្រកបដោយសន្ទុះមួយថ្មី។

-ប្រកាសជាឧឡារិកថា ប្រកាន់ខ្ជាប់យ៉ាងមុតមាំនូវគោលការណ៍ជាសារវន្ត ដូចដែលមានចែងក្នុងសេចក្ដីថ្លែងប្រកាសជាសាកលនៃសិទ្ធិមនុស្ស។

- ជំរុញឱ្យបានទៅដល់ប្រជាធិបតេយ្យផ្នែកនយោបាយ និង ប្រជាធិបតេយ្យផ្នែកសង្គមដែលត្រូវបំបាត់ឱ្យផុតរលត់នូវអំពើជិះជាន់មនុស្ស អំពើសង្កត់សង្កិននិងអំពើខ្វះអធ្យា-ស្រ័យដើម្បីសំដៅទៅកាន់សុភមង្គលនិងការសម្បូរណ៍សប្បាយរបស់ខ្មែរទាំងអស់គ្នា។

- ការពាររបបសាធារណរដ្ឋយើង ប្រឆាំងនិងគ្រប់ការប៉ុនប៉ងឱ្យមានរាជនិយមឡើងវិញ ហើយប្រឆាំងនឹងការបង្កើតឱ្យមានរបបបុគ្គលនិយមគ្រប់បែបយ៉ាង។

- រក្សាការពារបូរណភាពដែនដីខ្មែរ ឯករាជ្យ និង ឯកភាពជាតិ។

**យើងប្រជារាស្ត្រខ្មែរ**

ជាប់ចិត្តជានិច្ច នឹង ឧត្តមគតិសន្តិភាពរបស់យើង ។

## បព្វាក់សាជាថ្មីនូវ :

- សេចក្តីប្រាថ្នាចង់ឱ្យបានសន្តិភាពឋិតថេរក្នុងលោក

- និងឆន្ទៈចង់ធ្វើសហប្រតិបត្តិការយ៉ាងសកម្មជាមួយគ្រប់ប្រជាជាតិ ដោយពុំប្រកាន់អំពីជាតិសាសន៍ សាសនានិងរបបនយោបាយ ដើម្បីវឌ្ឍនភាព និង សន្តិភាព ។

ក្នុងន័យនេះ យើងប្រកាសនូវបច្ចុប្បន្នរដ្ឋធម្មនុញ្ញ មានសេចក្តីដូចតទៅ :

## ជំពូក ១- បទបញ្ញត្តិជាគ្រឹះ

**មាត្រា ១.-** ប្រទេសកម្ពុជា ជាសាធារណរដ្ឋឯករាជ្យ ប្រជាធិបតេយ្យ ហើយដែលនិយមប្រយោជន៍សង្គម ។ ប្រទេសកម្ពុជាមិនអាចបែងចែកបានទេ។ ប្រទេសកម្ពុជាមាននាមថា « **សាធារណរដ្ឋខ្មែរ** » ។

បាវចនារបស់សាធារណរដ្ឋខ្មែរ គឺ : សេរីភាព សមភាព ភាតរភាព វឌ្ឍនភាព និងសុភមង្គល ។

គោលការណ៍របស់សាធារណរដ្ឋខ្មែរ គឺ : ការគ្រប់គ្រងរបស់ប្រជារាស្ត្រ ដោយប្រជារាស្ត្រ និងដើម្បីប្រយោជន៍ប្រជារាស្ត្រ ។

ទង់ជាតិ ភ្លេងជាតិ និង វលញ្ជករ នៃសាធារណរដ្ឋខ្មែរ ត្រូវកំណត់ក្នុងច្បាប់មួយ ។

**មាត្រា ២.-** ព្រះពុទ្ធសាសនា ជាសាសនាសំរាប់រដ្ឋ ។

សេរីភាពខាងជំនឿ និង ខាងប្រតិបត្តិក្នុងផ្លូវសាសនា ត្រូវមានដោយបរិបូរណ៍។ ការបន្ថយសេរីភាពនេះ នឹងអាចធ្វើបាន លុះតែកិច្ចរក្សារបៀបរៀបរយសាធារណៈតម្រូវឱ្យធ្វើ។

រដ្ឋរ៉ាប់រងនូវសមភាពនៃពលរដ្ឋទាំងអស់ចំពោះមុខច្បាប់ ដោយឥតប្រកាន់ជាតិសាសន៍ដើម ភេទ មតិខាងនយោបាយ ខាងគំនិត ខាងសាសនាឬអំពីលក្ខណៈជីវភាព ឬលក្ខណៈអ្វីដទៃទៀតឡើយ។

ភាសាដែលត្រូវប្រើជាផ្លូវការ គឺ ភាសាខ្មែរ។

**មាត្រា ៣៎** អំណាចគ្រប់យ៉ាងចេញមកពីប្រជារាស្ត្រ។

អំណាចនីតិប្រតិបត្តិ អំណាចនីតិបញ្ញត្តិ និង អំណាចតុលាការ ត្រូវអនុវត្តតាមបទបញ្ញត្តិនៃបច្ចុប្បន្នរដ្ឋធម្មនុញ្ញ។

**មាត្រា ៤៎** ការបង្កើតគណៈបក្សនយោបាយធ្វើបានដោយសេរី ។ ក៏ប៉ុន្តែ រដ្ឋឧបត្ថម្ភនូវការផ្តើមគំនិតទាំងឡាយណា ដែលនាំឱ្យបន្ថយចំនួនគណៈបក្សនយោបាយឆ្ពោះទៅរករបបដែលមានគណៈបក្សតែពីរ។

## ជំពូក ២- សិទ្ធិនិងករណីយកិច្ច នៃ ពលរដ្ឋ

**មាត្រា ៥៎** ការប្រើសេរីភាពផ្ទាល់ខ្លួន របស់បុគ្គលម្នាក់ ៗ មិនត្រូវឱ្យប៉ះសិទ្ធិអ្នកដទៃ ការប្រើសេរីភាពនេះត្រូវប្រព្រឹត្តតាមលក្ខខ័ណ្ឌកំណត់ក្នុងច្បាប់។

**មាត្រា៦៎** រដ្ឋរ៉ាប់រងពុំឱ្យមានការរំលោភបំពានលើរូបកាយនៃបុគ្គលណាមួយឡើយ។

រដ្ឋការពារកិត្តិយស សេចក្ដីថ្លៃថ្នូរ និងជីវភាពឯកជនរបស់ពលរដ្ឋទាំងពួង ។

ការចោទប្រកាន់ ការចាប់ចងឬការឃុំឃាំងជនណាមួយនឹងអាចធ្វើទៅកើត លុះត្រាតែច្បាប់អនុញ្ញាត ។

ការបង្ខិតបង្ខំ ការធ្វើបាបលើរាងកាយឬប្រព្រឹត្តិកម្មណាមួយ ដែលបន្ថែមទម្ងន់ទណ្ឌកម្ម អនុវត្តចំពោះជនជាប់ឃុំឃាំង ឬជាប់ពន្ធនាគារ ត្រូវហាមមិនឱ្យធ្វើទេ ។ អ្នកដៃដល់ អ្នករួមប្រព្រឹត្តនិងអ្នកសមគំនិត ត្រូវទទួលទោសតាមច្បាប់ ។

ការទទួលសារភាពកើតឡើងពីការបង្ខំ ដោយឃោរឃៅតាមផ្លូវកាយក្ដី តាមផ្លូវចិត្តក្ដី មិនត្រូវទុកជាភស្តុតាង នៃ ពិរុទ្ធភាពទេ ។

បើបទល្មើសគ្រាន់តែមានវិមុតិសង្ស័យ ជនត្រូវចោទ ត្រូវឱ្យបានរួចខ្លួន ។

ជនជាប់ពិរុទ្ធណាក៏ដោយ ត្រូវទុកជាមនុស្សឥតទោស រហូតដល់ពេលកាត់ទោសជាស្ថាពរ ។

រដ្ឋរ៉ាប់រងចំពោះពលរដ្ឋទាំងអស់នូវសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ ។

ទោសប្រហារជីវិតត្រូវបំបាត់ចោលរៀវលែងតែក្នុងករណី ដែលប្រជាជាតិត្រូវប្រកាសថា ឋិតនៅក្នុងភយន្តរាយ ។ ក្នុងករណីណាក៏ដោយការប្រហារជីវិតមនុស្សដោយគ្មានកាត់សេចក្ដីមិនអាចប្រព្រឹត្តបានឡើយ ។

**មាត្រា ៧ ~** ពលរដ្ឋរាល់រូបមានសេរីភាពសំដែងគំនិតរបស់ខ្លួនតាមវាចា តាមលាយល័ក្ខអក្សរឬតាមមធ្យោបាយសំរាប់ផ្សាយដទៃទៀត ។ ក៏ប៉ុន្តែ ពលរដ្ឋត្រូវចៀសវាងកុំប្រើសិទ្ធិនេះ ដោយរំលោភហើយនិងកុំធ្វើឱ្យខូចរបៀបរៀបរយសាធារណៈ ។

ការប្រើសេរីភាពសារពត៌មានមិនត្រូវប៉ះពាល់កិត្តិយសបុគ្គល សន្តិសុខជាតិ ឬ ទំនៀមទំលាប់ល្អទេ ។ របបសារពត៌មានត្រូវរៀបចំឡើងដោយច្បាប់មួយ ។

**មាត្រា ៨.** សេរីភាពរួបរួមជាសមាគម និងសិទ្ធិរួមប្រជុំត្រូវបានរដ្ឋទទួលស្គាល់ចំពោះពលរដ្ឋទាំងអស់ ។ ការប្រើសេរីភាពនិងសិទ្ធិខាងលើនេះ នឹង បន្ថយទៅបាន លុះត្រាតែមានភ័ស្តុតាងថាមានការប៉ះពាល់ដល់សេរីភាពទាំងឡាយ ដែលបច្ចុប្បន្នរដ្ឋធម្មនុញ្ញបានធានាអះអាង ។

**មាត្រា ៩.** រដ្ឋរ៉ាប់រងចំពោះពលរដ្ឋទាំងអស់នូវការប្រើសិទ្ធិនយោបាយរបស់ខ្លួនដោយសេរី ជាអាទិ សិទ្ធិប្តឹងតវ៉ា ឬ សិទ្ធិប្រឆាំងជាសាធារណៈ ឱ្យតែការប្រើសិទ្ធិទាំងនេះធ្វើទៅដោយអហឹង្សា ហើយក្នុងទម្រង់ច្បាប់ផង ។

**មាត្រា ១០.** អ្នកមានសិទ្ធិបោះឆ្នោត គឺពលរដ្ឋទាំងពីរភេទ ដែលមានអាយុពី ១៨ ឆ្នាំ ទៅ ។

បទបញ្ញត្តិបន្ថយសិទ្ធិបោះឆ្នោត ត្រូវចែងក្នុងច្បាប់បោះឆ្នោត ។

**មាត្រា ១១.** ទីលំនៅមិនអាចនរណារំលោភបានជាដាច់ខាត វៀរលែងតែក្នុងករណី ដែលមានចែងក្នុងច្បាប់ ។

**មាត្រា ១២.** សេរីភាពក្នុងការសរសេរលិខិតឆ្លើយឆ្លង លក្ខណៈអាថិកំបាំងនៃលិខិតព្រមទាំងការទាក់ទងឆ្លងឆ្លើយតាមរបៀបដទៃទៀត មិនអាចនរណារំលោភបានជាដាច់ខាតលុះណាតែមានច្បាប់ចែងខុសពីនេះ ហើយសំរាប់តែមួងម្កាល ដោយហេតុឧត្តមប្រយោជន៍នៃប្រទេសជាតិតម្រូវឱ្យធ្វើ ។

**មាត្រា ១៣.** ការនិរទេស និងការដកសញ្ជាតិខ្មែរ ដោយហេតុនយោបាយ ត្រូវហាមប្រាម ។

**មាត្រា ១៤.** រដ្ឋទទួលស្គាល់ ហើយធានាអះអាងនូវកម្មសិទ្ធឯកជន ។ រដ្ឋជួយសំរួលឱ្យពលរដ្ឋបានជាម្ចាស់កម្មសិទ្ធិ ។

ការប៉ះពាល់កម្មសិទ្ធិត្រូវហាមមិនឱ្យមាន វៀរលែងតែប្រយោជន៍សាធារណៈតម្រូវឱ្យធ្វើក្នុងករណីដែលមានចែងក្នុងច្បាប់ ។ ក្នុងន័យនេះម្ចាស់កម្មសិទ្ធិ មានសិទ្ធិទទួលបំណាច់ជាមុនដោយត្រឹមត្រូវនិងសមរម្យ ។

**មាត្រា ១៥.** រដ្ឋត្រូវយកចិត្តទុកដាក់ ធ្វើឱ្យការរស់នៅ របស់ប្រភេទពលរដ្ឋដែលក្រខ្សត់ជាងគេ មានការចំរើនជាងមុនក្នុងបំណងរ៉ាប់រង ឱ្យជនជំពូកនេះមានឋានៈជីវភាពសមនឹងសេចក្តីថ្លៃថ្នូរនៃមនុស្ស ។

ពលរដ្ឋដែលត្រូវទទួលស្គាល់ថា ពិការធ្វើការមិនកើត ហើយគ្មានមធ្យោបាយចិញ្ចឹមជីវិតមានសិទ្ធិទទួលប្រជាសង្គ្រោះ ។

**មាត្រា ១៦.** រដ្ឋការពារសេរីភាពខាងសិល្បៈកម្ម ខាងកសិកម្ម ខាងពាណិជ្ជកម្ម និងឧស្សាហកម្ម ។

រដ្ឋមានករណីយកិច្ចដើម្បីសម្របសម្រួល សេដ្ឋកិច្ចជាតិសំដៅទៅរកប្រយោជន៍សង្គម និង ដើម្បីរារាំងមិនឱ្យមានការផ្តាច់មុខ ឬការប៉ុនប៉ងផ្តាច់មុខ ក្នុងពាណិជ្ជកម្ម ឬ ឧស្សាហកម្ម ។

**មាត្រា ១៧.** រដ្ឋត្រូវខិតខំបង្កើតការងារ និងមុខរបរឱ្យពលរដ្ឋគ្រប់គ្នា ។ ពលរដ្ឋរាល់រូបអាចសុំចូលធ្វើការបានដោយសេរី ។ ក្នុងការជ្រើសរើសឱ្យចូលធ្វើការមិនត្រូវគិតពីលក្ខខ័ណ្ឌ

អ្វី ក្រៅពីគុណូបការៈ ឬសមត្ថភាពផ្ទាល់ខ្លួនឡើយ ។

ពលរដ្ឋរាល់រូបមានសិទ្ធិទទួលការរ៉ាប់រងនិងអត្ថប្រយោជន៍ខាងសង្គមកិច្ច ដែលមានចែងក្នុងច្បាប់ ។

សេរីភាពខាងសហជីព ត្រូវប្រព្រឹត្តតាមលក្ខខ័ណ្ឌដែលកំរិតក្នុងច្បាប់ ។

**មាត្រា ១៨.** រដ្ឋត្រូវខិតខំប្រយុទ្ធបំបាត់ការចងការប្រាក់គ្រប់ប្រភេទ ដែលយកការលើសកំរិតច្បាប់ ។

**មាត្រា ១៩.** រដ្ឋរ៉ាប់រងចំពោះពលរដ្ឋទាំងអស់នូវសិទ្ធិទទួលការអប់រំ ។ ពលរដ្ឋម្នាក់ៗ ត្រូវទទួលការសិក្សាមូលដ្ឋានចាំបាច់ ហើយដោយឥតចេញថ្លៃ ។

រដ្ឋត្រូវជួយជំរុញឱ្យអក្សរសាស្ត្រ វិទ្យាសាស្ត្រសិល្បៈ និងបច្ចេកទេសវិជ្ជារីកចំរើន ។

**មាត្រា ២០.** រដ្ឋទទួលស្គាល់នូវសិទ្ធិឧបត្ថម្ភគ្រួសារ ចំពោះពលរដ្ឋទាំងអស់ ។

**មាត្រា ២១.** ពលរដ្ឋម្នាក់ ៗ មានករណីយកិច្ច ត្រូវគោរពច្បាប់ ការពារមាតុភូមិ និង ជួយរដ្ឋ ។

ពលរដ្ឋម្នាក់ ៗ ត្រូវបំពេញបរិចារកិច្ចខាងទាហានជាកាតព្វកិច្ច ក្នុងលក្ខខ័ណ្ឌដែលមានចែងក្នុងច្បាប់ ។

**មាត្រា ២២.** ការប្រើសិទ្ធិ និង សេរីភាព ធានាអះអាងដោយបច្ចុប្បន្នរដ្ឋធម្មនុញ្ញនៅមាត្រា ៧ - ៨ - ១១ និង ១២ និងអាចផ្អាកបានតែក្នុងករណីដែលមានភាពអាសន្ន មានវិក្រឹតិកាល ឬ បើមានប្រកាសថាប្រជាជាតិស្ថិតក្នុងភយន្តរាយ ឬ ក្នុងភាពសង្គ្រាម ។

ទារុណកម្មដល់រាងកាយនិងអំពើរំលោភផ្សេងៗ នាំឱ្យខូចសិទ្ធិអ្នកដទៃ ខាងភោគទ្រព្យក្តី ខាងផ្លូវចិត្តក្តី មិនអាចធ្វើបានឡើយ ។ អ្នកប្រព្រឹត្តនូវអំពើរំលោភទាំងនោះ ត្រូវ

ទទួលទោសតាមច្បាប់ ។

ទោះជាយ៉ាងណាក៏ដោយ វិធានការផ្អាកសិទ្ធិ និង សេរីភាព ដូចមានចែងក្នុងវាក្យខ័ណ្ឌទីមួយ មិនអាចមានថិរវេលាលើសពីប្រាំមួយខែឡើយ ។ ថិរវេលានេះ អាចបន្តបានក្នុងលក្ខខ័ណ្ឌដូចគ្នា ។

ដល់ផុតថិរវេលាពិសេស ជនណា ដែលយល់ថាខ្លួនបានទទួលការខូចខាតដោយអយុត្តិធម៌ អាចប្តឹងតុលាការមានសមត្ថកិច្ចសុំឱ្យជួសជុល អត្ថវិនាស ដែលខ្លួនជាអ្នករងគ្រោះ ។

## ជំពូក ៣- ប្រធានាធិបតី នៃសាធារណរដ្ឋខ្មែរ

**មាត្រា ២៣.** ប្រធានាធិបតីនៃសាធារណរដ្ឋ ប្រើអំណាចនីតិប្រតិបត្តិ ដែលប្រជារាស្ត្រប្រគល់ជូនលោក ។

**មាត្រា ២៤.** ក្នុងអម្លុងអាណត្តិរបស់លោក ប្រធានាធិបតីនៃសាធារណរដ្ឋ មានអនុប្រធានាធិបតីម្នាក់ជួយធ្វើការ ។ ប្រធានាធិបតីនៃសាធារណរដ្ឋ ខុទ្ទកាល័យប្រតិបត្តិការមួយ និងក្រុមប្រឹក្សាសន្តិសុខមួយ ឯការរៀបចំនិងការប្រព្រឹត្តទៅនៃអង្គការទាំងពីរនេះ ត្រូវកំណត់ក្នុងច្បាប់រៀបចំអង្គការមួយ ។

ប្រធានាធិបតី និង អនុប្រធានាធិបតី នៃសាធារណរដ្ឋ ត្រូវជ្រើសតាំងក្នុងសន្លឹកបញ្ជីជាមួយគ្នា សម្រាប់ប្រាំឆ្នាំដោយវិធីបោះឆ្នោតជាសាកលដោយចំពោះនិងជាសម្ងាត់ ។

មុខងារប្រធានាធិបតី និង អនុប្រធានាធិបតីនៃសាធារណរដ្ឋ មានវិសមិតភាពនិងការកាន់កាប់វិជ្ជាជីវៈឧស្សាហកម្ម និង ពាណិជ្ជកម្ម ហើយនិងមុខងារសាធារណៈដទៃទៀត ឬ និង មុខងារសមាជិករដ្ឋាភិបាល ។

ប្រធានាធិបតី នៃសាធារណរដ្ឋ អាចឈរឈ្មោះឱ្យគេជ្រើសតាំងសាជាថ្មីបានតែម្តងប៉ុណ្ណោះ ។

**មាត្រា ២៥.** ពលរដ្ឋខ្មែរទាំងពីរភេទ អាចឈរឈ្មោះជាបេក្ខជនប្រធានាធិបតី ឬ អនុប្រធានាធិបតីនៃសាធារណរដ្ឋបាន កាលណាបានបំពេញលក្ខខ័ណ្ឌដូចតទៅនេះ :

**ក.** មានសញ្ជាតិជាខ្មែរ តាំងពីកំណើតរហូតមក

**គ.** កើតពីមាតាបិតា មានសញ្ជាតិជាខ្មែរ

**ខ.** មានសហពទ្ធសញ្ជាតិជាខ្មែរពីកំណើត បើសាមីខ្លួនភរិយា ឬ ស្វាមីពេញច្បាប់

**ឃ.** មានអាយុយ៉ាងតិច សែសិបឆ្នាំ មកទល់ថ្ងៃបោះឆ្នោត

**ខ.** ជាអ្នកមានសិទ្ធិបោះឆ្នោតហើយប្រកបលក្ខខ័ណ្ឌដទៃទៀត ដែលមានចែងក្នុងច្បាប់ រៀបអង្គការ ។

**មាត្រា ២៦.** បេក្ខជននៃសន្លឹកបញ្ជីណា ដែលបានទទួលភាគច្រើនដាច់ខាតនៃសន្លឹកឆ្នោត សំដែងមតិ ត្រូវបានប្រកាសជាប្រធានាធិបតី និងអនុប្រធានាធិបតី នៃសាធារណរដ្ឋ ។

ក្នុងករណីដែលពុំបានភាគច្រើនដាច់ខាត នោះនិងមានចាត់ការបោះឆ្នោតលើកទីពីរ នៅថ្ងៃទីប្រាំពីរ រាប់ពីថ្ងៃបន្ទាប់ថ្ងៃបោះឆ្នោតលើកទីមួយ ។

នៅពេលបោះឆ្នោតលើកទីពីរ មានតែបេក្ខជននៃសន្លឹកបញ្ជីពីរ ដែលបានទទួលឆ្នោតច្រើនជាងគេ នាលើកទីមួយទេ ដែលអាចឈរឈ្មោះបាន ។

ក្នុងការបោះឆ្នោតលើកទីពីរ បេក្ខជននៃសន្លឹកឆ្នោតណា ដែលបានទទួលឆ្នោតច្រើនជាងគេ ត្រូវជ្រើសតាំងជាប្រធានាធិបតី និង អនុប្រធានាធិបតី។ ក្នុងករណីដែលមានសន្លឹកឆ្នោត មានចំនួនស្មើគ្នា សភាទាំងពីររួមប្រជុំជាសមាជសភា ក្នុងរយៈវេលាប្រាំពីរថ្ងៃ ដើម្បីបោះឆ្នោតជ្រើសរើសប្រធានាធិបតី និង អនុប្រធានាធិបតីនៃសាធារណរដ្ឋក្នុងសន្លឹកបញ្ជីមួយក្នុងចំណោមសន្លឹកបញ្ជីទាំងពីរខាងលើ ដោយយកតាមមតិភាគច្រើនដោយប្រៀប។

**មាត្រា ២៧.** ការចាត់ចែងបោះឆ្នោតជ្រើសរើសប្រធានាធិបតី និង អនុប្រធានាធិបតី នៃសាធារណរដ្ឋ ត្រូវធ្វើក្នុងម្ភៃថ្ងៃយ៉ាងតិច និងសែសិបថ្ងៃយ៉ាងយូរ មុនពេលផុតអាណត្តិប្រធានាធិបតីក្នុងតំណែង។

ក្នុងករណីបោះឆ្នោតមិនកើត ដោយហេតុមានសង្គ្រាម ឬអសន្តិសុខខ្លាំង អាណត្តិប្រធានាធិបតី និង អនុប្រធានាធិបតី នៃសាធារណរដ្ឋ អាចបន្តបានម្តងមួយឆ្នាំៗ។ ការពិនិត្យពិច័យអំពីភាពបោះឆ្នោតមិនកើត ព្រមទាំងការបន្តអាណត្តិនេះ ត្រូវសម្រេចដោយសភាទាំងពីររួមប្រជុំជាសមាជសភា បោះឆ្នោតយកមតិភាគច្រើនដាច់ខាតនៃសមាជិកសមាជសភា បន្ទាប់ពីបានពិគ្រោះនឹងតុលាការធម្មនុញ្ញ។

**មាត្រា ២៨.** ច្បាប់រៀបចំអង្គការមួយ ត្រូវកំរិតបែបបទ ជ្រើសតាំងប្រធានាធិបតី និង អនុប្រធានាធិបតី នៃសាធារណរដ្ឋ។

**មាត្រា ២៩.** មុខងារប្រធានាធិបតី និង អនុប្រធានាធិបតី ចាប់ផ្តើមនៅថ្ងៃថ្លែងសច្ចាប្រណិធាន។ មុខងារនេះ ត្រូវផុតនៅម៉ោងដប់ពីរថ្ងៃត្រង់ នាថ្ងៃទី ១៨ ខែ មីនា បន្ទាប់ពីពេលផុតរយៈប្រាំឆ្នាំបន្តបន្ទាប់គ្នារាប់ពីពេលជាប់ឆ្នោត។

មុនចូលកាន់តំណែង ប្រធានាធិបតីនៃសាធារណរដ្ឋ ថ្លែងសច្ចាប្រណិធាននៅចំពោះមុខប្រជារាស្ត្រ ដោយមានសមាជិកអង្គការរដ្ឋនានារួបរួមផង ជាសេចក្តីដូចតទៅ :

«ខ្ញុំតាំងសច្ចាជាឧឡារិក ចំពោះមុខប្រជារាស្ត្រថា ខ្ញុំនឹងការពារមាតុភូមិ បំពេញដោយស្មោះស្ម័គ្រ នូវភារៈប្រធានាធិបតីសាធារណរដ្ឋខ្មែរ គោរពធម្មនុញ្ញ ហើយបូជាខ្លួនខ្ញុំទាំងស្រុង ដើម្បីប្រយោជន៍ប្រជារាស្ត្រ និង ប្រជាជាតិ» ។

**មាត្រា ៣០.** ក្នុងករណីដែលប្រធានាធិបតីនៃសាធារណរដ្ឋ មានធុរៈម្តងម្កាល មុខងារប្រធានាធិបតី វៀរលែងតែមុខងារដែលមានចែងនៅមាត្រា ៣៦ - ៣៧ - ៣៨ - ៤១ និង ៤២ ចេញ ត្រូវអនុប្រធានាធិបតីនៃសាធារណរដ្ឋ កាន់កាប់ជំនួស ។

**មាត្រា ៣១.** ក្នុងករណីដែលតំណែងប្រធានាធិបតី នៃសាធារណរដ្ឋទំនេរជាស្ថាពរ ទោះមកពីហេតុអ្វីក៏ដោយ ឬ ក្នុងករណីដែលមានការរារាំងជាស្ថាពរ ដែលតុលាការធម្មនុញ្ញបានប្រកាសយកតាមមតិភាគច្រើនដាច់ខាតនៃសមាជិកខ្លួន អនុប្រធានាធិបតីជំនួសប្រធានាធិបតី ដោយទទួលអំណាចទាំងអស់របស់ប្រធានាធិបតី ។

ប៉ុន្តែ បើករណីនេះកើតឡើងជាងដប់ពីរខែ មុនពេលផុតអាណត្តិធម្មតា នោះនឹងត្រូវរៀបចំ ក្នុងរយៈពេលពីរខែយ៉ាងតិច និង បីខែយ៉ាងយូរ ឱ្យមានការបោះឆ្នោតជ្រើសរើសប្រធានាធិបតី និង អនុប្រធានាធិបតីសំរាប់អាណត្តិមួយថ្មី ។

**មាត្រា ៣២.** ក្នុងករណីដែលដោយហេតុដូចគ្នា នឹង ហេតុដែលមានចែងនៅមាត្រា ៣១ វាក្យខ័ណ្ឌទីមួយ អនុប្រធានាធិបតីពុំអាចកាន់កាប់មុខងារប្រធានាធិបតីនៃសាធារណរដ្ឋបាន មុខងារនេះ ត្រូវធ្លាក់ទៅលើប្រធានព្រឹទ្ធសភា ។ ប្រធានព្រឹទ្ធសភាត្រូវ

បង្គាប់ឱ្យមានការបោះឆ្នោតជ្រើសរើសប្រធានាធិបតី ក្នុងរយៈវេលាពីរខែយ៉ាងតិច ហើយបីខែយ៉ាងយូរ ។

ក្នុងរយៈពេលនេះ មិនឱ្យមានការរំលំរដ្ឋាភិបាល ឬមានការសើរើសមាសភាពនៃរដ្ឋាភិបាលទេ ហើយសភាជាតិ ក៏មិនអាចត្រូវរំលាយបានដែរ ។

ក្នុងករណីបោះឆ្នោតមិនកើត ដូចចែងនៅមាត្រា ២៧ វាក្យខ័ណ្ឌទីពីរ ដោយហេតុមានសង្គ្រាម ឬមានអសន្តិសុខខ្លាំង សភាទាំងពីរនៃសហសភា និងក្រុមប្រឹក្សាសេនានុភាព រួមប្រជុំនៅមន្ទីរសភាជាតិ នៅថ្ងៃបន្ទាប់ពីផុតរយៈពេលបីខែ ដែលចែងនៅវាក្យខ័ណ្ឌទីមួយនៃមាត្រានេះ ដើម្បីជ្រើសរើសប្រធានាធិបតីម្នាក់ឱ្យបំពេញបង្គ្រប់រយៈពេលអាណត្តិប្រធានាធិបតីសាមីជន ។

**មាត្រា ៣៣.** ប្រធានាធិបតីនៃសាធារណរដ្ឋ តែងតាំងរដ្ឋមន្ត្រីទីមួយហើយ និងសមាជិករដ្ឋាភិបាល តាមសេចក្តីស្នើពីរដ្ឋមន្ត្រីទីមួយ ។

ប្រធានាធិបតីនៃសាធារណរដ្ឋ អាចបញ្ឈប់សមាជិករដ្ឋាភិបាលមួយរូប១ ឬទាំងអស់គ្នាពីមុខងាររបស់ខ្លួនបាន ។

**មាត្រា ៣៤.** ប្រធានាធិបតីនៃសាធារណរដ្ឋ ដឹកនាំការពិភាក្សានៃគណៈរដ្ឋ-មន្ត្រី។ ក្នុងករណីមានធុរៈ ត្រូវអនុប្រធានាធិបតី ឬ បើអនុប្រធានាធិបតីមានធុរៈដែរនោះ ត្រូវរដ្ឋមន្ត្រីទីមួយបំពេញកិច្ចនេះជំនួស ។

**មាត្រា ៣៥.** ប្រធានាធិបតីនៃសាធារណរដ្ឋប្រកាសឱ្យប្រើច្បាប់ និងចុះហត្ថលេខាលើក្រិត្យ ។

ច្បាប់ដែលសហសភាបានបញ្ចេញមតិយល់ព្រមជាស្ថាពររួចហើយ ត្រូវប្រកាសឱ្យប្រើក្នុងដប់ប្រាំថ្ងៃ បន្ទាប់ពីពេលដែលប្រធានាធិបតីនៃសាធារណរដ្ឋបានទទួលច្បាប់នោះ។ មុនផុតរយៈពេលនេះ ប្រធានាធិបតីអាចសុំឱ្យសហសភាពិភាក្សាសាជាថ្មីនូវច្បាប់ឬមាត្រាខ្លះនៃច្បាប់នោះ។ ការពិភាក្សានេះត្រូវធ្វើក្នុងរយៈពេលម្ភៃថ្ងៃយ៉ាងយូរ។

**មាត្រា ៣៦.** ប្រធានាធិបតីនៃសាធារណរដ្ឋតែងតាំង ក្នុងមុខតំណែងស៊ីវិល និងទាហាន។

អ្នករដ្ឋការ ដែលត្រូវតែងតាំង ដោយមានការយល់ព្រមពីគណៈរដ្ឋមន្ត្រីគឺ ៖

- ឯកអគ្គរដ្ឋទូត និង ប្រេសិតវិសាមញ្ញ។
- សមាជិកនៃក្រុមប្រឹក្សារដ្ឋ។
- អភិបាលខេត្ត។
- ឧត្តមសេនានី។
- សាកលវិទ្យាធិការ។
- នាយករដ្ឋការកណ្តាល។
- ហើយនិងសមាជិកនៃក្រុមប្រឹក្សាសេន្យានុភាព។

មុខតំណែងដទៃទៀត ដែលត្រូវតែងតាំងដោយមានការយល់ព្រមពីគណៈរដ្ឋមន្ត្រីព្រមទាំងលក្ខខ័ណ្ឌដែលប្រធានាធិបតីនៃសាធារណរដ្ឋមានអំណាចតែងតាំងក្នុងនាមរបស់លោកត្រូវមានរៀបរាប់ក្នុងច្បាប់រៀបចំអង្គការមួយ។

**មាត្រា ៣៧.** ប្រធានាធិបតីនៃសាធារណរដ្ឋតាំងឯកអគ្គរដ្ឋទូត និងប្រេសិតវិសាមញ្ញជាតំណាងសាធារណរដ្ឋខ្មែរ នៅប្រទេសក្រៅ។ រីឯ ឯកអគ្គរដ្ឋទូត រាជទូត និងប្រេសិតវិសាមញ្ញបរទេស ត្រូវទទួលភារៈតាំងឱ្យនៅអម ប្រធានាធិបតីនៃសាធារណរដ្ឋ។

**មាត្រា ៣៨.** ប្រធានាធិបតីនៃសាធារណរដ្ឋចុះហត្ថលេខាលើសិទ្ធិសញ្ញា និងអនុសញ្ញាអន្តរជាតិ ហើយឱ្យសច្ចាប័ន លើឯកសារទាំងនេះ ដោយអាស្រ័យការអនុមតិនៃសហសភា។

**មាត្រា ៣៩.** បន្ទាប់ពីបានពិគ្រោះជាមួយប្រធាននៃសភាទាំងពីរ ប្រធានាធិបតីអាចប្រកាសនូវភាពអាសន្ន ឬវិក្រឹតិកាល ក្នុងករណីមានការគំរាមកំហែងធ្ងន់និងជាបន្ទាន់ប៉ះពាល់លើស្ថាប័ននានានៃសាធារណរដ្ឋ ដល់ឯករាជ្យជាតិនិងដល់បូរណភាពទឹកដីនៃសាធារណ-រដ្ឋ។ ប្រធានាធិបតី ត្រូវជូនដំណឹងនេះភ្លាមដល់ប្រជាជាតិតាមសារលិខិត។

ក្នុងរយៈពេលប្រាំពីរថ្ងៃ បន្ទាប់ពីពេលប្រកាសនូវភាពអាសន្ន ឬ វិក្រឹតិកាលនោះ សហសភារួមប្រជុំជាសមាជសភា ដើម្បីឱ្យការយល់ព្រម ឬ កែប្រែវិធានការដែលបានបញ្ញត្តិ ឬ បញ្ចប់វិធានការនោះ។

ក្នុងកម្លុង ពេលពិសេសនេះ សភាជាតិមិនអាចត្រូវរំលាយបានទេ។

**មាត្រា ៤០.** ប្រធានាធិបតីនៃសាធារណរដ្ឋ ជាមេបញ្ជាការជាន់ខ្ពស់បំផុតលើកម្លាំងទ័ពរបស់សាធារណរដ្ឋ។

លោកប្រកាសភាពសង្គ្រាម ឬប្រកាសថា ប្រជាជាតិស្ថិតក្នុងភយន្តរាយ តាមសេចក្តីស្នើពីរដ្ឋាភិបាល ហើយក្រោយដែលមានការយល់ព្រមពីសភាទាំងពីររួមប្រជុំជាសមាជ។

**មាត្រា ៤១.** ប្រធានាធិបតីនៃសាធារណរដ្ឋ ប្រាស្រ័យជាមួយនិងសភាទាំងពីរតាមសារលិខិត ហើយសារលិខិតនេះមិនត្រូវយកមកពិភាក្សាទេ។ ប្រសិនបើសភាស្ថិតនៅក្នុងវិស្សមកាល សហសភាត្រូវរួមប្រជុំជាពិសេស ដើម្បីស្ដាប់សារលិខិតនេះ។

**មាត្រា ៤២.** ប្រធានាធិបតីនៃសាធារណរដ្ឋ ជាអ្នកផ្ដល់គ្រឿងឥស្សរិយយសជាតិ។

លោកមានសិទ្ធិលើកលែង និងបន្ធូរបន្ថយទោស។

## ជំពូក ៤- រដ្ឋាភិបាល

**មាត្រា ៤៣.** រដ្ឋមន្ត្រីទីមួយ និង សមាជិករដ្ឋាភិបាលទទួលខុសត្រូវចំពោះប្រធានាធិបតី នៃសាធារណរដ្ឋ ពីកិច្ចចាត់ការអនុវត្តន៍នយោបាយរបស់រដ្ឋឱ្យបានសម្រេច។

រដ្ឋមន្ត្រីទីមួយដឹកនាំរដ្ឋាភិបាល និង អង្គការជាតិនានា។

**មាត្រា ៤៤.** មុខងារនៃសមាជិករដ្ឋាភិបាលមានវិសមិតភាព នឹងការកាន់កាប់វិជ្ជាជីវៈផ្នែកពាណិជ្ជកម្ម ឬ ឧស្សាហកម្ម ហើយនិងការកាន់កាប់តំណែងក្នុងអង្គការសាធារណៈណាមួយ។

**មាត្រា ៤៥.** សមាជិករដ្ឋាភិបាលអាចចូលរួមក្នុងពេលប្រជុំសភាជាតិ និងព្រឹទ្ធសភា ហើយនិងក្នុងពេលប្រជុំគណៈកម្មការនានានៃសភា។ បើសមាជិករដ្ឋាភិបាលសុំនិយាយ ត្រូវតែបើកឱកាសឱ្យនិយាយ វៀរលែងតែក្នុងពេលប្រជុំ ដើម្បីបោះឆ្នោតសម្រេចអំពីអនុសាសន៍ប៉ះពាល់ដល់ជោគវាសនា នៃរដ្ឋាភិបាលទាំងមូល ឬ មួយភាគ។

## ជំពូក ៥- សហសភា

**មាត្រា ៤៦.** សហសភា មានសភាពីរ គឺសភាជាតិ និង ព្រឹទ្ធសភា។

**មាត្រា ៤៧.** សភាជាតិ មានសមាជិកចំនួនប៉ែតសិបនាក់យ៉ាងតិច។

តំណាងរាស្ត្រត្រូវជ្រើសតាំងដោយការបោះឆ្នោតជាសាកល ដោយចំពោះ ជាសម្ងាត់ និង ដោយសន្លឹកឆ្នោតមួយមាននាមតែមួយ សំរាប់អាណត្តិបួនឆ្នាំ។ តំណាងរាស្ត្រអាចឈរឈ្មោះឱ្យគេជ្រើសតាំងសាជាថ្មីបាន។

អ្នកមានសិទ្ធិឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្រ គឺពលរដ្ឋមានសិទ្ធិបោះឆ្នោតទាំងពីរភេទ ដែលមានអាយុយ៉ាងតិចម្ភៃប្រាំឆ្នាំគត់មកទល់ថ្ងៃបោះឆ្នោត។

**មាត្រា ៤៨.** ព្រឹទ្ធសភាមានសមាជិកចំនួនពីម្ភៃប្រាំបីទៅសែសិបនាក់។ ព្រឹទ្ធ-សភាជាអង្គការតំណាងភូមិភាគផ្សេងៗ នៃសាធារណរដ្ឋ និង អង្គការធំៗ នៃរដ្ឋ។

ភូមិភាគផ្សេងៗ ត្រូវជ្រើសតាំងសមាជិកព្រឹទ្ធសភាចំនួនបីភាគប្រាំ «៣/៥» រដ្ឋការស៊ីវិលត្រូវជ្រើសតាំងសមាជិកព្រឹទ្ធសភាចំនួនមួយភាគប្រាំ «១/៥» ក្រុមប្រឹក្សាសេនានុភាពត្រូវជ្រើសតាំងសមាជិកព្រឹទ្ធសភាចំនួនមួយភាគប្រាំ «១/៥»។

សមាជិកព្រឹទ្ធសភា ត្រូវជ្រើសតាំងសម្រាប់ប្រាំមួយឆ្នាំ ដោយការបោះឆ្នោតជាសាកល ដោយមិនចំពោះ ជាសម្ងាត់ និង ដោយសន្លឹកឆ្នោតមួយមាននាមតែមួយ ក្នុងបណ្ដាអ្នកមានសិទ្ធិបោះឆ្នោតទាំងពីរភេទ ដែលមានអាយុយ៉ាងតិចសែសិបឆ្នាំគត់មកទល់ថ្ងៃបោះ-ឆ្នោត។ សមាជិកព្រឹទ្ធសភាអាចឈរឈ្មោះឱ្យគេជ្រើសតាំងសាជាថ្មីបាន។

សមាជិកព្រឹទ្ធសភាចំនួនពាក់កណ្ដាលត្រូវផ្លាស់ថ្មីក្នុងរយៈពេលបីឆ្នាំម្ដងៗ។ មុនផុត

ឆ្នាំទីបីនៃនីតិកាលទីមួយត្រូវមានការចាប់ឆ្នោត ដើម្បីរកសមាជិកព្រឹទ្ធសភា ដែលត្រូវផុត អាណត្តិមុនគេ។

**មាត្រា ៤៩.** ក្នុងពេលមានសង្គ្រាម ឬមានអសន្តិសុខខ្លាំង សមាជិកសហសភាអាច ត្រូវជ្រើសតាំងដោយការបោះឆ្នោតជាសាកល ដោយចំពោះ ជាសម្ងាត់ និង ដោយសន្លឹកបញ្ជី។

ក្នុងករណីដែលការបោះឆ្នោតមិនអាចធ្វើទៅកើត ប្រធានាធិបតីនៃសាធារណរដ្ឋអាច ពន្យារអាណត្តិសមាជិកសហសភាបានម្តងមួយឆ្នាំ ម្តងមួយឆ្នាំ។

ក្នុងករណីទាំងពីរខាងលើត្រូវពិគ្រោះជាមុន នឹង តុលាការធម្មនុញ្ញ។

**មាត្រា ៥០.** អាណត្តិសមាជិកសហសភាមានវិសមិតភាព នឹងការបំពេញមុខងារ សាធារណៈជាសកម្ម។

សមាជិកសហសភាម្នាក់ៗ មិនអាចបំពេញមុខងារជាសមាជិកនៃស្ថាប័នដទៃទៀត របស់សាធារណរដ្ឋ ដែលមានចែងក្នុងធម្មនុញ្ញ វៀរលែងតែមុខងារសមាជិកនៃតុលាការជាន់ ខ្ពស់ចេញ។

**មាត្រា ៥១.** ច្បាប់បោះឆ្នោត ត្រូវកំរិតបែបបទនៃការជ្រើសតាំងតំណាងរាស្ត្រ និង សមាជិកព្រឹទ្ធសភា។

**មាត្រា ៥២.** អំណាចនៃសភានីមួយៗ ចប់ត្រឹមពេលសភាថ្មីចូលកាន់តំណែង។

ក្នុងករណីមានសមាជិកសហសភា ទទួលអនិច្ចកម្ម លាលែង ប្រាសចាកសមាជិកភាព ដែលកើតមានឡើងប្រាំមួយខែ មុនចប់នីតិកាល ត្រូវចាត់ការជ្រើសតាំងជំនួសសមាជិកនោះ។

**មាត្រា ៥៣.** មុននឹងចាប់ផ្តើមធ្វើការ សភានីមួយៗ ត្រូវធ្វើសុពលកម្មសមាជិករបស់ខ្លួនណា ដែលគ្មានការតវ៉ាជំទាស់ ។

មុនចូលកាន់តំណែង សមាជិកសភានីមួយៗ ដែលបានទទួលសុពលកម្មរួចហើយត្រូវថ្លែងសច្ចាប្រណិធាន នៅចំពោះមុខប្រធានាធិបតីនៃសាធារណរដ្ឋ ហើយដោយមានតុលាការធម្មនុញ្ញរួមជាមួយផង ជាសេចក្តីថា :

«ខ្ញុំតាំងសច្ចាជាឧឡារិកថា នឹងគោរពរដ្ឋធម្មនុញ្ញ ហើយខិតខំប្រើកម្លាំងរបស់ខ្ញុំទាំងប៉ុន្មាន ដើម្បីបំពេញកិច្ចការជាប្រយោជន៍ប្រជារាស្ត្រ និងប្រជាជាតិ» ។

**មាត្រា ៥៤.** សមាជិកសបាសភាណាក៏ដោយ មិនអាចត្រូវគេចោទប្រកាន់តាមរកខ្លួន ចាប់ចង ឃុំឃាំង ឬ កាត់ទោសដោយហេតុថា បានសំដែងយោបល់ ឬបញ្ចេញមតិក្នុងការបំពេញមុខងាររបស់ខ្លួន។

សមាជិកសភាណាក៏ដោយ នឹងអាចត្រូវគេចោទប្រកាន់ ឬ ចាប់ចងអំពីបទឧក្រិដ្ឋ ឬបទមជ្ឈិមបាន លុះណាតែមានអនុញ្ញាតពីសភាដែលខ្លួនជាសមាជិក វៀរលែងតែក្នុងករណីបានប្រព្រឹត្តបទល្មើសជាក់ស្តែងចេញ។

ក្នុងករណីទាំងអស់ ការឃុំឃាំង ឬ ការចោទប្រកាន់សមាជិកសបាសភាណាមួយត្រូវផ្អាក ប្រសិនបើជាមានសមាជិកបីភាគបួន «៣/៤» នៃសភាដែលខ្លួនជាសមាជិកបានបញ្ចេញមតិសុំឱ្យផ្អាក។

**មាត្រា ៥៥.** អាណត្តិដាច់ខាតយ៉ាងណាក៏ដោយត្រូវទុកជាមោឃៈ។ សិទ្ធិបោះឆ្នោតបញ្ចេញមតិ ជាសិទ្ធិរបស់សមាជិកសបាសភាផ្ទាល់ សំរាប់តែខ្លួនឯងម្នាក់។

**មាត្រា ៥៦.** ក្នុងថិរវេលានៃអាណត្តិរបស់ខ្លួន សមាជិកសហសភា ដែលត្រូវទទួលទណ្ឌកម្ម ជាហេតុបណ្តាលឱ្យឈរឈ្មោះជាបេក្ខជនពុំបាន ត្រូវបាត់បង់ឋានៈជាសមាជិក ។

ការបាត់បង់ឋានៈជាសមាជិក ត្រូវប្រកាសសម្រេចដោយសភា ដែលសាមីខ្លួននោះជាសមាជិក ។

**មាត្រា ៥៧.** សហសភាប្រជុំដោយពេញច្បាប់ ជាសម័យប្រជុំសាមញ្ញពីរដងក្នុងមួយឆ្នាំ។ សម័យប្រជុំនិមួយ ៗ មានថិរវេលាយ៉ាងតិចបីខែ ។

ប្រធានាធិបតីសាធារណរដ្ឋ កោះសហសភាប្រជុំជាវិសាមញ្ញ តាមសេចក្តីសុំពីរដ្ឋមន្ត្រីទីមួយ ឬ ពីភាគច្រើននៃសមាជិកទាំងអស់របស់សភាជាតិ ឬ របស់ព្រឹទ្ធសភា ។

របៀបវារៈត្រូវកំណត់ជាក់លាក់ព្រមទាំងថ្ងៃប្រជុំ ហើយត្រូវផ្សាយជាមួយគ្នាក្នុងសេចក្តីអញ្ជើញប្រជុំ ។

សម័យប្រជុំសហសភាត្រូវធ្វើនៅរដ្ឋធានីសាធារណរដ្ឋខ្មែរ ហើយសម័យប្រជុំសភានិមួយៗ នោះ ត្រូវធ្វើក្នុងសាលមួយរៀបចំជាពិសេសសំរាប់កិច្ចនេះ ល្គីកណាតែមានការសំរេចផ្សេងចុះក្នុងលិខិតកោះប្រជុំ ព្រោះកាលៈទេសៈតម្រូវ ។

ក្រៅពីករណីដូចដែលចែងនៅវាក្យខ័ណ្ឌទាំងពួងខាងលើ និង ក្រៅពីកន្លែង និងពីកាលបរិច្ឆេទដែលកំណត់ក្នុងសេចក្តីអញ្ជើញ ការប្រជុំណាក៏ដោយ នៃសភានិមួយៗរបស់សហសភា ត្រូវទុកជាខុសច្បាប់ ហើយជាអសារសូន្យពេញលក្ខណៈ ។

**មាត្រា ៥៨.** ប្រធានសភាជាតិ ត្រូវជ្រើសតាំងសម្រាប់ពីរឆ្នាំ។ ប្រធានព្រឹទ្ធសភាត្រូវជ្រើសតាំងក្រោយពេលបោះឆ្នោតប្តូរចំនួនពាក់កណ្តាលនៃសមាជិកព្រឹទ្ធសភា។ សមាជិក

ក្រុមអភិបាលនៃសភានិមួយ ៗ ត្រូវជ្រើសតាំងនៅពេលជាមួយគ្នានឹងប្រធាន ។

**មាត្រា ៥៩.** ក្នុងករណីដែលត្រូវកោះសភាទាំងពីរប្រជុំរួមជាសមាជសភា កិច្ចប្រជុំត្រូវស្ថិតនៅក្រោមអធិបតីភាពនៃប្រធានសភាជាតិ ។

ក្នុងករណីដែលប្រធានសភាជាតិមានធុរៈ ប្រធានព្រឹទ្ធសភាជាអ្នកដឹកនាំការពិភាក្សា ។

**មាត្រា ៦០.** ការពិភាក្សារបស់សភានិមួយ ៗ នឹងទុកជាបានការ ទាល់តែមានសមាជិកនៃសភានេះចំនួនពីរភាគបី «២/៣» មករួមប្រជុំ ។

ការពិភាក្សានៃសមាជសភា នឹងទុកជាបានការ ទាល់តែតំណាងរាស្ត្រចំនួនពីរភាគបី «២/៣» និងសមាជិកព្រឹទ្ធសភាចំនួនពីរភាគបី «២/៣» មករួមប្រជុំ ។

ក្នុងករណីដែលមិនគ្រប់អង្គប្រជុំ នៅឱកាសកោះប្រជុំជាលើកទីមួយ សភា ឬ សមាជត្រូវកោះប្រជុំជាលើកទីពីរ ហើយអាចពិភាក្សាបានការ ទោះបីមានសមាជិកប៉ុន្មាននាក់មករួមប្រជុំក៏ដោយ ។ ការប្រជុំដែលជាកម្មវត្ថុនៃការកោះប្រជុំជាលើកទីពីរនឹងអាចធ្វើទៅបានតែក្នុងរយៈវេលាម្ភៃបួនម៉ោងយ៉ាងតិច បន្ទាប់ពីការប្រជុំលើកទីមួយ ។

**មាត្រា ៦១.** សហសភាតាំងបទបញ្ជាផ្ទៃក្នុងមួយ ។

**មាត្រា ៦២.** ពេលប្រជុំសភាទាំងពីរ ត្រូវធ្វើជាសាធារណៈ ។

សភានីមួយៗ អាចប្រជុំសម្ងាត់បាន តាមការសុំពីប្រធានសភានោះក្តី ពីសមាជិកចំនួនមួយភាគដប់ «១/១០» យ៉ាងតិចនៃសភានោះក្តី ពីរដ្ឋមន្ត្រីទីមួយក្តី ។

សេចក្តីរាយហេតុទាំងស្រុងនៃការពិភាក្សាក្នុងពេលប្រជុំសាធារណៈ ត្រូវចុះផ្សាយ

ក្នុងរដ្ឋកិច្ច ។

**មាត្រា ៦៣៊** តាមការសុំពីសមាជិកចំនួនមួយភាគដប់ «១/១០» យ៉ាងតិច សភាជាតិ ឬព្រឹទ្ធសភាអាចអញ្ជើញឥស្សរជនដ៏ឧត្ដមណាម្នាក់មកបំភ្លឺសភាអំពីបញ្ហាដែលមានសារៈសំខាន់ពិសេស ។

**មាត្រា ៦៤៊** សហសភា អនុមតិ ច្បាប់ ។

សហសភា អនុមតិថវិការដ្ឋ ការឱ្យរដ្ឋខ្ចីប្រាក់ ការខ្ចីប្រាក់របស់រដ្ឋ។ សហសភាឱ្យសេចក្តីយល់ព្រមចំពោះគណនីរដ្ឋបាល បន្ទាប់ពីបានយោបល់ពីក្រុមប្រឹក្សារដ្ឋ ។

សហសភា អនុមតិច្បាប់លើកលែងទោស ។

សហសភា អនុមតិច្បាប់ដែលប្រកាសថា ប្រជាជាតិឋិតនៅក្នុងភយន្តរាយ ឬ ក្នុងភាពសង្គ្រាម ។

## ជំពូក ៦- ការទាក់ទងរវាងសហសភា និងរដ្ឋាភិបាល

**មាត្រា ៦៥៊** ច្បាប់គឺជាការសំដែងនៃឆន្ទៈជាតិ ។

វិស័យរបស់ច្បាប់ត្រូវកំណត់ក្នុងច្បាប់រៀបចំអង្គការមួយ

**មាត្រា ៦៦៊** អ្នកផ្ដើមគំនិតបង្កើតច្បាប់គឺរដ្ឋាភិបាលក៏បាន សមាជិកសហសភាក៏បាន ។ ក៏ប៉ុន្តែការផ្ដើមគំនិតខាងចំណាយសំរាប់បុគ្គលិក ជាភារៈឯកឯងនៃរដ្ឋាភិបាល ។

**មាត្រា ៦៧៊** សេចក្តីព្រាងច្បាប់ត្រូវពិភាក្សាក្នុងគណៈរដ្ឋមន្ត្រី ក្រោយពីបានទទួលយោបល់ពីក្រុមប្រឹក្សារដ្ឋ ។

សេចក្តីព្រាងច្បាប់អាចដាក់ជូនទៅក្រុមអភិបាលសភាណាក៏បាន លើកលែងតែសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុ ដែលត្រូវដាក់ជូនសភាជាតិជាមុនគេ។

**មាត្រា ៦៨.** សមាជិកសហសភាមិនអាចធ្វើសេចក្តីស្នើច្បាប់ ឬ ធ្វើវិសោធនកម្មណាមួយ ដែលការអនុមតិនាំឱ្យមានការបន្ថយធនធានសាធារណៈក្តី នាំឱ្យបង្កើត ឬ បន្ថែមបន្ទុកសាធារណៈក្តី។

**មាត្រា ៦៩.** សេចក្តីព្រាងច្បាប់ ឬ សេចក្តីស្នើច្បាប់ណាក៏ដោយ ត្រូវពិនិត្យជាបន្តបន្ទាប់គ្នាពីសភាមួយទៅសភាមួយ។

ក្នុងករណីមានទំនាស់រវាងសភាទាំងពីរ សេចក្តីព្រាងច្បាប់ ឬ សេចក្តីស្នើច្បាប់ត្រូវដាក់ជូន ដប់ថ្ងៃក្រោយមកទៅសមាជសភា ដើម្បីបញ្ចេញមតិជាស្ថាពរ លើចំណុចមិនយល់ស្របគ្នា ដោយយកតាមសម្លេងភាគច្រើន។ ក្នុងករណីប្រញាប់រយៈវេលាដាក់ជូនសមាជសភាត្រូវបន្ថយមកត្រឹមប្រាំថ្ងៃ។

**មាត្រា ៧០.** សេចក្តីព្រាងហិរញ្ញប្បញ្ញត្តិ ត្រូវដាក់ជូនក្រុមអភិបាលសភាជាតិមួយរយ «១០០» ថ្ងៃយ៉ាងតិច មុនដំណាច់ឆ្នាំសារពើពន្ធ ដែលកំពុងប្រព្រឹត្ត។

ក្នុងករណីដែលសហសភាមិនបានអនុមតិជាស្ថាពរមុនដើមឆ្នាំសារពើពន្ធនូវសេចក្តីព្រាងច្បាប់សំរាប់ឆ្នាំនោះ រដ្ឋាភិបាលត្រូវសុំដោយរួសរាន់ ឱ្យសហសភាអនុញ្ញាតការទារពន្ធតាមច្បាប់ជាធរមាន។ នៅពេលជាមួយគ្នា ប្រធានាធិបតីនៃសាធារណរដ្ឋចេញក្រិត្យបើកឱ្យប្រើឥណទានម្តងមួយខែស្មើនឹងមួយភាគដប់ពីរ «១/១២» នៃថវិកាការិយបរិច្ឆេទឆ្នាំមុនរហូតដល់សហសភាអនុមតិហិរញ្ញប្បញ្ញត្តិជាស្ថាពរ។

**មាត្រា ៧១.** អត្ថបទទាំងច្បាប់ដែលសភាមួយបានកែប្រែរួចហើយ ឬ បានអនុមតិហើយ ត្រូវបញ្ជូនទៅសភាមួយទៀតក្នុងរយៈវេលាដប់ថ្ងៃគត់។

អត្ថបទច្បាប់ ដែលសហសភាបានអនុមតិជាស្ថាពរ ត្រូវបញ្ជូនទៅប្រធានាធិបតីនៃសាធារណរដ្ឋ ក្នុងរយៈវេលាដប់ថ្ងៃគត់។

ក្នុងករណីការប្រញាប់ រយៈវេលាដែលចែងនៅវាក្យខ័ណ្ឌខាងលើ ត្រូវបន្ថយមកប្រាំថ្ងៃគត់។

**មាត្រា ៧២.** ច្បាប់មិនអាចមានផលប្រតិសកម្មភាពទេ វៀរលែងតែមានបទបញ្ញត្តិពិសេស ដែលមានចែងជាក់លាក់ក្នុងច្បាប់នោះ។

**មាត្រា ៧៣.** ច្បាប់ត្រូវអនុវត្តបាននៅភ្នំពេញកំណត់មួយថ្ងៃគត់ ក្រោយដែលច្បាប់នោះបានចុះក្នុងរដ្ឋកិច្ច ហើយនិងនៅទីកន្លែងណាឯទៀតក៏ដោយ កំណត់ប្រាំថ្ងៃគត់បន្ទាប់ពីពេលដែលរដ្ឋកិច្ចមានចុះច្បាប់នោះ បានទៅដល់សាលាស្រុក។

ក៏ប៉ុន្តែច្បាប់ដែលបានប្រកាសថា ជាការប្រញាប់ ត្រូវអនុវត្តបាននៅភ្នំពេញកាលណាច្បាប់នោះមានបិទនៅសាលាក្រុង ហើយនៅស្រុកនីមួយ ៗ កាលណាមានបិទនៅសាលាស្រុក។

ច្បាប់នីមួយ ៗ ត្រូវមានការផ្សាយឱ្យបានជ្រួតជ្រាបយ៉ាងទូលំទូលាយជាទីបំផុត។ រដ្ឋាភិបាលមានភារៈត្រូវចុះផ្សាយភ្លាមនូវច្បាប់ទាំងអស់ ដែលប្រកាសឱ្យប្រើ។

ច្បាប់មួយត្រូវកំណត់បែបបទនៃការផ្សាយច្បាប់និងបទបញ្ជានានា ហើយនិងការផ្សាយកិច្ចព្រមព្រៀងអន្តរជាតិ។

**មាត្រា ៧៤.** ក្រោយពីបានរៀបចំសមាសភាពរដ្ឋាភិបាលរួចហើយ រដ្ឋមន្ត្រីទីមួយព្រមជាមួយនឹងសមាជិកទាំងអស់នៃគណៈរដ្ឋមន្ត្រី ត្រូវទៅកាន់សមាជសភា ដើម្បីថ្លែងការណ៍ជំរាបនូវកម្មវិធីដែលរដ្ឋាភិបាលប្រុងប្រៀបអនុវត្ត ។

ការជំរាបពីកម្មវិធីនេះ មិនត្រូវយកទៅពិភាក្សាឡើយ ។

**មាត្រា ៧៥.** តាមការសុំពីសមាជិកសភាជាតិចំនួនយ៉ាងតិចមួយភាគប្រាំ «១/៥» សមាជិករដ្ឋាភិបាលត្រូវទៅរ៉ាយរ៉ាប់ជំរាបសភាអំពីការគ្រប់គ្រងក្រសួងរបស់ខ្លួន ។

ការពិភាក្សាតទល់នៅសភាជាតិ ក្រោយពីសមាជិករដ្ឋាភិបាលបានរ៉ាយរ៉ាប់មកអាចនាំឱ្យមានការបោះឆ្នោតអនុមតិនូវអនុសាសន៍ ១ តាមទម្រង់ដែលមានចែងនៅមាត្រា ៧៦, ៧៧ និង ៧៨ ។

**មាត្រា ៧៦.** សភាជាតិសំដែងការមិនទុកចិត្តចំពោះសមាជិករដ្ឋាភិបាលម្នាក់ឬច្រើននាក់ ឬ ចំពោះរដ្ឋាភិបាលទាំងមូល ដោយការបោះឆ្នោតអនុមតិនូវអនុសាសន៍មួយមានចែងហេតុផល ។

សេចក្តីស្នើអនុសាសន៍ណាក៏ដោយ នឹងអាចទទួលបាន លុះណាតែមានសមាជិកសភាជាតិចំនួនមួយភាគប្រាំ «១/៥» យ៉ាងតិចបានធ្វើ ។

ការបោះឆ្នោតអនុមតិអនុសាសន៍ នឹងធ្វើឡើងបានតែក្រោយពេលសែសិបប្រាំបីម៉ោងរាប់ពីពេលដាក់អនុសាសន៍នោះ ។ ការអនុមតិនេះ ត្រូវធ្វើដោយវិធីបោះឆ្នោតចំហរ ។

អនុសាសន៍នឹងទុកជាបានការលុះណាតែភាគច្រើនដាច់ខាតនៃចំនួនសមាជិកសភាជាតិអនុមតិយល់ព្រម ។

**មាត្រា ៧៧.** អនុសាសន៍របស់សភាជាតិ ត្រូវបញ្ជូនក្នុងរយៈពេលបីថ្ងៃគត់ទៅប្រធានាធិបតីនៃសាធារណរដ្ឋដើម្បីសំរេច បើពុំដូច្នោះទេអនុសាសន៍នោះត្រូវទុកជាមោឃៈ ។

ប្រធានាធិបតីនៃសាធារណរដ្ឋ ត្រូវឱ្យដំណឹងអំពីសេចក្តីសំរេចរបស់លោក ដោយបញ្ជាក់ហេតុផលទៅ សភាជាតិក្នុងរយៈវេលាប្រាំថ្ងៃគត់ រាប់ពីថ្ងៃទទួលអនុសាសន៍ ។ បើគ្មានដំណឹងទេ នោះបានន័យថា យល់ព្រមតាមអនុសាសន៍ ។ ក្នុងករណីនេះ សមាជិកម្នាក់ ឬ ច្រើននាក់នៃរដ្ឋាភិបាល ដែលទាក់ទិននឹងរឿងនេះ ឬ រដ្ឋាភិបាលទាំងមូលត្រូវលាលែងដោយបញ្ញត្តិ ។

**មាត្រា ៧៨.** ក្នុងករណីដែលប្រធានាធិបតីនៃសាធារណរដ្ឋ រក្សាទុកសមាជិកម្នាក់ ឬ ច្រើននាក់នៃរដ្ឋាភិបាល ដែលជាប់ប្រកាន់ឱ្យនៅក្នុងតំណែងតទៅទៀត ឬ រដ្ឋាភិបាលទាំងមូលឱ្យនៅដដែលតទៅទៀត សភាជាតិអាចយកអនុសាសន៍មកពិនិត្យជាលើកទីពីរ ក្នុងរយៈវេលាប្រាំថ្ងៃគត់ ដោយមានពាក្យសុំរបស់សមាជិកសភាជាតិចំនួនមួយភាគប្រាំ «១/៥» យ៉ាងតិច ។

អនុសាសន៍នឹងទុកជាបានការ លុះណាតែពីរភាគបី «២/៣» នៃសមាជិកសភាជាតិអនុមតិយល់ព្រម ។

ក្នុងករណីនេះ អនុសាសន៍ត្រូវបណ្តាលឱ្យសមាជិកម្នាក់ ឬ ច្រើននាក់ដែលជាប់ប្រកាន់នេះ ឬ រដ្ឋាភិបាលទាំងមូលលាលែងដោយបញ្ញត្តិ ។

**មាត្រា ៧៩.** បើនៅក្នុងមួយអម្លុងពេលដប់ប្រាំបីខែ មានវិបត្តិគណៈរដ្ឋមន្ត្រីពីរដង ប្រធានាធិបតីនៃសាធារណរដ្ឋអាចរំលាយសភាជាតិបាន បន្ទាប់ពីបានពិគ្រោះជាមួយ

ប្រធានព្រឹទ្ធសភា ។

ដែលហៅថា វិបត្តិគណៈរដ្ឋមន្ត្រីដូចមានចែងនៅវាក្យខ័ណ្ឌទីមួយ គឺការលាលែងរបស់រដ្ឋាភិបាល បន្ទាប់តពីមានអនុសាសន៍របស់សភាជាតិជំទាស់នឹងរដ្ឋាភិបាលទាំងមូល ។

ក្នុងករណីមានការរំលាយសភាជាតិ ការបោះឆ្នោតជាថ្មី ត្រូវឱ្យមានឡើងក្នុងរយៈវេលាពីរខែយ៉ាងយូរ ។

## ជំពូក ៧- អំណាចតុលាការ

**មាត្រា ៨០~** ការកាត់ក្តីផ្តល់យុត្តិធម៌ ត្រូវធ្វើក្នុងនាមប្រជារាស្ត្រតាមនីតិក្រមដែលមានចែងក្នុងច្បាប់ ។

**មាត្រា ៨១~** អំណាចតុលាការ ជាអំណាចប្រកបដោយឥស្សរភាព អំណាចតុលាការរក្សាការពារអនាគតិ ។ អំណាចតុលាការការពារសិទ្ធិ និង សេរីភាព ពលរដ្ឋ។ អំណាចនេះត្រូវប្រគល់ទៅតុលាការកំពូលនិងទៅសាលាជំរះក្តីគ្រប់ជាន់ថ្នាក់ ។

**មាត្រា ៨២~** ច្បាប់រៀបចំអង្គការមួយ កំណត់ ការរៀបចំនិង ការប្រព្រឹត្តទៅនៃអំណាចតុលាការ ។

### ១~ ក្រុមចៅក្រម

**មាត្រា ៨៣~** ចៅក្រមជំរះក្តី និងចៅក្រមអយ្យការ មានលក្ខន្តិកៈដោយឡែកពីគ្នា ។

**មាត្រា ៨៤~** ចៅក្រមជំរះក្តីបំពេញមុខងារខាងយុត្តាធិការក្រោមការត្រួតត្រានៃតុលាការកំពូល ។

ចៅក្រមជំរះក្ដីនឹងអាចត្រូវរំហូតងារបានតែក្នុងករណីទទួលទោសអាជ្ញាប៉ុណ្ណោះ ។

**មាត្រា ៨៥.** ចៅក្រមអយ្យការទទួលរ៉ាប់រងអនុវត្តច្បាប់ក្រោមការត្រួតត្រានៃរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

វិធានការវិន័យដែលរដ្ឋមន្ត្រីក្រសួងយុត្តិធម៌បានសំរេចដាក់ទៅលើចៅក្រមអយ្យការ អាចឧទ្ធរណ៍ទៅគណៈរដ្ឋមន្ត្រីបាន

## ២. តុលាការកំពូល

**មាត្រា ៨៦.** តុលាការកំពូលមានចៅក្រមប្រាំបួននាក់ ជាសមាជិកគឺ ចាងហ្វាង និងចៅក្រមប្រឹក្សាប្រាំបីនាក់ ។ ចាងហ្វាងនិងចៅក្រមប្រឹក្សានៃតុលាការកំពូល ត្រូវសភាទាំងពីររួមប្រជុំជាសមាជសភាបោះឆ្នោតជ្រើសរើសសំរាប់បួនឆ្នាំក្នុងបណ្ដាចៅក្រមជំរះក្ដីម្ភៃនាក់ ដែលសហសេវិកខ្លួនបោះឆ្នោតជ្រើសរើសចុះក្នុងបញ្ជីមួយ ។ ចៅក្រមប្រឹក្សាជំនួយបួននាក់ ជ្រើសតាំងក្នុងលក្ខខ័ណ្ឌដូចគ្នា ត្រូវជំនួសសមាជិកនៃតុលាការកំពូលនៅពេលសមាជិកនេះមិននៅ ឬ មានធុរៈ ។

**មាត្រា ៨៧.** ចៅក្រមតុលាការកំពូល ត្រូវមានអតីតភាពយ៉ាងតិច ១២ ឆ្នាំ ក្នុងមុខងារចៅក្រម ។

**មាត្រា ៨៨.** ដទៃពីមុខងារខាងយុត្តាធិការកំពូលផ្នែកតុលាការ តុលាការកំពូល អាចផ្ដើមគំនិតបង្កើតច្បាប់អំពីបញ្ហាទាក់ទងនឹងការរៀបចំហើយនិងការប្រព្រឹត្តិទៅនៃអំណាចតុលាការ ។ តុលាការកំពូលវិនិច្ឆ័យ ប្រកាសរំលាយគណៈបក្សនយោបាយ យកតាមមតិពីរភាគបី ចំពោះគណៈបក្សនយោបាយណាដែលធ្វើសកម្មភាព បំផ្លេចបំផ្លាញរបបសាធារណរដ្ឋ ។

## ៣. ឧត្តមក្រុមប្រឹក្សាតុលាការ

**មាត្រា ៨៩.** ឧត្តមក្រុមប្រឹក្សាមានចៅក្រមជំរះក្តី ប្រាំនាក់ជាសមាជិកនិងចៅក្រមជំរះក្តីពីរនាក់ជាសមាជិកជំនួយ ដែលត្រូវបោះឆ្នោតជ្រើសរើសក្នុងបណ្តាចៅក្រមជំរះក្តីតាមលក្ខខ័ណ្ឌដូចគ្នានឹងការបោះឆ្នោតជ្រើសរើសសមាជិកនៃតុលាការកំពូល ។

**មាត្រា ៩០.** ឧត្តមក្រុមប្រឹក្សាតុលាការត្រូវឋិតនៅក្រោមអធិបតីភាពរបស់ប្រធានាធិបតីនៃសាធារណរដ្ឋ ហើយក្នុងករណីប្រធានាធិបតីមានធុរៈនោះត្រូវស្ថិតនៅក្រោមអធិបតីភាពរបស់អនុប្រធានាធិបតីនៃសាធារណរដ្ឋ ។

ក្នុងករណីដែលឧត្តមក្រុមប្រឹក្សាតុលាការពិភាក្សាអំពីការដាក់វិធានការវិន័យទៅលើចៅក្រមជំរះក្តី ត្រូវចាងហ្វាងតុលាការកំពូលដឹកនាំការជំនុំ ។

**មាត្រា ៩១.** ឧត្តមក្រុមប្រឹក្សាតុលាការរ៉ាប់រងនូវឥស្សរភាពនិងវិន័យរបស់ចៅក្រមជំរះក្តី ។ ឧត្តមក្រុមប្រឹក្សាតុលាការមានមុខងារដូចតទៅ :

- ស្នើការតែងតាំង ការឡើងឋានន្តរសក្តិ ការផ្លាស់តំណែងចៅក្រមជំរះក្តី
- អនុញ្ញាតការចោទប្រកាន់ចៅក្រមទាំងនេះខាងផ្លូវតុលាការ វៀរលែងតែក្នុងករណីប្រព្រឹត្តបទឧក្រិដ្ឋ ឬ បទមជ្ឈិមជាក់ស្តែងចេញ ។
- ដាក់វិធានការវិន័យទៅលើចៅក្រមទាំងនេះ
- ផ្តល់យោបល់ចំពោះសេចក្តីព្រាង ឬ សេចក្តីស្នើច្បាប់ណា ដែលទាក់ទងនឹងការរៀបចំហើយនិងការប្រព្រឹត្តិទៅនៃអំណាចតុលាការ ។

**មាត្រា ៩២-** មុខងារសមាជិកនៃឧត្តមក្រុមប្រឹក្សាតុលាការមានវិសមិតភាពនិង មុខងារដទៃទៀតក្នុងតុលាការ ។

## ជំពូក ៨- ស្ថាប័នដទៃទៀតរបស់សាធារណរដ្ឋ

## ១- តុលាការធម្មនុញ្ញ

**មាត្រា ៩៣-** តុលាការធម្មនុញ្ញមានសមាជិកប្រាំមួយនាក់ មានអាណត្តិប្រាំមួយឆ្នាំ។ សមាជិកតុលាការធម្មនុញ្ញចំនួនពាក់កណ្ដាលត្រូវផ្លាស់ថ្មីក្នុងរយៈពេល បីឆ្នាំម្ដង បីឆ្នាំម្ដង។ មុនផុតឆ្នាំទីបី នៃអាណត្តិទីមួយ ត្រូវមានចាត់ការបោះឆ្នោត ដើម្បីសមាជិកតុលាការធម្មនុញ្ញ ដែលត្រូវផុតអាណត្តិមុនគេ។

សមាជិកតុលាការធម្មនុញ្ញត្រូវជ្រើសក្នុងបណ្ដាឥស្សរជនខ្មែរដ៏ឧត្តម ដែលគេទទួលដឹងឮថាមានការចេះដឹងជ្រៅជ្រះខាងច្បាប់ ខាងសេដ្ឋកិច្ច ឬ ខាងរដ្ឋបាល ឬថាមានការពិសោធន៍ច្រើនខាងកិច្ចការរដ្ឋ។ ត្រូវឱ្យអាទិភាពទៅបេក្ខជន ដែលមិនមានចូលគណៈបក្សនយោបាយណាមួយ។

សមាជិកតុលាការធម្មនុញ្ញត្រូវចាត់តាំងតាមរបៀបដូចតទៅ : ពីរនាក់ដោយប្រធានាធិបតីនៃសាធារណរដ្ឋសំរេចក្នុងគណៈរដ្ឋមន្ត្រី ពីរនាក់ដោយសភាជាតិ និង ពីរនាក់ដោយព្រឹទ្ធសភា ក្រៅពីសមាជិករបស់ខ្លួន។

ប្រធានតុលាការធម្មនុញ្ញត្រូវជ្រើសតាំងក្នុងចំណោមសមាជិករបស់ខ្លួន។ ការបោះឆ្នោតនេះត្រូវធ្វើនៅពេលផ្លាស់សមាជិកពាក់កណ្ដាលចំនួន។ ប្រធានមានសម្លេងឧត្តមានុភាពក្នុងករណីចែកសម្លេងស្មើគ្នា។

**មាត្រា ៩៤.** មុខងារសមាជិកតុលាការធម្មនុញ្ញ មានវិសមិតភាពនិងមុខងារប្រធានាធិបតី ហើយនិងអនុប្រធានាធិបតីនៃសាធារណរដ្ឋ និង សមាជិករដ្ឋាភិបាល សមាជិកសហសភា សមាជិកតុលាការជាន់ខ្ពស់ ហើយនិងសមាជិកតុលាការកំពូល ។

**មាត្រា ៩៥.** តុលាការធម្មនុញ្ញអាចវះកាត់អំពីនីយតភាពនៃការបោះឆ្នោតជ្រើសរើសប្រធានាធិបតី និង អនុប្រធានាធិបតីនៃសាធារណរដ្ឋ ហើយប្រកាសលទ្ធផលអំពីការបោះឆ្នោតនេះ ។

តុលាការធម្មនុញ្ញអារកាត់អំពីករណីវិវាទកម្មទាក់ទង នឹងការបោះឆ្នោតជ្រើសរើសសមាជិកសហសភា ។

តុលាការធម្មនុញ្ញបកស្រាយជាចុងក្រោយនូវបទបញ្ញត្តិធម្មនុញ្ញ ។

ច្បាប់ដែលសហសភាបានអនុមតិហើយ ប្រធានាធិបតីត្រូវបញ្ជូនទៅតុលាការធម្មនុញ្ញមុនប្រកាសឱ្យប្រើ តុលាការធម្មនុញ្ញអារកាត់អំពីភាពត្រឹមត្រូវតាមរដ្ឋធម្មនុញ្ញរបស់ច្បាប់នោះក្នុងរយៈដប់ថ្ងៃ ។

គាហបញ្ហារបស់តុលាការធម្មនុញ្ញ ផ្អាករយៈពេលប្រកាសឱ្យប្រើ ។

ច្បាប់ណាដែលត្រូវប្រកាសថាមិនត្រឹមត្រូវតាមរដ្ឋធម្មនុញ្ញ មិនអាចត្រូវប្រកាសឱ្យប្រើហើយក៏មិនអាចត្រូវដាក់ឱ្យអនុវត្តិដែរ ។

**មាត្រា ៩៦.** ច្បាប់រៀបចំអង្គការមួយ កំណត់វិធានការរៀបចំ និង ការប្រព្រឹត្តិទៅនៃតុលាការធម្មនុញ្ញ ។

## ២. តុលាការជាន់ខ្ពស់

**មាត្រា ៩៧.** តុលាការជាន់ខ្ពស់មានអំណាចជំនុំជំរះ ប្រធានាធិបតីនៃសាធារណរដ្ឋ អនុប្រធានាធិបតីនៃសាធារណរដ្ឋ សមាជិករដ្ឋាភិបាល សមាជិកសហសភា សមាជិកតុលាការធម្មនុញ្ញ និង សមាជិកតុលាការកំពូល ពីបទឧក្រិដ្ឋនិងមជ្ឈឹមដែលបានប្រព្រឹត្តក្នុងពេលបំពេញមុខងាររៀងខ្លួន។

**មាត្រា ៩៨.** តុលាការជាន់ខ្ពស់មានសមាសភាពដូចតទៅ :

- សមាជិកបួននាក់ចាត់តាំងដោយប្រធានាធិបតី នៃសាធារណរដ្ឋក្នុងបណ្ដាយុត្តិបណ្ឌិត ហើយនិងទីប្រឹក្សារដ្ឋ
- សមាជិកបួននាក់ជ្រើសតាំងដោយសភាជាតិក្នុងបណ្ដាសមាជិករបស់ខ្លួន
- សមាជិកពីរនាក់ជ្រើសតាំងដោយព្រឹទ្ធសភាក្នុងបណ្ដាសមាជិករបស់ខ្លួន
- សមាជិកពីរនាក់ជ្រើសតាំងដោយតុលាការកំពូលក្នុងបណ្ដាសមាជិករបស់ខ្លួន។

**មាត្រា ៩៩.** តុលាការជាន់ខ្ពស់បោះឆ្នោតជ្រើសរើសចាងហ្វាងម្នាក់ក្នុងបណ្ដាសមាជិករបស់ខ្លួន ដើម្បីជំរះរឿងនីមួយៗ។

**មាត្រា ១០០.** អង្គការដែលអាចចោទប្រកាន់ ដើម្បីដាក់ទៅឱ្យតុលាការជាន់ខ្ពស់ជំនុំជំរះបាន គឺសភាជាតិនិងព្រឹទ្ធសភារួមប្រជុំជាសមាជសភា។

គាហបញ្ហាតុលាការជាន់ខ្ពស់ ត្រូវមានសមាជិកយ៉ាងតិចពាក់កណ្ដាលចំនួនសមាជិកសភានីមួយៗ ស្នើសុំ។ បើជាការចោទប្រកាន់ចំពោះប្រធានាធិបតីឬអនុប្រធានាធិបតីនៃសាធារណរដ្ឋ គាហបញ្ហាត្រូវមានសមាជិកសមាជសភាចំនួន បីភាគបួនយ៉ាងតិចអនុមតិ

យល់ព្រម ។ ចំពោះករណីដទៃទៀតភាគច្រើននេះ ត្រូវកំរិតយកពីរភាគបីនៃសមាជិកសមាជសភា ។

**មាត្រា ១០១.** កាលបើសមាជសភាអនុមតិយល់ព្រមនូវគាហបញ្ហា អ្នកជាប់ពិរុទ្ធត្រូវបញ្ឈប់ពីមុខងារខ្លួនរហូតដល់តុលាការចេញសាលក្រម ។

**មាត្រា ១០២.** ការវិនិច្ឆ័យរបស់តុលាការជាន់ខ្ពស់ ត្រូវយកតាមមតិពីរភាគបីនៃសមាជិករបស់ខ្លួន ។

**មាត្រា ១០៣.** ច្បាប់រៀបចំអង្គការមួយ កំណត់ការប្រព្រឹត្តិទៅនៃតុលាការជាន់ខ្ពស់និងនីតិក្រមដែលត្រូវអនុវត្តសំរាប់តុលាការនេះ ។

## ៣. ក្រុមប្រឹក្សារដ្ឋ

**មាត្រា ១០៤.** ក្រុមប្រឹក្សារដ្ឋរួបរួមក្នុងកិច្ចតាក់តែងច្បាប់ ។

ក្រុមប្រឹក្សារដ្ឋជាតុលាការកាត់ក្តីជាដាច់ខាតខាងវិស័យរដ្ឋបាល ។

ក្រុមប្រឹក្សារដ្ឋអារកាត់អំពីនីយតភាពនៃគណនីចំណូលនិងគណនីចំណាយកាន់ដោយគណនេយ្យករសាធារណៈ ។

**មាត្រា ១០៥.** ច្បាប់រៀបចំអង្គការមួយ កំណត់នូវវិធានស្តីពីសមាសភាព ការរៀបចំនិងការប្រព្រឹត្តិទៅរបស់ក្រុមប្រឹក្សារដ្ឋ ។

## ៤. ក្រុមប្រឹក្សាជាតិខាងការអប់រំ និងខាងវប្បធម៌

**មាត្រា ១០៦.** ក្រុមប្រឹក្សាជាតិខាងការអប់រំ និងខាងវប្បធម៌មានសមាជិកចំនួនមួយភាគបី ចាត់តាំងដោយប្រធានាធិបតីនៃសាធារណរដ្ឋ ដោយមានការយល់ព្រមពីគណៈ

រដ្ឋមន្ត្រី ហើយក្នុងចំនួនពីរភាគបីចាត់តាំងដោយអង្គការវប្បធម៌និងការអប់រំនានា ។

អាណត្តិសមាជិកក្រុមប្រឹក្សាជាតិខាងការអប់រំនិងខាងវប្បធម៌មានថិរៈវេលាបួនឆ្នាំ ។

ក្រុមប្រឹក្សាជាតិខាងការអប់រំនិងខាងវប្បធម៌ បោះឆ្នោតជ្រើសរើសប្រធានក្នុងបណ្តាសមាជិករបស់ខ្លួន ។

**មាត្រា ១០៧.** បើរដ្ឋាភិបាលសួរ ក្រុមប្រឹក្សាជាតិខាងការអប់រំនិងខាងវប្បធម៌ត្រូវឱ្យយោបល់លើបញ្ហានានាទាក់ទងនឹងអភិវឌ្ឍន៍នៃការអប់រំនិងវប្បធម៌ ។

**មាត្រា ១០៨.** ច្បាប់រៀបចំអង្គការមួយ កំណត់វិធានស្តីពីវិធីចាត់តាំងសមាជិក ការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រុមប្រឹក្សាជាតិខាងការអប់រំនិងខាងវប្បធម៌ ។

## ៥. ក្រុមប្រឹក្សាសេនានុភាព

**មាត្រា ១០៩.** ក្រុមប្រឹក្សាសេនានុភាពផ្តល់ជូនប្រធានាធិបតីនៃសាធារណរដ្ឋនូវយោបល់របស់ខ្លួនលើបញ្ហាខាងទាហានស្តីពីការឡើងឋានន្តរសក្តិ ការផ្លាស់តំណែង និងទណ្ឌកម្មខាងទាហានជាដើម ។

ច្បាប់រៀបចំអង្គការមួយ កំណត់ការរៀបចំនិងការប្រព្រឹត្តិទៅរបស់ក្រុមប្រឹក្សា-សេនានុភាព ។

## ៦. ក្រុមប្រឹក្សាសេដ្ឋកិច្ចនិងសង្គមកិច្ច

**មាត្រា ១១០.** ក្រុមប្រឹក្សាសេដ្ឋកិច្ចនិងសង្គមកិច្ច ផ្តល់យោបល់របស់ខ្លួនចំពោះបញ្ហាទាំងឡាយស្តីពីអភិវឌ្ឍន៍សេដ្ឋកិច្ចនិងសង្គមកិច្ច ។

ច្បាប់រៀបចំអង្គការមួយ កំណត់បែបបទចាត់តាំងសមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច

និងសង្គមកិច្ច ព្រមទាំងការរៀបចំនិងការប្រព្រឹត្តិទៅនៃអង្គការនេះ ។

## ៧. អភិបាលរដ្ឋ

**មាត្រា ១១១.** អភិបាលរដ្ឋត្រូវរ៉ាប់រងដោយអគ្គាភិបាលម្នាក់និងអ្នកអភិបាលនានាដែលប្រធានាធិបតីនៃសាធារណរដ្ឋតែងតាំង តាមការស្នើរបស់សហសភា។ អភិបាលរដ្ឋមានមុខងារត្រួតពិនិត្យនិងធ្វើអង្កេតលើបុគ្គលិកនៃអង្គការសាធារណៈ និងឯកជនដែលជាប់ទាក់ទិនក្នុងរឿងស៊ីសំណូក រឿងពុករលួយ រឿងប្រើអំណាចដោយរំលោភ រឿងរត់គយ រឿងស្តុកទំនិញខុសច្បាប់ រឿងតម្លើងថ្លៃខុសច្បាប់ រឿងប្រដេញប្រជែងដោយវៀចវេរ និងរឿងចងការប្រាក់យកការលើសកំរិតច្បាប់ ។

**មាត្រា ១១២.** ការរៀបចំនិងការប្រព្រឹត្តិទៅនៃអភិបាលរដ្ឋត្រូវកំណត់ក្នុងច្បាប់រៀបចំអង្គការមួយ ។

## ៨. កំណែនទូទៅ

**មាត្រា ១១៣.** កំណែនទូទៅដែលមានការរៀបចំជាប្រទាក់ក្រឡាគ្នាតាមបាវចនា «រដ្ឋាភិបាលជួយ ប្រជាជនសំរេច អ្នកបច្ចេកទេសឧបត្ថម្ភ» ជាស្ថាប័នជាតិ ។

ការរៀបចំនិងការប្រព្រឹត្តិទៅនៃអង្គការនេះ នឹងត្រូវកំរិតតាមច្បាប់អង្គការមួយ ។

## ជំពូក ៩- សមូហភាពដែនដី

**មាត្រា ១១៤.** សមូហភាពដែនដីនៃសាធារណរដ្ឋគឺ សង្កាត់ ខេត្ត និង ក្រុង ។

សមូហភាពទាំងនេះ នឹងត្រូវគ្រប់គ្រងខ្លួនតាមលក្ខខ័ណ្ឌមានចែងក្នុងច្បាប់រៀបចំអង្គការមួយ ។

## ជំពូក ១០- ការពិនិត្យនិងវិសោធនកម្ម

**មាត្រា ១១៥.** ការផ្ដើមគំនិតរើពិនិត្យ ឬវិសោធនកម្មនៃរដ្ឋធម្មនុញ្ញជាសិទ្ធិរដ្ឋាភិបាល ឬសមាជិកចំនួនពាក់កណ្ដាលនៃសភាណាមួយរបស់សហសភា។ ការរើពិនិត្យ ឬវិសោធនកម្ម ធ្វើឡើងតាមច្បាប់មួយដែលអនុមតិតាមវិធីបោះឆ្នោតចំហរ។ ត្រូវកំរិតយកភាគច្រើន បីភាគបួននៃសមាជិកសភានីមួយៗ នៃសហសភា ហើយការប្រញាប់មិនអាចត្រូវប្រកាសបានឡើយ។

**មាត្រា ១១៦.** ការរើពិនិត្យ ឬ វិសោធនកម្មណាក៏ដោយត្រូវហាមឃាត់ នៅពេលប្រធានាធិបតីនៃសាធារណរដ្ឋមានធុរៈម្ដងម្កាល ក្នុងករណីដូចចែងនៅមាត្រា ៣០។

**មាត្រា ១១៧.** ការរើពិនិត្យណាក៏ដោយ ដែលមានគោលបំណងកែប្រែសណ្ឋានសាធារណរដ្ឋ នៃប្រទេស ត្រូវហាមមិនឱ្យធ្វើឡើយ។

## ជំពូក ១១- អន្តរប្បញ្ញត្តិ

**មាត្រា ១១៨.** ក្នុងអម្លុងពេលបណ្ដោះអាសន្ន ហើយរហូតដល់ស្ថាប័នទាំងឡាយដូចមានចែងក្នុងបច្ចុប្បន្នរដ្ឋធម្មនុញ្ញបានរៀបចំតាំងឡើង ស្ថាប័នរដ្ឋដែលមានសព្វថ្ងៃដោយអាស្រ័យអត្ថបទរដ្ឋធម្មនុញ្ញមុននោះ ត្រូវបន្តការប្រព្រឹត្តិទៅជាបណ្ដោះអាសន្ន។

**មាត្រា ១១៩.** ក្រោយពេលដាក់បច្ចុប្បន្នរដ្ឋធម្មនុញ្ញជាធរមាន នឹងមានការបោះឆ្នោត ជ្រើសរើសប្រធានាធិបតីថ្មីនៃសាធារណរដ្ឋខ្មែរនៅថ្ងៃ អាទិត្យ ទី ៤ មិថុនា ១៩៧២ ដោយវិធីបោះឆ្នោតសាកលដោយចំពោះ និងសម្ងាត់តាមលក្ខណៈដែលរៀបចំក្នុងបញ្ញត្តិ

បោះឆ្នោតមួយ។ ក្នុងអាណត្តិរបស់ខ្លួន ប្រធានាធិបតីថ្មីនៃសាធារណរដ្ឋខ្មែរ អាចតែងតាំងអនុប្រធានាធិបតីមួយ បន្ទាប់ពីបានពិគ្រោះជាមួយប្រធាននៃសភាទាំងពីរ។

**មាត្រា ១២០**~ ប្រធានាធិបតីនៃសាធារណរដ្ឋ ប្រកាសឱ្យប្រើភ្លាមនូវបញ្ញត្តិមួយស្ដីពីការបោះឆ្នោតដើម្បីកំណត់របៀបជ្រើសរើសសភាជាតិនិងព្រឹទ្ធសភា ។ សភាជាតិទីមួយនិងព្រឹទ្ធសភាទីមួយ នៃសាធារណរដ្ឋ អាចត្រូវជ្រើសតាំងបាន :

- ឬតាមលក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា ៤៩ វាក្យខ័ណ្ឌទីមួយ
- ឬដោយវិធីបោះឆ្នោតសាកលមិនចំពោះ សម្ងាត់និងដោយសន្លឹកឆ្នោតមួយមាននាមតែមួយ
- ការបោះឆ្នោតត្រូវធ្វើក្នុងរយៈពេល ៣ ខែ គិតពីថ្ងៃបោះឆ្នោតជ្រើសរើសប្រធានាធិបតីនៃសាធារណរដ្ឋ។

**មាត្រា ១២១**~ ទំរាំតុលាការធម្មនុញ្ញរៀបចំហើយចូលកាន់តំណែង មុខការដែលប្រគល់ឱ្យតុលាការនេះ ដោយមាត្រា ៩៥ ត្រូវឱ្យតុលាការមួយកាន់កាប់ជាបណ្ដោះអាសន្ន។ តុលាការនេះមានសមាជិកប្រាំមួយនាក់ចាត់តាំងដោយប្រធានាធិបតី នៃសាធារណរដ្ឋ។

សមាជិកតុលាការធម្មនុញ្ញបណ្ដោះអាសន្នដែលមានចែងនៅវាក្យខ័ណ្ឌទីមួយ មិនអាចឈរឈ្មោះជាបេក្ខជនប្រធានាធិបតីឬអនុប្រធានាធិបតីនៃសាធារណរដ្ឋ ឬ សមាជិកសហសភាបានទេ។

# ក្រមលេខ ៤៧២/៧១- បរ

## ប្រមុខរដ្ឋ នៃ សាធារណរដ្ឋខ្មែរ

បានឃើញច្បាប់រដ្ឋធម្មនុញ្ញលេខ ៤៤២-៧០-បរ ចុះថ្ងៃទី ៨ តុលា គ.ស ១៩៧០ ដែលប្រកាសសាធារណរដ្ឋខ្មែរ និងតំកល់ទុកនូវការអនុវត្តតទៅទៀតនៃរដ្ឋធម្មនុញ្ញបច្ចុប្បន្ន លើកលែងតែបទបញ្ញត្តិណា ដែលផ្ទុយនឹងគោលគំនិត និង របបសាធារណរដ្ឋ។

បានឃើញក្រមលេខ ៤៧៣-នស ចុះថ្ងៃទី ២៩ ខែ តុលា គ.ស ១៩៤៨ ស្តីពីការបង្កើតទង់ជាតិ។

បានឃើញក្រមលេខ ១-បរ ចុះថ្ងៃទី ១២ ខែធ្នូ គ.ស ១៩៤១ កែប្រែដោយក្រមលេខ ៨១-នស ចុះថ្ងៃទី ២៨ ខែកក្កដា គ.ស ១៩៤៥ ស្តីពីការបង្កើតភ្លេងជាតិនគររាជ។

គណរដ្ឋមន្ត្រីបានយល់ព្រមផង

បានឃើញយោបល់នៃក្រុមប្រឹក្សាសាធារណរដ្ឋ

## ប្រកាសឱ្យប្រើ

ច្បាប់ដែលរដ្ឋសភាបានអនុមតិជាលើកទី២ នៅថ្ងៃទី ៣ ខែឧសភា គ.ស ១៩៧១ ដែលមានសេចក្តីដូចតទៅ :

«ច្បាប់ស្តីអំពីការបញ្ជាក់នៃទ្រង់ទ្រាយ និងលក្ខខ័ណ្ឌនៃទង់ជាតិ-ភ្លេងជាតិ និង រដ្ឋសង្ហារជាតិ» ។

## ១- ទង់ជាតិ

**មាត្រា ១.** ទង់ជាតិសាធារណរដ្ឋខ្មែរមាន ៣ ពណ៌គឺ ខៀវ ស និង ក្រហម។ ទង់ជាតិនេះមានរាងចតុកោណកែង កំពស់មានប្រវែង ២ ភាគ ៣ នៃបណ្ដោយ។ តួទង់ជាតិទាំងមូលមានពណ៌ខៀវលើកលែងតែ ១ ភាគ បួន នៃផ្ទៃកខាងលើជ្រុងខាងឆ្វេងដែលមានពណ៌ក្រហម។ នៅក្នុងផ្ទៃកក្រហមមានរូបប្រាសាទអង្គរវត្តពណ៌ស មើលចំពីមុខឃើញកំពូលប្រាសាទ ៣។

នៅក្នុងផ្ទៃកមួយភាគបួននៃពណ៌ខៀវ ភាគខាងលើមានផ្កាយបី ពណ៌ស តម្រៀបគ្នាត្រង់តាមខ្សែដេក។

គំរូព្រមទាំងខ័ណ្ឌនៃទង់ជាតិ មានរៀបរាប់យ៉ាងពិស្ដារក្នុងឧបសម្ព័ន្ធនៃក្រមនេះ។

ន័យនៃពណ៌និងរូបភាព មានដូចតទៅនេះ :

-ពណ៌ខៀវ តំណាងសិលធម៌។ ពណ៌នេះសំដែងនូវសន្ដានចិត្តសុចរិត យុត្តិធម៌ និងសុភមង្គលត្រជាក់ត្រជុំរបស់ប្រជាពលរដ្ឋខ្មែរ។

-ពណ៌ក្រហមតំណាងទឹកចិត្តអង់អាចនិងក្លាហានមុះមុតនៃប្រជាពលរដ្ឋខ្មែរ។

-ពណ៌ស ដែលជានិមិត្តរូបនៃភាពបរិសុទ្ធ និងភាពទៀងត្រង់ស្អាតស្អំតំណាង ព្រះពុទ្ធសាសនា។

-រូបប្រាសាទ ជានិមិត្តរូបនៃអារ្យធម៌ និងសេចក្ដីថ្កុំថ្កើងនៃប្រទេសជាតិ។

-រូបផ្កាយ ជានិមិត្តរូបនៃវឌ្ឍនធម៌ និង នក្ខត្តឫក្ស ចំនួន ៣ នៃផ្កាយនេះមានន័យថា :

-ត្រីបាវចនាគឺ ជាតិ សាសនា សាធារណរដ្ឋ។

-រតនត្រ័យគឺ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ។

-អំណាចទាំង ៣ គឺនីតិបញ្ញត្តិ - នីតិប្រតិបត្តិ - តុលាការ ។

## ២- ភ្លេងជាតិ

**មាត្រា ២.** ភ្លេងជាតិដែលមានបទភ្លេង និងទំនុកច្រៀងភ្ជាប់ឧបសម្ព័ន្ធនិងក្រមនេះ មានឈ្មោះថា ដំណើរសាធារណរដ្ឋខ្មែរ ។

## ៣- រដ្ឋសង្ហារ

**មាត្រា ៣.** រដ្ឋសង្ហារនៃសាធារណរដ្ឋខ្មែរ មានលក្ខណៈសំគាល់ដូចតទៅនេះ

១- រូបផ្កាយ ៣ មានរស្មីជាប់មកភ្ជិ គួរស្រូវទាំងសងខាង ស្ថិតនៅលើប្រាសាទ

២- រូបប្រាសាទអង្គរវត្ត មានពណ៌មាស ស្ថិតនៅក្នុងចន្លោះមែកកម្រងភ្ជីពីរ រាងកោងឡើងលើដែលរចនាដោយគួរស្រូវ ។

៣- រូបសំណាកគម្ពីររដ្ឋធម្មនុញ្ញដំកល់លើទ្រនាប់ជើងពានពីរជាន់ ។ ទាំងអស់នេះស្ថិតនៅក្នុងរង្វង់ ១ រាងពងក្រពើ មានស្នូលបញ្ឈរត្រង់ទៅលើ រួចហ៊ុំព័ទ្ធដោយកាំរស្មី ។

៤- ស្លាកមួយរាងកោងបន្តិច មានឆ្លាក់អក្សរខ្មែរថា «សាធារណរដ្ឋខ្មែរ»

រដ្ឋសង្ហារនៃសាធារណរដ្ឋខ្មែរ ធ្វើឡើងពីមាសទាំងអស់ ឬលាបពណ៌មាស លើកលែងតែអក្សរចារិកដែលមានពណ៌ខៀវ ។

គំរូព្រមទាំងលក្ខខ័ណ្ឌនៃរដ្ឋសង្ហារជាតិមានរៀបរាប់យ៉ាងពិស្តា ក្នុងឧបសម្ព័ន្ធនៃក្រមនេះ ។

ចំពោះទំហំអាចតម្រូវតាមការប្រើប្រាស់ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី ២១ ខែឧសភា គ.ស ១៩៧១

*ហត្ថលេខា* : **ចេង.ហេង**

# ឧបសម្ព័ន្ធទី១

## ពិពណ៌នា អំពីទង់ជាតិ សាធារណរដ្ឋខ្មែរ

ទង់ជាតិសាធារណរដ្ឋខ្មែរ រាងចតុកោណកែង ដែលមានសមមាត្រា ២ ភាគ ៣ «កំពស់ ២ ទល់នឹងបណ្ដោយ ៣ ឯកតា បានត្រូវចង្អុលបង្ហាញដោយតួអក្សរ «ក» ក្នុងគំរូដែលមានភ្ជាប់ជាមួយនេះ :

តួទង់ជាតិទាំងមូលមានពណ៌ខៀវ លើកលែងតែ ១ ភាគ ៤ នៃផ្នែកខាងលើជ្រុងខាងឆ្វេងដែលមានពណ៌ក្រហម។ នៅក្នុងផ្នែកក្រហមមានរូបប្រាសាទអង្គរវត្តពណ៌ស។

ប្រាសាទមានកំពស់ ៣ ភាគ ៥ នៃកំពស់ផ្នែកពណ៌ក្រហម។

បាតប្រាសាទត្រូវនៅចម្ងាយ ១ ភាគ ៥ ពីរឹមក្រោម នៃពណ៌ក្រហម។

បាតប្រាសាទមានប្រវែងពីរដង នៃកំពស់ «៦ ភាគ ៥ នៃឯកតា» ហើយរូបត្រូវចារិកក្នុងកន្លះរង្វង់មូល។

ស្នូលនៃកំពូលកណ្ដាលប្រាសាទ ស្ថិតនៅចំកណ្ដាលបណ្ដោយចតុកោណក្រហម ហើយស្នូល នៃកំពូលសងខាងនៅត្រង់ ១ ភាគ ៤ នៃបណ្ដោយនេះ ចុងកំពូលត្រូវកំណត់តាមគំនូសនៃរង្វង់មូលចារិកក្រៅ។

នៅក្នុងផ្នែក ១ ភាគ ៤ នៃពណ៌ខៀវ ភាគលើមានផ្កាយ ៣ រត់ត្រង់គ្នាតាមខ្សែដេកដែលកាត់ចំកណ្ដាលកំពស់នៃផ្នែក ១ ភាគ ៤ នៃភាគលើនេះ «គឺត្រង់ ៣ ភាគ ៤ នៃកំពស់ទាំងមូល» វិជ្ឈមាត្រានៃរង្វង់ដែលចារិកផ្កាយ ៥ ជ្រុង មានប្រវែង ១ ភាគ ៤ នៃឯកតា។

ផ្កាយកណ្ដាលស្ថិតនៅចំកណ្ដាលបណ្ដោយនៃផ្នែក ១ ភាគ ៤ នៃពណ៌ខៀវភាគលើ ឯផ្កាយពីរទៀតស្ថិតនៅចម្ងាយ ១ ភាគ ៤ នៃឯកតា ពីរឹមខាង។

បានឃើញដើម្បីឧបសម្ពន្ធ

នឹងក្រមលេខ ៤៧២ -- ៧១- បរ

ធ្វើនៅភ្នំពេញ, ថ្ងៃទី ២៤ ខែឧសភា គ.ស ១៩៧១

*ហត្ថលេខា* : **ចេង ហេង**

**កត់សំគាល់**- ខាងខ្មែរគ្មានឧបសម្ពន្ធទី ២ ទេ សុំមើលពាក្យ និងទំនុកច្រៀងជាភាសារខ្មែរ នៅកណ្ដាលសៀវភៅនេះតែម្ដង។

# ឧបសម្ពន្ធទី៣

## ពិពណ៌នា អំពីរដ្ឋសង្ហារ នៃសាធារណរដ្ឋខ្មែរ

រដ្ឋសង្ហារនៃសាធារណរដ្ឋខ្មែរមានលក្ខណ៍ណ្ឌសំខាន់ៗដូចតទៅ : រូបសំណាកគម្ពីររដ្ឋធម្មនុញ្ញភ្ជាប់នឹងរូបប្រាសាទអង្គរវត្ត រូបផ្កាយបី « ៣ » កម្រងភ្ញីរចនាដោយគួរស្រូវ ស្លាកមួយមានសរសេរអក្សរចារិកខ្មែរដែលអានថា « សាធារណរដ្ឋខ្មែ » ។

រូបសំណាកគម្ពីររដ្ឋធម្មនុញ្ញតំកល់លើទ្រនាប់ជើងពានពីរជាន់ដែលមានបាតភ្ជាប់ទៅលើក្បាច់ភ្ញីភ្លើងពីរ ។ រូបសំណាកនេះស្ថិត នៅក្នុងរង្វង់ពងក្រពើមានស្នូលឈរត្រង់ទៅលើហ៊ុមព័ទ្ធដោយកាំរស្មី ។ កាំរស្មីដែលវែងជាងគេបណ្តាកាំរស្មីឯទៀត ចង្អុលទិសទាំងប្រាំបី ។

ផ្នែកខាងលើនៃរូបក្បាច់ភ្ញីទាំងនេះ ដែលហ៊ុមព័ទ្ធទាំងសងខាងដោយរូបនាគពីរជាភ្ញីភ្លើងទ្រភ្ជាប់ទៅនឹងរូបប្រាសាទអង្គរវត្ត ។

នៅលើរូបប្រាសាទអង្គរវត្ត មានរូបផ្កាយបី « ៣ » ដែលជានិមិត្តរូបនៃបាវចនា គឺ ជាតិ សាសនា សាធារណរដ្ឋ និងនៃរតនត្រ័យ ព្រមទាំងអំណាចទាំងបី « ៣ » ។

រូបផ្កាយទាំង ៣ នេះភ្ជាប់ទៅនិងក្បាច់ភ្ញីកាំរស្មីដែលមានទំហំធំតូចជាលំដាប់ ។

រូបសំណាកទាំងឡាយនេះស្ថិតនៅក្នុងរង្វង់កម្រងភ្ញីរាងកោងទៅលើ រចនាដោយគួរស្រូវចងក្រងដោយអន្ទើនឹងបូរហូតដល់ផ្នែកខាងក្រោម ។

ស្លាកមួយរាងកោងបន្តិចបួចុងសងខាងស្ថិតនៅជិតផ្នែកក្រោមនៃកម្រងនេះមានឆ្លាក់ចារិកអក្សរខ្មែរពណ៌ខៀវដែលអានថា « សាធារណរដ្ឋខ្មែរ» ។

រដ្ឋសង្ហារធ្វើឡើងពីមាសទាំងមូល ឬលាបពណ៌មាស លើកលែងតែអក្សរចារិក ។

បានឃើញដើម្បីឧបសម្ពន្ធ

នឹងក្រមលេខ ៤៧២ - ៧១ - បរ ចុះថ្ងៃទី ២១ ខែឧសភា គ.ស ១៩៧១

*ហត្ថលេខា* : **ចេង~ហេង**


សាធារណរដ្ឋខ្មែរ




$\frac{1}{4}$ A
$\frac{1}{4}$ A
$\frac{1}{4}$ A
$\frac{1}{5}$ A
$\frac{3}{5}$ A
$\frac{1}{5}$ A
$\frac{1}{2}$ A
$\frac{1}{2}$ A
A
A
A
A

# ដំណើរសាធារណរដ្ឋខ្មែរ

## LA MARCHE DE LA REPUBLIQUE KHMERE




ជនជាតិខ្មែរ ល្បីល្បាញមួយក្នុងលោក

មានជ័យជោគ កសាងប្រាសាទសិលា

អារ្យធម៌ ខ្ពស់បវរជាតិសាសនា

កេរ្តិ៍ដូនតាទុកលើភពផែនដី

ខ្មែរក្រោកឡើង ខ្មែរក្រោកឡើង ខ្មែរក្រោកឡើង

តស៊ូតម្កើងសាធារណរដ្ឋ

ខ្ទរខ្ទាំលោក ខ្មែរប្រយុទ្ធ មិនតក់ស្លុត

យកជ័យបំផុតជូនជាតិខេមរា

ឯករាជ្យភ័ព្វថ្លា ជាមហាប្រទេសតទៅ ។

# រដ្ឋធម្មនុញ្ញ
# កម្ពុជាប្រជាធិបតេយ្យ

**មហាសន្និបាតជាតិ លើកទី ៣**

**អនុមតិ កាលពីថ្ងៃ ១៤ ធ្នូ ១៩៧៥**

**ប្រកាសប្រើជាផ្លូវការ នៅថ្ងៃ ៥ មករា ឆ្នាំ ១៩៧៦**



# សំណូមពរជាមូលដ្ឋាន និងជាពិសិដ្ឋ
# របស់
# ប្រជាជន កម្មករ កសិករ ពលករ
# ផ្សេងទៀត ហើយនិង យុទ្ធជន
# និង កម្មាភិបាល
# នៃ កងទ័ពបដិវត្តកម្ពុជា

ដោយយោងទៅតាម តួនាទីសំខាន់ របស់ប្រជាជន ពិសេសប្រជាជន កម្មករ កសិករក្រ កសិករកណ្តាលថ្នាក់ក្រោម និងស្រទាប់ពលករផ្សេងទៀត នៅជនបទនិង ទីក្រុងដែលមានចំនួនជាង ៩៥ ភាគរយ នៃប្រជាជាតិកម្ពុជាទាំងមូល ដែលបានទទួលបន្ទុកសង្គ្រាមរំដោះជាតិ រំដោះប្រជាជនធ្ងន់សែនធ្ងន់ជាងគេបំផុត ធ្វើពលិកម្មសែនធំធេងជាងគេបំផុតទាំងអាយុជីវិត ទាំងទ្រព្យសម្បត្តិ ទាំងមនោសញ្ចេតនា បំរើសមរភូមិមុខ គ្មានស្រាកស្រាន្ត គ្មានឈប់ឈរ ហើយលះបង់កូនចៅ ប្តីសីរាប់ម៉ឺនរាប់សែននាក់ ទៅប្រយុទ្ធនៅសមរភូមិមុខគ្មានរុញរាអ្វីទាំងអស់ ។

ដោយយោងទៅតាមពលីកម្មដ៏ធំធេងរបស់កងទ័ពបដិវត្តកម្ពុជាទាំងបីប្រភេទ ដែលប្រយុទ្ធ អង់អាចក្លាហាន ប្រយុទ្ធទាំងយប់ទាំងថ្ងៃ ទាំងប្រាំងទាំងវស្សា ទ្រាំទ្រលំបាកវេទនាសព្វបែបយ៉ាង ខ្វះស្បៀង ខ្វះថ្នាំសង្កូវ ខ្វះសំលៀកបំពាក់ ខ្វះគ្រាប់រំសេវ ខ្វះសព្វ ខ្វះគ្រប់ក្នុងសង្គ្រាមរំដោះជាតិ រំដោះប្រជាជនដ៏សន្ធោសន្ធៅ ។

ដោយយោងទៅតាមសំណូមពររបស់ប្រជាជនកម្ពុជាទាំងមូល និងរបស់កងទ័ពបដិវត្តកម្ពុជាទាំងមូល ដែលចង់បានប្រទេសកម្ពុជា ឯករាជ ឯកភាព សន្តិភាព អព្យាក្រិត មិនចូលបក្សសម្ពន្ធណា អធិបតេយ្យ ក្នុងបូរណភាពដែនដីរបស់ខ្លួន ក្នុងសង្គមជាតិមួយមានសុភមង្គល ស្មើភាពគ្នា យុត្តិធម៌ និងប្រជាធិបតេយ្យពិតប្រាកដ គ្មានអ្នកមាន គ្មានអ្នកក្រ គ្មានវណ្ណៈជិះជាន់គេ គ្មានវណ្ណៈត្រូវគេជិះជាន់ គឺជាសង្គមមួយ ដែលប្រជាជនទាំងអស់រស់នៅសុខដុមរមនា ក្នុងមហាសាមគ្គីជាតិទាំងមូល ហើយរួមគ្នាប្រកបការងារពលកម្ម បង្កបង្កើនផលកសាងប្រទេស និងការពារប្រទេសទាំងអស់គ្នា ។

ដោយយោងទៅតាមសេចក្ដីសំរេច របស់មហាសន្និបាតជាតិពិសេស សម័យប្រជុំថ្ងៃ ២៥-២៦ និង ២៧ ខែ មេសា ឆ្នាំ ១៩៧៥ ដែលបានប្រកាសជាឱឡារិក ទទួលស្គាល់និងគោរពតាមសំណូមពរខាងលើនេះ របស់ប្រជាជនទាំងមូល និងរបស់កងទ័ពបដិវត្តកម្ពុជាទាំងមូល រដ្ឋធម្មនុញ្ញ នៃប្រទេសកម្ពុជា មានខ្លឹមសារ ដូចតទៅ :

## ជំពូក ១

## អំពី របបរដ្ឋ

### មាត្រា ១ :

រដ្ឋកម្ពុជា ជារដ្ឋមួយឯករាជ ឯកភាព សន្តិភាព អព្យាក្រិត មិនចូលបក្ស សម្ពន្ធណា អធិបតេយ្យ ប្រជាធិបតេយ្យ ក្នុងបូរណភាពដែនដីរបស់ខ្លួន ។

រដ្ឋកម្ពុជា ជារដ្ឋរបស់ប្រជាជន កម្មករ កសិករ និងពលករកម្ពុជាផ្សេងទៀតទាំងអស់ ។

រដ្ឋកម្ពុជា មានឈ្មោះជាផ្លូវការថា : **"កម្ពុជា ប្រជាធិបតេយ្យ"**

## ជំពូក ២

## អំពី របបសេដ្ឋកិច្ច

### មាត្រា ២ :

មធ្យោបាយផលិតកម្មសំខាន់ៗជាទូទៅ ជាកម្មសិទ្ធិរួមរបស់ប្រជាជន និងជាកម្មសិទ្ធិរួមរបស់ប្រជាជនសមូហភាព ។

រីឯរបស់របរប្រើប្រាស់ ប្រចាំថ្ងៃ ស្ថិតនៅជាកម្មសិទ្ធិផ្ទាល់របស់ឯកជន ។

## ជំពូក ៣

## អំពី របបវប្បធម៌

### មាត្រា ៣ :

វប្បធម៌របស់ប្រទេសកម្ពុជា ប្រជាធិបតេយ្យ មានលក្ខណៈជាតិ ប្រជាជន និងចំរើនស្អាតស្អំ ដើម្បីបំរើភារកិច្ចការពារប្រទេស និងកសាងប្រទេសកម្ពុជាឱ្យបានរុងរឿងសំបូរសប្បាយ ។

វប្បធម៌ថ្មីនេះ ប្រឆាំងដាច់ខាត នឹងវប្បធម៌ពុករលួយប្រតិកិរិយា របស់វណ្ណៈជិះជាន់ផ្សេងៗ និងរបស់អាណានិគមនិយម ចក្រពត្តិនិយម នៅកម្ពុជា ។

## ជំពូក ៤

## អំពី របបដឹកនាំ និងធ្វើការងារ

### មាត្រា ៤ :

កម្ពុជា ប្រជាធិបតេយ្យ អនុវត្តរបបសមូហភាព ក្នុងការដឹកនាំ និងធ្វើការងារ ។

## ជំពូក ៥

## អំពី អំណាចធ្វើច្បាប់

### មាត្រា ៥ :

អំណាចធ្វើច្បាប់ ជាអំណាចរបស់សភាតំណាងប្រជាជន កម្មករ កសិករ និង ពលករកម្ពុជាផ្សេងទៀតទាំងអស់។

សភានេះ មានឈ្មោះជាផ្លូវការថា : **"សភាតំណាងប្រជាជនកម្ពុជា"**

សភាតំណាងប្រជាជនកម្ពុជា មានសមាជិកទាំងអស់ ២៥០ នាក់ តំណាងឱ្យប្រជាជន កម្មករ កសិករ និងពលករកម្ពុជាផ្សេងទៀត ហើយនិងតំណាងឱ្យកងទ័ពបដិវត្តកម្ពុជា ។គឺ :

- តំណាងកសិករ : ១៥០ នាក់
- តំណាងកម្មករ និងពលករផ្សេងទៀត : ៥០ នាក់
- តំណាងកងទ័ពបដិវត្ត : ៥០ នាក់

### មាត្រា ៦ :

សមាជិកសភា តំណាងប្រជាជនកម្ពុជា ត្រូវបានប្រជាជនជ្រើសតាំងឡើង ដោយការបោះឆ្នោតទូទាំងប្រទេស ដោយផ្ទាល់ និងដោយសម្ងាត់ ក្នុងរយៈកាល ៥ ឆ្នាំ មួយដង ។

### មាត្រា ៧ :

សភាតំណាងប្រជាជន មានភារៈសំរេចច្បាប់ និងកំណត់មាគ៌ានយោបាយផ្សេងៗ ក្នុងប្រទេស និងក្រៅប្រទេស របស់កម្ពុជាប្រជាធិបតេយ្យ ។

## ជំពូក ៦

## អំពី អង្គការអនុវត្តច្បាប់

### មាត្រា ៨ :

រដ្ឋាភិបាល ជាអង្គការមានភារកិច្ចអនុវត្តច្បាប់ និងអនុវត្តមាគ៌ានយោបាយទាំងអស់របស់សភាតំណាងប្រជាជនកម្ពុជា ។

រដ្ឋាភិបាល ត្រូវជ្រើសតាំងឡើងដោយសភាតំណាងប្រជាជនកម្ពុជា ហើយត្រូវទទួលខុសត្រូវទាំងស្រុង ចំពោះមុខសភាតំណាងប្រជាជនកម្ពុជា ក្នុងកិច្ចដំណើរការទាំងអស់របស់ខ្លួន ទាំងក្នុងប្រទេស ទាំងក្រៅប្រទេស ។

## ជំពូក ៧

## អំពី តុលាការ

### មាត្រា ៩ :

តុលាការ ជាតុលាការរបស់ប្រជាជន តំណាងយុត្តិធមិរបស់ប្រជាជន ការពារយុត្តិធមិរបស់ប្រជាជន ការពារសិទ្ធិ សេរីភាពប្រជាធិបតេយ្យរបស់ប្រជាជន ហើយផ្តន្ទាទោសដល់គ្រប់សកម្មភាព ដែលប្រឆាំងនឹងរដ្ឋ របស់ប្រជាជន ឬដែលល្មើសនឹងច្បាប់រដ្ឋរបស់ប្រជាជន ។

តុលាការគ្រប់ជាន់ថ្នាក់ ត្រូវសភាតំណាងប្រជាជនជ្រើសរើស និងតែងតាំង ។

### មាត្រា ១០ :

ប្រភេទល្មើសច្បាប់រដ្ឋប្រជាជន មានដូចតទៅ :

- ចំពោះ ប្រភេទសកម្មភាពប្រឆាំង និងបំផ្លិចបំផ្លាញ ដែលមានលក្ខណៈជាខ្សែ

សង្វាក់ ហើយគ្រោះថ្នាក់ដល់រដ្ឋរបស់ប្រជាជន ត្រូវផ្ដន្ទាទោសកំរិតខ្ពស់បំផុត ។

- ចំពោះប្រភេទល្មើស ក្រៅពីប្រភេទខាងលើ ត្រូវអប់រំកសាងក្នុងក្របខណ្ឌអង្គការរដ្ឋ ឬក្នុងក្របខណ្ឌអង្គការប្រជាជន ។

## ជំពូក ៨

## អំពី គណៈប្រធានរដ្ឋ

### មាត្រា ១១ :

កម្ពុជា ប្រជាធិបតេយ្យ មានគណៈប្រធានរដ្ឋមួយ ជ្រើសរើស និងតែងតាំងឡើងដោយសភាតំណាងប្រជាជនកម្ពុជា ក្នុងរយៈកាល ៥ ឆ្នាំម្ដង ។

គណៈប្រធានរដ្ឋ មានភារៈតំណាងឱ្យរដ្ឋកម្ពុជា ប្រជាធិបតេយ្យ នៅក្នុងប្រទេស និងក្រៅប្រទេស ក្នុងក្របខណ្ឌរដ្ឋធម្មនុញ្ញរបស់កម្ពុជាប្រជាធិបតេយ្យ ហើយនិងតាមច្បាប់ និងតាមមាគ៌ានយោបាយរបស់សភាតំណាងប្រជាជនកម្ពុជា ។

គណៈប្រធានរដ្ឋ មានសមាសភាពដូចតទៅ :

| | |
|---|---|
| - ប្រធាន | ១ រូប |
| - អនុប្រធានទី ១ | ១ រូប |
| - អនុប្រធានទី ២ | ១ រូប |

# ជំពូក ៩
# អំពី សិទ្ធិ និងករណីយកិច្ច
# របស់ប្រជាជនកម្ពុជាម្នាក់ៗ

## មាត្រា ១២ :

ប្រជាជនកម្ពុជា គ្រប់រូប មានសិទ្ធិជីវភាពពេញទី ខាងសំភារៈ ខាងស្មារតី និងខាងវប្បធម៌ ដែលត្រូវបានកែប្រែឱ្យរីកចំរើនកាន់តែខ្ពស់ឡើងជានិច្ច ។ ប្រជាជនកម្ពុជាគ្រប់រូបសុទ្ធតែត្រូវបានធានាអះអាងខាងជីវភាពទាំងអស់ ។

- កម្មករគ្រប់រូប ជាម្ចាស់រោងចក្រ ។

- កសិករគ្រប់រូប ជាម្ចាស់ស្រែចំការ ។

- ពលករផ្សេងទៀត មានសិទ្ធិមានការងារធ្វើទាំងអស់ ។ ភាពគ្មានការងារធ្វើមិនមានដាច់ខាត ក្នុងកម្ពុជាប្រជាធិបតេយ្យ ។

## មាត្រា ១៣ :

ត្រូវមានសមភាពពេញទី រវាងប្រជាជនកម្ពុជាទាំងអស់ ក្នុងសង្គមកម្ពុជាមួយស្មើភាព យុត្តិធម៌ ប្រជាធិបតេយ្យ សុខដុមរមនា មានសុភមង្គល ក្នុងមហាសាមគ្គីជាតិទាំងមូល ដើម្បីការពារប្រទេស និងកសាងប្រទេសទាំងអស់គ្នា ។

បុរស នឹង នារី ស្មើភាពគ្នាពេញទី លើគ្រប់វិស័យទាំងអស់ ។ មិនអនុញ្ញាត្តឱ្យមានប្រពន្ធច្រើន និង ប្តីច្រើនឡើយ ។

## មាត្រា ១៤ :

ប្រជាជនកម្ពុជាគ្រប់រូប មានករណីយកិច្ច ការពារប្រទេស និងកសាងប្រទេស ទាំងអស់គ្នា តាមសមត្ថភាព និងលទ្ធភាពរបស់ខ្លួន ។

# ជំពូក ១០

# អំពី រដ្ឋធានី

## មាត្រា ១៥ :

រដ្ឋធានីរបស់កម្ពុជាប្រជាធិបតេយ្យ គឺ ភ្នំពេញ ។

# ជំពូក ១១

# អំពី ទង់ជាតិ

## មាត្រា ១៦ :

ទង់ជាតិកម្ពុជា មានរូបភាព និងខ្លឹមសារដូចតទៅ :

ផ្ទៃក្រហម មានរូបប្រាសាទកំពូលបីពណ៌លឿង នៅចំកណ្តាល ។

ផ្ទៃក្រហម ជានិមិត្តរូប នៃចលនាបដិវត្ត ការប្រយុទ្ធមោះមុត អង់អាចក្លាហាន ក្នុងការរំដោះជាតិ ការពារជាតិ និងកសាងជាតិកម្ពុជា របស់ប្រជាជនកម្ពុជា ។

ប្រាសាទពណ៌លឿង ជានិមិត្តរូបនៃប្រពៃណីជាតិ និងប្រជាជនកម្ពុជា ដែលជាអ្នកការពារប្រទេស ជាអ្នកស្ថាបនាប្រទេសឱ្យបានចំរុងចំរើនរុងរឿង ។

## ជំពូក ១២

## អំពី សញ្ញាជាតិ

### មាត្រា ១៧ :

សញ្ញាជាតិ គឺមានប្រព័ន្ធភ្លឺស្រែ និងប្រឡាយទឹក ជានិមិត្តរូបនៃកសិកម្ម ជឿនលឿន មានរោងចក្រ ជានិមិត្តរូបនៃឧស្សាហកម្ម មានកម្រងកួរស្រូវ ជាស្នែងក្របីព័ទ្ធពីក្រៅ ហើយមានអក្សរ កម្ពុជា ប្រជាធិបតេយ្យនៅពីក្រោម ។

## ជំពូក ១៣

## អំពី ភ្លេងជាតិ

### មាត្រា ១៨ :

ភ្លេងជាតិ នៃកម្ពុជា ប្រជាធិបតេយ្យ គឺ : "**១៧ មេសា មហាជោគជ័យ**"

## ជំពូក ១៤

## អំពី កងទ័ពបដិវត្តកម្ពុជា

### មាត្រា ១៩ :

កងទ័ពបដិវត្តកម្ពុជា ទាំងបីប្រភេទ ស្រួច តំបន់ ឈ្លប ជាកងទ័ពរបស់ ប្រជាជន ដែលយុទ្ធជន យុទ្ធនារី កម្មាភិបាល ជាកូនចៅរបស់ប្រជាជន កម្មករ កសិករ ពលករកម្ពុជា ផ្សេងទៀត ការពាររដ្ឋអំណាច របស់ប្រជាជនកម្ពុជា ការពារកម្ពុជា ឯករាជ ឯកភាព សន្តិភាព អព្យាក្រិត មិនចូលបក្សសម្ពន្ធណា អធិបតេយ្យ ប្រជាធិបតេយ្យ ក្នុងបូរណភាព

ដែនដី ហើយទន្ទឹមនឹងនេះ រួមចំណែកកសាងប្រទេសឱ្យថ្កុំថ្កើងរុងរឿង លើកស្ទួយជីវភាពប្រជាជន ឱ្យបានរីកចំរើន និងសំបូរសប្បាយជាលំដាប់ ។

## ជំពូក ១៥

## អំពី សិទ្ធិខាងជំនឿ និង សាសនា

### មាត្រា ២០ :

ប្រជាជនកម្ពុជាគ្រប់រូប មានសិទ្ធិជឿជំនឿ ឬសាសនាណាក៏បាន ហើយក៏មានសិទ្ធិមិនមានជំនឿអ្វី ឬក៏មិនជឿសាសនាណាក៏បាន ។

មិនអនុញ្ញាតឱ្យមានសាសនាប្រតិកិរិយា ដែលបំផ្លិចបំផ្លាញកម្ពុជា ប្រជាធិបតេយ្យ និងប្រជាជនកម្ពុជា ដាច់ខាត ។

## ជំពូក ១៦

## អំពី នយោបាយក្រៅប្រទេស

### មាត្រា ២១ :

កម្ពុជា ប្រជាធិបតេយ្យ មានសុឆន្ទៈដ៏មោះមុត ចង់មានចំណងមិត្តភាពយ៉ាងជិតស្និទ្ធ ជាមួយប្រទេសទាំងអស់ ដែលមានព្រំដែនជាប់ជាមួយខ្លួន ហើយនិងជាមួយប្រទេសជិតឆ្ងាយទាំងអស់ លើសកលលោក តាមគោលការណ៍ គោរពអធិបតេយ្យភាព និងបូរណភាពដែនដីគ្នា ទៅវិញទៅមក ដាច់ខាត ។

កម្ពុជា ប្រជាធិបតេយ្យ ប្រកាន់ខ្ជាប់នូវនយោបាយឯករាជ សន្តិភាព អព្យាក្រិត មិនចូលបក្សសម្ពន្ធណា មិនអនុញ្ញាតឱ្យបរទេសណាតាំងមូលដ្ឋានសឹក នៅក្នុងប្រទេសកម្ពុជា

ដាច់ខាត តស៊ូដាច់ខាតនឹងការជ្រៀតជ្រែកគ្រប់បែបយ៉ាង ពីខាងក្រៅ មកក្នុងកិច្ចការផ្ទៃក្នុង ប្រទេសកម្ពុជា តស៊ូដាច់ខាតនឹងអំពើវិទ្ធង្សនា ឈ្លានពានគ្រប់បែបយ៉ាងពីខាងក្រៅមកលើ ប្រទេសកម្ពុជា ទោះជាវិទ្ធង្សនា ឬឈ្លានពានខាងយោធាក្តី ខាងនយោបាយក្តី ខាងវប្បធម៌ក្តី ខាងសេដ្ឋកិច្ចក្តី ខាងសង្គមកិច្ចក្តី ខាងទូត ឬតាមរូបភាពយកនាមថាមនុស្សធម៌ក្តី ។

កម្ពុជា ប្រជាធិបតេយ្យ មិនជ្រៀតជ្រែកដាច់ខាត កិច្ចការផ្ទៃក្នុងប្រទេសណាទាំងអស់ ។ កម្ពុជា ប្រជាធិបតេយ្យ គោរពដាច់ខាត លក្ខការណ៍ដែលប្រទេសនីមួយៗ មានអធិបតេយ្យភាព និងមានសិទ្ធិអំណាច ចាត់ចែងនិងសំរេចកិច្ចការប្រទេសខ្លួន ដោយខ្លួនឯងពេញទី គ្មានការជ្រៀតជ្រែកពីខាងក្រៅ ។

កម្ពុជា ប្រជាធិបតេយ្យ ស្ថិតនៅក្នុងមហាគ្រួសារ ប្រទេសមិនចូលបក្សសម្ពន្ធណាដាច់ខាត។

កម្ពុជា ប្រជាធិបតេយ្យ ខិតខំបង្កើនសាមគ្គីភាព ជាមួយប្រជាជនតតិយលោក នៅអាស៊ី អាហ្វ្រិក អាមេរិកឡាទីន ហើយនិងប្រជាជន ដែលស្នេហាសន្តិភាព និងយុត្តិធម៌ ក្នុងសកលលោកទាំងមូល ជួយឧបត្ថម្ភគ្នាទៅវិញទៅមកយ៉ាងសកម្ម ក្នុងការតស៊ូនឹងចក្រពត្តិនិយម អាណានិគមនិយមចាស់ ថ្មី ដើម្បីឯករាជភាព សន្តិភាព មិត្តភាព ប្រជាធិបតេយ្យ យុត្តិធម៌ និងវឌ្ឍនភាព ពិតប្រាកដនៅលើសកលលោក។

# រដ្ឋធម្មនុញ្ញ

# នៃ

# សាធារណរដ្ឋប្រជាមានិតកម្ពុជា




**សញ្ញាជាតិ**
នៃ
សាធារណរដ្ឋប្រជាមានិតកម្ពុជា



ទង់ជាតិ

នៃ

សាធារណរដ្ឋប្រជាមានិតកម្ពុជា



# បុព្វកថា

អស់រយៈកាលជាច្រើនពាន់ឆ្នាំមកហើយ ប្រជាជនកម្ពុជាបានតស៊ូដើម្បីកសាង និងការពារមាតុប្រទេសជាទីស្នេហាដែលមានអារ្យធម៌អង្គរជាសក្ខីភាព និងជាមោទនភាព ។ ប៉ុន្តែក្រោមការជិះជាន់ហួងហែងរបស់របបទាសភាព សក្តិភូមិ និងរបស់អាណានិគមនិយមចក្រពត្រនិយម ប្រជាជនកម្ពុជាមិនបានទទួលសមិទ្ធផលនៃស្នាដៃរបស់ខ្លួន ហើយមិនបានពង្រីកប្រពៃណីជាតិ វប្បធម៌ជាតិដ៏ថ្លៃថ្នូរ អត្តចរិតមនុស្សធម៌ និងសុខសន្តិភាពរបស់ខ្លួនបន្តិចសោះឡើយ ។

នៅចុងសតវត្សទី ១៩ ពួកអាណានិគមនិយមបារាំង បានឈ្លានពានចូលមកយកទឹកដីកម្ពុជា ទឹកដីវៀតណាម និងទឹកដីឡាវធ្វើជាអាណានិគមរបស់វា ។ ស្ថិតក្នុងស្ថានភាពដូចគ្នា ប្រជាជនកម្ពុជា រួមកម្លាំងគ្នាយ៉ាងជិតស្និទ្ធ ជាមួយប្រជាជនវៀតណាម និងប្រជាជនឡាវ បានតស៊ូប្រឆាំងនឹងសត្រូវរួម ។ ការតស៊ូរបស់ប្រជាជនកម្ពុជា និងការតស៊ូរបស់ប្រជាជននៅឥណ្ឌូចិន ជាវិភាគទានមួយយ៉ាងសំខាន់ក្នុងការតស៊ូរួម នៃប្រជាជនលើសាកលលោកប្រឆាំងនឹងអាណានិគមនិយម ចក្រពត្រនិយម ។

ប៉ុន្តែ ចក្រពត្រអាមេរិក ជាមេក្លោង និងជាអាវុធហត្ថរបស់ចក្រពត្រនិយមសាកលលោក បានប្រើកលល្បិចគ្រប់បែបយ៉ាងមានការជ្រៀតជ្រែកកិច្ចការផ្ទៃក្នុង និងការឈ្លានពានដោយកម្លាំងអាវុធ ដើម្បីដាក់នឹមត្រួតត្រាអាណានិគមនិយមបែបថ្មី តាមរបៀបអាមេរិកមកលើឧបទ្វីបឥណ្ឌូចិនទាំងមូល ។ ប្រជាជនកម្ពុជាបានក្រោកឈរឡើងជាថ្មីម្តងទៀត តស៊ូ

ប្រឆាំងនឹងចក្រពត្រឈ្លានពាន ។ នៅដើមឆ្នាំ ១៩៧៥ ប្រជាជនកម្ពុជារួមសហការយ៉ាងជិតស្និទ្ធជាមួយកងកម្លាំងតស៊ូនៅប្រទេសវៀតណាម និងនៅប្រទេស ឡាវ បានបើកការវាយសំរុកផ្ទួនៗ ហើយបានទទួលជ័យជំនះជាបន្តបន្ទាប់លើពួកចក្រពត្រអាមេរិក និងបរិវាររបស់វា។ ជ័យជំនះរបស់ប្រជាជននៃប្រទេសទាំងបីនៅឥណ្ឌូចិនក្នុងការតស៊ូប្រឆាំងនឹងចក្រពត្រអាមេរិក បានកត់សំគាល់ជាថ្មីម្តងទៀត នូវជ័យជំនះក្នុងយុគសម័យតស៊ូប្រឆាំងនឹងលទ្ធិអាណានិគមនិយមបែបថ្មី នៅលើសាកលលោក ។

ក្រោយជ័យជំនះជាប្រវត្តិសាស្ត្រនាថ្ងៃ ១៧ មេសា ១៩៧៥ គួរណាស់តែប្រជាជនកម្ពុជា បានរស់នៅក្នុងសន្តិភាព ឯករាជ្យ និងសេរីភាព ដើម្បីកសាងប្រទេសជាតិឡើងវិញ ប៉ុន្តែពួក ប៉ុល-ពត អៀង-សារី ខៀវ-សំផន បានប្លន់យកសមិទ្ធផលបដិវត្តន៏មកក្តាប់ក្នុងដៃរបស់វា ហើយលក់ខ្លួនធ្វើជាបរិវារដាច់ថ្លៃអោយពួកវាតទីនិយម អនុត្តរភាពនិយមនៃអ្នកកាន់អំណាចចិនប៉េកាំង ។ ក្នុងរយៈកាលកាន់អំណាចតែជិតបួនឆ្នាំប៉ុណ្ណោះ ពួកវាបានកំទេចអស់សមិទ្ធផលបដិវត្តន៏ បានសម្លាប់ប្រជាជនស្លូតត្រង់អស់រាប់លាននាក់ បានជាន់ឈ្លីសិទ្ធិជាមូលដ្ឋានរបស់មនុស្សជាតិ បំផ្លាញចោលអស់មូលដ្ឋានសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌នៃទឹកដីកម្ពុជាដ៏ស្រស់បំព្រងរបស់យើង ។ តាមបញ្ជារបស់ពួកប្រតិកិរិយានៃមជ្ឈដ្ឋានអ្នកកាន់អំណាចចិន ពួកវាបានបញ្ជូនកងទ័ពជាច្រើនកងពលទៅឈ្លានពានទឹកដីវៀតណាម កាប់សម្លាប់ប្រជាជនស្លូតត្រង់ជាអ្នកភូមិផងរបងជាមួយ ដែលធ្លាប់បានរួមប្រយុទ្ធក្នុងលេណដ្ឋានតែមួយ ធ្លាប់ដណ្តើមបានជ័យជំនះយ៉ាងត្រចះត្រចង់ក្នុងការតស៊ូប្រឆាំងនឹងចក្រពត្តិអាមេរិក ។ នៅចំពោះគ្រោះប្រល័យពូជសាសន៏ និងគ្រោះបាត់បង់ទឹកដី ក្នុងកណ្តាប់ដៃរបស់ពួកប្រតិ-

កិរិយាចិនប៉េកាំង ប្រជាជនកម្ពុជាបានកំណត់ថា ផ្លូវតែមួយដើម្បីរស់ គឺត្រូវកំទេចរបបដ៏សាហាវយង់ឃ្នង ប៉ុល-ពត អៀង-សារី ខៀវ-សំផន ។ ដោយសារមានមាគ៌ានយោបាយភ្លឺស្វាងរបស់បក្ស និងដោយសារមានសាមគ្គីភាព យ៉ាងជិតស្និទ្ធក្នុងរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ព្រមទាំងដោយសារមានការឧបត្ថម្ភពីប្រជាជន និងកងទ័ពវៀតណាម ហើយនិងការគាំទ្រពីប្រទេសសង្គមនិយមជាបងប្អូន និងពីប្រជាជនស្នេហាសន្តិភាពលើសាកលលោក ប្រជាជនកម្ពុជាយើង បានវាយរំលំរបបប្រល័យពូជសាសន៍ជាស្ថាពរនាថ្ងៃ ៧ មករា ឆ្នាំ១៩៧៩ ។ ការចាត់តាំងរដ្ឋអំណាចប្រជាជន និងការគ្រប់គ្រងលើទឹកដីកម្ពុជាទាំងមូលរបស់ក្រុមប្រឹក្សាប្រជាជនបដិវត្តកម្ពុជាក៏បានធ្វើឡើងដោយឆាប់រហ័ស ។ ជ័យជំនះដ៏ត្រចះត្រចង់នេះបានបើកទំព័រប្រវត្តិសាស្ត្រថ្មីមួយ ហើយបាននាំមកជូនប្រជាជនយើង នូវឯករាជ្យ សេរីភាព ប្រជា-ធិបតេយ្យនិងសិទ្ធិធ្វើជាម្ចាស់ លើជោគវាសនារបស់ខ្លួនពិតប្រាកដ ដើម្បីកសាងប្រទេសកម្ពុជាជាទីស្នេហានៃយើងឡើងវិញ អោយសមស្របតាមគោលបំណងដ៏ត្រឹមត្រូវរបស់យើង ។ ពួកវាតទីនិយម អនុត្តរភាពនិយមចិនប៉េកាំង បានឃុបឃិតជាមួយចក្រពត្តិអាមេរិក និងអានុភាពប្រតិកិរិយាផ្សេងទៀតយ៉ាងឆ្កួតលីលា ក្នុងគោលបំណងបំផ្លិចបំផ្លាញបដិវត្តន៍របស់យើង ។ ប៉ុន្តែសភាពការណ៍នៅប្រទេសកម្ពុជាយើង មិនអាចប្រែក្រឡាស់បានឡើយ ។ ប្រជាជនកម្ពុជាប្រាកដជាឈ្នះ ខ្មាំងសត្រូវប្រាកដជាចាញ់ដាច់ខាត ។

ប្រវត្តិសាស្ត្រតស៊ូប្រកបទៅដោយជ័យជំនះ នៃប្រជាជនកម្ពុជាយើង បានបញ្ជាក់យ៉ាងច្បាស់នូវសច្ចធម៌មួយគឺ : ដោយមានមាគ៌ាដឹកនាំដ៏ត្រឹមត្រូវរបស់បក្ស ប្រជាជនកម្ពុជាទាំងមូលរួមសាមគ្គីជាធ្លុងមួយ តស៊ូយ៉ាងអង់អាចក្លាហាន រួមសាមគ្គី និងសហប្រតិបត្តិការ

យ៉ាងជិតស្និទ្ធជាមួយប្រជាជនវៀតណាម ប្រជាជនឡាវ និងប្រជាជននៃប្រទេសសង្គមនិយមឯទៀតជាបងប្អូន និងដោយមានការស្រុះចិត្ត និង ការគាំទ្រពីប្រជាជនស្នេហាសន្តិភាពនិងយុត្តិធម៌លើសាកលលោកផងនោះ ជាកម្លាំងខ្លាំងក្លាដើម្បីឈ្នះ ។

រដ្ឋធម្មនុញ្ញ នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ជាលទ្ធផលនៃការតស៊ូយូរអង្វែងពោរពេញទៅដោយការលំបាកវេទនារបស់ប្រជាជនយើងទាំងមូល ក្នុងកិច្ចការពារឯករាជជាតិអោយរឹងមាំ កសាងមាតុប្រទេស ឈានជាជំហាន ៗ ឆ្ពោះឡើងសង្គមនិយម ។ ប្រជាជនយើងរឹតចំណងសាមគ្គីភាពជាតិជាធ្លុងមួយ លើកជ្រោងទង់ស្នេហាជាតិ និងទង់សាមគ្គីអន្តរជាតិវណ្ណៈអធន អនុវត្តយ៉ាងម៉ឺងម៉ាត់នូវរដ្ឋធម្មនុញ្ញនេះ ប្តេជ្ញាខិតខំដណ្តើមយកជ័យជំនះក្នុងបុព្វហេតុកសាងទឹកដីកម្ពុជា ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គលដ៏ឧត្តម ។

អ្វី ៗ ទាំងអស់ គឺដើម្បីបំរើផលប្រយោជន៍ឧត្តុង្គឧត្តម នៃមាតុប្រទេស និង ដើម្បីសុភមង្គលរបស់ប្រជាជន ។

ជយោ ! សាធារណរដ្ឋប្រជាមានិតកម្ពុជា ។

# ជំពូកទី១

## ព្រះរាជាណាចក្រ

### មាត្រា ១

ប្រទេសកម្ពុជា មាននាមជាផ្លូវការថា " សាធារណរដ្ឋប្រជាមានិតកម្ពុជា " ។

សាធារណរដ្ឋប្រជាមានិតកម្ពុជា ជារដ្ឋមួយមានឯករាជ្យ អធិបតេយ្យ បូរណភាពដែនដី សន្តិភាព ប្រជាធិបតេយ្យ ឈានជាជំហាន ៗ ឆ្ពោះឡើងសង្គមនិយម ។

អធិបតេយ្យ នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា លាតសន្ធឹងលើដែនដីគោក ដែនកោះ ដែនទឹក ដែនសមុទ្រ បាតសមុទ្រនិងក្រោមបាតសមុទ្រ ហើយនិងដែនអាកាស ។

បាវចនា នៃសាធារណរដ្ឋប្រជាមានិតកម្ពុជាគឺ : ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល ។

ភាសា និង អក្សរដែលប្រើជាផ្លូវការ គឺភាសា និងអក្សរខ្មែរ ។

### មាត្រា ២

ប្រជាជនកម្ពុជា ជាម្ចាស់វាសនានៃប្រទេសរបស់ខ្លួន ។ អំណាចទាំងអស់ជារបស់ប្រជាជន ។

ប្រជាជនប្រើរដ្ឋអំណាច តាមរយៈរដ្ឋសភា និងអង្គការរដ្ឋអំណាចនានា ដែលប្រជាជនជ្រើសតាំងឡើង និងទទួលខុសត្រូវចំពោះប្រជាជន ។ ប្រជាជន មានសិទ្ធិដកហូតតំណាងរូបណាដែលខ្លួនឈប់ទុកចិត្ត ។

រដ្ឋមានភារកិច្ចការពារឯករាជ្យនៃមាតុប្រទេស សេរីភាពរបស់ប្រជាជន សមិទ្ធផលរបស់បដិវត្តន៍ ស្តារនិងពង្រីកផលិតកម្ម ពង្រីកវប្បធម៌ យកចិត្តទុកដាក់ដោះស្រាយ និងលើកដំកើងជីវភាពរស់នៅរបស់ប្រជាជន ទាំងខាងសម្ភារៈ ទាំងខាងស្មារតី ។

ស្ថាប័នរដ្ឋនានា ត្រូវចាត់តាំង និងប្រព្រឹត្តអោយស្របតាមរដ្ឋធម្មនុញ្ញ និងច្បាប់ នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ។

## មាត្រា ៣

រណសិរ្សកសាងមាតុភូមិកម្ពុជា អង្គការមហាជនបដិវត្តនានាជាបង្អែកដ៏រឹងមាំរបស់រដ្ឋ លើកទឹកចិត្តប្រជាជនអោយអនុវត្តរាល់ភារកិច្ចបដិវត្ត ។

## មាត្រា ៤

បក្សប្រជាជនបដិវត្តកម្ពុជា ជាកម្លាំងដឹកនាំផ្ទាល់ នូវការងារបដិវត្តទាំងមូល នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ។

## មាត្រា ៥

រដ្ឋអនុវត្តនយោបាយសាមគ្គីភាព និងស្មើភាពរវាងជនជាតិទាំងអស់ ដែលរស់នៅក្នុងសហគមន៍ជាតិកម្ពុជា ។

ជនជាតិទាំងអស់ត្រូវស្រឡាញ់រាប់អានគ្នា និងជួយគ្នាទៅវិញទៅមក។ អំពើប្រមាថមាក់ងាយ អំពើជិះជាន់ និងការបែងចែកជនជាតិនានា ត្រូវហាមឃាត់ ។

ភាសា និងអក្សរ ព្រមទាំងទំនៀមទំលាប់ល្អ ៗ របស់ជនជាតិភាគតិច ត្រូវបានគោរព ។

គ្រប់ជនជាតិភាគតិច ត្រូវបានរដ្ឋជួយទំនុកបំរុង ដើម្បីអោយតាមទាន់កិរិតរួម ។ រដ្ឋ

យកចិត្តទុកដាក់ជាពិសេស ពង្រីកសេដ្ឋកិច្ច សិក្សាធិការ វប្បធម៌ សង្គមកិច្ច សុខាភិបាល គមនាគមន៍នៅតាមតំបន់ព្រៃភ្នំ និងតំបន់ដាច់ស្រយាល ។

## មាត្រា ៦

សេរីភាពខាងជំនឿ ត្រូវបានគោរព ។

សកម្មភាពខាងសាសនាទាំងឡាយ ដែលស្របរដ្ឋធម្មនុញ្ញ និងច្បាប់ ត្រូវបានរដ្ឋធានា ។

សកម្មភាពណាដែលឆ្លៀតយកសាសនា ដើម្បីធ្វើអោយប៉ះពាល់ដល់សន្តិសុខ របៀបរៀបរយសាធារណៈនិងផលប្រយោជន៍របស់ប្រជាជន ត្រូវហាមឃាត់ ។

## មាត្រា ៧

បុរស និង ស្ត្រី មានសិទ្ធិស្មើគ្នា ក្នុងអាពាហ៍ពិពាហ៍ និងក្នុងគ្រួសារ ។ អាពាហ៍ពិពាហ៍ ត្រូវធ្វើតាមល័ក្ខខ័ណ្ឌដែលបានចែងក្នុងច្បាប់ និងតាមល័ក្ខការណ៍ស្ម័គ្រចិត្ត ជឿនលឿន ប្តីមួយប្រពន្ធមួយ ។ ការបង្ខិតបង្ខំក្នុងអាពាហ៍ពិពាហ៍ ត្រូវហាមឃាត់ ។

រដ្ឋយកចិត្តទុកដាក់ជាពិសេស ចំពោះកិច្ចការពារ មាតា និង កុមារ ។

## មាត្រា ៨

សិទ្ធិ និងករណីយកិច្ចសំខាន់របស់មាតាបិតា គឺអប់រំ និងថែទាំចិញ្ចឹមកូន ដើម្បីអោយទៅជាពលរដ្ឋល្អ មានមនសិការស្នេហាជាតិ ស្រឡាញ់ការងារពលកម្ម មានសម្បជញ្ញៈទទួលខុសត្រូវចំពោះសង្គម ។

កូនមានកាតព្វកិច្ចបីបាច់ថែរក្សា មាតា បិតា ។

## មាត្រា ៩

សាធារណរដ្ឋប្រជាមានិតកម្ពុជា អនុវត្តល័ក្ខការណ៍ : ប្រជាជនទាំងមូលរួមប្រាស្រ័យក្នុងកិច្ចកសាងនិងការពារមាតុប្រទេស ។

កងកម្លាំងប្រដាប់អាវុធប្រជាជនបដិវត្តកម្ពុជា ទាំងបីប្រភេទនិងនគរបាលប្រជាជនជាកូនចៅរបស់ប្រជាជន ត្រូវស្មោះត្រង់ចំពោះមាតុប្រទេសនិងប្រជាជន មានករណីយកិច្ចការពារមាតុភូមិ និងរដ្ឋអំណាចបដិវត្ត ការពារសមិទ្ធផលបដិវត្តន៍ និងការរស់នៅដ៏សុខសាន្តរបស់ប្រជាជន ហើយរួមជាមួយប្រជាជនកសាងប្រទេស ។

កងកម្លាំងប្រដាប់អាវុធទាំងអស់ ត្រូវមានការប៉ិនប្រសប់ក្នុងការប្រយុទ្ធ ក្នុងការបង្កបង្កើនផល ត្រូវចេះបំផុសចលនាប្រជាជន គោរព និងជួយទំនុកបំរុងប្រជាជន មិនត្រូវប៉ះពាល់ដល់ផលប្រយោជន៏របស់ប្រជាជន ត្រូវធ្វើយ៉ាងណាអោយសមនឹងការស្រឡាញ់រាប់អាន និងការទុកចិត្តរបស់ប្រជាជន ។

## មាត្រា ១០

គោលនយោបាយក្រៅប្រទេសនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា គឺ ឯករាជ្យសន្តិភាព និង មិនចូលបក្សសម្ព័ន្ធ ។

សាធារណរដ្ឋប្រជាមានិតកម្ពុជា រឹតចំណងសាមគ្គីភាព និងសហប្រតិបត្តិការជាមួយវៀតណាម ឡាវ សហភាពសូវៀត និងប្រទេសសង្គមនិយមជាបងប្អូនឯទៀត ។

សាធារណរដ្ឋប្រជាមានិតកម្ពុជា ចូលរួមប្រាស្រ័យយ៉ាងសកម្មក្នុងការតស៊ូ នៃចលនាមិនចូលបក្សសម្ព័ន្ធ ដើម្បីការពារឯករាជ្យ អធិបតេយ្យនៃប្រជាជាតិទាំងឡាយ ការពារសន្តិភាព

និងសន្តិសុខអន្តរជាតិ ឈានដល់ការកសាងរបបសេដ្ឋកិច្ចថ្មីមួយនៅលើសាកលលោក ។

សាធារណរដ្ឋប្រជាមានិតកម្ពុជា គាំទ្រយ៉ាងសកម្មដល់ការតស៊ូ នៃប្រជាជននៅលើសាកលលោក ប្រឆាំងនឹងចក្រពត្តិនិយម អាណានិគមនិយម ចាស់ និងថ្មី រ៉ាតទីនិយមចិនប៉េកាំង លទ្ធិប្រកាន់ពូជសាសន៍ និងអានុភាពប្រតិកិរិយាទាំងឡាយជាបរិវាររបស់ពួកវា ដើម្បីសន្តិភាព និងឯករាជជាតិ ប្រជាធិបតេយ្យ វឌ្ឍនភាពសង្គម ។

---

## ជំពូកទី២

## របបសេដ្ឋកិច្ច

## និង គោលនយោបាយ

## វប្បធម៌_សង្គមកិច្ច

### មាត្រា ១១

សេដ្ឋកិច្ចជាតិ ស្ថិតនៅក្រោមការដឹកនាំរបស់រដ្ឋ ។

រដ្ឋលើកស្ទួយជីវភាពរបស់ប្រជាជន អោយមានកំរិតខ្ពស់ជាលំដាប់លើគ្រប់ផ្នែកដើម្បីកសាងប្រទេសជាតិ ។

### មាត្រា ១២

សេដ្ឋកិច្ចជាតិមានបីផ្នែក : សេដ្ឋកិច្ចរដ្ឋ សេដ្ឋកិច្ចសមូហភាព សេដ្ឋកិច្ចគ្រួសារ និងសេដ្ឋកិច្ចឯកជន។

ឆ្លង:

រដ្ឋគ្រប់គ្រងសហគ្រាសរដ្ឋយ៉ាងជិតដិត ដើម្បីពង្រីកតួនាទីសំខាន់នៃផ្នែកសេដ្ឋកិច្ចរដ្ឋក្នុងសេដ្ឋកិច្ចជាតិ ហើយទន្ទឹមនឹងនោះ ជួយទំនុកបំរុង និងណែនាំយ៉ាងសកម្ម នូវការកសាងសេដ្ឋកិច្ចសម្ូហភាព សេដ្ឋកិច្ចគ្រួសារ និងសេដ្ឋកិច្ចឯកជន អោយរីកចំរើន តាមទិសដែលមានប្រយោជន៏ដល់រដ្ឋ និងដល់ជីវភាពរបស់ប្រជាជន ។

## មាត្រា ១៣

រដ្ឋយកចិត្តទុកដាក់ ពង្រីកផលិតកម្មកសិកម្ម ផលិតកម្មឧស្សាហកម្ម ដែលបំរើកសិកម្ម ពង្រីកផលិតកម្មរបស់ប្រើប្រាស់ ពង្រីកពាណិជ្ជកម្ម គមនាគមន៏ និងការដឹកជញ្ជូន ។ រដ្ឋជួយទំនុកបំរុងនិងពង្រីកសិប្បកម្ម និងឧស្សាហកម្មតូចៗ ។

## មាត្រា ១៤

ទ្រព្យសម្បត្តិជាកម្មសិទ្ធិរបស់រដ្ឋមាន ដីធ្លី ព្រៃឈើ សមុទ្រ ទន្លេ បឹង ធនធានធម្មជាតិ មជ្ឈមណ្ឌលសេដ្ឋកិច្ច វប្បធម៌ មូលដ្ឋានការពារប្រទេស និងសំណង់ផ្សេងៗទៀតរបស់រដ្ឋ ។

## មាត្រា ១៥

ពលរដ្ឋ មានសិទ្ធិពេញទី ក្នុងការប្រើប្រាស់ និងមានសិទ្ធិតំណមរតកលើដីដែលរដ្ឋប្រគល់អោយគ្រួសារនីមួយៗតាមកំណត់នៃច្បាប់ ដើម្បីសង់ផ្ទះនៅ និងធ្វើជាសួនច្បារ សួនបន្លែ ។

## មាត្រា ១៦

ក្រៅពីដីសំរាប់សង់ផ្ទះនៅ និងធ្វើជាសួនច្បារ សួនបន្លែដែលមានកំណត់ក្នុងច្បាប់ និងក្រៅពីចំណែកដីដែលក្រុមសាមគ្គីបង្កបង្កើនផលបានប្រគល់អោយ ដើម្បីបំពេញផលិតកម្ម របស់ក្រុម ពលករកសិកម្មមួយរូបៗ អាចបានរដ្ឋអោយខ្ចីដីជាបន្ថែម ដើម្បីដាំដំណាំរដូវ តាម លទ្ធភាពពលកម្ម ហើយមានសិទ្ធិទទួលផលនៃការងារនេះ ។

## មាត្រា ១៧

ជនណាក៏ដោយគ្មានសិទ្ធិ ទិញ លក់ បញ្ចាំ ឬ ប្រវាស់ដីធ្លីបានឡើយ ។ ជនណាក៏ ដោយមិនអាចប្រើប្រាស់ដីធ្លីកសិកម្ម ដីព្រៃដោយចិត្តឯង ក្នុងគោលបំណងផ្សេងទៀតបាន បើ គ្មានការអនុញ្ញាតពីក្រសួងមានសមត្ថកិច្ច ។

## មាត្រា ១៨

កម្មសិទ្ធិឯកជន នៃពលរដ្ឋ លើកំរៃការងារ លើកំរៃនិងទ្រព្យសម្បត្តិស្របច្បាប់ផ្សេង ទៀត ត្រូវបានច្បាប់ការពារ ។ ការរឹបអូសទ្រព្យសម្បត្តិរបស់ពលរដ្ឋដោយរំលោភ ត្រូវហាម ឃាត់ជាដាច់ខាត ។

## មាត្រា ១៩

ពាណិជ្ជកម្មក្នុងប្រទេសរបស់រដ្ឋ ត្រូវពង្រីក ដើម្បីបង្កើនសកម្មភាពផ្លាស់ប្តូរមុខ ទំនិញ ជំរុញការបង្កបង្កើនផល បំរើជីវភាពរបស់ប្រជាជន ។

ពលរដ្ឋ អាចលក់ដូរផលិតផលកសិកម្ម និងផលិតផលសិប្បកម្មគ្រួសារ ។ ការទិញ និងការលក់របស់ប្រជាជន ដែលស្របតាមគោលនយោបាយរបស់រដ្ឋ ត្រូវបានច្បាប់ធានា ។

ពាណិជ្ជកម្មក្រៅប្រទេស ស្ថិតនៅក្នុងការគ្រប់គ្រងផ្ទាច់មុខរបស់រដ្ឋ ។

## មាត្រា ២០

របបគ្រប់គ្រងរូបិយវត្ថុ និងប្រព័ន្ធហិរញ្ញវត្ថុ ត្រូវកំណត់ក្នុងច្បាប់ ។

ការយកពន្ធដារ នឹងអាចធ្វើទៅបាន លុះត្រាតែមានច្បាប់អនុញ្ញាត ។

ការតម្រូវអោយលក់ជូនរដ្ឋ ឬ ការយកទៅប្រើប្រាស់មួយរយៈនូវសម្បត្តិឯកជន នឹងអាចធ្វើទៅបាន លុះត្រាតែមានច្បាប់អនុញ្ញាត ។

## មាត្រា ២១

រដ្ឋយកចិត្តទុកដាក់កសាងវប្បធម៌ជាតិជឿនលឿន ពង្រីកភាសា និង អក្សរជាតិ ដែលសមស្របនឹងសេចក្តីត្រូវការនៃសង្គមថ្មីមួយ ។ រាល់ឥទ្ធិពល និង សំណល់ នៃវប្បធម៌ប្រតិកិរិយាពុករលួយ ត្រូវកំចាត់ចោលជាដាច់ខាត ។

## មាត្រា ២២

រដ្ឋអនុវត្តកម្មវិធីសិក្សា តាមគោលការណ៍គរុកោសល្យដោយផ្សារភ្ជាប់ការសិក្សាចំណេះវិជ្ជាទូទៅ ជាមួយនឹងការអនុវត្តន៍ ផ្សារភ្ជាប់ការអប់រំជាមួយនឹងការបង្កបង្កើនផល ផ្សារភ្ជាប់សាលារៀនជាមួយនឹងសង្គម ។

រដ្ឋបើកមត្តេយ្យសាលា សំរាប់អប់រំកុមារមុនគ្រប់វ័យសិក្សា ។

រដ្ឋទទួលខុសត្រូវ លើការអប់រំវិជ្ជាទូទៅ ដល់កុមារគ្រប់វ័យសិក្សា ដោយកសាងសាលារៀនបឋមសិក្សា ដោយពង្រីកជាបណ្តើរៗនូវសាលារៀនមធ្យមសិក្សា សាលារៀននិង

ថ្នាក់អប់រំវិជ្ជាជីវៈ ថ្នាក់ជាន់ខ្ពស់ផ្សេងៗ និងឧត្តមសិក្សា ដើម្បីតម្រូវតាមការចាំបាច់នៃប្រទេសជាតិ ដែលកំពុងឈានទៅកាន់វឌ្ឍនភាព ។

រដ្ឋលើកទឹកចិត្ត និងផ្តល់អាហារូបករណ៍សិក្សាដល់យុវជនដែលមានសមត្ថភាពអាចបន្តការសិក្សានៅថ្នាក់ខ្ពស់ និងថ្នាក់បច្ចេកទេស នៅក្នុងប្រទេស និង ក្រៅប្រទេស ។

ដើម្បីបំបាត់ភាពមិនចេះអក្សរនិងដើម្បីលើកកំរិតវប្បធម៌ ដល់ពលរដ្ឋទូទៅអោយបានខ្ពស់ រដ្ឋជំរុញចលនាអក្ខរកម្ម ដោយបើកថ្នាក់សិក្សាសំរាប់មនុស្សចាស់ ដែលមិនទាន់ចេះអក្សរ និងថ្នាក់អប់រំបំពេញវិជ្ជាផ្សេងៗទៀត តម្រូវទៅតាមការចាំបាច់របស់ប្រទេសជាតិ ។

## មាត្រា ២៣

រដ្ឋយកចិត្តទុកដាក់ជំរុញការលូតលាស់ វិទ្យាសាស្ត្រ និង បច្ចេកទេស អក្សរសាស្ត្រនិងសិល្បៈ ដោយពង្រីកប្រព័ន្ធសិក្សាធិការ ជំរុញការងារស្រាវជ្រាវ ដោយរួមផ្សំការរៀនសូត្រខាងទ្រឹស្តីទៅនឹងការជាក់ស្តែង ។ រដ្ឋលើកទឹកចិត្តដល់អ្នកវិទ្យាសាស្ត្រ អ្នកបច្ចេកទេស អ្នកនិពន្ធ សិល្បករ ក្នុងសកម្មភាពច្នៃប្រឌិតរបស់ខ្លួនដែលមានប្រយោជន៍ដល់ប្រទេសជាតិ និងប្រជាជន ដោយជួយទំនុកបំរុងដល់អ្នកទាំងនោះខាងផ្នែកសម្ភារៈនិងខាងផ្លូវចិត្ត ។

រដ្ឋបង្កើនសហប្រតិបត្តិការជាមួយប្រទេសសង្គមនិយមជាបងប្អូន និងផ្លាស់ប្តូរការពិសោធន៍គ្នាទៅវិញទៅមក ។ រដ្ឋពង្រីកការទាក់ទងជាមួយប្រទេសផ្សេងៗទៀត ។

## មាត្រា ២៤

រដ្ឋចាត់ចែងអោយថែរក្សាប្រាសាទបុរាណ និងសិល្បវត្ថុបុរាណ កែលំអតំបន់ទេសភាពនានាឡើងវិញ ពង្រីកផ្នែកទេសចរណ៍ ដើម្បីបំរើប្រជាជនក្នុងប្រទេស និងពង្រីកការ

ទាក់ទងខាងវប្បធម៌ ជាមួយប្រទេសក្រៅ ។

## មាត្រា ២៥

រដ្ឋយកចិត្តទុកដាក់ដល់ការរីកចំរើន ខាងរូបកាយរបស់ពលរដ្ឋ លើកទឹកចិត្តដល់សកម្មភាពខាងកីឡា និងខាងហាត់ប្រាណសំដៅធ្វើអោយពលរដ្ឋ មានកម្លាំងពលំមាំមួនជាចាំបាច់ ដើម្បីជំរុញផលិតកម្ម និងចូលរួមយ៉ាងសកម្មក្នុងកិច្ចការពារជាតិ ។

## មាត្រា ២៦

ដើម្បីធានាដល់សុខភាពរបស់ប្រជាជន រដ្ឋយកចិត្តទុកដាក់ដល់ការការពារជម្ងឺ និងព្យាបាលជម្ងឺ ណែនាំប្រជាជនអោយកាន់ក្បួនអនាម័យយ៉ាងខ្ជាប់ខ្ជួន ។ ប្រជាជនត្រូវបានទទួលការពិនិត្យរោគដោយឥតបង់ថ្លៃ ។ រដ្ឋបង្កើតមន្ទីរពេទ្យនានា ធ្វើការស្រាវជ្រាវខាងវេជ្ជសាស្ត្រ និងឱសថសាស្ត្រ ដោយរួមផ្សំវេជ្ជសាស្ត្របូរាណជាមួយវេជ្ជសាស្ត្រសម័យ ។

## មាត្រា ២៧

រដ្ឋយកចិត្តទុកដាក់ ចំពោះមាតានិងកុមារ ។ រដ្ឋនិងសង្គមរៀបចំអោយមាន មន្ទីរសម្ភព ទារកដ្ឋាន សួនកុមារ និងអនុវត្តនូវវិធានការសមស្របនានា ដើម្បីសំរាលបន្ទុកមេផ្ទះដល់ស្ត្រី និងរ៉ាប់រងលក្ខណៈចាំបាច់អោយស្ត្រី មានលទ្ធភាពចូលរួមក្នុងសកម្មភាពសង្គមដូចបុរសដែរ ។

ស្ត្រីកម្មករ បុគ្គលិក ត្រូវបានឈប់សំរាកក្នុងពេលសំរាលកូនចំនួន ៩០ ថ្ងៃ ដោយបានទទួលបៀវត្ស ។ ស្ត្រីមានកូននៅបៅដោះត្រូវបានទទួលការបន្ថយពេលធ្វើការប្រចាំថ្ងៃ និងបានទទួលអត្ថប្រយោជន៍នានាតាមការកំណត់របស់រដ្ឋ ។

រដ្ឋនឹងកំណត់បទបញ្ញត្តិជាក់ស្តែង ចំពោះស្ត្រីធ្វើការ ក្រៅផ្ទៃករដ្ឋ ។

## មាត្រា ២៨

រដ្ឋយកចិត្តទុកដាក់ជាពិសេស ដល់អ្នកដែលធ្វើសកម្មភាពបដិវត្តយូរឆ្នាំ ហើយដែលបានរួមវិភាគទានច្រើនអោយបដិវត្តន៍ដល់យុទ្ធជនពិការ ដល់គ្រួសារយុទ្ធជនដែលបានទទួលមរណៈដើម្បីបដិវត្តន៍ និងដល់គ្រួសារដែលមានសគុណធំៗចំពោះបដិវត្តន៍ ។

## មាត្រា ២៩

រដ្ឋចាត់ចែងអោយមានរបបធានារ៉ាប់រងសង្គម ដល់កម្មាភិបាល បុគ្គលិក កម្មករដែលអស់លទ្ធភាពបំពេញពលកម្មបណ្តាលមកពីមានជម្ងឺ ជរាភាព ឬ ពិការដោយគ្រោះថ្នាក់ក្នុងការងារ ។

រដ្ឋនិងសង្គម ជួយទំនុកបំរុងដល់មនុស្សចាស់ជរា ជនពិការ ស្ត្រីមេម៉ាយ និង ក្មេងកំព្រាគ្មានទីពឹង ។

---

# ជំពូកទី៣

# សិទ្ធិ និង ករណីយកិច្ច

# របស់ពលរដ្ឋ

## មាត្រា ៣០

សាធារណរដ្ឋប្រជាមានិតកម្ពុជា ទទួលស្គាល់និងគោរពសិទ្ធិមនុស្ស ។

ពលរដ្ឋ នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា មានភាពស្មើគ្នាចំពោះច្បាប់ មានសិទ្ធិ និង មានករណីយកិច្ចដូចគ្នាទាំងអស់ ដោយឥតប្រកាន់ភេទ ជំនឿសាសនា ឬ ពូជសាសន៍ ។

ការប្រើសិទ្ធិនេះ មានភាពជាប់គ្នាមិនអាចបំបែកបានពីការបំពេញករណីយកិច្ចរបស់ពលរដ្ឋ ។

## មាត្រា ៣១

ពលរដ្ឋនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា សុទ្ធតែមានសិទ្ធិបោះឆ្នោត និងអាចឈរឈ្មោះអោយគេបោះឆ្នោត ។

ពលរដ្ឋ ដែលបំរើក្នុងកងកម្លាំងប្រដាប់អាវុធប្រជាជនបដិវត្តកម្ពុជា ព្រមទាំងបព្វជិតក៏មានសិទ្ធិបោះឆ្នោត និងអាចឈរឈ្មោះអោយគេបោះឆ្នោតដែរ ។

ពលរដ្ឋទាំងពីរភេទ ដែលមានអាយុយ៉ាងតិច ១៨ ឆ្នាំ មានសិទ្ធិបោះឆ្នោត ។

ពលរដ្ឋទាំងពីរភេទ ដែលមានអាយុយ៉ាងតិច ២១ ឆ្នាំ អាចឈរឈ្មោះអោយគេបោះឆ្នោត ។

បទបញ្ញត្តិបន្ថយសិទ្ធិបោះឆ្នោត ត្រូវចែងក្នុងច្បាប់បោះឆ្នោត ។

## មាត្រា ៣២

ពលរដ្ឋនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា មានសិទ្ធិចូលរួមយ៉ាងសកម្ម ក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ប្រទេសជាតិ ។

ពលរដ្ឋទាំងអស់ អាចធ្វើសេចក្តីស្នើ ស្តីពីបញ្ហានយោបាយរបស់រដ្ឋ និងពីជីវភាពរបស់ប្រជាជន ជូនអង្គការរដ្ឋ និងអង្គការមហាជន ។ សេចក្តីស្នើទាំងឡាយត្រូវតែបានទទួលការពិនិត្យយ៉ាងម៉ត់ចត់ពីអង្គការរដ្ឋ និងអង្គការមហាជន ។

## មាត្រា ៣៣

ពលរដ្ឋ ត្រូវតែបានទទួលការណែនាំក្នុងការជ្រើសរើសមុខរបរ អោយបានសមស្របតាមសមត្ថភាពរបស់ខ្លួន និងតាមការតម្រូវរបស់សង្គម ។

ពលរដ្ឋ មានសិទ្ធិទទួលប្រាក់បំណាច់សមស្របតាមបរិមាណ និងគុណភាពនៃការងារដែលខ្លួនបានបំពេញ ។ បុរសនិងស្ត្រីមានសិទ្ធិទទួលប្រាក់បំណាច់ដូចគ្នា ចំពោះ ការងារស្មើគ្នា ។

## មាត្រា ៣៤

រដ្ឋនិងសង្គម យកចិត្តទុកដាក់រៀបចំអោយមានការឈប់សំរាក ការលំហែដល់អ្នកបំពេញពលកម្ម ។ រដ្ឋកំណត់ពេលធ្វើការប្រចាំថ្ងៃ និងប្រចាំសប្តាហ៍ របបឈប់សំរាកប្រចាំឆ្នាំមានប្រាក់បំណាច់ ចំពោះកម្មាភិបាល កម្មករ បុគ្គលិក ពង្រីកមជ្ឈមណ្ឌលសំរាករបស់រដ្ឋនិងរបស់អង្គការសង្គម ។

## មាត្រា ៣៥

រដ្ឋរ៉ាប់រងមិនអោយមានការរំលោភបំពាន លើរូបកាយបុគ្គលណាមួយឡើយ ។

ច្បាប់ការពារកិត្តិយស សេចក្តីថ្លៃថ្នូរ និង ជីវិតរបស់ពលរដ្ឋ ។

ការចោទប្រកាន់ ការចាប់ចង ឬ ការឃុំឃាំងជនណាមួយ នឹងអាចធ្វើទៅកើតលុះត្រាតែមានច្បាប់អនុញ្ញាត ។ ក្នុងករណីចាប់បានជនប្រព្រឹត្តបទល្មើសជាក់ស្តែង ត្រូវធ្វើ

កំណត់ហេតុបញ្ជូនជាបន្ទាន់ទៅអង្គការមានសមត្ថកិច្ច ដើម្បីសំរេច ។

## មាត្រា ៣៦

សេរីភាព ក្នុងការធ្វើដំណើរ និងតាំងទីលំនៅរបស់ពលរដ្ឋ ត្រូវបានច្បាប់កំណត់។

ការរក្សាសិទ្ធិមិនអោយរំលោភទៅលើលំនៅឋាន និងអាថិកំបាំងនៃការឆ្លើយឆ្លងតាមលិខិត ត្រូវបានរដ្ឋធានា ។

ការឆែកឆេរលំនៅឋាន ត្រូវធ្វើអោយស្របនឹងបញ្ញត្តិច្បាប់ ។

## មាត្រា ៣៧

ពលរដ្ឋ មានសេរីភាពខាងការនិយាយ សេរីភាពខាងសារពត៌មាន សេរីភាពខាងការប្រជុំ ។ ជនណាក៏ដោយ មិនអាចឆ្លៀតប្រើសិទ្ធិនេះដោយរំលោភ នាំអោយប៉ះពាល់ដល់កិត្តិយសអ្នកដទៃ ដល់ទំនៀមទំលាប់ល្អរបស់សង្គម ដល់របៀបរៀបរយសាធារណៈ និងដល់សន្តិសុខជាតិ ។

## មាត្រា ៣៨

ពលរដ្ឋ មានសិទ្ធិបង្កើតសមាគម សិទ្ធិនេះត្រូវកំណត់ក្នុងច្បាប់ ។ ពលរដ្ឋទាំងឡាយអាចចូលរួមក្នុងអង្គការមហាជន ដើម្បីការពារសមិទ្ធផលបដិវត្តន៍ និង របៀបរៀបរយសង្គម ដើម្បីកសាងនិងការពារប្រទេស ដើម្បីបង្កើនសាមគ្គីភាពជាតិ និង អន្តរជាតិ ។

## មាត្រា ៣៩

ពលរដ្ឋទាំងឡាយ ត្រូវគោរពគោលការណ៍នៃការរស់នៅក្នុងសង្គម អនុវត្តគោលនយោបាយរបស់រដ្ឋ និង ការពារទ្រព្យសម្បត្តិរួម ។ ពលរដ្ឋ មានសិទ្ធិប្តឹងទារសំណងជួសជុល

ការខូចខាតដែលបណ្តាលមកពីអំពើខុសច្បាប់របស់អង្គការរដ្ឋ របស់អង្គការសង្គម និង របស់បុគ្គលិកនៃអង្គការទាំងនេះ ក្នុងពេលបំពេញភារកិច្ចរបស់ខ្លួន ។

## មាត្រា ៤០

ពលរដ្ឋនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ត្រូវគោរពយ៉ាងខ្ជាប់ខ្ជួនតាមរដ្ឋធម្មនុញ្ញ និងច្បាប់របស់រដ្ឋ មានករណីយកិច្ចបំរើកិច្ចការរបស់រដ្ឋ និង ជីវភាពរបស់ប្រជាជន ។

## មាត្រា ៤១

កិច្ចកសាង និងការពារមាតុភូមិ ជាករណីយកិច្ច និងជាកិត្តិយសដ៏ឧត្តមរបស់ពលរដ្ឋ ។

ពលរដ្ឋ ត្រូវការពារមាតុភូមិ ហើយត្រូវបំរើក្នុងកងទ័ពតាមបញ្ញត្តិច្បាប់ ។

ជនក្បត់ជាតិ ត្រូវផ្តន្ទាទោសយ៉ាងម៉ឺងម៉ាត់តាមច្បាប់ ។

## មាត្រា ៤២

ពលរដ្ឋនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលមានសន្តានចិត្តស្នេហាជាតិពិតប្រាកដ កំពុងរស់នៅឯបរទេស ត្រូវបានអង្គការនៃសាធារណរដ្ឋប្រជាមានិតកម្ពុជាគាំពារ ។

## មាត្រា ៤៣

សាធារណរដ្ឋប្រជាមានិតកម្ពុជា ផ្តល់សិទ្ធិជ្រកកោន និងការគាំពារដល់ជនបរទេសទាំងឡាយណា ដែលត្រូវចោទដោយបានធ្វើការតស៊ូដើម្បីសន្តិភាពនិងប្រជាធិបតេយ្យ ដើម្បីឯករាជជាតិនិងសង្គមនិយម ដើម្បីសេរីភាព ក្នុងសកម្មភាពខាងវិទ្យាសាស្ត្រនិងវប្បធម៌ ជាអត្ថប្រយោជន៍ដល់វឌ្ឍនភាពសង្គម ។

## មាត្រា ៤៤

អាណិកជនបរទេស ដែលរស់នៅក្នុងប្រទេសកម្ពុជា ត្រូវគោរពច្បាប់នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា និងបានទទួលការគាំពារពីសាធារណរដ្ឋប្រជាមានិតកម្ពុជា ។

---

# ជំពូកទី៤

# រដ្ឋសភា

## មាត្រា ៤៥

រដ្ឋសភា ជាអង្គការកំពូលនៃរដ្ឋអំណាច និងជាអង្គការតំណាងជាន់ខ្ពស់របស់ប្រជាជននៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ។

រដ្ឋសភា ជាអង្គការតែមួយគត់ ដែលមានសិទ្ធិធ្វើច្បាប់ ។

## មាត្រា ៤៦

រដ្ឋសភា មានតំណាងប្រជាជន ដែលត្រូវបានជ្រើសរើសតាមគោលការណ៍បោះឆ្នោតជាសាកល ដោយស្មើភាព ដោយចំពោះ និងតាមវិធីជ្រើសឆ្នោតជាសម្ងាត់ ។

ចំនួនតំណាងប្រជាជននៅរដ្ឋសភា និងបែបបទនៃការជ្រើសតាំង ត្រូវកំណត់ក្នុងច្បាប់បោះឆ្នោត ។

## មាត្រា ៤៧

នីតិកាលរបស់រដ្ឋសភាមានកំណត់ ៥ ឆ្នាំ ។ ៣ ខែមុនផុតកំណត់នីតិកាលរដ្ឋសភា

ក្រុមប្រឹក្សារដ្ឋ សំរេចនិងដឹកនាំការរៀបចំបោះឆ្នោតជ្រើសរើសតំណាងប្រជាជន នៅរដ្ឋសភាសំរាប់នីតិកាលថ្មី ។

ក្នុងពេលមានសង្គ្រាម ឬ ក្នុងកាលៈទេសៈពិសេសដទៃទៀត រដ្ឋសភា អាចប្រកាសបន្តនីតិកាលរបស់ខ្លួនបាន ។

## មាត្រា ៤៨

រដ្ឋសភាមានអំណាចដូចតទៅ ៖

១- អនុម័ត ឬ កែប្រែរដ្ឋធម្មនុញ្ញ និងច្បាប់នានា ។

២- ត្រួតពិនិត្យការអនុវត្តន៍រដ្ឋធម្មនុញ្ញនិងការអនុវត្តន៍ច្បាប់ ។

៣- កំណត់គោលនយោបាយក្នុងប្រទេសនិងក្រៅប្រទេស ។

៤- អនុម័តកម្មវិធី សេដ្ឋកិច្ច វប្បធម៌ និងថវិការដ្ឋ ។

៥- បោះឆ្នោតជ្រើសតាំង ឬ រំសាយប្រធាន អនុប្រធាន និងលេខាធិការនៃរដ្ឋសភា ។ បោះឆ្នោតជ្រើសតាំង ឬ រំសាយប្រធាន អនុប្រធាន អគ្គលេខាធិការ និង សមាជិកដទៃទៀតនៃក្រុមប្រឹក្សារដ្ឋ ។ បោះឆ្នោតជ្រើសតាំង ឬ រំសាយប្រធាន អនុប្រធាន និងសមាជិកក្រុមប្រឹក្សារដ្ឋមន្ត្រី ។

៦- បង្កើត ឬ លុបចោលទីស្តីការរដ្ឋមន្ត្រី ឬ ស្ថាប័នថ្នាក់ស្មើទីស្តីការរដ្ឋមន្ត្រី ។

៧- ត្រួតពិនិត្យសកម្មភាព របស់ក្រុមប្រឹក្សារដ្ឋ និង ក្រុមប្រឹក្សារដ្ឋមន្ត្រី ។

៨- បង្កើត កែប្រែ ឬ លុបពន្ធដារ ។

៩- កំណត់ការលើកលែងទោសជាទូទៅ ។

១០- អោយសច្ចាប័ន ឬ លុបចោលសន្ធិសញ្ញាអន្តរជាតិក្នុងករណីដែលក្រុមប្រឹក្សារដ្ឋ ជូនរដ្ឋសភាសំរេច ។

## មាត្រា ៤៩

រដ្ឋសភា បើកសម័យប្រជុំលើកដំបូង ៦០ ថ្ងៃ យ៉ាងយូរក្រោយពេលបោះឆ្នោត តាមការកោះប្រជុំរបស់ក្រុមប្រឹក្សារដ្ឋ ។

រដ្ឋសភា បើកសម័យប្រជុំជាសាមញ្ញ ២ ដងក្នុង ១ ឆ្នាំនិងអាចបើកសម័យប្រជុំជាវិសាមញ្ញ បើក្រុមប្រឹក្សារដ្ឋ យល់ឃើញថាជាការចាំបាច់ ។

## មាត្រា ៥០

ពេលចាប់ផ្តើមនីតិកាលនីមួយ ៗ រដ្ឋសភា ជ្រើសតាំងគណៈកម្មការមួយ ដើម្បីត្រួតពិនិត្យសុពលភាព នៃសមាជិករដ្ឋសភា ហើយរាយការណ៍អំពីលទ្ធផលនៃការពិនិត្យនេះ ជូនរដ្ឋសភាសំរេច ។

## មាត្រា ៥១

ប្រធានរដ្ឋសភា ដឹកនាំអង្គប្រជុំរបស់រដ្ឋសភា ទទួលអាញ្ញត្តិច្បាប់ និង សេចក្តីសំរេចចិត្តនានា ដែលរដ្ឋសភាបានអនុម័ត រ៉ាប់រងការអនុវត្តន៏បទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភា អនុវត្តការទាក់ទងអន្តរជាតិទាំងឡាយនៃរដ្ឋសភា ។ ប្រធានរដ្ឋសភា មានសិទ្ធិចូលរួមគ្រប់ការប្រជុំនៃក្រុមប្រឹក្សារដ្ឋ ។

អនុប្រធានរដ្ឋសភា ជួយប្រធានក្នុងមុខងារទាំងឡាយដែលបានពោលខាងលើ ។ លេខាធិការរដ្ឋសភា ធ្វើកំណត់ហេតុគ្រប់ការប្រជុំរបស់រដ្ឋសភា និងបំពេញការងារទាំងឡាយ

ដែលប្រធានរដ្ឋសភាប្រគល់អោយ ។

## មាត្រា ៥២

រដ្ឋសភា ចាត់តាំងគណៈកម្មការផ្សេង ៗ ដែលចាំបាច់ដើម្បីជួយរដ្ឋសភា និង ក្រុមប្រឹក្សារដ្ឋ ក្នុងការត្រួតពិនិត្យលើសេចក្ដីព្រាងច្បាប់ សេចក្ដីព្រាងក្រឹត្យ គំរោងកម្មវិធីសេដ្ឋកិច្ច និងថវិការដ្ឋ និងគំរោងផ្សេង ៗ ទៀត ដែលរដ្ឋសភា ឬ ក្រុមប្រឹក្សារដ្ឋប្រគល់អោយ ។

## មាត្រា ៥៣

ក្រុមប្រឹក្សារដ្ឋ ក្រុមប្រឹក្សារដ្ឋមន្ត្រី ប្រធានរដ្ឋសភា គណៈកម្មការនានារបស់រដ្ឋសភា ប្រធានគណៈកម្មាធិការមជ្ឈិមរណសិរ្សកសាងមាតុភូមិកម្ពុជា ប្រធានសហជីពកម្ពុជា ប្រធានយុវជនបដិវត្តកម្ពុជា ប្រធានសមាគមនារីកម្ពុជា មានសិទ្ធិធ្វើសេចក្ដីព្រាងច្បាប់ ជូនរដ្ឋសភា ។

## មាត្រា ៥៤

រដ្ឋសភា អនុម័តច្បាប់ និងសេចក្ដីសំរេចផ្សេង ៗ ទៀតតាមមតិយល់ព្រមលើសពីពាក់កណ្ដាលនៃសមាជិក ។

រដ្ឋសភា អនុម័តរដ្ឋធម្មនុញ្ញ និងកែប្រែរដ្ឋធម្មនុញ្ញតាមមតិយល់ព្រម ពីរភាគបីនៃចំនួនសមាជិករដ្ឋសភា ។

## មាត្រា ៥៥

ច្បាប់ដែលរដ្ឋសភាបានអនុម័តរួចហើយ ៣០ ថ្ងៃយ៉ាងយូរ ក្រុមប្រឹក្សារដ្ឋ ត្រូវប្រកាសអោយប្រើជាសាធារណៈ ។

## មាត្រា ៥៦

សមាជិករដ្ឋសភា មានអភ័យឯកសិទ្ធិ ។

សមាជិករដ្ឋសភារូបណាក៏ដោយ មិនអាចត្រូវចោទប្រកាន់ ឬ ចាប់ចង ឬ ឃុំឃាំង ដោយហេតុពីបានសំដែងយោបល់ ឬ បញ្ចេញមតិក្នុងការបំពេញមុខងាររបស់ ខ្លួនសោះឡើយ ។

ការចោទប្រកាន់ ឬ ការចាប់ចង ឬ ការឃុំឃាំងសមាជិករដ្ឋសភាណាមួយ នឹងអាចធ្វើទៅកើត លុះត្រាតែមានការយល់ព្រមពីរដ្ឋសភា ឬ ពីក្រុមប្រឹក្សារដ្ឋក្នុងចន្លោះសម័យប្រជុំនៃរដ្ឋសភា វៀរលែងតែក្នុងករណីបទល្មើសព្រហ្មទណ្ឌជាក់ស្តែង ។ ក្នុងករណីខាងក្រោយនេះ ក្រសួងមានសមត្ថកិច្ច ត្រូវធ្វើសេចក្តីរាយការណ៍ជូនរដ្ឋសភា ឬ ជូនក្រុមប្រឹក្សារដ្ឋជាបន្ទាន់ ដើម្បីសំរេច ។

សេចក្តីសំរេចរបស់ក្រុមប្រឹក្សារដ្ឋ ត្រូវដាក់ជូនរដ្ឋសភាអនុម័តនៅសម័យប្រជុំរដ្ឋសភាខាងមុខ ។

## មាត្រា ៥៧

សមាជិករដ្ឋសភា មានសិទ្ធិតាំងសំនួរដេញដោល ដល់ក្រុមប្រឹក្សារដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រុមប្រឹក្សារដ្ឋ ប្រធានរដ្ឋសភា ។ ស្ថាប័នរដ្ឋ និងអ្នកដែលត្រូវគេសួរដេញដោល ត្រូវឆ្លើយក្នុងសម័យប្រជុំរដ្ឋសភា ។

## មាត្រា ៥៨

សមាជិករដ្ឋសភា មានកាតព្វកិច្ចគោរពបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភា ជាគំរូក្នុងការអនុវត្តន៍រដ្ឋធម្មនុញ្ញ និងច្បាប់ទាំងឡាយមានភារកិច្ចនិយាយ និងប្រព្រឹត្តអោយសមស្របតាម

សេចក្ដីសំរេចរបស់រដ្ឋសភា ។

សមាជិករដ្ឋសភារូបណា មិនបានបំពេញភារកិច្ចរបស់ខ្លួនអាចត្រូវបានរំសាយតាមច្បាប់ ។

---

## ជំពូកទី៥

## ក្រុមប្រឹក្សារដ្ឋ

### មាត្រា ៥៩

ក្រុមប្រឹក្សារដ្ឋ ជាអង្គការតំណាងសាធារណរដ្ឋប្រជាមានិតកម្ពុជា និងជាអង្គការអចិន្ត្រៃយ៍របស់រដ្ឋសភា ។

ក្រុមប្រឹក្សារដ្ឋ មានភារកិច្ចរាយការណ៍អំពីសកម្មភាពរបស់ខ្លួន ជូនរដ្ឋសភា ។

ក្រុមប្រឹក្សារដ្ឋ មានប្រធាន អនុប្រធាន អគ្គលេខាធិការ និងសមាជិកមួយចំនួនដែលត្រូវរដ្ឋសភាកំណត់ ។ ក្រុមប្រឹក្សារដ្ឋ ត្រូវបានជ្រើសតាំងឡើងក្នុងចំណោមសមាជិករដ្ឋសភា ។

### មាត្រា ៦០

ក្រុមប្រឹក្សារដ្ឋមានមុខការដូចតទៅ :

១- សំរេច និង ដឹកនាំការរៀបចំបោះឆ្នោតជ្រើសរើសសមាជិក រដ្ឋសភា និងកោះសម័យប្រជុំរដ្ឋសភា ។

២- ប្រកាសអោយប្រើច្បាប់ ចេញក្រិត្យ-ច្បាប់ ក្រិត្យ និងបកស្រាយច្បាប់ ។

៣- ក្នុងចន្លោះសម័យប្រជុំរដ្ឋសភា តាមសំណើរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី

- ចេញសេចក្តីសំរេចតែងតាំង ឬ រំសាយសមាជិកក្រុមប្រឹក្សារដ្ឋមន្ត្រី

- បង្កើត ឬ លុបចោលទីស្តីការរដ្ឋមន្ត្រី និងស្ថាប័នថ្នាក់ស្មើទីស្តីការរដ្ឋមន្ត្រី

- សំរេចលើបញ្ហាពន្ធដារ

- តាមសំណើរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី តែងតាំង រំសាយ ឬ ដកឯកអគ្គរដ្ឋទូត ឬ ប្រេសិតនៃសាធារណរដ្ឋប្រជាមានិតកម្ពុជានៅឯបរទេស និងនៅអមអង្គការអន្តរជាតិនានា ។

៤- ត្រួតពិនិត្យការជំនុំជំរះ និងការប្រើសិទ្ធិអយ្យការ ។

៥- ទទួលសារតាំង របស់តំណាងការទូត ។

៦- អោយសច្ចាប័ន ឬ លុបចោលសន្ធិសញ្ញាអន្តរជាតិ លើកលែងតែក្នុងករណីចាំបាច់ ដែលត្រូវដាក់ជូនរដ្ឋសភាសំរេច ។

៧- កំណត់ និងប្រគល់គ្រឿងឥស្សរិយយស កំណត់ឋានន្តរសក្តិ និង ឋានៈយោធា ឋានៈទូត តាមសំណើរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ។

៨- សំរេចអនុគ្រោះទោស បន្ថយទោស និងលើកលែងទោស ។

៩- បំពេញភារកិច្ចផ្សេងៗទៀតដែលរដ្ឋសភាប្រគល់អោយ ។

## មាត្រា ៦១

អាណត្តិរបស់ក្រុមប្រឹក្សារដ្ឋ មានកំណត់ស្មើនឹងនីតិកាលរបស់រដ្ឋសភា ។ នៅពេលផុតនីតិកាលរដ្ឋសភា ក្រុមប្រឹក្សារដ្ឋបន្តសកម្មភាពរបស់ខ្លួន រហូតដល់រដ្ឋសភាថ្មីបោះឆ្នោតជ្រើសតាំងក្រុមប្រឹក្សារដ្ឋថ្មីបាន ។

ក្នុងករណីប្រធានក្រុមប្រឹក្សារដ្ឋ មានធុរៈមិនអាចបំពេញមុខងារបាន ដោយហេតុមកពីមានជម្ងឺ ឬ បំពេញបេសកកម្មនៅបរទេស អនុប្រធានក្រុមប្រឹក្សារដ្ឋ ត្រូវទទួលភារកិច្ចចាត់ការជំនួស ។

## មាត្រា ៦២

សេចក្តីសំរេចរបស់ក្រុមប្រឹក្សារដ្ឋ ត្រូវតែមានសមាជិកក្រុមប្រឹក្សារដ្ឋ លើសពីពាក់កណ្តាលយល់ព្រម ។

## មាត្រា ៦៣

ការរៀបចំ និង ការប្រព្រឹត្តិទៅនៃក្រុមប្រឹក្សារដ្ឋ ត្រូវកំណត់ក្នុងច្បាប់ ។

# ជំពូកទី៦

# ក្រុមប្រឹក្សារដ្ឋមន្ត្រី

## មាត្រា ៦៤

ក្រុមប្រឹក្សារដ្ឋមន្ត្រី ជារដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ជាអង្គការគ្រប់គ្រងសង្គមដោយផ្ទាល់ និងដឹកនាំការពង្រីកសេដ្ឋកិច្ចជាតិដោយផ្ទាល់ ។

ក្រុមប្រឹក្សារដ្ឋមន្ត្រី ទទួលខុសត្រូវចំពោះរដ្ឋសភា និងរាយការណ៍អំពីការងាររបស់ខ្លួនជូនអង្គការនេះ ។ ក្នុងចន្លោះសម័យប្រជុំរដ្ឋសភា ក្រុមប្រឹក្សារដ្ឋមន្ត្រី ទទួលខុសត្រូវចំពោះក្រុមប្រឹក្សារដ្ឋ និងរាយការណ៍អំពីការងាររបស់ខ្លួន ជូនអង្គការនេះ ។

## មាត្រា ៦៥

ក្រុមប្រឹក្សារដ្ឋមន្ត្រី មានប្រធាន អនុប្រធាន និងសមាជិក ។ ចំនួនអនុប្រធាន និងសមាជិកក្រុមប្រឹក្សារដ្ឋមន្ត្រី ត្រូវរដ្ឋសភាកំណត់ ។

## មាត្រា ៦៦

ក្រុមប្រឹក្សារដ្ឋមន្ត្រី មានមុខការដូចតទៅ :

១- ធ្វើសេចក្តីព្រាងច្បាប់ សេចក្តីព្រាងក្រិត្យ-ច្បាប់ និងគំរោងផ្សេងៗទៀត ដើម្បីជូនរដ្ឋសភា និងក្រុមប្រឹក្សារដ្ឋ ។

២- អនុវត្តរដ្ឋធម្មនុញ្ញ ច្បាប់ ក្រិត្យ-ច្បាប់ ក្រិត្យ អនុវត្តនយោបាយក្នុងប្រទេស និងក្រៅប្រទេស ។

៣- ធ្វើនិងអនុវត្តកម្មវិធីសេដ្ឋកិច្ច វប្បធម៌ និងថវិការដ្ឋ ។ កំចាត់ផលអាក្រក់ដែលរបបចាស់បន្សល់ទុក កែលំអជីវភាពប្រជាជន និងយកចិត្តទុកដាក់ដល់សុខភាពប្រជាជន ។

៤- កសាង និង ពង្រឹងអង្គការរដ្ឋ ពីថ្នាក់មជ្ឈិមដល់ថ្នាក់មូលដ្ឋាន បណ្តុះបណ្តាល និងគ្រប់គ្រងកម្មាភិបាល កម្មករ និងបុគ្គលិករបស់រដ្ឋ ។

៥- រ៉ាប់រងការដឹកនាំការងាររបស់ទីស្តីការរដ្ឋមន្ត្រីនិងស្ថាប័ននានា ដែលនៅក្រោមឱវាទក្រុមប្រឹក្សារដ្ឋមន្ត្រីអោយមានឯកភាពនិងរ៉ាប់រងការដឹកនាំការងារ របស់គណៈកម្មាធិការប្រជាជនបដិវត្តនៅមូលដ្ឋានគ្រប់ថ្នាក់អោយមានឯកភាព ។

៦- ផ្អាកការអនុវត្តន៍ កែប្រែឬលុបចោលអនុសញ្ញានិងសេចក្តីណែនាំមិនសមស្របរបស់រដ្ឋមន្ត្រីនិងរបស់ប្រធានស្ថាប័នរដ្ឋនានា។

ផ្អាកការអនុវត្តន៍ កែប្រែ ឬលុបចោលសេចក្តីសំរេចចិត្តនិង សេចក្តីណែនាំមិនសមស្រប របស់គណៈកម្មាធិការប្រជាជនបដិវត្តគ្រប់ថ្នាក់ ។

៧- កំណត់ព្រំដែនក្រុង សង្កាត់ ខេត្ត ស្រុក និងឃុំ ។

៨- ការពារផលប្រយោជន៏របស់ប្រជាជន រក្សាសន្តិសុខរបៀបរៀបរយសាធារណៈ ការពារសិទ្ធិ និងប្រយោជន៏ស្របច្បាប់ របស់ពលរដ្ឋ ។

៩-ពង្រឹងនិងបង្កើនកម្លាំងការពារជាតិ អនុវត្តការប្រមូលកម្លាំងទ័ព ចេញបំរាមគោចរ និង ចាត់វិធានការចាំបាច់ផ្សេងៗ ដើម្បីការពារជាតិ ។

១០- អនុវត្តសន្ធិសញ្ញាទាំងឡាយ ដែលបានព្រមព្រៀងជាមួយប្រទេសក្រៅ ។

១១- បំពេញភារកិច្ចផ្សេងៗទៀត ដែលរដ្ឋសភា និងក្រុមប្រឹក្សារដ្ឋ ប្រគល់អោយ ។

## មាត្រា ៦៧

ប្រធានក្រុមប្រឹក្សារដ្ឋមន្ត្រី ដឹកនាំការងាររបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ហើយធ្វើជាអធិបតីនៃអង្គប្រជុំក្រុមប្រឹក្សារដ្ឋមន្ត្រី ។

អនុប្រធាន ជួយប្រធាន និងកាន់កាប់មុខងារប្រធាន នៅពេលប្រធានអវត្តមាន ។

សមាជិកម្នាក់ ៗ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ទទួលខុសត្រូវពីសកម្មភាពរបស់ខ្លួន និងទទួលខុសត្រូវរួមជាមួយនឹងសមាជិកផ្សេង ៗ ទៀត ពីសកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ។

## មាត្រា ៦៨

សេចក្តីសំរេចរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ត្រូវតែមានសមាជិកភាគច្រើននៃក្រុមប្រឹក្សារដ្ឋមន្ត្រីយល់ព្រម ។

## មាត្រា ៦៩

អាណត្តិរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី មានកំណត់ស្មើនឹងនីតិកាលរបស់រដ្ឋសភា ។

នៅពេលផុតនីតិកាលរដ្ឋសភា ក្រុមប្រឹក្សារដ្ឋមន្ត្រីបន្តសកម្មភាពរបស់ខ្លួន រហូតដល់រដ្ឋសភាជ្រើសតាំងក្រុមប្រឹក្សារដ្ឋមន្ត្រីថ្មីបាន ។

## មាត្រា ៧០

ការរៀបចំ និង ការប្រព្រឹត្តិទៅនៃក្រុមប្រឹក្សារដ្ឋមន្ត្រី ត្រូវកំណត់ក្នុងច្បាប់ ។

# ជំពូកទី៧
# គណៈកម្មាធិការប្រជាជន
# បដិវត្តមូលដ្ឋាន
## មាត្រា ៧១

ដែនដីនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ត្រូវបែងចែកជាខេត្ត និងក្រុង ចំណុះរដ្ឋ-អំណាចមជ្ឈិមផ្ទាល់ ។

ខេត្ត ត្រូវបែងចែកជាស្រុក ។

ស្រុក ត្រូវបែងចែកជាឃុំ ។

ក្រុងចំណុះរដ្ឋអំណាចមជ្ឈិមផ្ទាល់ ត្រូវបែងចែកជាសង្កាត់ ។

## មាត្រា ៧២

គណៈកម្មាធិការប្រជាជនបដិវត្ត ត្រូវមាននៅគ្រប់ក្រុង គ្រប់សង្កាត់ គ្រប់ខេត្ត គ្រប់ស្រុក និងគ្រប់ឃុំ ។

សមាជិកគណៈកម្មាធិការប្រជាជនបដិវត្តឃុំនិងសង្កាត់ ត្រូវបានប្រជាជននៅឃុំនិងសង្កាត់ ជ្រើសរើសតាមគោលការណ៍បោះឆ្នោតជាសាកល ដោយស្មើភាព ដោយចំពោះ និងតាមវិធីជ្រើសរើសឆ្នោតជាសម្ងាត់ ។

សមាជិកគណៈកម្មាធិការប្រជាជនបដិវត្តស្រុក ត្រូវបានជ្រើសរើសដោយតំណាងគណៈកម្មាធិការប្រជាជនបដិវត្តឃុំ តំណាងរណសិរ្ស និង តំណាងអង្គការមហាជន ជាសមាជិករណសិរ្សថ្នាក់ស្រុក ។

សមាជិកនៃគណៈកម្មាធិការប្រជាជនបដិវត្តខេត្ត ត្រូវបានជ្រើសរើសដោយតំណាងគណៈកម្មាធិការប្រជាជនបដិវត្តស្រុក តំណាងរណសិរ្ស និង តំណាងអង្គការមហាជន ជាសមាជិករណសិរ្សថ្នាក់ខេត្ត ។

សមាជិកនៃគណៈកម្មាធិការប្រជាជនបដិវត្តក្រុង ត្រូវបានជ្រើសរើសដោយតំណាងគណៈកម្មាធិការប្រជាជនបដិវត្តសង្កាត់ តំណាងរណសិរ្ស និង តំណាងអង្គការមហាជន ជាសមាជិករណសិរ្សថ្នាក់ក្រុង ។

## មាត្រា ៧៣

គណៈកម្មាធិការប្រជាជនបដិវត្ត មាន ប្រធាន អនុប្រធាន និងសមាជិក ។

អាណត្តិរបស់គណៈកម្មាធិការប្រជាជនបដិវត្តខេត្ត ក្រុង មានកំណត់ ៥ ឆ្នាំ ។

អាណត្តិរបស់គណៈកម្មាធិការប្រជាជនបដិវត្តស្រុក សង្កាត់ ឃុំ មានកំណត់ ៣ ឆ្នាំ ។

## មាត្រា ៧៤

គណៈកម្មាធិការប្រជាជនបដិវត្តគ្រប់ថ្នាក់ ទទួលខុសត្រូវចំពោះប្រជាជននៅមូលដ្ឋាន និងទទួលខុសត្រូវចំពោះអង្គការរដ្ឋអំណាចថ្នាក់លើ ។

## មាត្រា ៧៥

គណៈកម្មាធិការប្រជាជនបដិវត្តមូលដ្ឋាន សំរេចនិងអនុវត្តគោលការណ៏កសាងមូលដ្ឋានលើគ្រប់វិស័យ អនុវត្តសេចក្តីសំរេច និងសារាចររបស់អង្គការរដ្ឋថ្នាក់លើ គ្រប់គ្រងការងាររដ្ឋបាលនៅមូលដ្ឋាន និងណែនាំគ្រប់ផ្នែក គ្រប់ថ្នាក់ ដែលនៅក្រោមឱវាទផ្ទាល់អោយ

អនុវត្តភារកិច្ច រក្សាសន្តិសុខសាធារណៈនិងរបៀបរៀបរយសង្គម កសាងសេដ្ឋកិច្ច ពង្រីកវប្បធម៌ ថែទាំសុខភាព លើកស្ទួយជីវភាពប្រជាជននៅមូលដ្ឋាន ។

## មាត្រា ៧៦

ដោយយោលតាមតំណែង និងមុខការដែលច្បាប់បានកំណត់ គណៈកម្មាធិការប្រជាជនបដិវត្តគ្រប់ថ្នាក់ ចេញសេចក្តីសំរេច ចេញសេចក្តីបង្គាប់ និងត្រួតពិនិត្យការអនុវត្តន៍សេចក្តីសំរេចនិងសេចក្តីបង្គាប់ទាំងនេះ ។

គណៈកម្មាធិការប្រជាជនបដិវត្ត មានសិទ្ធិផ្អាកការអនុវត្តន៍ កែប្រែ ឬ លុបចោលសេចក្តីសំរេច និងសេចក្តីបង្គាប់មិនសមស្របនៃអង្គការនៅក្រោមឱវាទផ្ទាល់របស់ខ្លួន និងរបស់គណៈកម្មាធិការប្រជាជនបដិវត្តថ្នាក់ក្រោម ។

## មាត្រា ៧៧

គណៈកម្មាធិការប្រជាជនបដិវត្តណា ឬ សមាជិកគណៈកម្មាធិការប្រជាជនបដិវត្តណា មិនបានបំពេញភារកិច្ចរបស់ខ្លួនអាចត្រូវបានហូតងារ ឬ រំសាយតាមលក្ខណៈដែលកំណត់ក្នុងច្បាប់ ។

## មាត្រា ៧៨

ការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈកម្មាធិការប្រជាជនបដិវត្តមូលដ្ឋានត្រូវកំណត់ក្នុងច្បាប់ ។

---

# ជំពូកទី៨

## សាលាជំរះក្តីនិងអយ្យការ

### មាត្រា ៧៩

សកម្មភាពនៃសាលាជំរះក្តី និងអយ្យការមានទីដៅដូចតទៅ :

១- ការពារអំណាចប្រជាជន និងការពារនីត្យានុកូលភាពប្រជាធិបតេយ្យ ។

២- រក្សាសន្តិសុខសាធារណៈ និងរបៀបរៀបរយសង្គម ។

៣- ការពារទ្រព្យសម្បត្តិសាធារណៈ ។

៤- ការពារសិទ្ធិ សេរីភាព ជីវិត និងប្រយោជន៍ស្របច្បាប់របស់ពលរដ្ឋ ។

### មាត្រា ៨០

តុលាការប្រជាជន និងតុលាការយោធា ជាអង្គការជំនុំជំរះនៃសាធារណរដ្ឋប្រជា-មានិតកម្ពុជា ។ រដ្ឋអាជ្ញាអមសាលាជំរះក្តី ធ្វើការចោទប្រកាន់ ប្តឹងទៅតុលាការតាមច្បាប់ ធានាការប្តឹងទៅតុលាការ ការជំនុំជំរះនិងការអនុវត្តន៍សាលក្រម អោយបានត្រឹមត្រូវ និងស្របច្បាប់ ។

ក្នុងករណីចាំបាច់ ក្រុមប្រឹក្សារដ្ឋអាចបង្កើតតុលាការពិសេសដើម្បីជំនុំជំរះរឿងដែលមានលក្ខណៈពិសេស ។

### មាត្រា ៨១

ដើម្បីជំនុំជំរះ សាលាជំរះក្តីផ្អែកលើច្បាប់និងផ្អែកលើលក្ខការណ៍ពលរដ្ឋគ្រប់រូបមានភាពស្មើគ្នាចំពោះច្បាប់ ដោយឥតប្រកាន់ជនជាតិ ជំនឿសាសនា ភេទ និង ឋានៈក្នុងសង្គម ។

## មាត្រា ៨២

ទីប្រឹក្សាប្រជាជន ចូលរួមក្នុងសកម្មភាពតុលាការតាមបញ្ញត្តិច្បាប់ ។ ក្នុងការជំនុំជំរះ ទីប្រឹក្សាប្រជាជន មានសិទ្ធិស្មើនឹងចៅក្រម ។

ក្រុមប្រឹក្សាជំនុំជំរះ ត្រូវសំរេចតាមមតិភាគច្រើន ។

## មាត្រា ៨៣

នៅគ្រប់សាលាជំរះក្តី ការជំនុំជំរះ ត្រូវធ្វើជាសាធារណៈ ។

ប៉ុន្តែការជំនុំជំរះ អាចប្រព្រឹត្តទៅជាសម្ងាត់ ក្នុងករណីដែលមានចែងក្នុងច្បាប់ ។

## មាត្រា ៨៤

សាលាជំរះក្តី នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ធានារ៉ាប់រងអោយពលរដ្ឋដែលជាជនជាតិភាគតិច មានសិទ្ធិប្រើភាសា និង អក្សរ របស់ខ្លួន ចំពោះមុខសាលាជំរះក្តី ។

## មាត្រា ៨៥

សិទ្ធិការពារខ្លួនរបស់ជនជាប់ចោទ ត្រូវបានធានា ។

ជនជាប់ចោទមានសិទ្ធិការពារខ្លួនដោយខ្លួនឯង ឬ ពឹងមេធាវី ឬ ពឹងអ្នកដទៃណាមួយ ដើម្បីអោយជួយការពារ ។

## មាត្រា ៨៦

ការរៀបចំ និង ការប្រព្រឹត្តិទៅនៃសាលាជំរះក្តី និងអយ្យការ ត្រូវកំណត់ក្នុងច្បាប់ ។

# ជំពូកទី៩

# សញ្ញាជាតិ ទង់ជាតិ ភ្លេងជាតិ និង រដ្ឋធានី

## មាត្រា ៨៧

សញ្ញាជាតិ នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា មានរាងមូលផ្ទៃក្រហមមានកម្រងកួរស្រូវពណ៌មាស អមសងខាងជារង្វង់ស្នែងក្របីជួបគ្នាខាងចុង ។

ខ្សែបូក្រហមរុំព័ទ្ធផ្នែកខាងក្រោមនៃកម្រងកួរស្រូវជាពីរថ្នាក់ ។ នៅកណ្ដាលខ្សែបូមានចារឹកអក្សរមាសថា : សាធារណរដ្ឋប្រជាមានិតកម្ពុជា ។

ស្មៀវភៅមាសរដ្ឋធម្មនុញ្ញ បើកទំព័រដាក់លើដើមស្រូវចងជាបូ ។ កង់គ្រឿងចក្រចេញរាងពាក់កណ្ដាលមានកាំ ៧ ផ្អែកពីមុខស្មៀវភៅមាស ។ នៅលើកង់គ្រឿងចក្រ រូបប្រាសាទអង្គរវត្តកំពូល ៥ ពណ៌មាសស្ថិតនៅចំរង្វង់កម្រងកួរស្រូវ ។

## មាត្រា ៨៨

ទង់ជាតិ នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា មានរាងចតុកោណកែងពណ៌ក្រហមចំកណ្ដាលផ្ទៃ មានប្រាសាទអង្គរវត្តកំពូលប្រាំពណ៌មាស ។

## មាត្រា ៨៩

ភ្លេងជាតិនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ត្រូវរដ្ឋសភាកំណត់ ។

ថ្ងៃបុណ្យជាតិ គឺថ្ងៃ ៧ មករា ។

## មាត្រា ៩០

រដ្ឋធានីនៃសាធារណរដ្ឋប្រជាមានិតកម្ពុជាគឺ ភ្នំពេញ ។

---

# ជំពូកទី១០
# អានុភាពនៃរដ្ឋធម្មនុញ្ញ និង
# ការកែប្រែរដ្ឋធម្មនុញ្ញ

## មាត្រា ៩១

រដ្ឋធម្មនុញ្ញនេះ ជាច្បាប់គោលនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ហើយមានអានុភាពខ្ពស់បំផុតខាងច្បាប់ ។

ច្បាប់ទាំងឡាយ ត្រូវស្របនឹងរដ្ឋធម្មនុញ្ញជាដាច់ខាត ។

## មាត្រា ៩២

ក្រិត្យ-ច្បាប់ និងសេចក្តីសំរេចចិត្តទាំងឡាយ របស់ក្រុមប្រឹក្សាប្រជាជនបដិវត្តកម្ពុជា ដែលមានលក្ខណៈជាច្បាប់ ត្រូវនៅជាធរមានលុះដល់ពេលណាមានច្បាប់ ។

## មាត្រា ៩៣

ការកែប្រែរដ្ឋធម្មនុញ្ញ ជាសមត្ថកិច្ចរបស់រដ្ឋសភា ហើយអាចនឹងប្រព្រឹត្តទៅបានលុះត្រាតែមានសមាជិករដ្ឋសភា ពីរភាគបីយល់ព្រម ។

**រដ្ឋធម្មនុញ្ញនេះ**

ត្រូវបានរដ្ឋសភានៃសាធារណរដ្ឋប្រជាមានិតកម្ពុជា
អនុម័តជាឯកច្ឆ័ន្ទ នៅថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ ១៩៨១
នាសម័យប្រជុំលើកទី ១ នៃ នីតិកាលទី ១ ។

ភ្នំពេញ ថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ ១៩៨១
ប្រធានរដ្ឋសភា
ហត្ថលេខា និង ត្រា

**ជា ស៊ីម**

ក្រុមប្រឹក្សារដ្ឋ
លេខ ០១ក្រ

សាធារណរដ្ឋប្រជាមានិតកម្ពុជា
ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល

# ក្រឹត្យ

## ក្រុមប្រឹក្សារដ្ឋ

បានឃើញសេចក្តីសំរេចចិត្តចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ១៩៨១ របស់រដ្ឋសភានៃសាធារណរដ្ឋប្រជាមានិតកម្ពុជា នាសម័យប្រជុំលើកទី ១ នៃនីតិកាលទី ១ ។

**សំរេច :**

- ប្រកាសអោយប្រើនូវរដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋប្រជាមានិតកម្ពុជាដែលរដ្ឋសភាបានអនុម័តជាឯកច្ឆ័ន្ទ នៅថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ ១៩៨១ ។

*ធ្វើនៅភ្នំពេញ ថ្ងៃទី ២៧ ខែមិថុនា ឆ្នាំ ១៩៨១*

*ក្រុមប្រឹក្សារដ្ឋ*

*ប្រធាន*

ហត្ថលេខា និង ត្រា

**ហេង សំរិន**

# រដ្ឋធម្មនុញ្ញ

# នៃ

# រដ្ឋកម្ពុជា

# រដ្ឋធម្មនុញ្ញ

# នៃ

# រដ្ឋកម្ពុជា

**បោះពុម្ពផ្សាយដោយ**

**ខុទ្ទកាល័យ រដ្ឋសភា**

**១៩៩២**

ក្រុមប្រឹក្សារដ្ឋ សាធារណរដ្ឋប្រជាមានិតកម្ពុជា

លេខ ០១ ក្រ ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល

# ក្រឹត្យ

## ក្រុមប្រឹក្សារដ្ឋ

បានឃើញសេចក្តីសំរេចចិត្ត ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ១៩៨១ របស់រដ្ឋសភានៃសាធារណរដ្ឋប្រជាមានិតកម្ពុជា នាសម័យប្រជុំលើកទី ១ នៃនីតិកាលទី ១

**សំរេច**

ប្រកាសអោយប្រើនូវរដ្ឋធម្មនុញ្ញ នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលរដ្ឋសភាបានអនុម័តជាឯកច្ឆន្ទ នៅថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ១៩៨១ ។

ធ្វើនៅភ្នំពេញ , ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ១៩៩១

ក្រុមប្រឹក្សារដ្ឋ

ប្រធាន

ហត្ថលេខា និងត្រា

ហេង សំរិន

ក្រុមប្រឹក្សារដ្ឋ

លេខ : ២៩ ក្រ

សាធារណរដ្ឋប្រជាមានិតកម្ពុជា

ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល

# ក្រឹត្យ

## ក្រុមប្រឹក្សារដ្ឋ

## នៃ

## សាធារណរដ្ឋប្រជាមានិតកម្ពុជា

**បានឃើញរដ្ឋធម្មនុញ្ញ នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា**

**សំរេច**

ប្រកាសអោយប្រើរដ្ឋធម្មនុញ្ញកែប្រែ " រដ្ឋធម្មនុញ្ញនៃរដ្ឋកម្ពុជា " ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៨៩ នាសម័យប្រជុំវិសាមញ្ញនីតិកាលទី ១។

ធ្វើនៅភ្នំពេញ , ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៨៩

ជ.ក្រុមប្រឹក្សារដ្ឋ

ប្រធាន

ហត្ថលេខានឹងត្រា : ហេង សំរិន

ក្រុមប្រឹក្សារដ្ឋ　　　　　　　　　　　　រដ្ឋកម្ពុជា
លេខ : ១១៤ ក្រ　　　　　　　　　　ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល

# ក្រឹត្យ

ក្រុមប្រឹក្សារដ្ឋ

នៃ

រដ្ឋកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃរដ្ឋកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំរដ្ឋសភា និង ក្រុមប្រឹក្សារដ្ឋ នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៤ ក្រ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២

**សំរេច**

ប្រកាសអោយប្រើច្បាប់ ស្តីពីការកែប្រែ មាត្រា ៤ មាត្រា ៤៧ និង មាត្រា ៦០ នៃ រដ្ឋធម្មនុញ្ញនៃរដ្ឋកម្ពុជា ដែលរដ្ឋសភានៃរដ្ឋកម្ពុជា បានអនុម័តនៅថ្ងៃ ទី ២៧ ខែ ធ្នូ ឆ្នាំ ១៩៩១ នាសម័យប្រជុំវិសាមញ្ញ នីតិកាលទី ១ ។

ធ្វើនៅភ្នំពេញ , ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩១

ជ.ក្រុមប្រឹក្សារដ្ឋ

ប្រធាន

ហត្ថលេខា និង ត្រា : ហេង សំរិន

ក្រុមប្រឹក្សារដ្ឋ                                    រដ្ឋកម្ពុជា

លេខ : ៥២ ក្រ                    ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល

# ក្រឹត្យ

## ក្រុមប្រឹក្សារដ្ឋ នៃ រដ្ឋកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃរដ្ឋកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំរដ្ឋសភា និង ក្រុមប្រឹក្សារដ្ឋ នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៤ ក្រ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២

**សំរេច**

ប្រកាសអោយប្រើច្បាប់ ស្តីពីការកែប្រែមាត្រា ៤៧ វាក្យខ័ណ្ឌ ៣ មាត្រា ៤៨ មាត្រា ៤៩ (ស្ទួន) មាត្រា ៦១ មាត្រា ៦៥ និង មាត្រា ៦៦ នៃរដ្ឋធម្មនុញ្ញនៃ រដ្ឋកម្ពុជា ដែលរដ្ឋសភា នៃរដ្ឋកម្ពុជា បានអនុម័តនៅថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ១៩៩២ នាសម័យប្រជុំវិសាមញ្ញនៃនីតិកាលទី ១ ។

ធ្វើនៅភ្នំពេញ ,ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ១៩៩២

ជ.ក្រុមប្រឹក្សារដ្ឋ

ប្រធាន

ហត្ថលេខា និងត្រា  ហេង សំរិន

# ជំពូកទី ១

# របបនយោបាយ

## មាត្រា ១

ប្រទេសកម្ពុជាមាននាមជាផ្លូវការថា " រដ្ឋកម្ពុជា " ។

រដ្ឋកម្ពុជាជារដ្ឋមួយឯករាជ អធិបតេយ្យ បូរណភាពដែនដី សន្តិភាព ប្រជាធិបតេយ្យ អព្យាក្រឹត និងមិនចូលបក្សសម្ព័ន្ធ ។

អធិបតេយ្យនៃរដ្ឋកម្ពុជា លាតសន្ធឹងលើដែនគោក ដែនកោះ ដែនទឹក ដែនសមុទ្រ បាតសមុទ្រ ក្រោមបាតសមុទ្រ ហើយនិងដែនអាកាស ។

បាវចនានៃរដ្ឋកម្ពុជា គឺ ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល ។

ភាសានិងអក្សរដែលប្រើជាផ្លូវការគឺភាសា និងអក្សរខ្មែរ ។

## មាត្រា ១ (ស្ទួន)

រដ្ឋកម្ពុជាជារដ្ឋមួយមិនអាចបំបែកបាន ។

ស្ថាប័នរដ្ឋនានាត្រូវចាត់តាំង និងប្រព្រឹត្តអោយសមស្របតាមរដ្ឋធម្មនុញ្ញ និងច្បាប់នៃរដ្ឋកម្ពុជា ។

រដ្ឋមានភារកិច្ចការពារឯករាជ្យនៃមាតុភូមិ សិទ្ធិ សេរីភាពរបស់ប្រជាជន សមិទ្ធផលរបស់សង្គមជាតិ ស្តារនិងពង្រីកសេដ្ឋកិច្ច វប្បធម៌ យកចិត្តទុកដាក់ដោះស្រាយ និងលើកតម្កើង

ជីវភាពរស់នៅរបស់ប្រជាជន ទាំងខាងសម្ភារៈ ទាំងខាងស្មារតី ។

## មាត្រា ២

ប្រជាជនកម្ពុជាជាម្ចាស់វាសនានៃប្រទេសរបស់ខ្លួន ។ អំណាចទាំងអស់ជារបស់ប្រជាជន ។

ប្រជាជនប្រើអំណាចរបស់ខ្លួនតាមរយៈរដ្ឋសភា និងអង្គការរដ្ឋអំណាចនានា ដែលប្រជាជនជ្រើសតាំងឡើង និងទទួលខុសត្រូវចំពោះប្រជាជន ។ ប្រជាជនមានសិទ្ធិដកហូតតំណាងរបស់ខ្លួនដែលខ្លួនឈប់ទុកចិត្ត ។

## មាត្រា ៣

ក្រុមប្រឹក្សាជាតិរណសិរ្សសាមគ្គីកសាងការពារមាតុភូមិកម្ពុជា អង្គការមហាជននានាដែលជាបង្អែកដ៏រឹងមាំរបស់រដ្ឋ ត្រូវមានភារកិច្ចលើកទឹកចិត្តប្រជាជន អោយអនុវត្តនយោបាយ និងផែនការរបស់រដ្ឋ ។

## មាត្រា ៤ ថ្មី

រដ្ឋកម្ពុជា អនុវត្តរបបនយោបាយពហុបក្ស ។

## មាត្រា ៥

រដ្ឋអនុវត្តនយោបាយសាមគ្គីភាព និងស្មើភាពរវាងជនជាតិទាំងអស់ ដែលរស់នៅក្នុងសហគមន៍ជាតិកម្ពុជា ។

ជនជាតិទាំងអស់ត្រូវស្រឡាញ់រាប់អានគ្នា និងជួយគ្នាទៅវិញទៅមក។ អំពើប្រមាថមាក់ងាយ អំពើជិះជាន់ និងការបែងចែកជនជាតិនានាត្រូវហាមឃាត់ ។

ភាសានិងអក្សរ ព្រមទាំងទំនៀមទំលាប់ល្អៗរបស់ជនជាតិភាគតិចត្រូវបានគោរព ។

គ្រប់ជនជាតិភាគតិចត្រូវបានរដ្ឋជួយទំនុកបម្រុង ដើម្បីអោយតាមទាន់កម្រិតរួម ។

រដ្ឋយកចិត្តទុកដាក់ជាពិសេស ពង្រីកសេដ្ឋកិច្ច សិក្សាធិការ វប្បធម៌ សង្គមកិច្ច សុខាភិបាល គមនាគមន៍ នៅតាមតំបន់ព្រៃភ្នំ និងតំបន់ដាច់ស្រយាល ។

## មាត្រា ៦

ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ ។

សកម្មភាពខាងសាសនាទាំងឡាយ ដែលស្របរដ្ឋធម្មនុញ្ញ និង ច្បាប់ ត្រូវបានរដ្ឋធានា ។

សកម្មភាពណាដែលឆ្លៀតយកសាសនា ដើម្បីធ្វើអោយប៉ះពាល់ដល់សន្តិសុខ របៀបរៀបរយសាធារណៈ និងផលប្រយោជន៍របស់ប្រជាជនត្រូវហាមឃាត់ ។

## មាត្រា ៧

បុរស និងស្ត្រី មានសិទ្ធិស្មើគ្នាក្នុងអាពាហ៍ពិពាហ៍ និងគ្រួសារ ។

អាពាហ៍ពិពាហ៍ ត្រូវធ្វើតាមល័ក្ខខ័ណ្ឌដែលបានចែងក្នុងច្បាប់ និងតាមលក្ខណការណ៍ស្ម័គ្រចិត្ត ប្តីមួយ ប្រពន្ធមួយ ។

រដ្ឋយកចិត្តទុកដាក់ជាពិសេស ចំពោះកិច្ចការពារមាតា និងកុមារ ។

## មាត្រា ៨

មាតាបិតាត្រូវអប់រំ និង ថែទាំចិញ្ចឹមកូន ដើម្បីអោយទៅជាពលរដ្ឋល្អ មានមនសិការស្នេហាជាតិ ស្រឡាញ់ការងារពលកម្ម មានសម្បជញ្ញៈទទួលខុសត្រូវចំពោះសង្គម ។

កូនមានកាតព្វកិច្ចបីបាច់ ថែរក្សា មាតា បិតា ។

## មាត្រា ៩

រដ្ឋកម្ពុជាអនុវត្តលក្ខណការណ៍ ៖ ប្រជាជនទាំងមូលរួមប្រាស្រ័យក្នុងកិច្ចកសាង និង ការពារមាតុភូមិ ។

កងកំលាំងប្រដាប់អាវុធប្រជាជនកម្ពុជាទាំងបីប្រភេទ និងនគរបាលប្រជាជន ជាកូនចៅរបស់ប្រជាជន ត្រូវស្មោះត្រង់ចំពោះប្រទេសជាតិនិងប្រជាជន មានករណីយកិច្ចការពារមាតុភូមិនិងរដ្ឋអំណាចប្រជាជន ការពារសមិទ្ធផលសង្គមជាតិ និងការរស់នៅដ៏សុខសាន្តរបស់ប្រជាជន ហើយរួមជាមួយប្រជាជនកសាងប្រទេស ។

កងកំលាំងប្រដាប់អាវុធទាំងអស់ត្រូវមានការប៉ិនប្រសប់ក្នុងការប្រយុទ្ធនិងក្នុងការបង្កបង្កើនផល ត្រូវចេះបំផុសចលនាប្រជាជន គោរពនិងជួយទំនុកបំរុងប្រជាជន មិនត្រូវប៉ះពាល់ដល់ផលប្រយោជន៍របស់ប្រជាជននិងសេចក្តីទុកចិត្តរបស់ប្រជាជន ។

## មាត្រា ១០

នយោបាយក្រៅប្រទេសរបស់រដ្ឋកម្ពុជាគឺ ឯករាជ្យ សន្តិភាព អព្យាក្រឹត និង មិនចូលបក្សសម្ព័ន្ធ ។

រដ្ឋកម្ពុជាអនុវត្តគោលការណ៍សន្តិសហវិជ្ជមាន ពង្រីកទំនាក់ទំនងមិត្តភាព និង ការទូតជាមួយប្រទេសទាំងអស់ ដោយមិនប្រកាន់របបនយោបាយ លើមូលដ្ឋានស្មើភាព គោរពឯករាជ្យ អធិបតេយ្យ បូរណភាពដែនដី និងផលប្រយោជន៍គ្នាទៅវិញទៅមក ដើម្បីបុព្វហេតុការពារសន្តិភាពនៅអាស៊ីអាគ្នេយ៍ និងនៅលើសកលលោក ។

## ជំពូកទី២

## របបសេដ្ឋកិច្ច និងគោលនយោបាយ

## វប្បធម៌ សង្គមកិច្ច

### មាត្រា ១១

សេដ្ឋកិច្ចជាតិស្ថិតនៅក្រោមការដឹកនាំរបស់រដ្ឋ។ រដ្ឋលើកស្ទួយជីវភាពរបស់ប្រជាជនអោយមានកម្រិតខ្ពស់ជាលំដាប់លើគ្រប់ផ្នែក ដើម្បីកសាងប្រទេសជាតិ ។

### មាត្រា ១២

សេដ្ឋកិច្ចជាតិមានប្រាំផ្នែក : សេដ្ឋកិច្ចរដ្ឋ សេដ្ឋកិច្ចរដ្ឋចម្រុះនឹងឯកជន សេដ្ឋកិច្ចសមូហភាព សេដ្ឋកិច្ចគ្រួសារ និងសេដ្ឋកិច្ចឯកជន ។

រដ្ឋគ្រប់គ្រងសហគ្រាសរដ្ឋយ៉ាងជិតដិត ដើម្បីពង្រីកតួនាទីសំខាន់នៃផ្នែកសេដ្ឋកិច្ចរដ្ឋ និងសេដ្ឋកិច្ចរដ្ឋចម្រុះនឹងឯកជន ក្នុងសេដ្ឋកិច្ចជាតិ ហើយទទ្ទឹមនឹងនោះ ជួយទំនុកបម្រុងនិងណែនាំយ៉ាងសកម្ម នូវការកសាងសេដ្ឋកិច្ចសមូហភាព សេដ្ឋកិច្ចគ្រួសារ និងសេដ្ឋកិច្ចឯកជនអោយរីកចម្រើនតាមទិសដែលមានប្រយោជន៍ដល់រដ្ឋ និងដល់ជីវភាពរបស់ប្រជាជន ។

### មាត្រា ១៣

រដ្ឋយកចិត្តទុកដាក់ ពង្រីកផលិតកម្មកសិកម្ម ផលិតកម្មឧស្សាហកម្មដែលបំរើកសិកម្ម ពង្រីកផលិតកម្មរបស់ប្រើប្រាស់ ពង្រីកពាណិជ្ជកម្ម គមនាគមន៍ និងការដឹកជញ្ជូន ។

រដ្ឋជួយទំនុកបម្រុង និងពង្រីកសិប្បកម្ម និងឧស្សហកម្ម ។

## មាត្រា ១៤

ទ្រព្យសម្បត្តិរបស់រដ្ឋមាន ដីធ្លី ព្រៃឈើ សមុទ្រ ទន្លេ បឹង ធនធានធម្មជាតិ មជ្ឈមណ្ឌលសេដ្ឋកិច្ច វប្បធម៌ មូលដ្ឋានការពារប្រទេស និងសំណង់ផ្សេងៗទៀតរបស់រដ្ឋ ។

## មាត្រា ១៥

ពលរដ្ឋកម្ពុជាមានសិទ្ធិពេញទី ក្នុងការកាន់កាប់ប្រើប្រាស់ដីធ្លី និងមានសិទ្ធិតំណមរតកលើ ដីធ្លី ដែលរដ្ឋប្រគល់អោយសម្រាប់រស់នៅនិងធ្វើអាជីវកម្ម ។

## មាត្រា ១៦

រដ្ឋហាមឃាត់ការចាប់ដីទំនេរបង់ពន្ធទុកសម្រាប់លក់ និងជួលអោយអ្នកដទៃ ។ ជនណាក៏ដោយមិនអាចប្រើប្រាស់ ដីធ្លីកសិកម្ម ដីព្រៃ ដោយចិត្តឯងក្នុងគោលបំណងផ្សេងៗទៀតបានឡើយ បើគ្មានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច ។

## មាត្រា ១៧

សិទ្ធិកាន់កាប់ និងប្រើប្រាស់ដីនឹងត្រូវកំណត់ដោយច្បាប់មួយដោយឡែក ។

## មាត្រា ១៨

កម្មសិទ្ធិឯកជននៃពលរដ្ឋ លើកំរៃការងារ លើកំរៃស្របច្បាប់ និងទ្រព្យសម្បត្តិស្របច្បាប់ផ្សេងទៀត ត្រូវបានច្បាប់ការពារ។

ការរឹបអូសទ្រព្យសម្បត្តិរបស់ពលរដ្ឋដោយរំលោភ ត្រូវហាមឃាត់ជាដាច់ខាត។

## មាត្រា ១៨ (ស្ទួន)

ការប៉ះពាល់ដល់កម្មសិទ្ធិឯកជននៃពលរដ្ឋ ត្រូវហាមឃាត់មិនអោយមាន វៀរលែងតែប្រយោជន៍សាធារណៈតម្រូវអោយធ្វើ ក្នុងករណីដែលមានចែងក្នុងច្បាប់ ។ ក្នុងន័យនេះ

ម្ចាស់កម្មសិទ្ធិមានសិទ្ធិទទួលបំណាច់ជាមុនដោយត្រឹមត្រូវ និង សមរម្យ ។

## មាត្រា ១៩

ពាណិជ្ជកម្មក្នុងប្រទេសត្រូវពង្រីក ដើម្បីបង្កើនសកម្មភាពផ្លាស់ប្តូរមុខទំនិញ ជំរុញផលិតកម្មបំរើជីវភាពរបស់ប្រជាជន ។

ពលរដ្ឋ ឬអង្គភាពផលិតកម្ម អាចលក់ដូរផលិតផលរបស់ខ្លួនបាន ។ ការទិញ និងការលក់របស់ប្រជាជនដែលស្របតាមគោលនយោបាយរបស់រដ្ឋត្រូវបានច្បាប់ធានា ។

ពាណិជ្ជកម្មក្រៅប្រទេស ស្ថិតនៅក្រោមការគ្រប់គ្រង និងចាត់ចែងរបស់រដ្ឋ ។

## មាត្រា ២០

របបគ្រប់គ្រងរូបិយវត្ថុ និងប្រព័ន្ធហិរញ្ញវត្ថុត្រូវកំណត់ក្នុងច្បាប់ ។

ការយកពន្ធដារ នឹងអាចធ្វើទៅបាន លុះត្រាតែមានច្បាប់អនុញ្ញាត ។

ការតម្រូវអោយលក់ជូនរដ្ឋ ឬការយកទៅប្រើប្រាស់មួយរយៈនូវទ្រព្យសម្បត្តិឯកជន នឹងអាចធ្វើទៅបាន លុះត្រាតែមានច្បាប់អនុញ្ញាត ។

## មាត្រា ២១

រដ្ឋយកចិត្តទុកដាក់កសាងវប្បធម៌ជាតិជឿនលឿន ពង្រីកភាសាជាតិ អោយសមស្របនឹងសេចក្តីត្រូវការនៃសង្គមថ្មីមួយ ។

រាល់ឥទ្ធិពល និង សំណល់នៃវប្បធម៌មិនជឿនលឿន ត្រូវកំចាត់ចោលជាដាច់ខាត ។

## មាត្រា ២២

រដ្ឋអនុវត្តកម្មវិធីសិក្សា តាមគោលការណ៍គរុកោសល្យដោយផ្សារភ្ជាប់ការសិក្សាចំណេះទូទៅ និង ការអប់រំជាមួយនឹងការអនុវត្ត ផ្សារភ្ជាប់សាលារៀនជាមួយនឹងសង្គម ។

រដ្ឋគ្រប់គ្រងចាត់ចែងអោយបើកមត្តេយ្យសាលា សម្រាប់អប់រំកុមារមុនគ្រប់វ័យសិក្សា ។

រដ្ឋគ្រប់គ្រងចាត់ចែងលើការអប់រំវិជ្ជាទូទៅ ដល់កុមារគ្រប់វ័យសិក្សា ដោយកសាងសាលារៀនបឋមសិក្សា ដោយពង្រីកជាបណ្តើរៗ នូវសាលារៀនមធ្យមសិក្សា សាលារៀន និងថ្នាក់អប់រំវិជ្ជាជីវៈ ថ្នាក់ជាន់ខ្ពស់ផ្សេងៗនិងឧត្តមសិក្សា ដើម្បីតម្រូវតាមការចាំបាច់នៃប្រទេសជាតិដែលកំពុងឈានទៅកាន់វឌ្ឍនភាព ។

រដ្ឋលើកទឹកចិត្ត និង ផ្តល់អាហាររូបករណ៍សិក្សាដល់យុវជនដែលមានសមត្ថភាព អាចបន្តការសិក្សា នៅថ្នាក់ខ្ពស់ នៅថ្នាក់បច្ចេកទេស នៅក្នុងប្រទេស និងក្រៅប្រទេស ។

ដើម្បីបំបាត់ភាពមិនចេះអក្សរ និងដើម្បីលើកកម្រិតវប្បធម៌ដល់ពលរដ្ឋទូទៅអោយបានខ្ពស់ រដ្ឋជំរុញចលនាអក្ខរកម្ម ដោយបើកថ្នាក់សិក្សា សម្រាប់មនុស្សចាស់ដែលមិនទាន់ចេះអក្សរ និងថ្នាក់អប់រំបំពេញវិជ្ជាផ្សេងៗទៀត តម្រូវទៅតាមការចាំបាច់របស់ប្រទេសជាតិ ។

## មាត្រា ២៣

រដ្ឋយកចិត្តទុកដាក់ជំរុញការលូតលាស់ វិទ្យាសាស្ត្រ និងបច្ចេកទេស អក្សរសាស្ត្រ និងសិល្បៈ ដោយពង្រីកប្រព័ន្ធសិក្សាធិការជំរុញការងារស្រាវជ្រាវ ដោយរួមផ្សំការរៀនសូត្រខាងទ្រឹស្តីទៅនឹងការជាក់ស្តែង ។

រដ្ឋលើកទឹកចិត្តដល់អ្នកវិទ្យាសាស្ត្រ អ្នកបច្ចេកទេស អ្នកនិពន្ធ សិល្បករ ក្នុងសកម្មភាពច្នៃប្រឌិតរបស់ខ្លួន ដែលមានប្រយោជន៍ដល់ប្រទេសជាតិ និងប្រជាជន ដោយជួយទំនុកបម្រុងដល់អ្នកទាំងនោះ ទាំងខាងផ្នែកសម្ភារៈ ទាំងខាងផ្លូវចិត្ត ។

រដ្ឋបង្កើនសហប្រតិបត្តិការជាមួយប្រទេសក្រៅ និងផ្លាស់ប្តូរបទពិសោធន៍គ្នាទៅវិញទៅមក ។

## មាត្រា ២៤

រដ្ឋចាត់ចែងអោយថែរក្សាប្រាសាទបូរាណ និង សិល្បៈវត្ថុបូរាណ កែលំអតំបន់ទេសភាពនានាឡើងវិញ ពង្រីកទេសចរណ៍ និងពង្រីកការទាក់ទងខាងវប្បធម៌ជាមួយប្រទេសក្រៅ ។

## មាត្រា ២៥

រដ្ឋយកចិត្តទុកដាក់ ដល់ការរីកចម្រើនខាងរូបកាយរបស់ពលរដ្ឋ លើកទឹកចិត្តដល់សកម្មភាពខាងកីឡា និងខាងហាត់ប្រាណសំដៅធ្វើអោយពលរដ្ឋមានកម្លាំងពលំមាំមួនជាចាំបាច់ ដើម្បីចូលរួមក្នុងការកសាង និងការការពារប្រទេស ។

## មាត្រា ២៦

ដើម្បីធានាដល់សុខភាពរបស់ប្រជាជន រដ្ឋយកចិត្តទុកដាក់ដល់ការការពារជំងឺ និងព្យាបាលជំងឺ ណែនាំប្រជាជនអោយកាន់ក្បួនអនាម័យយ៉ាងខ្ជាប់ខ្ជួន ។ ប្រជាជនត្រូវបានទទួលការពិនិត្យរោគដោយឥតបង់ថ្លៃ ។ រដ្ឋគ្រប់គ្រង និងចាត់ចែងបង្កើតមន្ទីរពេទ្យនានា ធ្វើការស្រាវជ្រាវខាងវេជ្ជសាស្ត្រ និងឱសថសាស្ត្រ ដោយរួមផ្សំវេជ្ជសាស្ត្របូរាណជាមួយវេជ្ជសាស្ត្រសម័យ ។

## មាត្រា ២៧

រដ្ឋយកចិត្តទុកដាក់ចំពោះកុមារ និងមាតា ។ រដ្ឋនិងសង្គមរៀបចំអោយមាន មន្ទីរសម្ភព ទារកដ្ឋាន សួនកុមារ និងអនុវត្តនូវវិធានការសមស្របនានា ដើម្បីសម្រាលបន្ទុកមេផ្ទះ

ដល់ស្ត្រី និងរ៉ាប់រងលក្ខណៈចាំបាច់ អោយស្ត្រីមានលទ្ធភាពចូលរួម ក្នុងសកម្មភាពសង្គមដូចបុរសដែរ ។

ស្ត្រីជាកម្មករ ជានិយោជិត ត្រូវបានឈប់សម្រាកក្នុងពេលសម្រាលកូនចំនួន ៩០ ថ្ងៃ ដោយបានទទួលបៀវត្ស ។ ស្ត្រីមានកូននៅបៅដោះ ត្រូវបានទទួលការបន្ថយពេលធ្វើការប្រចាំថ្ងៃ និងបានទទួលអត្ថប្រយោជន៍នានា តាមការកំណត់របស់រដ្ឋ ។

រដ្ឋនឹងកំណត់បទបញ្ញត្តិជាក់ស្តែង ចំពោះស្ត្រីជាកម្មករ ជានិយោជិតក្រៅផ្ទៃករដ្ឋ ។

## មាត្រា ២៨

រដ្ឋយកចិត្តទុកដាក់ ជាពិសេសដល់អ្នកដែលធ្វើសកម្មភាពបដិវត្តយូរឆ្នាំ ហើយដែលរួមវិភាគទានច្រើនអោយបដិវត្តន៍ ដល់យុទ្ធជនពិការ ដល់គ្រួសារយុទ្ធជន ដែលបានទទួលមរណៈ ដើម្បីបដិវត្តន៍ និងដល់គ្រួសារដែលមានសគុណធំៗចំពោះបដិវត្តន៍ ។

## មាត្រា ២៩

រដ្ឋចាត់ចែងអោយមានរបបធានារ៉ាប់រងសង្គម ដល់កម្មករ និងនិយោជិតដែលអស់លទ្ធភាពបំពេញពលកម្ម បណ្តាលមកពីមានជំងឺ ជរាភាព ឬពិការដោយគ្រោះថ្នាក់ក្នុងការងារ ។

រដ្ឋ និង សង្គម ជួយទំនុកបម្រុងដល់មនុស្សចាស់ជរា ជនពិការ ស្ត្រីមេម៉ាយ និងក្មេងកំព្រាគ្មានទីពឹង ។

# ជំពូក ទី ៣
# សិទ្ធិ និង ករណីយកិច្ច
# របស់ពលរដ្ឋ

## មាត្រា ៣០

រដ្ឋកម្ពុជាបានទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ។

ពលរដ្ឋកម្ពុជា មានភាពស្មើគ្នាចំពោះច្បាប់ មានសិទ្ធិសេរីភាព និងមានករណីយកិច្ច ដូចគ្នាទាំងអស់ ដោយឥតប្រកាន់ភេទ ជំនឿ សាសនា ពូជសាសន៍ ឬឋានៈក្នុងសង្គម។

ការប្រើសិទ្ធិសេរីភាពផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ ៗ មិនត្រូវអោយប៉ះពាល់សិទ្ធិសេរីភាព អ្នកដទៃឡើយ ។ ការប្រើសិទ្ធិសេរីភាពនេះ ត្រូវប្រព្រឹត្តតាមលក្ខខណ្ឌកំណត់ក្នុងច្បាប់ ។

## មាត្រា ៣១

ពលរដ្ឋកម្ពុជា សុទ្ធតែមានសិទ្ធិបោះឆ្នោត និង អាចឈរឈ្មោះអោយគេបោះឆ្នោត ។

ពលរដ្ឋ ដែលបំរើក្នុងកងកំលាំងប្រដាប់អាវុធប្រជាជនកម្ពុជា មានសិទ្ធិបោះឆ្នោត និង អាចឈរឈ្មោះ អោយគេបោះឆ្នោតដែរ ។

ពលរដ្ឋទាំងពីរភេទ ដែលមានអាយុយ៉ាងតិច ១៨ ឆ្នាំ មានសិទ្ធិបោះឆ្នោត ។

ពលរដ្ឋទាំងពីរភេទ ដែលមានអាយុយ៉ាងតិច ២១ ឆ្នាំអាចឈរឈ្មោះអោយគេ បោះឆ្នោត ។

បទបញ្ញត្តិ បន្ថយសិទ្ធិបោះឆ្នោត ត្រូវចែងក្នុងច្បាប់បោះឆ្នោត ។

## មាត្រា ៣២

ពលរដ្ឋ កម្ពុជាមានសិទ្ធិចូលរួមយ៉ាងសកម្ម ក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គម-កិច្ច និងវប្បធម៌របស់ប្រទេសជាតិ ។

ពលរដ្ឋទាំងអស់អាចធ្វើសេចក្តីស្នើ ស្តីពីបញ្ហានយោបាយរបស់រដ្ឋ និងពីជីវភាពរបស់ប្រជាជន ជូនអង្គការរដ្ឋ និងអង្គការមហាជន ។ សេចក្តីស្នើទាំងឡាយត្រូវបានទទួលការពិនិត្យ និងដោះស្រាយយ៉ាងហ្មត់ចត់ពីអង្គការរដ្ឋ និងអង្គការមហាជន ។

## មាត្រា ៣៣

ពលរដ្ឋមានសិទ្ធិជ្រើសរើសមុខរបរ សមស្របតាមសមត្ថភាពរបស់ខ្លួននិងតាមសេចក្តីត្រូវការរបស់សង្គម ។

ពលរដ្ឋ មានសិទ្ធិទទួលប្រាក់បំណាច់សមស្របតាមបរិមាណ និងគុណភាពនៃការងារដែលខ្លួនបានបំពេញ។ បុរសនិងស្ត្រី មានសិទ្ធិទទួលប្រាក់បំណាច់ដូចគ្នាចំពោះការងារស្មើគ្នា ។

ពលរដ្ឋ រាល់រូបមានសិទ្ធិទទួលការរ៉ាប់រង និងអត្ថប្រយោជន៍ខាងសង្គមកិច្ច ដែលមានចែងក្នុងច្បាប់ ។

## មាត្រា ៣៤

រដ្ឋនិងសង្គមយកចិត្តទុកដាក់ រៀបចំអោយមានការឈប់សំរាក ការលំហែដល់អ្នកបំពេញពលកម្ម ។ រដ្ឋកំណត់ពេលធ្វើការងារប្រចាំថ្ងៃ និងប្រចាំសប្តាហ៍ របបឈប់សំរាកប្រចាំឆ្នាំ មានប្រាក់បំណាច់ចំពោះកម្មករ និងនិយោជិត ពង្រីកមជ្ឈមណ្ឌលសំរាករបស់រដ្ឋ និងរបស់អង្គការសង្គម ។

## មាត្រា ៣៥

រដ្ឋការពារមិនអោយមានការរំលោភបំពានលើរូបរាងកាយបុគ្គលណាមួយឡើយ ។

ច្បាប់ការពារកិត្តិយស សេចក្តីថ្លៃថ្នូរនិងជីវិតរបស់ពលរដ្ឋ ។

ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនជនណាមួយនឹងអាចធ្វើទៅកើត លុះត្រាមានច្បាប់អនុញ្ញាត ។

ការបង្ខិតបង្ខំ ការធ្វើបាបលើរាងកាយ ឬប្រព្រឹត្តិកម្មណាមួយដែលបន្ថែមទម្ងន់ទណ្ឌកម្មអនុវត្តចំពោះជនជាប់ឃុំឃាំង ឬជាប់ពន្ធនាគារ ត្រូវហាមមិនអោយធ្វើឡើយ ។ អ្នកដៃដល់ អ្នករួមប្រព្រឹត្ត និងអ្នកសមគំនិតត្រូវទទួលទោសតាមច្បាប់ ។

ការទទួលសារភាព កើតឡើងពីការបង្ខំដោយឃោរឃៅតាមផ្លូវកាយក្តី តាមផ្លូវចិត្តក្តី មិនត្រូវទុកជាភ័ស្តុតាងនៃពិរុទ្ធភាពទេ ។

បើបទល្មើសគ្រាន់តែមានវិមតិសង្ស័យ ជនត្រូវចោទត្រូវអោយបានរួចខ្លួន ។

ជនជាប់ពិរុទ្ធណាក៏ដោយត្រូវទុកជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ ។

រដ្ឋការពារចំពោះពលរដ្ឋទាំងអស់ នូវសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ ។

ទោសប្រហារជីវិតត្រូវបំបាត់ចោល ។

## មាត្រា ៣៦

សេរីភាពក្នុងការដើរហើរ និងតាំងទីលំនៅរបស់ពលរដ្ឋ ត្រូវបានគោរពតាមច្បាប់កំណត់ ។

ពលរដ្ឋអាចចេញទៅតាំងទីលំនៅ នៅប្រទេសក្រៅ ឬវិលត្រឡប់មកវិញបាន ។

ការរក្សាសិទ្ធិមិនអោយរំលោភលើលំនៅឋាន និងអាថិកំបាំងនៃការឆ្លើយឆ្លងតាមលិខិត តាមសារទូរលេខ និងតាមទូរស័ព្ទ ត្រូវបានរដ្ឋធានា ។

ការឆែកឆេរលំនៅឋាន សម្ភារៈ វត្ថុ និងលើខ្លួនបុគ្គល ត្រូវធ្វើអោយស្របនឹងបញ្ញត្តិច្បាប់ ។

## មាត្រា ៣៧

ពលរដ្ឋមានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារពត៌មាន បោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ ។ ជនណាក៏ដោយមិនអាចឆ្លៀតប្រើសិទ្ធិនេះដោយរំលោភ នាំអោយប៉ះពាល់ដល់កិត្តិយសរបស់អ្នកដទៃ ដល់ទំនៀមទម្លាប់ល្អរបស់សង្គម ដល់របៀបរៀបរយសាធារណៈ និងដល់សន្តិសុខជាតិបានឡើយ ។

របបសារពត៌មានត្រូវរៀបចំឡើងដោយច្បាប់ ។

## មាត្រា ៣៧ (ស្ទួន)

សេរីភាពខាងជំនឿត្រូវបានគោរព ។

## មាត្រា ៣៨

ពលរដ្ឋមានសិទ្ធិបង្កើតសមាគម ។ សិទ្ធិនេះត្រូវកំណត់ក្នុងច្បាប់ ។

ពលរដ្ឋទាំងឡាយអាចចូលរួមក្នុងអង្គការមហាជន ដើម្បីការពារសមិទ្ធផលសង្គមជាតិ និងរបៀបរៀបរយសង្គម ដើម្បីកសាង និងការពារប្រទេស ដើម្បីបង្កើនសាមគ្គីភាពជាតិ និងអន្តរជាតិ ។

## មាត្រា ៣៩

ពលរដ្ឋទាំងឡាយត្រូវរស់នៅតាមរបៀបរបបរបស់សង្គម ហើយរួមចំណែកការពារទ្រព្យសម្បត្តិសាធារណៈ ។

ពលរដ្ឋមានសិទ្ធិប្ដឹងបរិហារ ប្ដឹងតវ៉ា ឬប្ដឹងទារសំណង ជួសជុលការខូចខាតដែលបណ្ដាលមកពីអំពើខុសច្បាប់របស់អង្គការរដ្ឋ របស់អង្គការសង្គម និងរបស់បុគ្គលិកនៃអង្គការទាំងនោះ ក្នុងពេលបំពេញភារកិច្ចរបស់ខ្លួន ។

## មាត្រា ៤០

ពលរដ្ឋគ្រប់រូបត្រូវគោរពរដ្ឋធម្មនុញ្ញ គោរពច្បាប់ និងអនុវត្តគោលមាគ៌ានយោបាយរបស់រដ្ឋ ។

## មាត្រា ៤១

កិច្ចកសាង និងការពារមាតុភូមិជាករណីយកិច្ច និងជាកិត្តិយសដ៏ឧត្ដមរបស់ពលរដ្ឋ ។

ពលរដ្ឋគ្រប់រូប ត្រូវរួមចំណែកយ៉ាងសកម្មកសាងប្រទេសជាតិ និងការពារមាតុភូមិ ។ កាតព្វកិច្ចការពារមាតុភូមិត្រូវអនុវត្តតាមបញ្ញត្តិច្បាប់ ។

## មាត្រា ៤២

ពលរដ្ឋកម្ពុជាមិនអាចត្រូវបានដកសញ្ជាតិ និរទេស ឬចាប់បញ្ជូនខ្លួនទៅអោយប្រទេសក្រៅណាមួយឡើយ ។

ពលរដ្ឋកម្ពុជាដែលកំពុងរស់នៅឯបរទេស ត្រូវបានរដ្ឋគាំពារ ។

## មាត្រា ៤៣

" លុបចោល "

## មាត្រា ៤៤

" លុបចោល "

# ជំពូក ទី ៧

# រដ្ឋសភា

## មាត្រា ៤៥

រដ្ឋសភាជាអង្គការកំពូលនៃរដ្ឋអំណាច និង ជាអង្គការតំណាងជាន់ខ្ពស់របស់ប្រជាជននៃរដ្ឋកម្ពុជា ។

រដ្ឋសភាជាអង្គការតែមួយគត់ដែលមានសិទ្ធិធ្វើច្បាប់ ។

## មាត្រា ៤៦

រដ្ឋសភា មានតំណាងប្រជាជន ដែលត្រូវបានជ្រើសតាំងតាមគោលការណ៍បោះឆ្នោតជាសាកល ដោយស្មើភាព ដោយចំពោះ និងតាមវិធីជ្រើសឆ្នោតជាសម្ងាត់ ។

ចំនួនតំណាងប្រជាជននៅរដ្ឋសភា និង បែបបទនៃការជ្រើសតាំង ត្រូវកំណត់ក្នុងច្បាប់បោះឆ្នោត ។

## មាត្រា ៤៧ ថ្មី

នីតិកាលរបស់រដ្ឋសភាមានកំណត់ ៥ ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលដែលរដ្ឋសភាថ្មីចូលកាន់តំណែង ។

ក្នុងពេលមានសង្គ្រាម ឬក្នុងកាលៈទេសៈពិសេសដទៃទៀតដែលមិនអាចធ្វើការបោះឆ្នោតកើត រដ្ឋសភាអាចប្រកាសបន្តនីតិកាលរបស់ខ្លួនមួយដងបានមួយឆ្នាំ តាមសំណើរបស់ក្រុមប្រឹក្សារដ្ឋ ។

ការប្រកាសបន្តនីតិកាលរបស់រដ្ឋសភា ត្រូវសំរេចដោយមតិយល់ព្រមពីរភាគបីយ៉ាងតិចនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

## មាត្រា ៤៨ ថ្មី

រដ្ឋសភាមានអំណាចដូចតទៅ :

១ - អនុម័ត ឬកែប្រែរដ្ឋធម្មនុញ្ញ និងច្បាប់នានា ។

២ - អនុម័តថវិការដ្ឋ ការអោយរដ្ឋខ្ចីប្រាក់ និងការខ្ចីប្រាក់រដ្ឋ ។

៣ - អនុម័តផែនការរដ្ឋ ។

៤ - ត្រួតពិនិត្យការអនុវត្តរដ្ឋធម្មនុញ្ញ និងការអនុវត្តច្បាប់ ។

៥ - កំណត់នយោបាយក្នុងប្រទេសនិងក្រៅប្រទេស ។

៦ - បោះឆ្នោតជ្រើសតាំង រំសាយ ឬ ផ្លាស់ប្តូរប្រធាន អនុប្រធាន និង អគ្គលេខាធិការរដ្ឋសភា ។ បោះឆ្នោតជ្រើសតាំង រំសាយ ឬផ្លាស់ប្តូរប្រធាន អនុប្រធាន អគ្គលេខាធិការ និងសមាជិកដទៃទៀត នៃក្រុមប្រឹក្សារដ្ឋ ។ បោះឆ្នោតជ្រើសតាំង រំសាយ ឬផ្លាស់ប្តូរប្រធាន អនុប្រធាន និង សមាជិកក្រុមប្រឹក្សារដ្ឋមន្ត្រី ។ បោះឆ្នោតជ្រើសតាំង រំសាយ ឬផ្លាស់ប្តូរប្រធានតុលាការប្រជាជនកំពូល និង អគ្គរដ្ឋអាជ្ញាអមតុលាការប្រជាជនកំពូល ។

៧ - បង្កើតឬលុបចោលតុលាការប្រជាជនកំពូល និងមហាអយ្យការអមតុលាការប្រជាជនកំពូល ទីស្តីការរដ្ឋមន្ត្រី ឬស្ថាប័នថ្នាក់ស្មើទីស្តីការរដ្ឋមន្ត្រី ខ័ណ្ឌ សង្កាត់ ខេត្ត

ទីរួមខេត្ត ស្រុក និងឃុំ ។

៨ - បង្កើត កែប្រែ ឬលុបចោលពន្ធដារ ។

៩ - ត្រួតពិនិត្យសកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋ ក្រុមប្រឹក្សារដ្ឋមន្ត្រី តុលាការប្រជា-ជនកំពូល មហាអយ្យការអមតុលាការប្រជាជនកំពូល ។

១០ - កំណត់ការលើកលែងទោសជាទូទៅ ។

១១ - អនុម័ត ឬលុបចោលសន្ធិសញ្ញា អនុសញ្ញាអន្តរជាតិរបស់រដ្ឋាភិបាល។

១២ - អនុម័តច្បាប់ស្តីពីការដាក់ប្រទេសជាតិ ឋិតក្នុងភយន្តរាយ ឬឋិតក្នុងភាពអាសន្ននៅក្នុងទូទាំងប្រទេស ឬនៅក្នុងតំបន់ខ្លះ ។

១៣ - សម្រេចអំពីបញ្ហាសង្គ្រាម និងអំពីបញ្ហាសន្តិភាព ។

## មាត្រា ៤៩

រដ្ឋសភាបើកសម័យប្រជុំដំបូង ៦០ ថ្ងៃ យ៉ាងយូរក្រោយពេលបោះឆ្នោត តាមការកោះប្រជុំរបស់ក្រុមប្រឹក្សារដ្ឋ ។

រដ្ឋសភាប្រជុំសាមញ្ញយ៉ាងតិចពីរដងក្នុងមួយឆ្នាំ ។

រដ្ឋសភាអាចប្រជុំវិសាមញ្ញ បើមានសំណូមពរពីក្រុមប្រឹក្សារដ្ឋ ពីក្រុមប្រឹក្សារដ្ឋមន្ត្រី ឬពីសមាជិករដ្ឋសភាចំនួនមួយភាគបីយ៉ាងតិចនៃសមាជិករដ្ឋសភាទាំងមូល។

ក្នុងករណីខាងលើនេះ របៀបវារៈនៃសម័យប្រជុំវិសាមញ្ញ ត្រូវផ្សាយដល់ប្រជាជនព្រមជាមួយនឹងថ្ងៃកំណត់ប្រជុំ ។

## មាត្រា ៤៩ (ស្ទួន ១)

នៅពេលវិស្សមកាលរបស់រដ្ឋសភា គណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភា ទទួលភារកិច្ចចាត់ចែងការងារ ។

គណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភារួមមាន : ប្រធានរដ្ឋសភា អនុប្រធាន អគ្គ-លេខាធិការ និងប្រធានបណ្ដាគណៈកម្មការនានារបស់រដ្ឋសភា ។

## មាត្រា ៤៩ (ស្ទួន ២) ថ្មី

គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាមានភារកិច្ច :

១- រៀបចំសម័យប្រជុំរដ្ឋសភា

២- កោះអញ្ជើញប្រជុំសាមញ្ញ ឬវិសាមញ្ញរបស់រដ្ឋសភា

៣- បកស្រាយច្បាប់

៤- មានសិទ្ធិផ្ដើមធ្វើសេចក្ដីព្រាងច្បាប់

៥- ពិនិត្យនិងសំរេចលើសេចក្ដីស្នើ ដាក់បំរ៉ាមគោចររបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ។

## មាត្រា ៥០

ពេលចាប់ផ្ដើមនីតិកាលនីមួយៗ រដ្ឋសភាជ្រើសតាំងគណៈកម្មការមួយ ដើម្បីត្រួតពិនិត្យសុពលភាព នៃសមាជិករដ្ឋសភា ហើយរាយការណ៍អំពីលទ្ធផលនៃការពិនិត្យនេះ ជូនរដ្ឋសភាសម្រេច ។

## មាត្រា ៥១

ប្រធានរដ្ឋសភាដឹកនាំអង្គប្រជុំរបស់រដ្ឋសភា ទទួលអាញ្ញត្តិច្បាប់ និងសេចក្ដីសម្រេច

ទាំងឡាយដែលរដ្ឋសភាអនុម័ត រ៉ាប់រងការអនុវត្តបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភា ចាត់ចែងការទាក់ទងអន្តរជាតិទាំងឡាយនៃរដ្ឋសភា ។

ក្នុងករណីដែលប្រធានរដ្ឋសភា មានធុរៈមិនអាចបំពេញមុខងារបាន ដោយហេតុមកពីមានជំងឺ ឬបំពេញបេសកកម្មនៅបរទេស អនុប្រធានរដ្ឋសភាមួយរូបត្រូវទទួលភារកិច្ចចាត់ចែងជំនួស ។

ក្នុងករណីដែលប្រធានរដ្ឋសភាលាលែងពីមុខតំណែង ឬទទួលអនិច្ចកម្ម រដ្ឋសភាត្រូវបោះឆ្នោតជ្រើសតាំងប្រធានថ្មី ។

អនុប្រធានរដ្ឋសភា ជួយប្រធានក្នុងមុខការទាំងឡាយដែលបានពោលខាងលើ ។

អគ្គលេខាធិការរដ្ឋសភា ធ្វើកំណត់ហេតុគ្រប់ការប្រជុំរដ្ឋសភា និងបំពេញការងារទាំងឡាយដែលប្រធានរដ្ឋសភាប្រគល់អោយ ។

## មាត្រា ៥២

រដ្ឋសភាចាត់តាំងគណៈកម្មការផ្សេងៗដែលចាំបាច់ ដើម្បីជួយរដ្ឋសភា ក្នុងការត្រួតពិនិត្យលើសេចក្តីព្រាងច្បាប់ គំរោងផែនការរដ្ឋ គំរោងថវិការដ្ឋ និងគំរោងផ្សេងៗទៀត ។

## មាត្រា ៥៣

ក្រុមប្រឹក្សារដ្ឋ ក្រុមប្រឹក្សារដ្ឋមន្ត្រី ប្រធានរដ្ឋសភា គណៈកម្មការនានារបស់រដ្ឋសភា ប្រធានក្រុមប្រឹក្សាជាតិរណសិរ្សសាមគ្គីកសាងការពារមាតុភូមិកម្ពុជា ប្រធានសហព័ន្ធសហជីពកម្ពុជា ប្រធានសមាគមយុវជនកម្ពុជា ប្រធានសមាគមនារីកម្ពុជា ប្រធានសមាគមកសិករកម្ពុជា ប្រធានតុលាការប្រជាជនកំពូល និងអគ្គរដ្ឋអាជ្ញាអមតុលាការប្រជាជនកំពូល

មានសិទ្ធិធ្វើសេចក្តីព្រាងច្បាប់ជូនរដ្ឋសភា ។

## មាត្រា ៥៤

រដ្ឋសភាអនុម័តច្បាប់ និងសេចក្តីសំរេចផ្សេងៗទៀត តាមមតិយល់ព្រមលើសពីពាក់កណ្តាលនៃសមាជិកទាំងមូល ។

រដ្ឋសភាអនុម័តរដ្ឋធម្មនុញ្ញ និង កែប្រែរដ្ឋធម្មនុញ្ញតាមមតិយល់ព្រមពីរភាគបីនៃសមាជិករដ្ឋសភាទាំងមូល ។

## មាត្រា ៥៥

ច្បាប់ដែលរដ្ឋសភាបានអនុម័តរួចហើយ ក្រុមប្រឹក្សារដ្ឋត្រូវប្រកាសអោយប្រើក្នុងរយៈ ១៥ ថ្ងៃយ៉ាងយូរ ។

ច្បាប់នេះត្រូវចូលជាធរមាន នៅរដ្ឋធានីភ្នំពេញក្នុងរយៈ១០ថ្ងៃ ក្រោយថ្ងៃប្រកាសអោយប្រើ និងនៅទូទាំងប្រទេសក្នុងរយៈ១ខែ ក្រោយពេលប្រកាសអោយប្រើ ។

ប៉ុន្តែបើច្បាប់នេះបានចែងថាជាការប្រញាប់ ច្បាប់នេះត្រូវចូលជាធរមានភ្លាមនៅទូទាំងប្រទេស ក្រោយថ្ងៃប្រកាសអោយប្រើ ។

ច្បាប់នេះត្រូវចុះក្នុងរដ្ឋកិច្ច និង ផ្សព្វផ្សាយនៅទូទាំងប្រទេសអោយទាន់តាមកាលកំណត់ខាងលើ ។

## មាត្រា ៥៦

សមាជិករដ្ឋសភាម្នាក់ៗ ត្រូវធ្វើការទាក់ទងយ៉ាងជិតស្និទ្ធជាមួយប្រជាជន យកចិត្តទុក

ដាក់ចំពោះសេចក្តីស្នើ ឬការទិតៀនរបស់ប្រជាជន ជួយណែនាំប្រជាជនអោយយល់ពីនយោបាយរបស់រដ្ឋ ហើយរាយការណ៍ពីសកម្មភាពរបស់ខ្លួននៅក្នុងរដ្ឋសភាជូនប្រជាជនជាម្ចាស់ឆ្នោត ។

សមាជិករដ្ឋសភារូបណា មិនបានបំពេញភារកិច្ចរបស់ខ្លួនអាចត្រូវរំសាយតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងច្បាប់ ។

ក្នុងករណីសមាជិករដ្ឋសភាណាមួយ ទទួលអនិច្ចកម្ម លាលែង ប្រាសចាកសមាជិកភាព ដែលកើតមានឡើង ១២ខែមុនចប់នីតិកាល ត្រូវចាត់ការបោះឆ្នោតជ្រើសតាំងជំនួសសមាជិកនោះ ។

## មាត្រា ៥៧

សមាជិករដ្ឋសភា មានសិទ្ធិតាំងសំនួរដេញដោលដល់ប្រធាន និងសមាជិកក្រុមប្រឹក្សារដ្ឋមន្ត្រី ប្រធាន និងសមាជិកក្រុមប្រឹក្សារដ្ឋ ប្រធាន អនុប្រធាន និងអគ្គលេខាធិការរដ្ឋសភា ប្រធានតុលាការប្រជាជនកំពូល អគ្គរដ្ឋអាជ្ញាអមតុលាការប្រជាជនកំពូល ។

អ្នកដែលត្រូវគេសួរដេញដោល ត្រូវឆ្លើយក្នុងសម័យប្រជុំរដ្ឋសភា ។

អ្នកដែលត្រូវរដ្ឋសភាសួរដេញដោល ត្រូវបានរំសាយពីមុខងារ បើសមាជិករដ្ឋសភាភាគច្រើនលើសពីពាក់កណ្តាលបានបោះឆ្នោតដកសេចក្តីទុកចិត្ត ។

## មាត្រា ៥៨

សមាជិករដ្ឋសភាមានអភ័យឯកសិទ្ធិ ។

សមាជិករដ្ឋសភារូបណាក៏ដោយ មិនអាចត្រូវចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬ ឃុំខ្លួន

ដោយហេតុពីបានសំដែងយោបល់ ឬបញ្ចេញមតិក្នុងការបំពេញមុខងាររបស់ខ្លួនសោះឡើយ ។

ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនសមាជិករដ្ឋសភាណាមួយនឹងអាចធ្វើទៅកើត លុះត្រាតែមានការយល់ព្រមពីរដ្ឋសភា ឬពីគណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភាក្នុងចន្លោះសម័យប្រជុំនៃរដ្ឋសភា វៀរលែងតែក្នុងករណីបទល្មើសព្រហ្មទណ្ឌជាក់ស្តែង ។ ក្នុងករណីខាងក្រោយនេះ ក្រសួងមានសមត្ថកិច្ចត្រូវធ្វើសេចក្តីរាយការណ៍ជូនរដ្ឋសភា ឬជូនគណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភាជាបន្ទាន់ ដើម្បីសំរេច ។

សេចក្តីសំរេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភា ត្រូវដាក់ជូនរដ្ឋសភាអនុម័តនៅសម័យប្រជុំរដ្ឋសភាខាងមុខ ។

### មាត្រា ៥៨ (ស្ទួន )

សមាជិករដ្ឋសភាត្រូវទទួលប្រាក់បំណាច់មានកំណត់ ដោយប្រៀបស្មើទៅនឹងប្រាក់បៀវត្ស នៃអ្នករដ្ឋការថ្នាក់ណាមួយនៃក្របខ័ណ្ឌជាន់ខ្ពស់ ។

## ជំពូកទី ៥

## ក្រុមប្រឹក្សារដ្ឋ

### មាត្រា ៥៩

ក្រុមប្រឹក្សារដ្ឋ ជាអង្គការតំណាងរដ្ឋកម្ពុជា ។

ក្រុមប្រឹក្សារដ្ឋមានប្រធាន អនុប្រធាន អគ្គលេខាធិការ និងសមាជិកមួយចំនួនដែលត្រូវរដ្ឋសភាកំណត់ ។

ក្រុមប្រឹក្សារដ្ឋត្រូវបានជ្រើសតាំងដោយរដ្ឋសភា ។

ប្រធានក្រុមប្រឹក្សារដ្ឋជាប្រមុខរដ្ឋកម្ពុជា ។

## មាត្រា ៦០ ថ្មី

ក្រុមប្រឹក្សារដ្ឋ មានមុខការដូចតទៅ ÷

១ - កោះសម័យប្រជុំរដ្ឋសភាលើកទី ១ នៃនីតិកាលនិមួយៗ ។

២ - ប្រកាសអោយប្រើច្បាប់ និងចេញក្រឹត្យ ។

៣ - ចេញក្រឹត្យតែងតាំងឬរំសាយ ប្រធាន អនុប្រធាន អគ្គលេខាធិការ និងសមាជិករដ្ឋសភា ប្រធាន អនុប្រធាន អគ្គលេខាធិការ និងសមាជិកក្រុមប្រឹក្សារដ្ឋ ប្រធាន អនុប្រធាន និងសមាជិកក្រុមប្រឹក្សារដ្ឋមន្ត្រី ប្រធានតុលាការប្រជាជនកំពូល និងអគ្គរដ្ឋអាជ្ញាអមតុលាការប្រជាជនកំពូល ក្រោយពីរដ្ឋសភាបានអនុម័ត ។

៤ - ចេញក្រឹត្យប្រកាសអោយប្រើច្បាប់ស្ដីពីការបង្កើត ឬលុបចោលតុលាការប្រជាជនកំពូល និងមហាអយ្យការអមតុលាការប្រជាជនកំពូល ទីស្ដីការរដ្ឋមន្ត្រី និង ស្ថាប័នថ្នាក់ស្មើទីស្ដីការរដ្ឋមន្ត្រី ក្រុង ខ័ណ្ឌ សង្កាត់ ខេត្ត ទីរួមខេត្ត ស្រុក និងឃុំ ក្រោយ ពីរដ្ឋសភាបានអនុម័ត ។

៥ - ចេញក្រឹត្យប្រកាសអោយប្រើច្បាប់ ស្ដីពីការដាក់ប្រទេសជាតិស្ថិតក្នុងភយន្តរាយ ឬស្ថិតក្នុងភាពអាសន្ន នៅក្នុងទូទាំងប្រទេស ឬនៅក្នុងតំបន់ខ្លះ ក្រោយពីរដ្ឋសភាបានអនុម័ត។

៦ - តាមសំណើររបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី តែងតាំង រំសាយ ឬដកឯកអគ្គរដ្ឋទូត ឬប្រេសិតនៃរដ្ឋកម្ពុជា នៅឯបរទេស និងនៅអមអង្គការអន្តរជាតិនានា។

៧ - ទទួលសារតាំង របស់តំណាងការទូត។

៨ - អោយសច្ចាប័នលើសន្ធិសញ្ញា និងអនុសញ្ញាអន្តរជាតិរបស់រដ្ឋាភិបាល ក្រោយពីរដ្ឋសភាបានអនុម័ត ។

៩ - បង្កើតនិងប្រគល់គ្រឿងឥស្សរិយយសតាមសំណើរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ។

១០ - សំរេចប្រគល់ឋានន្តរសក្តិ ឋានៈយោធា នគរបាល និងឋានៈស៊ីវិលតាមច្បាប់កំណត់ និងតាមសំណើរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ។

១១ - សំរេចអំពីការសុំចូលសញ្ជាតិតាមច្បាប់កំណត់ ។

១២ - សំរេចអនុគ្រោះទោស បន្ថយទោស និងលើកលែងទោស ។

១៣ - បំពេញភារកិច្ចផ្សេងៗទៀត ដែលរដ្ឋសភាប្រគល់អោយ ។

## មាត្រា ៦០ (ស្ទួន ១)

សេចក្តីសំរេចរបស់ក្រុមប្រឹក្សារដ្ឋ ត្រូវតែមានសមាជិកក្រុមប្រឹក្សារដ្ឋលើសពីពាក់កណ្តាលយល់ព្រម ។

## មាត្រា ៦០ (ស្ទួន ២)

ក្រុមប្រឹក្សារដ្ឋ មានភារកិច្ចរាយការណ៍អំពីសកម្មភាពរបស់ខ្លួនជូនរដ្ឋសភា ។

## មាត្រា ៦១ ថ្មី

អាណត្តិរបស់ក្រុមប្រឹក្សារដ្ឋ មានកំណត់ស្មើនឹងនីតិកាលរបស់រដ្ឋសភា ។ នៅពេលផុតកំណត់នីតិកាលរដ្ឋសភា ក្រុមប្រឹក្សារដ្ឋបន្តសកម្មភាពរបស់ខ្លួន រហូតដល់រដ្ឋសភាថ្មីបោះឆ្នោតជ្រើសតាំងក្រុមប្រឹក្សារដ្ឋថ្មីបាន ។

ក្នុងករណីប្រមុខរដ្ឋមានធុរៈ មិនអាចបំពេញការងារបានដោយហេតុមកពីមានជំងឺ ឬ

បំពេញបេសសកម្មនៅបរទេស អនុប្រធានក្រុមប្រឹក្សារដ្ឋមួយរូបត្រូវទទួលភារកិច្ចចាត់ការជំនួស លើកលែងតែមុខការដែលមានចែងក្នុងចំណុចទី ៦ ទី ៨ ទី ៩ ទី ១០ ទី ១១ និងទី ១២ នៃមាត្រា ៦០ ។

ក្នុងករណីដែលប្រធាន ឬសមាជិកក្រុមប្រឹក្សារដ្ឋលាលែង ឬធ្លាក់ពីតំណែង ឬទទួលអនិច្ចកម្ម ត្រូវធ្វើការបោះឆ្នោតជ្រើសតាំងសាជាថ្មី ។

ប្រធានរដ្ឋសភា ត្រូវទទួលមុខងារជាប្រធានក្រុមប្រឹក្សារដ្ឋស្ដីទី រហូតដល់ប្រធានក្រុមប្រឹក្សារដ្ឋថ្មីចូលកាន់តំណែង ។

### មាត្រា ៦២

ប្រធានក្រុមប្រឹក្សារដ្ឋ ជាអគ្គមេបញ្ជាការកំពូលនៃកងកំលាំងប្រដាប់អាវុធប្រជាជនកម្ពុជា និងជាប្រធានក្រុមប្រឹក្សាការពារជាតិ ។

### មាត្រា ៦៣

ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សារដ្ឋ និងក្រុមប្រឹក្សាការពារជាតិត្រូវកំណត់ក្នុងច្បាប់ ។

## ជំពូក ៦

## ក្រុមប្រឹក្សារដ្ឋមន្ត្រី

### មាត្រា ៦៤

ក្រុមប្រឹក្សារដ្ឋមន្ត្រីជារដ្ឋាភិបាលនៃរដ្ឋកម្ពុជា ជាអង្គការគ្រប់គ្រងសង្គមដោយផ្ទាល់ និងដឹកនាំការពង្រីកសេដ្ឋកិច្ចជាតិដោយផ្ទាល់ ។

ក្រុមប្រឹក្សារដ្ឋមន្ត្រីទទួលខុសត្រូវចំពោះរដ្ឋសភា ក្រុមប្រឹក្សារដ្ឋ និងរាយការណ៍អំពីការងាររបស់ខ្លួនជូនអង្គការទាំងនេះ ។

## មាត្រា ៦៥ ថ្មី

ក្រុមប្រឹក្សារដ្ឋមន្ត្រីមានប្រធាន អនុប្រធាន និងសមាជិក ។ ចំនួនអនុប្រធាន និងសមាជិកក្រុមប្រឹក្សារដ្ឋមន្ត្រី ត្រូវរដ្ឋសភាកំណត់ ។

ការជ្រើសតាំង រំសាយ ឬផ្លាស់ប្តូរប្រធាន អនុប្រធាន និងសមាជិក ក្រុមប្រឹក្សារដ្ឋមន្ត្រីត្រូវសុំការអនុម័តិពីរដ្ឋសភាតាមវិធីជ្រើសឆ្នោតជាសម្ងាត់ ។

## មាត្រា ៦៦ ថ្មី

ក្រុមប្រឹក្សារដ្ឋមន្ត្រីមានមុខការដូចតទៅ :

១ - ធ្វើសេចក្តីព្រាងច្បាប់ និងសេចក្តីព្រាងផ្សេងៗទៀត ដើម្បីជូនរដ្ឋសភា និងក្រុមប្រឹក្សារដ្ឋ ។

២ - អនុវត្តរដ្ឋធម្មនុញ្ញ ច្បាប់ ក្រឹត្យ អនុវត្តនយោបាយក្នុងប្រទេស និងក្រៅប្រទេស ។

៣ - ធ្វើសេចក្តីព្រាងផែនការរដ្ឋ និង ថវិការដ្ឋ ។

៤ - អនុវត្តផែនការរដ្ឋ និង ថវិការដ្ឋ ។

៥ - កសាង និង ពង្រឹងអង្គការរដ្ឋ ពីថ្នាក់មជ្ឈឹមដល់ថ្នាក់មូលដ្ឋាន បណ្តុះបណ្តាល និងគ្រប់គ្រងកម្មករ និងនិយោជិតរបស់រដ្ឋ ។

៦ - រ៉ាប់រងការដឹកនាំការងាររបស់ទីស្តីការរដ្ឋមន្ត្រី និងស្ថាប័ននានាដែលនៅក្រោមឱវាទក្រុមប្រឹក្សារដ្ឋមន្ត្រី អោយមានឯកភាព និងរ៉ាប់រងការដឹកនាំការងារ របស់គណៈកម្មាធិការប្រជាជនមូលដ្ឋានគ្រប់ថ្នាក់អោយមានឯកភាព ។

៧ - ផ្អាកការអនុវត្ត កែប្រែ ឬលុបចោលអនុសញ្ញា និងសេចក្តីណែនាំមិនសមស្របរបស់រដ្ឋមន្ត្រី និងរបស់ប្រធានស្ថាប័នរដ្ឋនានា ។

ផ្អាកការអនុវត្ត កែប្រែ ឬលុបចោលសេចក្តីសំរេច និងសេចក្តីណែនាំមិនសមស្របរបស់គណៈកម្មាធិការប្រជាជនគ្រប់ថ្នាក់ ។

៨ - ចាត់វិធានការ កំណត់ព្រំដែន ក្រុង ខ័ណ្ឌ សង្កាត់ ខេត្ត ទីរួមខេត្ត ស្រុក និងឃុំតាមបញ្ញត្តិច្បាប់ ។

៩ - ការពារផលប្រយោជន៏របស់ប្រជាជន រក្សាសន្តិសុខ របៀបរៀបរយសាធារណៈ ការពារសិទ្ធិ និង ផលប្រយោជន៏ស្របច្បាប់របស់ពលរដ្ឋ ។

១០ - ពង្រឹង និង បង្កើនកំលាំងការពារជាតិ អនុវត្តការប្រមូលកំលាំងទ័ព ចេញបំរ៉ាមគោចរក្នុងករណីចាំបាច់ ក្រោយពីបានការយល់ព្រមពីគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា និងចាត់វិធានការចាំបាច់ផ្សេងៗដើម្បីការពារជាតិ ។

១១ - អនុវត្តសន្ធិសញ្ញា និងអនុសញ្ញាអន្តរជាតិទាំងឡាយ ។

១២ - បំពេញភារកិច្ចផ្សេងៗទៀត ដែលរដ្ឋសភា និងក្រុមប្រឹក្សារដ្ឋប្រគល់អោយ ។

## មាត្រា ៦៧

ប្រធានក្រុមប្រឹក្សារដ្ឋមន្ត្រី ដឹកនាំការងាររបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ហើយធ្វើជាអធិបតី

នៃអង្គប្រជុំក្រុមប្រឹក្សារដ្ឋមន្ត្រី ។

អនុប្រធានមួយរូបជួយប្រធាន និងកាន់កាប់មុខងារប្រធាននៅពេលប្រធានអវត្តមាន ។

សមាជិកម្នាក់ៗរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ទទួលខុសត្រូវពីសកម្មភាពរបស់ខ្លួន និងទទួលខុសត្រូវរួមជាមួយនឹងសមាជិកផ្សេងៗទៀត ពីសកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ។

## មាត្រា ៦៨

សេចក្តីសំរេចរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ត្រូវតែមានការយល់ព្រមពីសមាជិកភាគច្រើននៃក្រុមប្រឹក្សារដ្ឋមន្ត្រីទាំងមូល ។

ប្រធានក្រុមប្រឹក្សាជាតិរណសិរ្សសាមគ្គីកសាងការពារមាតុភូមិកម្ពុជា ប្រធានសហព័ន្ធសហជីពកម្ពុជា ប្រធានសមាគមយុវជនកម្ពុជា ប្រធានសមាគមនារីកម្ពុជា និងប្រធានសមាគមកសិករកម្ពុជា មានសិទ្ធិចូលរួមក្នុងការប្រជុំរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ។

## មាត្រា ៦៩

អាណត្តិរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី មានកំណត់ស្មើនឹងនីតិកាលរបស់រដ្ឋសភា ។

នៅពេលផុតនីតិកាលរដ្ឋសភា ក្រុមប្រឹក្សារដ្ឋមន្ត្រីបន្តសកម្មភាពរបស់ខ្លួនរហូតដល់រដ្ឋសភា ជ្រើសតាំងក្រុមប្រឹក្សារដ្ឋមន្ត្រីថ្មីបាន ។

## មាត្រា ៧០

ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សារដ្ឋមន្ត្រីត្រូវកំណត់ក្នុងច្បាប់ ។

# ជំពូក ៧

# គណៈកម្មាធិការប្រជាជនមូលដ្ឋាន

## មាត្រា ៧១

ដែនដីនៃរដ្ឋកម្ពុជាត្រូវបែងចែកជាខេត្ត និងក្រុង ចំណុះរដ្ឋអំណាចមជ្ឈិមផ្ទាល់។

ខេត្តត្រូវបែងចែកជាទីរួមខេត្ត និង ស្រុក ។

ទីរួមខេត្តត្រូវបែងចែកជាសង្កាត់ ។

ស្រុកត្រូវបែងចែកជាឃុំ ។

ក្រុងចំណុះរដ្ឋអំណាចមជ្ឈិមផ្ទាល់ត្រូវបែងចែកជាខ័ណ្ឌ និងស្រុកជាយក្រុង ។

ខ័ណ្ឌត្រូវបែងចែកជាសង្កាត់ ។

ស្រុកជាយក្រុងត្រូវបែងចែកដូចស្រុកចំណុះខេត្ត ។

## មាត្រា ៧២

គណៈកម្មាធិការប្រជាជនត្រូវមាននៅគ្រប់ក្រុង គ្រប់ខ័ណ្ឌ គ្រប់ស្រុកជាយក្រុង គ្រប់សង្កាត់ គ្រប់ខេត្ត គ្រប់ទីរួមខេត្ត គ្រប់ស្រុក និង គ្រប់ឃុំ។

សមាជិកគណៈកម្មាធិការប្រជាជនឃុំ និងសង្កាត់ត្រូវបានប្រជាជននៅឃុំ និងសង្កាត់ជ្រើសរើស តាមលក្ខណការណ៍បោះឆ្នោតជាសកល ដោយស្មើភាព ដោយចំពោះ និងតាមវិធីជ្រើសរើសជាសម្ងាត់ ។

សមាជិកគណៈកម្មាធិការប្រជាជនទីរួមខេត្ត និងស្រុកត្រូវបានជ្រើសរើស ដោយតំណាងគណៈកម្មាធិការប្រជាជនឃុំ និងសង្កាត់ តំណាងរណសិរ្ស និងតំណាងអង្គការមហា-

ជនជាសមាជិករណសិរ្សថ្នាក់ទីរួមខេត្ត និង ស្រុក ។

សមាជិកគណៈកម្មាធិការប្រជាជនខ័ណ្ឌ និង ស្រុកជាយក្រុងត្រូវបានជ្រើសរើសដោយតំណាងគណៈកម្មាធិការប្រជាជនឃុំ និង សង្កាត់ តំណាងរណសិរ្ស និងតំណាងអង្គការមហាជនជាសមាជិករណសិរ្សថ្នាក់ខ័ណ្ឌ និងស្រុកជាយក្រុង ។

សមាជិកគណៈកម្មាធិការប្រជាជនខេត្ត ត្រូវបានជ្រើសរើសដោយតំណាងគណៈ-កម្មាធិការប្រជាជនទីរួមខេត្ត និង ស្រុក តំណាងរណសិរ្ស និងតំណាងអង្គការមហាជនជាសមាជិករណសិរ្សថ្នាក់ខេត្ត ។

សមាជិកគណៈកម្មាធិការប្រជាជនក្រុង ត្រូវបានជ្រើសរើសដោយតំណាងគណៈ-កម្មាធិការប្រជាជនខ័ណ្ឌ និងស្រុកជាយក្រុង តំណាងរណសិរ្ស និងតំណាងអង្គការមហាជនជាសមាជិករណសិរ្សថ្នាក់ក្រុង ។

## មាត្រា ៧៣

គណៈកម្មាធិការប្រជាជន មានប្រធាន អនុប្រធាន និងសមាជិក ។

អាណត្តិរបស់គណៈកម្មាធិការប្រជាជនខេត្ត ក្រុង មានកំណត់ ៥ ឆ្នាំ ។

អាណត្តិរបស់គណៈកម្មាធិការប្រជាជនទីរួមខេត្ត ស្រុក ឃុំ ខ័ណ្ឌ សង្កាត់ ស្រុកជាយក្រុង មានកំណត់ ៣ ឆ្នាំ ។

## មាត្រា ៧៤

គណៈកម្មាធិការប្រជាជនគ្រប់ថ្នាក់ ទទួលខុសត្រូវចំពោះប្រជាជននៅមូលដ្ឋាន និងទទួលខុសត្រូវចំពោះអង្គការរដ្ឋអំណាចថ្នាក់លើ ។

## មាត្រា ៧៥

គណៈកម្មាធិការប្រជាជនមូលដ្ឋានសំរេច និងអនុវត្តគោលការណ៍កសាងមូលដ្ឋានលើគ្រប់វិស័យ អនុវត្តសេចក្តីសំរេច និងសារាចររបស់អង្គការរដ្ឋថ្នាក់លើ គ្រប់គ្រងការងាររដ្ឋបាលនៅមូលដ្ឋាន និងណែនាំគ្រប់ផ្នែក គ្រប់ថ្នាក់ដែលនៅក្រោមឪវាទផ្ទាល់អោយអនុវត្តភារកិច្ច រក្សាសន្តិសុខសាធារណៈនិងរបៀបរៀបរយសង្គម កសាងសេដ្ឋកិច្ច ពង្រីកវប្បធម៌ថែទាំសុខភាព លើកស្ទួយជីវភាពប្រជាជននៅមូលដ្ឋាន ។

## មាត្រា ៧៦

ដោយយោលតាមតំណែង និង មុខការដែលច្បាប់បានកំណត់ គណៈកម្មាធិការប្រជាជនគ្រប់ថ្នាក់ ចេញសេចក្តីសំរេច ចេញសេចក្តីបង្គាប់ និងត្រួតពិនិត្យការអនុវត្តសេចក្តីសំរេចសេចក្តីបង្គាប់ទាំងនេះ ។

គណៈកម្មាធិការប្រជាជន មានសិទ្ធិផ្អាកការអនុវត្ត កែប្រែ ឬលុបចោលសេចក្តីសំរេច និងសេចក្តីបង្គាប់មិនសមស្របនៃអង្គការនៅក្រោមឪវាទផ្ទាល់របស់ខ្លួន និង របស់គណៈកម្មាធិការប្រជាជនថ្នាក់ក្រោម ។

## មាត្រា ៧៧

គណៈកម្មាធិការប្រជាជនណា ឬសមាជិកគណៈកម្មាធិការប្រជាជនណា មិនបានបំពេញភារកិច្ចរបស់ខ្លួន អាចត្រូវបានហូតងារ ឬ រំសាយតាមលក្ខណៈដែលកំណត់ក្នុងច្បាប់ ។

## មាត្រា ៧៨

ការតែងតាំង ការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈកម្មាធិការប្រជាជនមូលដ្ឋានត្រូវកំណត់ក្នុងច្បាប់ ។

# ជំពូកទី ៨
# សាលាជម្រះក្តី និង អយ្យការ

## មាត្រា ៧៩

សកម្មភាពនៃសាលាជម្រះក្តី និងអយ្យការមានទីដៅដូចតទៅ :

១ - ការពារអំណាចប្រជាជន និង ការពារនីត្យានុកូលភាពប្រជាធិបតេយ្យ ។

២ - រក្សាសន្តិសុខសាធារណៈ និង របៀបរៀបរយសង្គម ។

៣ - ការពារទ្រព្យសម្បត្តិសាធារណៈ ។

៤ - ការពារសិទ្ធិ សេរីភាព ជីវិត និងប្រយោជន៍ស្របច្បាប់របស់ពលរដ្ឋ ។

## មាត្រា ៨០

តុលាការប្រជាជន និងតុលាការយោធា ជាអង្គការជំនុំជម្រះនៃរដ្ឋកម្ពុជា ។ រដ្ឋអាជ្ញាអមសាលាជម្រះក្តី ធ្វើការចោទប្រកាន់ ប្តឹងទៅតុលាការតាមច្បាប់ ធានាការប្តឹងទៅតុលាការជំនុំជម្រះ និងការអនុវត្តសាលក្រមអោយបានត្រឹមត្រូវ និងស្របច្បាប់។

ក្នុងករណីចាំបាច់ ក្រុមប្រឹក្សារដ្ឋអាចបង្កើតតុលាការពិសេស ដើម្បីជំនុំជម្រះរឿងដែលមានលក្ខណៈពិសេស ។

## មាត្រា ៨១

ដើម្បីជំនុំជម្រះ សាលាជម្រះក្តីផ្អែកលើច្បាប់ និងផ្អែកលើលក្ខណការណ៍ពលរដ្ឋគ្រប់រូបមានភាពស្មើគ្នាចំពោះច្បាប់ ដោយឥតប្រកាន់ជនជាតិ ជំនឿ សាសនា ភេទ និង ឋានៈក្នុងសង្គម ។

## មាត្រា ៨២

ទីប្រឹក្សាប្រជាជនចូលរួមក្នុងសកម្មភាពតុលាការ តាមបញ្ញត្តិច្បាប់ ។ ក្នុងការជំនុំជម្រះ ទីប្រឹក្សាប្រជាជនមានសិទ្ធិស្មើនឹងចៅក្រម ។

ក្រុមប្រឹក្សាជំនុំជម្រះ ត្រូវសំរេចតាមមតិភាគច្រើន ។

## មាត្រា ៨៣

នៅគ្រប់សាលាជម្រះក្តី ការជំនុំជម្រះត្រូវធ្វើជាសាធារណៈ ។

ប៉ុន្តែការជំនុំជម្រះអាចប្រព្រឹត្តទៅជាសម្ងាត់ ក្នុងករណីដែលមានចែងក្នុងច្បាប់ ។

## មាត្រា ៨៤

សាលាជម្រះក្តីនៃរដ្ឋកម្ពុជា ធានារ៉ាប់រងអោយពលរដ្ឋដែលជាជនជាតិភាគតិចមានសិទ្ធិប្រើភាសា និងអក្សររបស់ខ្លួនចំពោះមុខសាលាជម្រះក្តី ។

## មាត្រា ៨៥

សិទ្ធិការពារខ្លួនរបស់ជនជាប់ចោទ ត្រូវបានធានា ។

ជនជាប់ចោទមានសិទ្ធិការពារខ្លួនដោយខ្លួនឯង ឬពឹងមេធាវី ឬ ពឹងអ្នកដទៃណាមួយដើម្បីអោយជួយការពារ ។

## មាត្រា ៨៦

ការរៀបចំនិងការប្រព្រឹត្តទៅនៃសាលាជម្រះក្តី និងអយ្យការត្រូវកំណត់ក្នុងច្បាប់ ។

# ជំពូកទី ៩
# សញ្ញាជាតិ ទង់ជាតិ ភ្លេងជាតិ
# និង រដ្ឋធានី

## មាត្រា ៨៧

សញ្ញាជាតិនៃរដ្ឋកម្ពុជា មានរាងមូល ផ្ទៃក្រហម មានកម្រងកួរស្រូវពណ៌មាស អមសងខាងជារង្វង់ស្នែងក្របីជួបគ្នាខាងចុង ។

ខ្សែបូក្រហមរុំព័ទ្ធផ្នែកខាងក្រោមនៃកម្រងកួរស្រូវ ជាពីរថ្នាក់ ។ នៅកណ្តាលខ្សែបូមានចរិកអក្សរមាសថា "រដ្ឋកម្ពុជា" ។

ស្បៀវភៅមាសរដ្ឋធម្មនុញ្ញ បើកទំព័រតម្កល់លើដើមស្រូវចងជាបូ ។ កង់គ្រឿងចក្រចេញរាងពាក់កណ្តាលមានកាំ ៧ ផ្អែកពីមុខស្បៀវភៅមាស ។ នៅលើកង់គ្រឿងចក្រ មានរូបប្រាសាទអង្គរវត្តកំពូល ៥ ពណ៌មាស ស្ថិតនៅចំរង្វង់កម្រងកួរស្រូវ ។

## មាត្រា ៨៨

ទង់ជាតិមានផ្ទៃពណ៌ខៀវក្រោម ក្រហមលើដែលមានទំហំផ្ទៃខៀវ និងផ្ទៃក្រហមស្មើគ្នា ហើយទទឹងស្មើនឹង ២ ភាគបីនៃបណ្តោយ ។ ឯរូបប្រាសាទខាងក្នុង ជារូបប្រាសាទកំពូល ៥ ពណ៌លឿង ប្រកបទៅដោយក្បូរក្បាច់រចនា កម្ពស់ពីបាទខឿនប្រាសាទទៅដល់កំពូលប្រាសាទកណ្តាល ស្មើនឹងពាក់កណ្តាលនៃបាតខឿន កម្ពស់ប្រាសាទស្មើនឹង ២ ភាគ ៥ នៃទទឹងផ្ទៃ ។ មុំនៃកំពូលប្រាសាទកណ្តាលមកកំពូលប្រាសាទសងខាង មាន ១៣០ អង្សារ ។

ពណ៌ក្រហម តំណាងឆន្ទៈដ៏អង់អាចក្លាហានរបស់ប្រជាជនកម្ពុជា ក្នុងការការពារ និង កសាងប្រទេសជាតិអោយសំបូររុងរឿង ។

ពណ៌ខៀវ តំណាងប្រជាជនទាំងមូលដែលអបអរសាទរទ្រព្យធនធានជាតិ និង តំណាង ភោគផលធម្មជាតិ ទាំងលើដី ក្នុងដី ក្នុងទឹក ក្រោមទឹក អោយឋិតថេរជាអមតៈ ។

ពណ៌លឿង តំណាងអរិយធម៌ដ៏យូរលង់របស់ប្រជាជនកម្ពុជា និង សាសនា ។

## មាត្រា ៨៩

ភ្លេងជាតិនៃរដ្ឋកម្ពុជា ត្រូវរដ្ឋសភាកំណត់ ។

ថ្ងៃបុណ្យជាតិ គឺថ្ងៃ ៧ មករា ។

## មាត្រា ៩០

រដ្ឋធានីនៃរដ្ឋកម្ពុជាគឺ " ភ្នំពេញ " ។

# ជំពូកទី ១០

# អានុភាព នៃ រដ្ឋធម្មនុញ្ញ និង ការកែប្រែរដ្ឋធម្មនុញ្ញ

## មាត្រា ៩១

រដ្ឋធម្មនុញ្ញនេះ ជាច្បាប់គោលនៃរដ្ឋកម្ពុជា ហើយមានអានុភាពខ្ពស់បំផុតខាងច្បាប់ ។ ច្បាប់ទាំងឡាយត្រូវស្របនឹងរដ្ឋធម្មនុញ្ញជាដាច់ខាត ។

## មាត្រា ៩២

ច្បាប់ ក្រឹត្យ-ច្បាប់ ក្រឹត្យ អនុក្រឹត្យ ប្រកាស និងសេចក្តីសំរេច ទាំងឡាយរបស់

ស្ថាប័ននានា នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលស្របនឹងរដ្ឋធម្មនុញ្ញនៃរដ្ឋកម្ពុជា ត្រូវនៅជាធរមាន លុះដល់ពេលមានអត្ថបទថ្មីជំនួស ។

ក្រឹត្យ-ច្បាប់ និង សេចក្តីសំរេចទាំងឡាយ របស់ក្រុមប្រឹក្សាប្រជាជនបដិវត្តកម្ពុជា ដែលមានលក្ខណៈជាច្បាប់ ហើយស្របនឹងរដ្ឋធម្មនុញ្ញនៃរដ្ឋកម្ពុជា ត្រូវនៅជាធរមាន លុះដល់ពេលណាមានច្បាប់ ។

## មាត្រា ៩៣

ការកែប្រែរដ្ឋធម្មនុញ្ញ ជាសមត្ថកិច្ចរបស់រដ្ឋសភា ហើយអាចប្រព្រឹត្តទៅបាន លុះត្រាតែមានសមាជិករដ្ឋសភាពីរភាគបីយល់ព្រម ។

រដ្ឋធម្មនុញ្ញកែប្រែ (រដ្ឋធម្មនុញ្ញនៃរដ្ឋកម្ពុជា) នេះ ត្រូវបានរដ្ឋសភា នៃសាធារណរដ្ឋប្រជាមានិតកម្ពុជាអនុម័តជាឯកច្ឆ័ន្ទ នៅថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៨៩ នាសម័យប្រជុំវិសាមញ្ញនៃនីតិកាលទី ១ ។

ធ្វើនៅភ្នំពេញ, ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៨៩

**ជ. រដ្ឋសភា**

**ប្រធាន**

**ហត្ថលេខា និង ត្រា : ជា ស៊ីម**

**បោះពុម្ពដោយ**

**ខុទ្ទកាល័យរដ្ឋសភា**

**១៩៩២**

**ចំនួន ៥.៥០០ ច្បាប់**


បោះពុម្ពដោយរោងពុម្ព

**ឈុប បុផាន់**

១៩៩២

# រដ្ឋធម្មនុញ្ញ
# នៃ
# ព្រះរាជាណាចក្រកម្ពុជា

Constitution
du
ROYAUME DU CAMBODGE



# បុព្វកថា

****

## យើង ប្រជារាស្ត្រខ្មែរ

ដែលធ្លាប់មានអារ្យធម៌ឧត្តុង្គឧត្តម ប្រទេសជាតិស្តុកស្តម្ភធំទូលាយ ថ្កុំថ្កើងរុងរឿងកិត្យានុភាពខ្ពង់ខ្ពស់ភ្លឺចែងចាំងដូចពេជ្រពណ្ណរាយ

បានធ្លាក់ខ្លួនដ៏សែនរន្ធត់ ក្នុងអំឡុងពីរទសវត្សរ៍ចុងក្រោយនេះ ឆ្លងកាត់ទុក្ខសោកវិនាសអន្តរាយ ទ្រុឌទ្រោម ឱនថយ មហាសោកស្តាយ

បានភ្ញាក់រលឹក ក្រោកឈរឡើង ចងបាច់ឆន្ទៈមោះមុត ប្តូរផ្តាច់រួបរួមគ្នា ពង្រឹងឯកភាពជាតិ រក្សាការពារទឹកដីកម្ពុជា អធិបតេយ្យថ្លៃថ្លា និង អារ្យធម៌អង្គរដ៏បវរ កសាងប្រទេសជាតិឱ្យទៅជា " កោះសន្តិភាព " ឡើងវិញ ផ្អែកលើប្រព័ន្ធប្រជាធិបតេយ្យសេរីពហុបក្ស ធានាសិទ្ធិមនុស្ស គោរពច្បាប់ ទទួលខុសត្រូវខ្ពស់ ចំពោះវាសនាអនាគតជាតិឱ្យបានឈានឡើងរីកចម្រើន លូតលាស់ សម្បូររុងរឿងជានិច្ចនិរន្តរ៍ ។

## ក្នុងឆន្ទៈមោះមុតនេះ

យើងសរសេរចារឹកក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាដូចតទៅ ÷

## ជំពូកទី ១

## អំពីអធិបតេយ្យ

**មាត្រា ១ .-**

ប្រទេសកម្ពុជា ជាព្រះរាជាណាចក្រដែលព្រះមហាក្សត្រទ្រង់ប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ និងតាមលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស ។

ព្រះរាជាណាចក្រកម្ពុជា ជារដ្ឋឯករាជ្យ អធិបតេយ្យ សន្តិភាព អព្យាក្រឹត អចិន្ត្រៃយ៍ មិនចូលបក្សសម្ព័ន្ធ ។

**មាត្រា ២ .-**

បូរណភាពទឹកដីរបស់ព្រះរាជាណាចក្រកម្ពុជា មិនអាចរំលោភបានដាច់ខាតក្នុងព្រំដែនរបស់ខ្លួនដែលមានកំណត់ក្នុងផែនទីខ្នាត ១/១០០.០០០ ធ្វើនៅចន្លោះឆ្នាំ១៩៣៣-១៩៥៣ ហើយដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ នៅចន្លោះឆ្នាំ១៩៦៣-១៩៦៩ ។

**មាត្រា ៣ .-**

ព្រះរាជាណាចក្រកម្ពុជា ជារដ្ឋដែលមិនអាចបំបែកបាន ។

**មាត្រា ៤ .-**

បាវចនានៃព្រះរាជាណាចក្រកម្ពុជា គឺ : ជាតិ សាសនា ព្រះមហាក្សត្រ ។

**មាត្រា ៥ .-**

ភាសា និង អក្សរ ដែលប្រើជាផ្លូវការ គឺភាសា និង អក្សរខ្មែរ ។

**មាត្រា ៦ .-**

ភ្នំពេញជារាជធានីនៃព្រះរាជាណាចក្រកម្ពុជា ។

ទង់ជាតិ ភ្លេងជាតិ និង សញ្ញាជាតិមានកំណត់នៅក្នុងឧបសម្ព័ន្ធ ១ ២ និង ៣ ។

## ជំពូកទី ២

## អំពីព្រះមហាក្សត្រ

**មាត្រា ៧ .-**

ព្រះមហាក្សត្រកម្ពុជា ទ្រង់គ្រងរាជសម្បត្តិ ប៉ុន្តែទ្រង់មិនកាន់អំណាចឡើយ ។

ព្រះមហាក្សត្រ ទ្រង់ជាព្រះប្រមុខរដ្ឋមួយជីវិត ។

អង្គព្រះមហាក្សត្រ មិនអាចនរណារំលោភបំពានបានឡើយ ។

**មាត្រា ៨ .-**

ព្រះមហាក្សត្រ ព្រះអង្គទ្រង់ជានិមិត្តរូបនៃឯកភាពជាតិ និង និរន្តរភាពជាតិ ។

ព្រះមហាក្សត្រ ទ្រង់ជាអ្នកធានាឯករាជ្យជាតិ អធិបតេយ្យ និង បូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ជាអ្នកធានាការគោរពសិទ្ធិ និង សេរីភាពរបស់ប្រជាពលរដ្ឋ និងការគោរពសន្ធិសញ្ញាអន្តរជាតិ ។

**មាត្រា ៩ .-**

ព្រះមហាក្សត្រ ទ្រង់មានតួនាទីខ្ពង់ខ្ពស់ជាអាជ្ញាកណ្តាល ដើម្បីធានាការប្រព្រឹត្តទៅនៃអំណាចសាធារណៈឱ្យមានភាពទៀងទាត់ ។

**មាត្រា ១០ .-**

របបរាជានិយមកម្ពុជា ជារបបជ្រើសតាំង ។

ព្រះមហាក្សត្រ ទ្រង់ឥតមានព្រះរាជអំណាចចាត់តាំងព្រះរជ្ជទាយាទសម្រាប់គ្រងរាជសម្បត្តិឡើយ ។

**មាត្រា ១១ .- ថ្មី**

ក្នុងករណីដែលព្រះមហាក្សត្រ ពុំអាចបំពេញព្រះរាជភារៈ ជាព្រះប្រមុខរដ្ឋបានដូចធម្មតា ដោយព្រះអង្គទ្រង់ប្រឈួនជាទម្ងន់ មានការបញ្ជាក់ដោយក្រុមគ្រូពេទ្យជំនាញជ្រើសរើសដោយប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា និង នាយករដ្ឋមន្ត្រី នោះប្រធានព្រឹទ្ធសភាបំពេញភារកិច្ចប្រមុខរដ្ឋជំនួសព្រះអង្គ ក្នុងឋានៈជាព្រះរាជានុសិទ្ធិ ។

ក្នុងករណីដែលប្រធានព្រឹទ្ធសភា ពុំមានលទ្ធភាពបំពេញភារកិច្ចជាប្រមុខរដ្ឋជំនួសព្រះមហាក្សត្រ ក្នុងឋានៈជាព្រះរាជានុសិទ្ធិ ពេលព្រះអង្គទ្រង់ប្រឈួនជាទម្ងន់ ដូចមានចែងក្នុងវាក្យខ័ណ្ឌខាងលើ ប្រធានរដ្ឋសភាជាអ្នកបំពេញភារកិច្ចនេះ ។

តំណែងជាប្រមុខរដ្ឋជំនួសព្រះមហាក្សត្រ ក្នុងឋានៈជាព្រះរាជានុសិទ្ធិនេះ អាចនឹងដូរឥស្សរជនផ្សេងទៀត ក្នុងករណីដូចដែលបានចែងក្នុងវាក្យខ័ណ្ឌខាងលើ តាមឋានានុក្រមដូចតទៅ :

**ក**-អនុប្រធានទី១ ព្រឹទ្ធសភា

**ខ**-អនុប្រធានទី១ រដ្ឋសភា

**គ**-អនុប្រធានទី២ ព្រឹទ្ធសភា

**ឃ**-អនុប្រធានទី២ រដ្ឋសភា

**មាត្រា ១២ .‒ ថ្មី**

នៅពេលព្រះមហាក្សត្រទ្រង់ចូលទីវង្គត ប្រធានព្រឹទ្ធសភាទទួលភារកិច្ចជាប្រមុខរដ្ឋស្តីទី ក្នុងឋានៈជាព្រះរាជានុសិទ្ធិនៃព្រះរាជាណាចក្រកម្ពុជា ។

ក្នុងករណីដែលប្រធានព្រឹទ្ធសភា ពុំមានលទ្ធភាពបំពេញភារកិច្ចជាប្រមុខរដ្ឋស្តីទីជំនួសព្រះមហាក្សត្រ ក្នុងពេលព្រះអង្គចូលទីវង្គត ការទទួលភារកិច្ចជាប្រមុខរដ្ឋស្តីទី ក្នុងឋានៈជាព្រះរាជានុសិទ្ធិ ត្រូវអនុវត្តតាមវាក្យខ័ណ្ឌទី២ និង ទី៣ នៃមាត្រា ១១ ថ្មី ។

**មាត្រា ១៣ .‒ ថ្មី**

ក្នុងរយៈវេលា ៧ ថ្ងៃយ៉ាងយូរ ព្រះមហាក្សត្រថ្មីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានជ្រើសរើសដោយក្រុមប្រឹក្សារាជសម្បត្តិ ។

សមាសភាពនៃក្រុមប្រឹក្សារាជសម្បត្តិមាន :

- ប្រធានព្រឹទ្ធសភា
- ប្រធានរដ្ឋសភា
- នាយករដ្ឋមន្ត្រី
- សម្តេចព្រះសង្ឃរាជ គណៈមហានិកាយ និង គណៈធម្មយុត្តិកនិកាយ
- អនុប្រធានទី១ និង អនុប្រធានទី២ ព្រឹទ្ធសភា
- អនុប្រធានទី១ និង អនុប្រធានទី២ រដ្ឋសភា

ការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សារាជសម្បត្តិនឹងមានកំណត់ក្នុងច្បាប់មួយ ។

**មាត្រា ១៤ .-**

ត្រូវបានជ្រើសរើសជាព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា សមាជិកនៃព្រះរាជវង្សានុវង្សខ្មែរ ដែលមានព្រះជន្មាយុយ៉ាងតិច ៣០ ព្រះវស្សា ហើយដែលជាព្រះរាជបច្ឆាញាតិនៃព្រះមហាក្សត្រ **អង្គឌួង** ឬព្រះមហាក្សត្រ **នរោត្តម** ឬក៏ព្រះមហាក្សត្រ **ស៊ីសុវត្ថិ** ។

មុនចូលគ្រងរាជសម្បត្តិ ព្រះមហាក្សត្រទ្រង់ថ្លែងសច្ចាប្រណិធាន ដូចមានចែងក្នុងឧបសម្ព័ន្ធទី៤ ។

**មាត្រា ១៥ .-**

ព្រះជាយានៃព្រះមហាក្សត្រ មានព្រះរាជឋានៈជាព្រះមហេសីនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ១៦ .-**

ព្រះមហេសីនៃព្រះរាជាណាចក្រកម្ពុជា ពុំមានព្រះរាជសិទ្ធិធ្វើនយោបាយ ទទួលតួនាទីជាអ្នកដឹកនាំរដ្ឋ ឬជាអ្នកដឹកនាំរាជរដ្ឋាភិបាល ឬទទួលតួនាទីរដ្ឋបាល ឬនយោបាយឡើយ ។

ព្រះមហេសីនៃព្រះរាជាណាចក្រកម្ពុជា ទុកព្រះរាជកាយពលបំពេញព្រះរាជភារៈបម្រើប្រយោជន៍សង្គម មនុស្សធម៌ សាសនា និង ជួយព្រះមហាក្សត្រក្នុងព្រះរាជកាតព្វកិច្ចផ្នែកពិធីការ និង ការទូត ។

**មាត្រា ១៧ .-**

ប្រការដែលព្រះមហាក្សត្រទ្រង់គ្រងរាជសម្បត្តិ ប៉ុន្តែទ្រង់មិនកាន់អំណាចឡើយ ហើយដែលមានចែងក្នុងវាក្យខ័ណ្ឌទី ១ នៃមាត្រា ៧ នៃរដ្ឋធម្មនុញ្ញនេះ មិនអាចសុំកែប្រែបានជាដាច់ខាត ។

**មាត្រា ១៨ ._ ថ្មី**

ព្រះមហាក្សត្រ ព្រះអង្គទ្រង់ទាក់ទងជាមួយព្រឹទ្ធសភានិងរដ្ឋសភាដោយព្រះរាជសារ ។

ព្រះរាជសារនេះ ព្រឹទ្ធសភានិងរដ្ឋសភា មិនអាចយកទៅជជែកពិភាក្សាឡើយ ។

**មាត្រា ១៩ ._ ថ្មី**

ព្រះមហាក្សត្រ ទ្រង់តែងតាំងនាយករដ្ឋមន្ត្រី និង ទ្រង់តែងតាំងគណៈរដ្ឋមន្ត្រី តាមបែបបទដែលមានចែងក្នុងមាត្រា ១១៩ ថ្មី ។

**មាត្រា ២០ ._**

ព្រះមហាក្សត្រ ទ្រង់ទទួលសវនាការជាផ្លូវការពីរដងក្នុងមួយខែ ឱ្យនាយករដ្ឋមន្ត្រី និងគណៈរដ្ឋមន្ត្រីចូលគាល់រាយការណ៍ទូលថ្វាយទ្រង់ជ្រាបអំពីសភាពការណ៍នៃប្រទេសជាតិ ។

**មាត្រា ២១ ._**

តាមសេចក្តីស្នើរបស់គណៈរដ្ឋមន្ត្រី ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាលើព្រះរាជក្រឹត្យតែងតាំង ផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីជាន់ខ្ពស់ស៊ីវិល និង យោធា ឯកអគ្គរាជទូត និង ប្រេសិតវិសាមញ្ញ និង ពេញសមត្ថភាព ។

តាមសេចក្តីស្នើរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាលើព្រះរាជក្រឹត្យតែងតាំង ផ្លាស់ប្តូរ ឬដកចៅក្រមផ្នែកយុត្តាធិការ ។

**មាត្រា ២២ ._ ថ្មី**

នៅពេលប្រជាជាតិប្រឈមមុខនឹងគ្រោះថ្នាក់ ព្រះមហាក្សត្រទ្រង់ប្រកាសប្រទានដំណឹងជាសាធារណៈ ដាក់ប្រទេសជាតិឋិតនៅក្នុងភាពអាសន្ន ក្រោយពីបានមតិឯកភាពពីនាយករដ្ឋមន្ត្រី ប្រធានរដ្ឋសភា និង ប្រធានព្រឹទ្ធសភា ។

**មាត្រា ២៣ .–**

ព្រះមហាក្សត្រ ទ្រង់ជាមេបញ្ជាការកំពូលនៃកងយោធពលខេមរភូមិន្ទ។ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ ត្រូវបានតែងតាំងឡើងដើម្បីបញ្ជាកងយោធពលខេមរភូមិន្ទនេះ។

**មាត្រា ២៤ .– ថ្មី**

ព្រះមហាក្សត្រ ទ្រង់គង់ជាព្រះអធិបតីនៃឧត្តមក្រុមប្រឹក្សាការពារជាតិ ដែលនឹងត្រូវបង្កើតឡើងដោយច្បាប់មួយ ។

ព្រះមហាក្សត្រ ទ្រង់ប្រកាសសង្គ្រាមក្រោយការអនុម័តរបស់រដ្ឋសភា និង ព្រឹទ្ធសភា។

**មាត្រា ២៥ .–**

ព្រះមហាក្សត្រ ទ្រង់ទទួលសារតាំងឯកអគ្គរដ្ឋទូត ឬប្រេសិតវិសាមញ្ញ និង ពេញសមត្ថភាពនៃប្រទេសក្រៅមកប្រចាំព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២៦ .– ថ្មី**

ព្រះមហាក្សត្រ ទ្រង់ឡាយព្រះហស្តលេខាលើសន្ធិសញ្ញា និង អនុសញ្ញាអន្តរជាតិ ហើយទ្រង់ប្រទានសច្ចាប័នលើសន្ធិសញ្ញា និង អនុសញ្ញាទាំងនេះ ក្រោយបានទទួលការអនុម័តយល់ព្រមពីរដ្ឋសភា និង ព្រឹទ្ធសភា ។

**មាត្រា ២៧ .–**

ព្រះមហាក្សត្រ ទ្រង់មានព្រះរាជសិទ្ធិបន្ធូរបន្ថយទោស និង លើកលែងទោស ។

### មាត្រា ២៨ .- ថ្មី

ព្រះមហាក្សត្រ ទ្រង់ឡាយព្រះហស្ថលេខាលើព្រះរាជក្រមប្រកាសឱ្យប្រើរដ្ឋធម្មនុញ្ញ ច្បាប់ដែលរដ្ឋសភាបានអនុម័ត និង ព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់រួចហើយ និង ទ្រង់ឡាយព្រះហស្ថលេខាលើព្រះរាជក្រឹត្យ តាមសេចក្តីស្នើសុំពីគណៈរដ្ឋមន្ត្រី ។

ក្នុងពេលដែលព្រះមហាក្សត្រប្រឈួន ហើយត្រូវព្យាបាលព្រះរោគនៅបរទេស ក្នុងពេលនោះ ព្រះមហាក្សត្រមានសិទ្ធិផ្ទេរអំណាចឡាយព្រះហស្ថលេខានៅលើព្រះរាជក្រម ឬ ព្រះរាជក្រឹត្យខាងលើនេះ ទៅប្រមុខរដ្ឋស្តីទីចុះហត្ថលេខាជំនួសដោយព្រះរាជសារប្រគល់សិទ្ធិ។

### មាត្រា ២៩ .- ថ្មី

ព្រះមហាក្សត្រ ទ្រង់បង្កើត និង ប្រទានគ្រឿងឥស្សរិយយសជាតិ ។

ព្រះមហាក្សត្រ ទ្រង់សម្រេចប្រទានឋានន្តរសក្តិ ឋានៈ យោធា និង ស៊ីវិល តាមច្បាប់កំណត់ ។

### មាត្រា ៣០ .- ថ្មី

ក្នុងរយៈពេលព្រះមហាក្សត្រទ្រង់អវត្តមាន ប្រធានព្រឹទ្ធសភាទទួលភារកិច្ចជាប្រមុខរដ្ឋស្តីទី ។

ក្នុងករណីដែលប្រធានព្រឹទ្ធសភា ពុំមានលទ្ធភាពបំពេញភារកិច្ចជាប្រមុខរដ្ឋស្តីទីជំនួសព្រះមហាក្សត្រ ពេលព្រះអង្គទ្រង់អវត្តមាន ការទទួលភារកិច្ចជាប្រមុខរដ្ឋស្តីទី ត្រូវអនុវត្តតាមវាក្យខ័ណ្ឌទី២ និង ទី៣ នៃមាត្រា ១១ ថ្មី ។

# ជំពូកទី ៣
# អំពីសិទ្ធិ និង ករណីយកិច្ចរបស់ប្រជាពលរដ្ឋខ្មែរ

**មាត្រា ៣១ .-**

ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និង គោរពសិទ្ធិមនុស្សដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស និង កតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និង សិទ្ធិកុមារ ។

ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និង ករណីយកិច្ចដូចគ្នាទាំងអស់ ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬ ស្ថានភាពឯទៀតឡើយ ។ ការប្រើសិទ្ធិសេរីភាពផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗ មិនត្រូវឱ្យប៉ះពាល់ដល់សិទ្ធិ សេរីភាពអ្នកដទៃឡើយ ។ ការប្រើសិទ្ធិ សេរីភាពនេះ ត្រូវប្រព្រឹត្តតាមល័ក្ខខ័ណ្ឌកំណត់ក្នុងច្បាប់ ។

**មាត្រា ៣២ .-**

ជនគ្រប់រូប មានសិទ្ធិរស់រានមានជីវិត មានសេរីភាពនិងមានសន្តិសុខផ្ទាល់ខ្លួន ។

ទោសប្រហារជីវិតមិនត្រូវឱ្យមានឡើយ ។

**មាត្រា ៣៣ .-**

ប្រជាពលរដ្ឋខ្មែរ មិនអាចត្រូវបានដកសញ្ជាតិ និរទេស ឬចាប់បញ្ជូនខ្លួនទៅឱ្យប្រទេសក្រៅណាមួយឡើយ លើកលែងតែមានកិច្ចព្រមព្រៀងជាមួយគ្នាទៅវិញទៅមក ។

ប្រជាពលរដ្ឋខ្មែរដែលកំពុងរស់នៅឯបរទេសត្រូវបានរដ្ឋគាំពារ ។

ការទទួលសញ្ជាតិខ្មែរត្រូវកំណត់ក្នុងច្បាប់ ។

**មាត្រា ៣៤ .- ថ្មី**

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិបោះឆ្នោត និងអាចឈរឈ្មោះឱ្យគេបោះឆ្នោត ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុយ៉ាងតិច ១៨ ឆ្នាំ មានសិទ្ធិបោះឆ្នោត ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុយ៉ាងតិច ២៥ឆ្នាំ អាចឈរឈ្មោះឱ្យគេបោះឆ្នោតជ្រើសតាំងជាតំណាងរាស្ត្រ ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុយ៉ាងតិច ៤០ឆ្នាំ អាចឈរឈ្មោះឱ្យគេបោះឆ្នោតជ្រើសតាំងជាសមាជិកព្រឹទ្ធសភា ។

បទប្បញ្ញត្តិបន្ថយសិទ្ធិបោះឆ្នោត និង សិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោតត្រូវចែងក្នុងច្បាប់បោះឆ្នោត ។

**មាត្រា ៣៥ .-**

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌របស់ប្រទេសជាតិ ។

សេចក្តីស្នើទាំងឡាយរបស់ប្រជាពលរដ្ឋ ត្រូវបានទទួលការពិនិត្យ និង ដោះស្រាយយ៉ាងហ្មត់ចត់ពីអង្គការរដ្ឋ ។

**មាត្រា ៣៦ .-**

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិជ្រើសរើសមុខរបរសមស្របតាមសមត្ថភាព

របស់ខ្លួន តាមសេចក្តីត្រូវការរបស់សង្គម ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិទទួលប្រាក់បំណាច់ស្មើគ្នាចំពោះការងារដូចគ្នា។

ការងារមេផ្ទះមានតម្លៃស្មើគ្នានឹងកម្រៃដែលបានមកពីការងារធ្វើនៅក្រៅផ្ទះ ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិទទួលការធានារ៉ាប់រងសង្គម និងអត្ថប្រយោជន៍ខាងសង្គមកិច្ចដែលមានចែងក្នុងច្បាប់ ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិបង្កើតសហជីព និងចូលជាសមាជិកសហជីពនេះ។

ការរៀបចំ និង ការប្រព្រឹត្តទៅនៃសហជីពនឹងមានកំណត់ក្នុងច្បាប់ ។

**មាត្រា ៣៧ .-**

សិទ្ធិធ្វើកូដកម្ម និង ធ្វើបាតុកម្មដោយសន្តិវិធី ត្រូវយកមកអនុវត្តនៅក្នុងក្របខ័ណ្ឌនៃច្បាប់ ។

**មាត្រា ៣៨ .-**

ច្បាប់រ៉ាប់រងមិនឱ្យមានការរំលោភបំពានលើរូបរាងកាយបុគ្គលណាមួយឡើយ ។

ច្បាប់ការពារជីវិត កិត្តិយស និង សេចក្តីថ្លៃថ្នូររបស់ប្រជាពលរដ្ឋ ។

ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនជនណាមួយនឹងអាចធ្វើទៅកើត លុះត្រាតែអនុវត្តត្រឹមត្រូវតាមបញ្ញត្តិច្បាប់ ។

ការបង្ខិតបង្ខំ ការធ្វើបាបលើរូបរាងកាយ ឬប្រព្រឹត្តិកម្មណាមួយដែលបន្ថែមទម្ងន់ទណ្ឌកម្ម អនុវត្តចំពោះជនជាប់ឃុំឃាំង ឬជាប់ពន្ធនាគារ ត្រូវហាមឃាត់មិនឱ្យធ្វើឡើយ ។ អ្នកដែដល់ អ្នករួមប្រព្រឹត្ត និង អ្នកសមគំនិត ត្រូវទទួលទោសតាមច្បាប់ ។

ការទទួលសារភាពដែលកើតឡើងពីការបង្ខិតបង្ខំតាមផ្លូវកាយក្តី តាមផ្លូវចិត្តក្តី មិនត្រូវទុកជាភស្តុតាងនៃពិរុទ្ធភាពទេ ។

វិមតិសង្ស័យ ត្រូវបានជាប្រយោជន៏ដល់ជនជាប់ចោទ ។

ជនជាប់ចោទណាក៏ដោយ ត្រូវទុកជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ ។

ជនគ្រប់រូប មានសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ ។

**មាត្រា ៣៩ .-**

ប្រជាពលរដ្ឋខ្មែរមានសិទ្ធិប្តឹងបរិហារ ប្តឹងតវ៉ា ឬ ប្តឹងទារសំណងជួសជុលការខូចខាតដែលបណ្តាលមកពីអំពើខុសច្បាប់របស់អង្គការរដ្ឋ របស់អង្គការសង្គម និង របស់បុគ្គលិកនៃអង្គការទាំងនោះ ។ ការដោះស្រាយបណ្តឹងតវ៉ា និង សំណងជួសជុលការខូចខាតជាសមត្ថកិច្ចរបស់តុលាការ ។

**មាត្រា ៤០ .-**

សេរីភាពក្នុងការដើរឆ្ងាយជិត និង តាំងទីលំនៅក្នុងស្ថានភាពស្របច្បាប់របស់ប្រជាពលរដ្ឋ ត្រូវបានគោរព ។

ប្រជាពលរដ្ឋខ្មែរអាចចេញទៅតាំងទីលំនៅ នៅប្រទេសក្រៅ ឬវិលត្រឡប់មកវិញបាន ។

ការរក្សាសិទ្ធិមិនឱ្យរំលោភលើលំនៅឋាន និង អាថិកំបាំងនៃការឆ្លើយឆ្លងតាមលិខិត តាមសារទូរលេខ ទូរពុម្ព ទូរគមន៏ និង តាមទូរស័ព្ទ ត្រូវបានធានា ។

ការឆែកឆេរលំនៅឋាន សម្ភារៈវត្ថុ និង សើរូបបុគ្គល ត្រូវធ្វើឱ្យស្របនឹងបញ្ញត្តិច្បាប់ ។

**មាត្រា ៤១ .-**

ប្រជាពលរដ្ឋខ្មែរមានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ ។ ជនណាក៏ដោយ មិនអាចឆ្លៀតប្រើសិទ្ធិនេះដោយរំលោភ នាំឱ្យប៉ះពាល់ដល់កិត្តិយសរបស់អ្នកដទៃ ដល់ទំនៀមទម្លាប់ល្អរបស់សង្គម ដល់សណ្ដាប់ធ្នាប់សាធារណៈ និងដល់សន្តិសុខជាតិបានឡើយ ។

របបសារព័ត៌មាន ត្រូវរៀបចំឡើងដោយច្បាប់ ។

**មាត្រា ៤២ .-**

ប្រជាពលរដ្ឋខ្មែរមានសិទ្ធិបង្កើតសមាគម និង គណបក្សនយោបាយ ។ សិទ្ធិនេះត្រូវកំណត់ក្នុងច្បាប់ ។

ប្រជាពលរដ្ឋខ្មែរទាំងឡាយ អាចចូលរួមក្នុងអង្គការមហាជន ជួយគ្នាទៅវិញទៅមក ការពារសមិទ្ធផលជាតិ និង សណ្ដាប់ធ្នាប់សង្គម ។

**មាត្រា ៤៣ .-**

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិពេញទីខាងជំនឿ ។

សេរីភាពខាងជំនឿ និង ការប្រតិបត្តិខាងផ្លូវសាសនា ត្រូវបានរដ្ឋធានាក្នុងល័ក្ខខ័ណ្ឌដែលមិនប៉ះពាល់ដល់ជំនឿ ឬសាសនាដទៃទៀត ដល់សណ្ដាប់ធ្នាប់ និង សន្តិសុខសាធារណៈ ។

ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ ។

**មាត្រា ៤៤ .-**

ជនណាក៏ដោយ ទោះជាបុគ្គលក្តី ជាសមូហភាពក្តី មានសិទ្ធិជាម្ចាស់កម្មសិទ្ធិ ។ មានតែ

រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលមានសញ្ជាតិជាខ្មែរទេ ទើបមានសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីធ្លី ។

កម្មសិទ្ធិឯកជនស្របច្បាប់ ឋិតនៅក្រោមការគាំពារនៃច្បាប់ ។

ដែលនឹងដកហូតកម្មសិទ្ធិអំពីជនណាមួយបាននោះ លុះត្រាតែប្រយោជន៍សាធារណៈតម្រូវឱ្យធ្វើ ក្នុងករណីដែលច្បាប់បានបញ្ញត្តិទុក ហើយត្រូវផ្តល់សំណងជាមុន ដោយសមរម្យ និងយុត្តិធម៌ ។

**មាត្រា ៤៥ .-**

ការរើសអើងគ្រប់ប្រភេទ ប្រឆាំងនឹងស្ត្រីភេទ ត្រូវបំបាត់ចោល ។

ការធ្វើអាជីវកម្មលើការងាររបស់ស្ត្រី ត្រូវហាមឃាត់ ។

បុរសនិងស្ត្រីមានសិទ្ធិស្មើគ្នាក្នុងគ្រប់វិស័យទាំងអស់ ជាពិសេសក្នុងអាពាហ៍ពិពាហ៍ និងគ្រួសារ ។

អាពាហ៍ពិពាហ៍ ត្រូវធ្វើតាមលក្ខខ័ណ្ឌដែលមានចែងក្នុងច្បាប់ និងតាមគោលការណ៍ស្ម័គ្រចិត្ត ប្តីមួយ ប្រពន្ធមួយ ។

**មាត្រា ៤៦ .-**

អំពើលក់ដូរមនុស្ស អំពើធ្វើអាជីវកម្មផ្នែកពេស្យាកម្ម និង អំពើអាសអាភាស ដែលប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់នារី ត្រូវហាមឃាត់ ។

ត្រូវហាមឃាត់មិនឱ្យមានការបញ្ឈប់នារីពីការងារ ដោយមូលហេតុមានគភ៌ ។ នារីមានសិទ្ធិឈប់សំរាកនៅពេលសំរាលកូនដោយទទួលប្រាក់បៀវត្ស និងដោយមានការធានារក្សាសិទ្ធិអតីតភាពក្នុងការងារ និងអត្ថប្រយោជន៍សង្គមផ្សេងៗទៀត ។

រដ្ឋ និង សង្គមយកចិត្តទុកដាក់បង្កលក្ខណៈឱ្យនារី ជាពិសេសនារីនៅជនបទដែលគ្មានទីពឹងបានទទួលការឧបត្ថម្ភដើម្បីមានមុខរបរ មានលទ្ធភាពព្យាបាលជំងឺ ឱ្យកូនទៅរៀន និងមានជីវភាពរស់នៅសមរម្យ ។

**មាត្រា ៤៧ .-**

មាតាបិតាមានកាតព្វកិច្ចចិញ្ចឹមថែរក្សា និង អប់រំកូនឱ្យទៅជាពលរដ្ឋល្អ ។

កូនមានករណីយកិច្ចចិញ្ចឹម និង បីបាច់ថែរក្សាមាតាបិតាដែលចាស់ជរា តាមទំនៀមទម្លាប់ខ្មែរ ។

**មាត្រា ៤៨ .-**

រដ្ឋធានារក្សាការពារសិទ្ធិរបស់កុមារ ដែលមានចែងក្នុងអនុសញ្ញាស្តីពីកុមារ ជាពិសេស សិទ្ធិមានជីវិតរស់នៅ សិទ្ធិទទួលការអប់រំរៀនសូត្រ សិទ្ធិត្រូវបានទទួលការគាំពារក្នុងស្ថានការណ៍មានសង្គ្រាម និង ការការពារប្រឆាំងនឹងអាជីវកម្ម សេដ្ឋកិច្ច ឬកាមគុណលើកុមារ ។

រដ្ឋគាំពារប្រឆាំងនឹងការងារទាំងឡាយ ដែលអាចធ្វើឱ្យខូចដល់ការអប់រំ និង ការរៀនសូត្ររបស់កុមារ ឬដែលនាំឱ្យអន្តរាយដល់សុខភាព ឬសុខុមាលភាពរបស់កុមារ ។

**មាត្រា ៤៩ .-**

ប្រជាពលរដ្ឋខ្មែរគ្រប់រូបត្រូវគោរពរដ្ឋធម្មនុញ្ញ និង គោរពច្បាប់ ។

ប្រជាពលរដ្ឋខ្មែរគ្រប់រូបមានកាតព្វកិច្ចរួមចំណែកកសាងប្រទេសជាតិ និងការពារមាតុភូមិ ។

កាតព្វកិច្ចការពារមាតុភូមិត្រូវអនុវត្តតាមបញ្ញត្តិច្បាប់ ។

**មាត្រា ៥០ .-**

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទត្រូវគោរពគោលការណ៍អធិបតេយ្យជាតិ និង លទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទត្រូវគោរពទ្រព្យសម្បត្តិសាធារណៈ និង កម្មសិទ្ធិស្របច្បាប់របស់ឯកជន ។

## ជំពូកទី ៤

## អំពីរបបនយោបាយ

**មាត្រា ៥១ .- ថ្មី**

ព្រះរាជាណាចក្រកម្ពុជា អនុវត្តនយោបាយប្រជាធិបតេយ្យ សេរីពហុបក្ស ។

ប្រជាពលរដ្ឋខ្មែរជាម្ចាស់វាសនានៃប្រទេសជាតិរបស់ខ្លួន ។

អំណាចទាំងអស់ជារបស់ប្រជាពលរដ្ឋ ។ ប្រជាពលរដ្ឋប្រើអំណាចរបស់ខ្លួន តាមរយៈរដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាល និង សាលាជម្រះក្តី ។

អំណាចបែងចែកដាច់ពីគ្នា រវាងអំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និង អំណាចតុលាការ ។

**មាត្រា ៥២ .-**

រាជរដ្ឋាភិបាលកម្ពុជា ប្តេជ្ញារក្សាការពារឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដី នៃព្រះរាជាណាចក្រកម្ពុជា អនុវត្តនយោបាយបង្រួបបង្រួមជាតិ ដើម្បីការពារឯកភាពជាតិ រក្សា

ការពារទំនៀមទម្លាប់ និង ប្រពៃណីល្អរបស់ជាតិ ។ រាជរដ្ឋាភិបាលកម្ពុជា ត្រូវការពារនីត្យានុកូលភាព ធានាសណ្តាប់ធ្នាប់ និង សន្តិសុខសាធារណៈ ។ រដ្ឋយកចិត្តទុកដាក់ជាអាទិភាព ចំពោះជីវភាពរស់នៅ និង សុខុមាលភាពរបស់ប្រជាពលរដ្ឋ ។

**មាត្រា ៥៣ .-**

ព្រះរាជាណាចក្រកម្ពុជា ប្រកាន់ខ្ជាប់ជានិច្ចនូវនយោបាយអព្យាក្រឹតអចិន្ត្រៃយ៍ និងមិនចូលបក្សសម្ព័ន្ធ ។ ព្រះរាជាណាចក្រកម្ពុជា រួមរស់ដោយសន្តិសហវិជ្ជមានជាមួយប្រទេសជិតខាង និង ប្រទេសដទៃទៀតទាំងអស់នៅលើសកលលោក ។

ព្រះរាជាណាចក្រកម្ពុជា មិនឈ្លានពានប្រទេសណាដាច់ខាត មិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងនៃប្រទេសដទៃដោយផ្ទាល់ ឬដោយប្រយោល ទោះបីក្រោមរូបភាពណាក៏ដោយ ដោះស្រាយរាល់បញ្ហាដោយសន្តិវិធី និង គោរពផលប្រយោជន៍ផងគ្នាទៅវិញទៅមក ។

ព្រះរាជាណាចក្រកម្ពុជា មិនចងសម្ព័ន្ធយោធា ឬចូលក្នុងកិច្ចព្រមព្រៀងយោធាណាមួយ ដែលមិនស្របនឹងអព្យាក្រឹតភាពរបស់ខ្លួនឡើយ ។

ព្រះរាជាណាចក្រកម្ពុជា មិនអនុញ្ញាតឱ្យមានមូលដ្ឋានយោធាបរទេសនៅលើទឹកដីរបស់ខ្លួន ហើយក៏មិនអនុញ្ញាតឱ្យមានមូលដ្ឋានយោធារបស់ខ្លួននៅបរទេសដែរ លើកលែងតែក្នុងក្របខ័ណ្ឌនៃសំណូមពររបស់អង្គការសហប្រជាជាតិ ។

ព្រះរាជាណាចក្រកម្ពុជា រក្សាសិទ្ធិទទួលយកជំនួយបរទេសជាសម្ភារៈ យោធា អាវុធ គ្រាប់រំសេវ ការហ្វឹកហ្វឺនកងកម្លាំងប្រដាប់អាវុធ និង ជំនួយផ្សេងៗទៀត ដើម្បីការពារខ្លួន និងធានាសណ្តាប់ធ្នាប់ និងសន្តិសុខសាធារណៈនៅផ្ទៃក្នុងប្រទេស ។

**មាត្រា ៥៤ .-**

ការផលិត ការប្រើប្រាស់ ការរក្សាទុកអាវុធបរមាណូ អាវុធគីមី ឬអាវុធវេជ្ជាណូ ត្រូវហាមឃាត់ដាច់ខាត ។

**មាត្រា ៥៥ .-**

សន្ធិសញ្ញា និង កិច្ចព្រមព្រៀងទាំងឡាយណា ដែលមិនស្របនឹងឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដី អព្យាក្រឹតភាព និង ឯកភាពជាតិរបស់ព្រះរាជាណាចក្រកម្ពុជា ត្រូវលុបចោល ។

## ជំពូកទី ៥

## អំពីសេដ្ឋកិច្ច

**មាត្រា ៥៦ .-**

ព្រះរាជាណាចក្រកម្ពុជា អនុវត្តប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ ។

ការរៀបចំ និង ការប្រព្រឹត្តទៅនៃប្រព័ន្ធសេដ្ឋកិច្ចនេះ នឹងមានកំណត់ក្នុងច្បាប់ ។

**មាត្រា ៥៧ .-**

ការយកពន្ធដារនឹងអាចធ្វើទៅបាន លុះត្រាតែមានច្បាប់អនុញ្ញាត ។ ថវិកាជាតិត្រូវបានកំណត់ឱ្យអនុវត្តតាមច្បាប់ ។

របបគ្រប់គ្រងរូបិយវត្ថុ និង ប្រព័ន្ធហិរញ្ញវត្ថុត្រូវកំណត់ក្នុងច្បាប់ ។

**មាត្រា ៥៨ .-**

ទ្រព្យសម្បត្តិរបស់រដ្ឋមានជាអាទិ៍ ដីធ្លី ក្រោមដី ភ្នំ សមុទ្រ បាតសមុទ្រ ក្រោមបាតសមុទ្រ ឆ្នេរសមុទ្រ អាកាស កោះ ទន្លេ ព្រែក ស្ទឹង បឹង ព្រៃឈើ ធនធានធម្មជាតិ មជ្ឈមណ្ឌលសេដ្ឋកិច្ច វប្បធម៌ មូលដ្ឋានការពារប្រទេស សំណង់ផ្សេងៗទៀត ដែលបានកំណត់ថាជារបស់រដ្ឋ ។

ការគ្រប់គ្រង ការប្រើប្រាស់ និង ការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ នឹងត្រូវកំណត់ក្នុងច្បាប់ ។

**មាត្រា ៥៩ .-**

រដ្ឋត្រូវរក្សាការពារបរិស្ថាន និង តុល្យភាព នៃភោគទ្រព្យធម្មជាតិ ហើយត្រូវចាត់ចែងឱ្យមានផែនការច្បាស់លាស់ ក្នុងការគ្រប់គ្រង មានជាអាទិ៍ ដីធ្លី ទឹក អាកាស ខ្យល់ ភោគោត្តសាស្ត្រ ប្រព័ន្ធអេកូឡូស៊ី រ៉ែ ថាមពល ប្រេងកាត និង ឧស្ម័ន ថ្ម និង ខ្សាច់ ត្បូងថ្ម ព្រៃឈើ និង អនុផលព្រៃឈើ ពពួកសត្វព្រៃ មច្ឆជាតិ ធនធានជលផល ។

**មាត្រា ៦០ .-**

ពលរដ្ឋមានសិទ្ធិលក់ដូរផលិតផលរបស់ខ្លួនដោយសេរី ។ ការតម្រូវឱ្យលក់ផលិតផលជូនរដ្ឋ ឬការយកភោគផល ឬទ្រព្យសម្បត្តិឯកជនទៅប្រើប្រាស់ ទោះបីមួយរយៈពេលក៏ដោយត្រូវហាមឃាត់ វៀរលែងតែក្នុងករណីពិសេស ដែលមានច្បាប់អនុញ្ញាត ។

**មាត្រា ៦១ .–**

រដ្ឋជំរុញការអភិវឌ្ឍសេដ្ឋកិច្ចគ្រប់វិស័យ ជាពិសេសវិស័យកសិកម្ម សិប្បកម្ម ឧស្សាហកម្ម ចាប់ពីតំបន់ដាច់ស្រយាលដោយយកចិត្តទុកដាក់ទៅលើនយោបាយទឹក ភ្លើង ផ្លូវ និងមធ្យោបាយដឹកជញ្ជូន បច្ចេកទេសទំនើប និង ប្រព័ន្ធឥណទាន ។

**មាត្រា ៦២ .–**

រដ្ឋយកចិត្តទុកដាក់ជួយដោះស្រាយមធ្យោបាយផលិត ការពារថ្លៃផលិតផលជូនកសិករ សិប្បករ និងជួយរកទីផ្សារលក់ផលិតផល ។

**មាត្រា ៦៣ .–**

រដ្ឋយកចិត្តទុកដាក់គ្រប់គ្រងទីផ្សារ ជួយឱ្យជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ មានកម្រិតសមរម្យ ។

**មាត្រា ៦៤ .–**

រដ្ឋហាមឃាត់ និង ផ្តន្ទាទោសជាទម្ងន់ដល់ជនណាដែលនាំចូល ផលិត លក់ដូរគ្រឿងញៀន ទំនិញក្លែងក្លាយ ហួសរយៈពេលប្រើ ដែលប៉ះពាល់ដល់សុខភាព អាយុជីវិតរបស់អ្នកប្រើ ។

# ជំពូកទី ៦
## អំពីអប់រំ វប្បធម៌ និង សង្គមកិច្ច

**មាត្រា ៦៥ .-**

រដ្ឋត្រូវការពារ និង លើកស្ទួយសិទ្ធិរបស់ប្រជាពលរដ្ឋ ក្នុងការទទួលការអប់រំ ប្រកបដោយគុណភាពនៅគ្រប់កម្រិត និង ត្រូវចាត់វិធានការគ្រប់បែបយ៉ាងជាជំហានៗ ដើម្បីឱ្យការអប់រំនេះ បានទៅដល់ប្រជាពលរដ្ឋគ្រប់រូប ។

រដ្ឋយកចិត្តទុកដាក់ដល់វិស័យអប់រំកាយ និង កីឡា ដែលជាសុខុមាលភាពរបស់ប្រជាពលរដ្ឋខ្មែរគ្រប់រូប ។

**មាត្រា ៦៦ .-**

រដ្ឋកសាងប្រព័ន្ធអប់រំមួយពេញលេញ និង ឯកភាពនៅទូទាំងប្រទេស ដែលធានាឱ្យបាននូវគោលការណ៍សេរីភាពខាងសិក្សាធិការ និង គោលការណ៍សមភាពក្នុងការអប់រំ ដើម្បីឱ្យប្រជាពលរដ្ឋគ្រប់រូបមានភ័ព្វសំណាងគ្រប់គ្រាន់ស្មើគ្នាក្នុងការកសាងជីវិត ។

**មាត្រា ៦៧ .-**

រដ្ឋអនុវត្តកម្មវិធីសិក្សា និង គោលការណ៍គរុកោសល្យទំនើប រាប់បញ្ចូលទាំងបច្ចេកវិទ្យា និងភាសាបរទេស ។

រដ្ឋគ្រប់គ្រងគ្រឹះស្ថានសិក្សា និង ថ្នាក់សិក្សាសាធារណៈ និង ឯកជននៅគ្រប់ភូមិសិក្សា ។

**មាត្រា ៦៨ .-**

រដ្ឋផ្តល់កិច្ចការអប់រំផ្នែកបឋម និង មធ្យមសិក្សា នៅសាលារៀនសាធារណៈ សម្រាប់ប្រជាពលរដ្ឋគ្រប់រូបដោយឥតបង់ថ្លៃ ។

ប្រជាពលរដ្ឋ ត្រូវបានទទួលការអប់រំយ៉ាងតិចប្រាំបួនឆ្នាំ ។

រដ្ឋជួយផ្សព្វផ្សាយ និង លើកតម្កើងសាលាបាលី និង ពុទ្ធិកសិក្សា ។

**មាត្រា ៦៩ .-**

រដ្ឋមានកាតព្វកិច្ចថែរក្សា និង ពង្រីកវប្បធម៌ជាតិ ។

រដ្ឋមានកាតព្វកិច្ចការពារ និង ពង្រីកភាសាខ្មែរឱ្យសមស្របនឹងសេចក្តីត្រូវការ ។

រដ្ឋមានកាតព្វកិច្ចថែរក្សា និង ការពារប្រាសាទបុរាណ វត្ថុសិល្បៈបុរាណ និង កែលំអរមណីយដ្ឋានប្រវត្តិសាស្ត្រឡើងវិញ ។

**មាត្រា ៧០ .-**

បទល្មើសទាំងឡាយ ដែលប៉ះពាល់ ឬទាក់ទងនឹងបេតិកភណ្ឌវប្បធម៌ និង បេតិកភណ្ឌសិល្បៈ ត្រូវផ្តន្ទាទោសជាទម្ងន់ ។

**មាត្រា ៧១ .-**

បរិវេណបេតិកភណ្ឌជាតិ  ក៏ដូចជាបេតិកភណ្ឌដែលបានបញ្ចូលជាបេតិកភណ្ឌពិភពលោក ត្រូវទុកជាតំបន់អព្យាក្រឹត ដែលមិនឱ្យមានសកម្មភាពយោធា ។

**មាត្រា ៧២ ._**

សុខភាពរបស់ប្រជារាស្ត្រត្រូវបានធានា ។ រដ្ឋយកចិត្តទុកដាក់ដល់ការការពារជំងឺ និង ព្យាបាលជំងឺ ។ ប្រជារាស្ត្រក្រីក្រត្រូវបានទទួលការពិនិត្យរោគដោយឥតបង់ថ្លៃនៅតាមមន្ទីរពេទ្យ គិលានដ្ឋាន និង មន្ទីរសម្ភពសាធារណៈ ។

រដ្ឋរៀបចំឱ្យមានគិលានដ្ឋាន និង មន្ទីរសម្ភពដល់ជនបទ ។

**មាត្រា ៧៣ ._**

រដ្ឋយកចិត្តទុកដាក់ចំពោះកុមារ និង មាតា ។ រដ្ឋរៀបចំឱ្យមានទារកដ្ឋាន និង ជួយឧបត្ថម្ភនារីដែលមានកូនច្រើនក្នុងបន្ទុក ហើយឥតទីពឹង ។

**មាត្រា ៧៤ ._**

រដ្ឋជួយឧបត្ថម្ភជនពិការ និង ដល់គ្រួសារយុទ្ធជន ដែលបានបូជាជីវិតដើម្បីប្រទេសជាតិ ។

**មាត្រា ៧៥ ._**

រដ្ឋចាត់ចែងឱ្យមានរបបសន្តិសុខសង្គមដល់កម្មករ និង និយោជិត ។

## ជំពូកទី ៧
## អំពីរដ្ឋសភា

**មាត្រា ៧៦ ._**

រដ្ឋសភាមានសមាជិកជាតំណាងរាស្ត្រយ៉ាងតិច ១២០រូប ។

តំណាងរាស្ត្រ ត្រូវជ្រើសតាំងដោយការបោះឆ្នោតជាសកល ដោយសេរី ដោយស្មើភាព ដោយចំពោះ និង តាមវិធីជ្រើសរើសឆ្នោតជាសម្ងាត់ ។

តំណាងរាស្ត្រអាចឈរឈ្មោះបោះឆ្នោតសាជាថ្មីបាន ។

អ្នកដែលមានសិទ្ធិឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្រ គឺជាប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានសិទ្ធិបោះឆ្នោត មានអាយុយ៉ាងតិច ២៥ ឆ្នាំ មានសញ្ជាតិជាខ្មែរតាំងពីកំណើត ។

អង្គការរៀបចំការបោះឆ្នោត បែបបទ និង ការប្រព្រឹត្តទៅនៃការបោះឆ្នោតត្រូវកំណត់ក្នុងច្បាប់បោះឆ្នោត ។

**មាត្រា ៧៧ .-**

តំណាងរាស្ត្រក្នុងរដ្ឋសភា ជាតំណាងប្រជាជាតិខ្មែរទាំងមូល ពុំមែនគ្រាន់តែជាតំណាងប្រជាពលរដ្ឋក្នុងមណ្ឌលរបស់ខ្លួននោះទេ ។

អាណត្តិអាជ្ញាបញ្ជាទាំងឡាយ ត្រូវទុកជាមោឃៈ ។

**មាត្រា ៧៨ .-**

នីតិកាលរបស់រដ្ឋសភាមានកំណត់ ៥ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលដែលរដ្ឋសភាថ្មីចូលកាន់តំណែង ។ រដ្ឋសភាមិនអាចត្រូវបានរំលាយមុនផុតអាណត្តិបានឡើយ វៀរលែងតែក្នុងករណីដែលរាជរដ្ឋាភិបាល ត្រូវបានទម្លាក់ពីរដងក្នុងរយៈ ១២ ខែ ។

ក្នុងករណីនេះ ព្រះមហាក្សត្រត្រូវរំលាយរដ្ឋសភា ក្រោយពីព្រះអង្គទ្រង់បានទទួលការស្នើពីនាយករដ្ឋមន្ត្រី និង បន្ទាប់ពីទ្រង់បានការយល់ព្រមពីប្រធានរដ្ឋសភា ។

ការបោះឆ្នោតដើម្បីជ្រើសរើសរដ្ឋសភាថ្មី នឹងប្រព្រឹត្តទៅក្នុងរយៈពេល ៦០ ថ្ងៃយ៉ាងយូរ

ចាប់តាំងពីថ្ងៃរំលាយរដ្ឋសភាមក ។

ក្នុងរយៈកាលនេះ រាជរដ្ឋាភិបាលមានតែភារកិច្ចដឹកនាំការងារប្រចាំថ្ងៃតែប៉ុណ្ណោះ ។

ក្នុងពេលមានសង្គ្រាម ឬ ក្នុងកាលៈទេសៈពិសេសដទៃទៀត ដែលមិនអាចធ្វើការបោះឆ្នោតកើត រដ្ឋសភាអាចប្រកាសបន្តនីតិកាលរបស់ខ្លួនមួយដងបានមួយឆ្នាំ តាមសំណើរបស់ព្រះមហាក្សត្រ ។

ការប្រកាសបន្តនីតិកាលរបស់រដ្ឋសភា ត្រូវសម្រេចដោយមតិយល់ព្រមពីរភាគបីយ៉ាងតិចនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

**មាត្រា ៧៩ .-**

អាណត្តិនៃសមាជិករដ្ឋសភា មានវិសមិតភាពជាមួយការបំពេញមុខងារសាធារណៈជាសកម្ម និងជាមួយមុខងារជាសមាជិកនៃស្ថាប័នដទៃទៀតដែលមានចែងក្នុងរដ្ឋធម្មនុញ្ញនេះ វៀរលែងតែទៅបំពេញមុខងារក្នុងគណៈរដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាល ។

ក្នុងករណីនេះ សមាជិករដ្ឋសភារូបនោះមានឋានៈជាសមាជិករដ្ឋសភាធម្មតា ប៉ុន្តែមិនត្រូវមានមុខតំណែងអ្វីទាំងអស់ក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍ និងក្នុងគណៈកម្មការផ្សេងៗនៃរដ្ឋសភា ។

**មាត្រា ៨០ .-**

តំណាងរាស្ត្រមានអភ័យឯកសិទ្ធិសភា ។

តំណាងរាស្ត្ររូបណាក៏ដោយ មិនអាចត្រូវបានចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬឃុំខ្លួនដោយហេតុពីបានសំដែងយោបល់ ឬបញ្ចេញមតិក្នុងការបំពេញមុខងាររបស់ខ្លួនសោះឡើយ ។

ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនសមាជិកណាមួយនៃរដ្ឋសភា នឹងអាចធ្វើទៅកើត លុះត្រាតែមានការយល់ព្រមពីរដ្ឋសភា ឬពីគណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភា ក្នុងចន្លោះសម័យប្រជុំនៃរដ្ឋសភា វៀរលែងតែក្នុងករណីបទល្មើសព្រហ្មទណ្ឌជាក់ស្តែង ។ ក្នុងករណីខាងក្រោយនេះ ក្រសួងមានសមត្ថកិច្ចត្រូវធ្វើសេចក្តីរាយការណ៍ជូនរដ្ឋសភា ឬជូនគណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភាជាបន្ទាន់ដើម្បីសម្រេច ។

សេចក្តីសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភា ត្រូវដាក់ជូនសម័យប្រជុំរដ្ឋសភាខាងមុខ ដើម្បីអនុម័តតាមមតិភាគច្រើនពីរភាគបីនៃសមាជិករដ្ឋសភាទាំងមូល ។

ក្នុងករណីទាំងអស់ខាងលើនេះ ការឃុំខ្លួន ការចោទប្រកាន់តំណាងរាស្ត្រណាមួយត្រូវផ្អាក ប្រសិនបើរដ្ឋសភាបានបញ្ចេញមតិឱ្យផ្អាក តាមមតិភាគច្រើនបីភាគបួននៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

**មាត្រា ៨១ ._**

រដ្ឋសភាមានថវិកាស្វយ័តសម្រាប់ដំណើរការ ។

តំណាងរាស្ត្រត្រូវទទួលប្រាក់បំណាច់ ។

**មាត្រា ៨២ ._ ថ្មី**

រដ្ឋសភាបើកសម័យប្រជុំដំបូង ហុកសិបថ្ងៃយ៉ាងយូរ ក្រោយពេលបោះឆ្នោត តាមការកោះប្រជុំរបស់ព្រះមហាក្សត្រ ។

មុនចាប់ផ្តើមការងាររបស់ខ្លួន រដ្ឋសភាត្រូវប្រកាសសុពលភាពនៃអាណត្តិរបស់សមាជិកនីមួយៗ ត្រូវបោះឆ្នោតជ្រើសរើសដាច់ដោយឡែកពីគ្នានូវ ប្រធាន អនុប្រធាន រដ្ឋសភា និង

សមាជិកទាំងអស់នៃគណៈកម្មការនានារបស់រដ្ឋសភា ដោយមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

រដ្ឋសភាត្រូវអនុម័តបទបញ្ជាផ្ទៃក្នុង ដោយមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

តំណាងរាស្ត្រទាំងអស់ត្រូវធ្វើសច្ចាប្រណិធានមុនចូលកាន់តំណែង ដូចមានខ្លឹមសារចែងក្នុងឧបសម្ព័ន្ធទី៥ នៃរដ្ឋធម្មនុញ្ញ ។

**មាត្រា ៨៣ .-**

រដ្ឋសភាប្រជុំជាសាមញ្ញពីរដងក្នុងមួយឆ្នាំ ។

សម័យប្រជុំនីមួយៗ មានថិរៈវេលាយ៉ាងតិចបីខែ ។ បើមានសំណូមពរពីព្រះមហាក្សត្រ ឬសេចក្តីស្នើសុំពីនាយករដ្ឋមន្ត្រី ឬ ពីសមាជិករដ្ឋសភាចំនួនមួយភាគបីយ៉ាងតិច គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា កោះប្រជុំរដ្ឋសភាជាវិសាមញ្ញ ។

ក្នុងករណីនេះ របៀបវារៈជាក់លាក់នៃសម័យប្រជុំជាវិសាមញ្ញ ត្រូវផ្សាយដល់ប្រជារាស្ត្រជាមួយនឹងថ្ងៃកំណត់ប្រជុំ ។

**មាត្រា ៨៤ .-**

នៅចន្លោះសម័យប្រជុំរបស់រដ្ឋសភា គណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភាទទួលភារកិច្ចចាត់ចែងការងារ ។

គណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភារួមមាន : ប្រធានរដ្ឋសភា អនុប្រធានរដ្ឋសភា និងប្រធានគណៈកម្មការទាំងអស់របស់រដ្ឋសភា ។

**មាត្រា ៨៥ .-**

សម័យប្រជុំរដ្ឋសភា ត្រូវធ្វើនៅរាជធានីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងសាលប្រជុំរបស់រដ្ឋសភា លើកលែងតែមានការសម្រេចផ្សេងចុះក្នុងលិខិតកោះប្រជុំដោយកាលៈទេសៈតម្រូវ ។

ក្រៅពីករណីខាងលើ និង ក្រៅពីកន្លែង និង ពីកាលបរិច្ឆេទដែលកំណត់ក្នុងសេចក្តីអញ្ជើញ ការប្រជុំណាក៏ដោយរបស់រដ្ឋសភាត្រូវទុកជាខុសច្បាប់ ហើយជាអាសាសូន្យពេញលក្ខណៈ ។

**មាត្រា ៨៦ .-**

ក្នុងកាលៈទេសៈដែលប្រទេសជាតិស្ថិតក្នុងភាពអាសន្ន រដ្ឋសភាប្រជុំរាល់ថ្ងៃជាប់ជាប្រចាំ ។ រដ្ឋសភាមានសិទ្ធិសម្រេចបញ្ចប់កាលៈទេសៈពិសេសខាងលើនេះ កាលបើសភាពការណ៍អនុញ្ញាត ។

បើរដ្ឋសភាមិនអាចប្រជុំបានទេ ដោយមូលហេតុចាំបាច់ ជាអាទិ៍នៅពេលដែលកម្លាំងបរទេសចូលមកកាន់កាប់ទឹកដី ការប្រកាសភាពអាសន្នត្រូវបន្តទៅមុខជាស្វ័យប្រវត្តិ ។

នៅពេលដែលប្រទេសជាតិឋិតក្នុងភាពអាសន្ន រដ្ឋសភាមិនអាចត្រូវរំលាយបានឡើយ ។

**មាត្រា ៨៧ .-**

ប្រធានរដ្ឋសភាដឹកនាំអង្គប្រជុំរបស់រដ្ឋសភា ទទួលអាញត្តិច្បាប់ និង សេចក្តីសម្រេចចិត្តទាំងឡាយ ដែលរដ្ឋសភាបានអនុម័ត រ៉ាប់រងការអនុវត្តបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភា និងចាត់ចែងការទាក់ទងអន្តរជាតិទាំងឡាយរបស់រដ្ឋសភា ។

ក្នុងករណីដែលប្រធានរដ្ឋសភាមានធុរៈមិនអាចបំពេញមុខងារបាន ដោយហេតុមកពីមានជំងឺ ឬបំពេញមុខងារជាប្រមុខរដ្ឋស្តីទី ឬជាព្រះរាជានុសិទ្ធិ ឬបំពេញបេសកកម្មនៅបរទេស អនុប្រធានរដ្ឋសភាមួយរូប ត្រូវទទួលភារកិច្ចចាត់ចែងការងារជំនួស ។

ក្នុងករណីដែលប្រធាន ឬអនុប្រធានរដ្ឋសភាលាលែងពីមុខតំណែង ឬទទួលអនិច្ចកម្ម រដ្ឋសភាត្រូវបោះឆ្នោតជ្រើសតាំងប្រធាន ឬអនុប្រធានថ្មី ។

**មាត្រា ៨៨ .- ថ្មី ( ពីរ )**

ការប្រជុំរដ្ឋសភាត្រូវធ្វើជាសាធារណៈ ។

រដ្ឋសភាអាចប្រជុំជាសម្ងាត់បាន តាមការស្នើសុំពីប្រធាន ឬពីសមាជិកចំនួនមួយភាគដប់យ៉ាងតិច ពីព្រះមហាក្សត្រ ឬពីនាយករដ្ឋមន្ត្រី ។

ការប្រជុំរដ្ឋសភានឹងយកជាការបានលុះត្រាតែមាន :

**ក**-កូរ៉ុមលើសពី ពីរភាគបីនៃចំនួនសមាជិករដ្ឋសភាទាំងមូល សម្រាប់ការអនុម័តទាំងឡាយណា ដែលតម្រូវឱ្យយកមតិភាគច្រើន ពីរភាគបីនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

**ខ**-កូរ៉ុមលើសពី ពាក់កណ្តាលនៃចំនួនសមាជិករដ្ឋសភាទាំងមូល សម្រាប់ការអនុម័តទាំងឡាយណា ដែលតម្រូវឱ្យយកមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

**មាត្រា ៨៩ .-**

តាមការសុំពីសមាជិកចំនួនមួយភាគដប់យ៉ាងតិច រដ្ឋសភាអាចអញ្ជើញឥស្សរជនដ៏ឧត្តមណាមួយមកបំភ្លឺរដ្ឋសភា អំពីបញ្ហាដែលមានសារៈសំខាន់ពិសេស ។

**មាត្រា ៩០ ._ ថ្មី ( ពីរ )**

រដ្ឋសភាជាអង្គការដែលមានអំណាចនីតិប្បញ្ញត្តិ ហើយបំពេញភារកិច្ចរបស់ខ្លួន ដូចបានកំណត់ក្នុងរដ្ឋធម្មនុញ្ញ និង ច្បាប់ជាធរមាន ។

រដ្ឋសភាអនុម័តថវិកាជាតិ ផែនការរដ្ឋ ការឱ្យរដ្ឋខ្ចីប្រាក់ពីគេ ការឱ្យរដ្ឋឱ្យប្រាក់គេខ្ចី ការសន្យានានាផ្នែកហិរញ្ញវត្ថុ និង ការបង្កើត កែប្រែ ឬលុបចោលពន្ធដារ ។

រដ្ឋសភាឱ្យសេចក្តីយល់ព្រមចំពោះគណនីរដ្ឋបាល ។

រដ្ឋសភាអនុម័តច្បាប់ស្តីពីការលើកលែងទោសជាទូទៅ ។

រដ្ឋសភាអនុម័តយល់ព្រម ឬលុបចោលសន្ធិសញ្ញា ឬអនុសញ្ញាអន្តរជាតិ ។

រដ្ឋសភាអនុម័តច្បាប់ស្តីពីការប្រកាសសង្គ្រាម ។

ការអនុម័តខាងលើនេះ ប្រព្រឹត្តទៅដោយមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

រដ្ឋសភាបោះឆ្នោតទុកចិត្តដល់រាជរដ្ឋាភិបាល តាមមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

**មាត្រា ៩១ ._ ថ្មី**

សមាជិកព្រឹទ្ធសភា សមាជិករដ្ឋសភា និង នាយករដ្ឋមន្ត្រី មានសិទ្ធិផ្តួចផ្តើមគំនិតធ្វើច្បាប់ ។

តំណាងរាស្ត្រមានសិទ្ធិស្នើធ្វើវិសោធនកម្មច្បាប់ ប៉ុន្តែសំណើនេះមិនអាចទទួលយកបានទេ បើវិសោធនកម្មនោះសំដៅបន្ថយប្រាក់ចំណូលសាធារណៈ ឬបន្ថែមបន្ទុកលើប្រជាពលរដ្ឋ។

**មាត្រា ៩២ .-**

ការអនុម័តទាំងឡាយរបស់រដ្ឋសភា ដែលផ្ទុយនឹងគោលការណ៍ រក្សាការពារឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ហើយដែលនាំឱ្យប៉ះពាល់ដល់ឯកភាពនយោបាយ ឬការគ្រប់គ្រងរដ្ឋបាលរបស់ប្រទេសជាតិនឹងត្រូវចាត់ទុកជាអាសាសូន្យ ។ ក្រុមប្រឹក្សាធម្មនុញ្ញជាអង្គការតែមួយគត់ដែលមានសមត្ថកិច្ចសម្រេចពីមោឃភាពនេះ ។

**មាត្រា ៩៣ .- ថ្មី**

ច្បាប់ដែលរដ្ឋសភាបានអនុម័ត និង ព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់រួចហើយ ហើយត្រូវបានព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាប្រកាសឱ្យប្រើ ត្រូវចូលជាធរមាននៅរាជធានីភ្នំពេញក្នុងរយៈពេលដប់ថ្ងៃគត់ ក្រោយពីថ្ងៃប្រកាសឱ្យប្រើ និង នៅទូទាំងប្រទេសក្នុងរយៈពេលម្ភៃថ្ងៃគត់ ក្រោយពីថ្ងៃប្រកាសឱ្យប្រើ ។ ប៉ុន្តែបើច្បាប់នេះបានចែងថាជាការប្រញាប់ ច្បាប់នេះត្រូវចូលជាធរមានភ្លាមនៅទូទាំងប្រទេស ក្រោយថ្ងៃប្រកាសឱ្យប្រើ ។

ច្បាប់ដែលព្រះមហាក្សត្រ ទ្រង់បានឡាយព្រះហស្តលេខាប្រកាសឱ្យប្រើ ត្រូវចុះក្នុងរាជកិច្ច និង ផ្សព្វផ្សាយនៅទូទាំងប្រទេស ឱ្យទាន់តាមពេលកំណត់ខាងលើ ។

**មាត្រា ៩៤ .-**

រដ្ឋសភាបង្កើតគណៈកម្មការផ្សេងៗដែលចាំបាច់ ។ ការរៀបចំ និង ការប្រព្រឹត្តទៅនៃរដ្ឋសភានឹងមានកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ។

**មាត្រា ៩៥ .-**

ក្នុងករណីមានសមាជិករដ្ឋសភាទទួលអនិច្ចកម្ម លាលែង ឬប្រាសចាកសមាជិកភាព ដែលកើតមានឡើង ៦ ខែ យ៉ាងតិចមុនចប់នីតិកាល ត្រូវចាត់ការជ្រើសតាំងជំនួសសមាជិក នោះ តាមល័ក្ខខ័ណ្ឌកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងរដ្ឋសភា និង ក្នុងច្បាប់បោះឆ្នោត ។

**មាត្រា ៩៦ .-**

តំណាងរាស្ត្រមានសិទ្ធិដាក់សំណួរដល់រាជរដ្ឋាភិបាល ។ សំណួរនេះត្រូវសរសេរជាលាយល័ក្ខអក្សរ ប្រគល់ជូនតាមរយៈប្រធានរដ្ឋសភា ។

ចម្លើយអាចធ្វើឡើងដោយរដ្ឋមន្ត្រីមួយរូប ឬច្រើនរូប អាស្រ័យដោយបញ្ហាដែលបានចោទឡើងពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់រដ្ឋមន្ត្រីមួយរូប ឬច្រើនរូប ។ បើបញ្ហាពាក់ព័ន្ធដល់នយោបាយទូទៅរបស់រាជរដ្ឋាភិបាល នាយករដ្ឋមន្ត្រីត្រូវឆ្លើយផ្ទាល់ខ្លួន ។

ចម្លើយរបស់រដ្ឋមន្ត្រី ឬរបស់នាយករដ្ឋមន្ត្រី អាចធ្វើដោយផ្ទាល់មាត់ ឬសរសេរជាលាយលក្ខណ៍អក្សរ ។

ចម្លើយខាងលើនេះ ត្រូវធ្វើឡើងក្នុងរយៈពេលប្រាំពីរថ្ងៃ បន្ទាប់ពីបានទទួលសំណួរ ។

ចំពោះចម្លើយផ្ទាល់មាត់ ប្រធានរដ្ឋសភាអាចសម្រេចបើកឱ្យមាន ឬមិនឱ្យមានការជជែកដេញដោល ។ បើគ្មានការបើកឱ្យជជែកដេញដោលទេ នោះចម្លើយរបស់រដ្ឋមន្ត្រី ឬនាយករដ្ឋមន្ត្រីនឹងបញ្ចប់សំណួរតែម្តង ។

បើមានការបើកឱ្យជជែកដេញដោល ម្ចាស់សំណួរ វាគ្មិនឯទៀត និង រដ្ឋមន្ត្រីពាក់ព័ន្ធ ឬនាយករដ្ឋមន្ត្រី អាចជជែកប្តូរយោបល់ក្នុងរយៈពេលដែលមិនអាចលើសពីមួយពេលប្រជុំឡើយ ។

រដ្ឋសភាកំណត់ទុកពេលមួយថ្ងៃក្នុងមួយសប្តាហ៍ សម្រាប់ការឆ្លើយសំណួរ ។

ទោះបីយ៉ាងណាក៏ដោយ សម័យប្រជុំសម្រាប់ឆ្លើយសំណួរខាងលើនេះ មិនអាចបើកលទ្ធភាពឱ្យមានការបោះឆ្នោតប្រភេទណាមួយបានឡើយ ។

**មាត្រា ៩៧ .-**

គណៈកម្មការទាំងឡាយរបស់រដ្ឋសភា អាចអញ្ជើញរដ្ឋមន្ត្រីមកបំភ្លឺអំពីបញ្ហាអ្វីមួយ ដែលពាក់ព័ន្ធនឹងវិស័យទទួលខុសត្រូវរបស់ខ្លួន ។

**មាត្រា ៩៨ .- ថ្មី**

រដ្ឋសភាអាចទម្លាក់សមាជិកគណៈរដ្ឋមន្ត្រី ឬទម្លាក់រាជរដ្ឋាភិបាលពីតំណែង ដោយអនុម័តញត្តិបន្ទោស តាមសំឡេងឆ្នោតភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

ញត្តិបន្ទោសរាជរដ្ឋាភិបាលត្រូវបានលើកឡើងជូនរដ្ឋសភា ដោយតំណាងរាស្ត្រចំនួនសាមសិបនាក់ ទើបរដ្ឋសភាអាចលើកមកពិភាក្សាបាន ។

## ជំពូកទី ៨ ថ្មី
## អំពីព្រឹទ្ធសភា

**មាត្រា ៩៩ .- ថ្មី**

ព្រឹទ្ធសភាជាអង្គការដែលមានអំណាចនីតិបញ្ញត្តិ ហើយបំពេញភារកិច្ចរបស់ខ្លួនដូចបានកំណត់ក្នុងរដ្ឋធម្មនុញ្ញ និង ច្បាប់ជាធរមាន ។

ព្រឹទ្ធសភាមានចំនួនសមាជិកយ៉ាងច្រើន ស្មើនឹងពាក់កណ្តាលនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

សមាជិកព្រឹទ្ធសភាត្រូវចាត់តាំងខ្លះ និង ត្រូវជ្រើសតាំងដោយការបោះឆ្នោតអសកលខ្លះ។

សមាជិកព្រឹទ្ធសភាអាចត្រូវបានចាត់តាំង និង ជ្រើសតាំងសាជាថ្មីបាន ។ អ្នកដែលមានសិទ្ធិឈរឈ្មោះជាបេក្ខជនព្រឹទ្ធសភា គឺជាប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានសិទ្ធិបោះឆ្នោត មានអាយុយ៉ាងតិច ៤0 ឆ្នាំ មានសញ្ជាតិខ្មែរតាំងពីកំណើត ។

**មាត្រា ១០០ .- ថ្មី**

សមាជិកព្រឹទ្ធសភាចំនួន ២រូប ត្រូវបានចាត់តាំងដោយព្រះមហាក្សត្រ ។

សមាជិកព្រឹទ្ធសភាចំនួន ២រូប ត្រូវបានរដ្ឋសភាជ្រើសតាំងតាមមតិភាគច្រើនដោយប្រៀប ។

រីឯសមាជិកព្រឹទ្ធសភាឯទៀតត្រូវបានជ្រើសតាំងដោយការបោះឆ្នោតអសកល ។

**មាត្រា ១០១ .- ថ្មី**

ការរៀបចំបែបបទ និង ការប្រព្រឹត្តទៅនៃការចាត់តាំង និង ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ព្រមទាំងការកំណត់អំពីអ្នកបោះឆ្នោត អង្គបោះឆ្នោត និង មណ្ឌលបោះឆ្នោត ត្រូវចែងក្នុងច្បាប់មួយ ។

**មាត្រា ១០២ .- ថ្មី**

នីតិកាលរបស់ព្រឹទ្ធសភាមានកំណត់ ៦ ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលដែលព្រឹទ្ធសភាថ្មីចូលកាន់តំណែង ។

ក្នុងពេលមានសង្គ្រាម ឬក្នុងកាលៈទេសៈពិសេសដទៃទៀតដែលមិនអាចធ្វើការបោះឆ្នោតកើត ព្រឹទ្ធសភាអាចប្រកាសបន្តនីតិកាលរបស់ខ្លួនមួយដងបានមួយឆ្នាំ តាមសំណើរបស់ព្រះមហាក្សត្រ ។

ការប្រកាសបន្តនីតិកាលរបស់ព្រឹទ្ធសភា ត្រូវសម្រេចដោយមតិយល់ព្រមពីរភាគបីយ៉ាងតិចនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។

ក្នុងកាលៈទេសៈដូចបានរៀបរាប់ខាងលើ ព្រឹទ្ធសភាប្រជុំរាល់ថ្ងៃជាប់ជាប្រចាំ ។ ព្រឹទ្ធសភាមានសិទ្ធិសម្រេចបញ្ចប់កាលៈទេសៈពិសេសខាងលើនេះ កាលបើសភាពការណ៍អនុញ្ញាត ។

បើព្រឹទ្ធសភាមិនអាចប្រជុំបានទេ ដោយមូលហេតុចាំបាច់ជាអាទិ៍ នៅពេលដែលកម្លាំងបរទេសចូលមកកាន់កាប់ទឹកដី ការប្រកាសភាពអាសន្នត្រូវបន្តទៅមុខជាស្វ័យប្រវត្តិ ។

## មាត្រា ១០៣ .- ថ្មី

អាណត្តិនៃសមាជិកព្រឹទ្ធសភា មានវិសមិតភាពជាមួយការបំពេញមុខងារសាធារណៈជាសកម្ម ជាមួយមុខងារជាតំណាងរាស្ត្រ និង ជាមួយមុខងារជាសមាជិកស្ថាប័នដទៃទៀតដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ។

## មាត្រា ១០៤ .- ថ្មី

សមាជិកព្រឹទ្ធសភាមានអភ័យឯកសិទ្ធិសភា ។

សមាជិកព្រឹទ្ធសភារូបណាក៏ដោយ មិនអាចត្រូវបានចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬឃុំខ្លួន ដោយហេតុពីបានសំដែងយោបល់ឬបញ្ចេញមតិក្នុងការបំពេញមុខងាររបស់ខ្លួនសោះ

ឡើយ ។ ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនសមាជិកណាមួយនៃព្រឹទ្ធសភា នឹងអាចធ្វើទៅកើត លុះត្រាតែមានការយល់ព្រមពីព្រឹទ្ធសភា ឬពីគណៈកម្មាធិការអចិន្ត្រៃយ៍របស់ព្រឹទ្ធសភាក្នុងចន្លោះសម័យប្រជុំនៃព្រឹទ្ធសភា វៀរលែងតែក្នុងករណីបទល្មើសព្រហ្មទណ្ឌជាក់ស្តែង ។ ក្នុងករណីចុងក្រោយនេះ ក្រសួងមានសមត្ថកិច្ចត្រូវធ្វើសេចក្តីរាយការណ៍ជូនព្រឹទ្ធសភា ឬជូនគណៈកម្មាធិការអចិន្ត្រៃយ៍របស់ព្រឹទ្ធសភាជាបន្ទាន់ដើម្បីសម្រេច ។

សេចក្តីសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍របស់ព្រឹទ្ធសភា ត្រូវដាក់ជូនសម័យប្រជុំព្រឹទ្ធសភាខាងមុខ ដើម្បីអនុម័តតាមមតិភាគច្រើនពីរភាគបីនៃសមាជិកព្រឹទ្ធសភាទាំងមូល ។

ក្នុងករណីទាំងអស់ខាងលើនេះ ការឃុំខ្លួន ការចោទប្រកាន់សមាជិកព្រឹទ្ធសភាណាមួយត្រូវផ្អាក ប្រសិនបើព្រឹទ្ធសភាបានបញ្ចេញមតិឱ្យផ្អាកតាមមតិភាគច្រើនបីភាគបួននៃសមាជិកព្រឹទ្ធសភាទាំងមូល ។

## មាត្រា ១០៥ .- ថ្មី

ព្រឹទ្ធសភាមានថវិកាស្វយ័តសម្រាប់ដំណើរការ ។

សមាជិកព្រឹទ្ធសភាត្រូវទទួលប្រាក់បំណាច់ ។

## មាត្រា ១០៦ .- ថ្មី ( មួយ )

ព្រឹទ្ធសភាបើកសម័យប្រជុំដំបូង ហុកសិបថ្ងៃយ៉ាងយូរ ក្រោយពេលបោះឆ្នោត តាមការកោះប្រជុំរបស់ព្រះមហាក្សត្រ ។

មុនចាប់ផ្តើមការងាររបស់ខ្លួន ព្រឹទ្ធសភាត្រូវប្រកាសសុពលភាពនៃអាណត្តិរបស់សមាជិកនីមួយៗ និងត្រូវបោះឆ្នោតជ្រើសរើសដាច់ដោយឡែកពីគ្នានូវប្រធាន អនុប្រធានព្រឹទ្ធសភា និង សមាជិកទាំងអស់នៃគណៈកម្មការនានារបស់ព្រឹទ្ធសភា ដោយមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។

សមាជិកព្រឹទ្ធសភាទាំងអស់ ត្រូវធ្វើសច្ចាប្រណិធានមុនចូលកាន់តំណែង ដូចមានខ្លឹមសារចែងក្នុងឧបសម្ព័ន្ធទី៧ នៃរដ្ឋធម្មនុញ្ញ ។

**មាត្រា ១០៧ .- ថ្មី**

ព្រឹទ្ធសភាប្រជុំជាសាមញ្ញពីរដងក្នុងមួយឆ្នាំ ។

សម័យប្រជុំនីមួយៗ មានថិរៈវេលាយ៉ាងតិចបីខែ។ បើមានសំណូមពរពីព្រះមហាក្សត្រ ឬសេចក្តីស្នើសុំពីនាយករដ្ឋមន្ត្រី ឬពីសមាជិកព្រឹទ្ធសភាចំនួនមួយភាគបីយ៉ាងតិច ព្រឹទ្ធសភាកោះប្រជុំជាវិសាមញ្ញ ។

**មាត្រា ១០៨ .- ថ្មី**

នៅចន្លោះសម័យប្រជុំរបស់ព្រឹទ្ធសភា គណៈកម្មាធិការអចិន្ត្រៃយ៍របស់ព្រឹទ្ធសភាទទួលភារកិច្ចចាត់ចែងការងារ ។

គណៈកម្មាធិការអចិន្ត្រៃយ៍របស់ព្រឹទ្ធសភារួមមាន : ប្រធានព្រឹទ្ធសភា អនុប្រធានព្រឹទ្ធសភា និង ប្រធានគណៈកម្មការទាំងអស់របស់ព្រឹទ្ធសភា ។

**មាត្រា ១០៩ .- ថ្មី**

សម័យប្រជុំព្រឹទ្ធសភាត្រូវធ្វើនៅរាជធានីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងសាលប្រជុំរបស់

ព្រឹទ្ធសភា លើកលែងតែមានការសម្រេចផ្សេង ចុះក្នុងលិខិតកោះប្រជុំដោយកាលៈទេសៈតម្រូវ ។

ក្រៅពីករណីខាងលើ និង ក្រៅពីកន្លែង និង កាលបរិច្ឆេទដែលកំណត់ក្នុងសេចក្តីអញ្ជើញ ការប្រជុំណាក៏ដោយរបស់ព្រឹទ្ធសភាត្រូវទុកជាខុសច្បាប់ ហើយអសារសូន្យពេញលក្ខណៈ ។

## មាត្រា ១១០ .. ថ្មី

ប្រធានព្រឹទ្ធសភាដឹកនាំអង្គប្រជុំរបស់ព្រឹទ្ធសភា ទទួលអាញត្តិច្បាប់ និង សេចក្តីសម្រេចចិត្តទាំងឡាយដែលព្រឹទ្ធសភាបានអនុម័ត រ៉ាប់រងការអនុវត្តបទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភា និង ចាត់ចែងការទាក់ទងអន្តរជាតិទាំងឡាយរបស់ព្រឹទ្ធសភា ។

ក្នុងករណីដែលប្រធានព្រឹទ្ធសភាមានធុរៈមិនអាចបំពេញមុខងារបាន ដោយហេតុមកពីមានជំងឺ ឬបំពេញមុខងារជាប្រមុខរដ្ឋស្តីទី ឬជាព្រះរាជានុសិទ្ធិ ឬបំពេញបេសកកម្មនៅបរទេស អនុប្រធានព្រឹទ្ធសភាមួយរូប ត្រូវទទួលភារកិច្ចចាត់ចែងការងារជំនួស ។

ក្នុងករណីដែលប្រធាន ឬអនុប្រធានព្រឹទ្ធសភាលាលែងពីមុខតំណែង ឬទទួលអនិច្ចកម្ម ព្រឹទ្ធសភាត្រូវបោះឆ្នោតជ្រើសតាំងប្រធាន ឬអនុប្រធានថ្មី ។

## មាត្រា ១១១ .. ថ្មី ( ពីរ )

ការប្រជុំព្រឹទ្ធសភាត្រូវធ្វើជាសាធារណៈ ។

ព្រឹទ្ធសភាអាចប្រជុំជាសម្ងាត់បានតាមការស្នើសុំពីប្រធាន ឬពីសមាជិកចំនួនមួយភាគដប់យ៉ាងតិច ពីព្រះមហាក្សត្រ ពីនាយករដ្ឋមន្ត្រី ឬពីប្រធានរដ្ឋសភា ។

ការប្រជុំព្រឹទ្ធសភានឹងយកជាការបាន លុះត្រាតែមាន :

**ក**-កូរ៉ុមលើសពី ពីរភាគបីនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល សម្រាប់ការអនុម័ត ទាំងឡាយណា ដែលតម្រូវឱ្យយកមតិភាគច្រើនពីរភាគបីនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។

**ខ**-កូរ៉ុមលើសពី ពាក់កណ្ដាលនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល សម្រាប់ការអនុម័ត ទាំងឡាយណា ដែលតម្រូវឱ្យយកមតិភាគច្រើនដោយប្រៀប ឬយកមតិភាគច្រើនដាច់ខាត នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។

ចំនួនសំឡេងដែលតម្រូវសម្រាប់រដ្ឋសភាអនុម័តយល់ព្រម ហើយដែលមានកំណត់ក្នុង រដ្ឋធម្មនុញ្ញ ត្រូវយកមកប្រើសម្រាប់ព្រឹទ្ធសភាផងដែរ ។

## មាត្រា ១១២ .- ថ្មី

ព្រឹទ្ធសភាមានភារកិច្ចសម្របសម្រួលការងាររវាងរដ្ឋសភា និង រដ្ឋាភិបាល ។

## មាត្រា ១១៣ .- ថ្មី

ព្រឹទ្ធសភាពិនិត្យ ហើយឱ្យយោបល់ក្នុងរយៈពេលមួយខែយ៉ាងយូរ លើសេចក្ដីព្រាង ច្បាប់ ឬសេចក្ដីស្នើច្បាប់ ដែលរដ្ឋសភាបានអនុម័តយល់ព្រមលើកដំបូងរួចហើយ ព្រមទាំងលើ បញ្ហាទាំងពួងដែលរដ្ឋសភាបានដាក់ឱ្យពិនិត្យ ។ បើជាការប្រញាប់ រយៈពេលនោះត្រូវបន្ថយ មកនៅត្រឹមតែប្រាំថ្ងៃ ។

បើព្រឹទ្ធសភាបានឱ្យយោបល់យល់ព្រម ឬពុំបានឱ្យយោបល់សោះ ក្នុងរយៈពេលដែល មានកំណត់ទុកហើយនោះទេ ច្បាប់ដែលរដ្ឋសភាបានអនុម័តយល់ព្រមហើយនោះ នឹងត្រូវ បានយកទៅប្រកាសឱ្យប្រើ ។

បើព្រឹទ្ធសភាសុំឱ្យកែសម្រួលសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់នោះ រដ្ឋសភាត្រូវយកមកពិចារណាភ្លាមជាលើកទីពីរ ។ រដ្ឋសភាត្រូវពិនិត្យ និង សម្រេចតែត្រង់បទប្បញ្ញត្តិ ឬចំណុចណាដែលព្រឹទ្ធសភាសុំឱ្យកែសម្រួល ដោយបដិសេធចោលទាំងមូល ឬទុកជាបានការខ្លះ។

ការបង្វិលទៅបង្វិលមករវាងព្រឹទ្ធសភា និង រដ្ឋសភា ត្រូវធ្វើតែក្នុងរយៈពេលមួយខែ។ រយៈពេលនេះ ត្រូវបន្ថយមកត្រឹមដប់ថ្ងៃ បើត្រូវពិនិត្យសម្រេចពីថវិកាជាតិ និង ហិរញ្ញវត្ថុ ហើយមកត្រឹមតែពីរថ្ងៃ បើជាការប្រញាប់ ។

បើរដ្ឋសភាទុកឱ្យហួសរយៈពេលកំណត់ ឬពន្យារពេលដែលកំណត់ទុកសម្រាប់ពិនិត្យនោះ រយៈពេលជាគោលការណ៍សម្រាប់រដ្ឋសភា និង ព្រឹទ្ធសភាត្រូវបន្ថែមឱ្យស្មើគ្នាដែរ ។

បើព្រឹទ្ធសភាបដិសេធសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់នោះជាអសារបង់ រដ្ឋសភាមិនអាចនឹងយកមកពិចារណាជាលើកទីពីរបាន មុនរយៈពេលមួយខែទេ ។ រយៈពេលនេះត្រូវបន្ថយមកត្រឹមដប់ប្រាំថ្ងៃ បើពិនិត្យពីថវិកាជាតិ និង ហិរញ្ញវត្ថុ ហើយមកត្រឹមតែបួនថ្ងៃបើជាការប្រញាប់ ។

ក្នុងការពិនិត្យសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ជាលើកទី២នេះ រដ្ឋសភាត្រូវអនុម័តដោយវិធីបោះឆ្នោតចំហ និង យកតាមមតិភាគច្រើនដាច់ខាត ។

សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ណា ដែលបានសម្រេចដូចខាងលើនេះ ហើយនោះនឹងត្រូវបានយកទៅប្រកាសឱ្យប្រើ ។

**មាត្រា ១១៤ .- ថ្មី ( មួយ )**

ព្រឹទ្ធសភាបង្កើតគណៈកម្មការផ្សេងៗដែលចាំបាច់ ។ ការរៀបចំ និង ការប្រព្រឹត្តទៅនៃព្រឹទ្ធសភានឹងកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភា។ បទបញ្ជាផ្ទៃក្នុងនេះ ត្រូវអនុម័តយល់ព្រមដោយសំឡេងភាគច្រើនដាច់ខាតនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។

**មាត្រា ១១៥ .- ថ្មី**

ក្នុងករណីមានសមាជិកព្រឹទ្ធសភាទទួលអនិច្ចកម្ម លាលែង ឬប្រាសចាកសមាជិកភាពដែលកើតមានឡើងប្រាំមួយខែយ៉ាងតិចមុនចប់នីតិកាល ត្រូវចាត់តាំង ឬជ្រើសតាំងជំនួសសមាជិកនោះ តាមល័ក្ខខ័ណ្ឌកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងនៃព្រឹទ្ធសភា និង ក្នុងច្បាប់ស្តីពីការចាត់តាំង និង ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

## ជំពូកទី ៩ ថ្មី
## អំពីសមាជរដ្ឋសភា និង ព្រឹទ្ធសភា

**មាត្រា ១១៦ .- ថ្មី**

ក្នុងករណីចាំបាច់ រដ្ឋសភា និង ព្រឹទ្ធសភាអាចប្រជុំរួមគ្នាជាសមាជ ដើម្បីដោះស្រាយបញ្ហាសំខាន់ៗ របស់ប្រទេសជាតិ ។

**មាត្រា ១១៧ .- ថ្មី**

បញ្ហាសំខាន់ៗរបស់ប្រទេសជាតិ ដូចមានចែងក្នុងមាត្រា ១១៦ ថ្មី ខាងលើ ព្រមទាំងការរៀបចំ និង ការប្រព្រឹត្តទៅនៃសមាជនឹងត្រូវកំណត់ក្នុងច្បាប់មួយ ។

## ជំពូកទី ១០ ថ្មី
## អំពីរាជរដ្ឋាភិបាល

### មាត្រា ១១៨ .- ថ្មី ( មាត្រា ៩៩ ចាស់ )

គណៈរដ្ឋមន្ត្រីជារាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។

គណៈរដ្ឋមន្ត្រី ត្រូវបានដឹកនាំដោយនាយករដ្ឋមន្ត្រីមួយរូប អមដោយឧបនាយករដ្ឋមន្ត្រី ព្រមទាំងមានទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និង រដ្ឋលេខាធិការជាសមាជិក ។

### មាត្រា ១១៩ .- ថ្មី ( មាត្រា ១០០ ចាស់ )

តាមសេចក្តីស្នើពីប្រធាន ដោយមានមតិឯកភាពពីអនុប្រធានទាំងពីរនៃរដ្ឋសភា ព្រះមហាក្សត្រទ្រង់ចាត់តាំងវរជនមួយរូប ក្នុងចំណោមតំណាងរាស្ត្រនៃគណបក្សដែលឈ្នះឆ្នោត ឱ្យបង្កើតរាជរដ្ឋាភិបាល ។ វរជនដែលត្រូវបានចាត់តាំងនេះ នាំសហការីដែលជាតំណាងរាស្ត្រ ឬជាសមាជិកគណបក្សតំណាងនៅក្នុងរដ្ឋសភា ដែលផ្តូវផ្តងឱ្យកាន់តំណែងផ្សេងៗក្នុងរាជរដ្ឋាភិបាល ទៅសុំសេចក្តីទុកចិត្តពីរដ្ឋសភា ។ កាលបើរដ្ឋសភាបានបោះឆ្នោតទុកចិត្តហើយនោះ ព្រះមហាក្សត្រទ្រង់ចេញព្រះរាជក្រឹត្យតែងតាំងគណៈរដ្ឋមន្ត្រីទាំងមូល ។

មុនចូលកាន់តំណែងគណៈរដ្ឋមន្ត្រីត្រូវធ្វើសច្ចាប្រណិធាន ដូចមានខ្លឹមសារចែងក្នុងឧបសម្ព័ន្ធ ៦ ។

### មាត្រា ១២០ .- ថ្មី ( មាត្រា ១០១ ចាស់ )

មុខងារនៃសមាជិករាជរដ្ឋាភិបាល មានវិសមិតភាពនឹងសកម្មភាពខាងវិជ្ជាជីវៈ ផ្នែកពាណិជ្ជកម្ម ឬឧស្សាហកម្ម ហើយនិងការកាន់តំណែងណាមួយក្នុងមុខងារសាធារណៈ ។

**មាត្រា ១២១ ._ ថ្មី ( មាត្រា ១០២ ចាស់ )**

សមាជិកទាំងឡាយនៃរាជរដ្ឋាភិបាលទទួលខុសត្រូវរួមគ្នាចំពោះរដ្ឋសភា អំពីនយោបាយទូទៅរបស់រាជរដ្ឋាភិបាល ។

សមាជិកមួយរូប១នៃរាជរដ្ឋាភិបាលទទួលខុសត្រូវរៀងខ្លួន ចំពោះនាយករដ្ឋមន្ត្រី និងចំពោះរដ្ឋសភា អំពីការដែលខ្លួនបានប្រព្រឹត្ត ។

**មាត្រា ១២២ ._ ថ្មី ( មាត្រា ១០៣ ចាស់ )**

សមាជិកទាំងឡាយនៃរាជរដ្ឋាភិបាលមិនអាចយកសំអាងនៃសេចក្តីបង្គាប់ដោយលាយលក្ខអក្សរ ឬដោយវាចាអំពីនរណាមួយ ដើម្បីដោះសាខ្លួនពីការទទួលខុសត្រូវរបស់ខ្លួនបានឡើយ ។

**មាត្រា ១២៣ ._ ថ្មី ( មាត្រា ១០៤ ចាស់ )**

គណៈរដ្ឋមន្ត្រី ត្រូវប្រជុំរាល់សប្តាហ៍ ជាប្រជុំធំ ឬជាប្រជុំពិនិត្យស្រាវជ្រាវ ។

អង្គប្រជុំធំ ត្រូវដឹកនាំដោយនាយករដ្ឋមន្ត្រី ។ នាយករដ្ឋមន្ត្រីអាចប្រគល់ភារកិច្ចជូនឧបនាយករដ្ឋមន្ត្រីដឹកនាំអង្គប្រជុំពិនិត្យស្រាវជ្រាវបាន ។

កំណត់ហេតុនៃអង្គប្រជុំទាំងអស់របស់គណៈរដ្ឋមន្ត្រី ត្រូវធ្វើថ្វាយព្រះមហាក្សត្រទ្រង់ជ្រាប ។

**មាត្រា ១២៤ ._ ថ្មី ( មាត្រា ១០៥ ចាស់ )**

នាយករដ្ឋមន្ត្រីអាចរំលែកអំណាចរបស់ខ្លួនឱ្យទៅឧបនាយករដ្ឋមន្ត្រី ឬសមាជិកណាមួយនៃរាជរដ្ឋាភិបាលបាន ។

**មាត្រា ១២៥ .- ថ្មី ( មាត្រា ១០៦ ចាស់ )**

បើតំណែងនាយករដ្ឋមន្ត្រីនៅទំនេរជាស្ថាពរនោះ ត្រូវតែងតាំងគណៈរដ្ឋមន្ត្រីមួយជាថ្មី ក្នុងល័ក្ខខ័ណ្ឌដែលមានចែងក្នុងរដ្ឋធម្មនុញ្ញនេះ ។ បើការទំនេរនេះ ជាការទំនេរមួយកាលមួយគ្រាទេ ត្រូវចាត់តាំងនាយករដ្ឋមន្ត្រីស្ដីទី ជាបណ្ដោះអាសន្ន ។

**មាត្រា ១២៦ .- ថ្មី ( មាត្រា ១០៧ ចាស់ )**

សមាជិកមួយរូបៗនៃរាជរដ្ឋាភិបាល ត្រូវទទួលទណ្ឌកម្មពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ដែលខ្លួនបានប្រព្រឹត្តក្នុងការបំពេញការងាររបស់ខ្លួន ។

ក្នុងករណីនេះ និង ក្នុងករណីធ្វើខុសជាទម្ងន់ក្នុងការបំពេញការងាររបស់ខ្លួន រដ្ឋសភាអាចសម្រេចប្ដឹងទៅតុលាការមានសមត្ថកិច្ច ។

រដ្ឋសភាសម្រេចក្នុងរឿងនេះ ដោយវិធីបោះឆ្នោតជាសម្ងាត់ តាមមតិភាគច្រើនដាច់ខាតនៃសមាជិករដ្ឋសភាទាំងមូល ។

**មាត្រា ១២៧ .- ថ្មី ( មាត្រា ១០៨ ចាស់ )**

ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី នឹងត្រូវកំណត់ក្នុងច្បាប់មួយ ។

## ជំពូកទី ១១ ថ្មី

## អំពីអំណាចតុលាការ

**មាត្រា ១២៨ .- ថ្មី ( មាត្រា ១០៩ ចាស់ )**

អំណាចតុលាការជាអំណាចឯករាជ្យ ។

អំណាចតុលាការ ធានារក្សាអនាគតិ និង ការពារសិទ្ធិ សេរីភាពរបស់ប្រជាពលរដ្ឋ ។

អំណាចតុលាការគ្របដណ្តប់ទៅលើរឿងក្តីទាំងអស់ រួមទាំងរឿងក្តីរដ្ឋបាលផង ។

អំណាចនេះ ត្រូវប្រគល់ឱ្យតុលាការកំពូល និង សាលាជំរះក្តីគ្រប់ផ្នែក និង គ្រប់ជាន់ថ្នាក់ ។

**មាត្រា ១២៩ ._ ថ្មី ( មាត្រា ១១០ ចាស់ )**

ការជំរះក្តីផ្តល់យុត្តិធម៌ ត្រូវធ្វើក្នុងនាមប្រជារាស្ត្រខ្មែរ តាមនីតិវិធី និង ច្បាប់ជាធរមាន ។

មានតែចៅក្រមទេដែលមានសិទ្ធិជំរះក្តី ។ ចៅក្រមត្រូវបំពេញភារកិច្ចនេះ ដោយគោរពច្បាប់យ៉ាងម៉ឺងម៉ាត់ និងឱ្យអស់ពីដួងចិត្ត និង សម្បជញ្ញៈរបស់ខ្លួន ។

**មាត្រា ១៣០ ._ ថ្មី ( មាត្រា ១១១ ចាស់ )**

គ្មានអង្គការណាមួយនៃអំណាចនីតិបញ្ញត្តិ ឬ នីតិប្រតិបត្តិ អាចទទួលអំណាចតុលាការអ្វីបានឡើយ ។

**មាត្រា ១៣១ ._ ថ្មី ( មាត្រា ១១២ ចាស់ )**

មានតែអង្គការអយ្យការទេ ដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា ។

**មាត្រា ១៣២ ._ ថ្មី ( មាត្រា ១១៣ ចាស់ )**

ព្រះមហាក្សត្រ ទ្រង់ជាអ្នកធានាឯករាជ្យនៃអំណាចតុលាការ ។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមជួយព្រះមហាក្សត្រក្នុងកិច្ចការនេះ ។

## មាត្រា ១៣៣ .- ថ្មី ( មាត្រា ១១៤ ចាស់ )

ចៅក្រមមិនអាចត្រូវគេដកពីមុខងារបានទេ ។ ប៉ុន្តែឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមសំរេចដាក់វិន័យលើចៅក្រមដែលបានប្រព្រឹត្តខុស ។

## មាត្រា ១៣៤ .- ថ្មី ( មាត្រា ១១៥ ចាស់ )

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនឹងត្រូវបង្កើតដោយច្បាប់រៀបចំអង្គការមួយ ដែលនឹងកំណត់សមាសភាព និង មុខងារ ។

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមស្ថិតក្រោមព្រះរាជាធិបតីភាពនៃព្រះមហាក្សត្រ ។ ព្រះមហាក្សត្រ ព្រះអង្គទ្រង់អាចចាត់តាំងព្រះរាជតំណាងម្នាក់របស់ព្រះអង្គឱ្យធ្វើជាអធិបតីនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនេះ ។

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម លើកសេចក្តីស្នើថ្វាយព្រះមហាក្សត្រ អំពីការតែងតាំងចៅក្រម និង ព្រះរាជអាជ្ញាអមសាលាជំរះក្តីទាំងអស់ ។

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ក្នុងមុខការដាក់វិន័យចំពោះចៅក្រម និង ព្រះរាជអាជ្ញាត្រូវប្រជុំក្រោមអធិបតីភាពនៃប្រធានតុលាការកំពូល ឬអគ្គព្រះរាជអាជ្ញាអមតុលាការកំពូលអាស្រ័យដោយករណីទាក់ទងនឹងចៅក្រម ឬព្រះរាជអាជ្ញា ។

## មាត្រា ១៣៥ .- ថ្មី ( មាត្រា ១១៦ ចាស់ )

លក្ខន្តិកៈនៃចៅក្រម និង ព្រះរាជអាជ្ញា និង ការរៀបចំអង្គការតុលាការនឹងត្រូវកំណត់ក្នុងច្បាប់ដោយឡែកពីគ្នា ។

# ជំពូកទី ១២ ថ្មី
# អំពីក្រុមប្រឹក្សាធម្មនុញ្ញ

**មាត្រា ១៣៦ .- ថ្មី**

ក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចធានាការពារការគោរពរដ្ឋធម្មនុញ្ញ បកស្រាយរដ្ឋធម្មនុញ្ញ និង ច្បាប់ដែលរដ្ឋសភាបានអនុម័ត និង ព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយ ។

ក្រុមប្រឹក្សាធម្មនុញ្ញមានសិទ្ធិពិនិត្យ និង សំរេចអំពីករណីវិវាទកម្មទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

**មាត្រា ១៣៧ .- ថ្មី ( មាត្រា ១១៨ ចាស់ )**

ក្រុមប្រឹក្សាធម្មនុញ្ញមានសមាជិកប្រាំបួនរូប ដែលទទួលអាណត្តិប្រាំបួនឆ្នាំ ។ សមាជិកក្រុមប្រឹក្សាធម្មនុញ្ញចំនួនមួយភាគបី ត្រូវផ្លាស់ថ្មីក្នុងរយៈពេលបីឆ្នាំម្តង បីឆ្នាំម្តង ។ សមាជិកបីរូបត្រូវតែងតាំងដោយព្រះមហាក្សត្រ បីរូបត្រូវជ្រើសតាំងដោយរដ្ឋសភា ហើយបីរូបទៀតត្រូវតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។

ប្រធានត្រូវបានជ្រើសតាំងដោយសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ។ ប្រធានមានសម្លេងឧត្តមានុភាព ក្នុងករណីបែកសម្លេងជាពីរស្មើគ្នា ។

**មាត្រា ១៣៨ .- ថ្មី ( មាត្រា ១១៩ ចាស់ )**

សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវជ្រើសរើសក្នុងចំណោមឥស្សរជន ដែលមានសញ្ញាប័ត្រចាប់ពីឧត្តមសិក្សាទៅ ខាងច្បាប់ ខាងរដ្ឋបាល ខាងការទូត ឬខាងសេដ្ឋកិច្ច ហើយមានពិសោធន៍ច្រើនក្នុងការងារ ។

**មាត្រា ១៣៩ .- ថ្មី**

មុខងារសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ មានវិសមិតភាពនឹងមុខងារសមាជិកព្រឹទ្ធសភា សមាជិករដ្ឋសភា សមាជិករាជរដ្ឋាភិបាល ចៅក្រមក្នុងតំណែង ការកាន់តំណែងណាមួយក្នុងមុខងារសាធារណៈ ប្រធាន ឬអនុប្រធានគណបក្សនយោបាយ ប្រធាន ឬអនុប្រធានសហជីព ។

**មាត្រា ១៤០ .- ថ្មី**

ព្រះមហាក្សត្រ នាយករដ្ឋមន្ត្រី ប្រធានរដ្ឋសភា តំណាងរាស្ត្រចំនួនមួយភាគដប់ ប្រធានព្រឹទ្ធសភា ឬសមាជិកព្រឹទ្ធសភាចំនួនមួយភាគបួន អាចបញ្ជូនច្បាប់ដែលរដ្ឋសភាបានអនុម័តទៅឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យ មុននឹងច្បាប់នោះត្រូវប្រកាសឱ្យប្រើ ។

បទបញ្ជាផ្ទៃក្នុងរដ្ឋសភា បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា និង ច្បាប់រៀបចំអង្គការទាំងឡាយត្រូវតែបញ្ជូនទៅក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យមុននឹងប្រកាសឱ្យប្រើ ។ ក្រុមប្រឹក្សាធម្មនុញ្ញត្រូវសំរេចក្នុងរយៈពេលសាមសិប ( ៣០ ) ថ្ងៃយ៉ាងយូរ ថាតើច្បាប់ បទបញ្ជាផ្ទៃក្នុងរដ្ឋសភា និងបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភាខាងលើ ស្រប ឬមិនស្របនឹងរដ្ឋធម្មនុញ្ញ ។

**មាត្រា ១៤១ .- ថ្មី**

ក្រោយពីច្បាប់ណាមួយត្រូវបានប្រកាសឱ្យប្រើ ព្រះមហាក្សត្រ ប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី សមាជិកព្រឹទ្ធសភាចំនួនមួយភាគបួន តំណាងរាស្ត្រចំនួនមួយភាគដប់ ឬតុលាការ អាចសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យអំពីធម្មនុញ្ញភាពនៃច្បាប់នោះ ។

ប្រជារាស្ត្រមានសិទ្ធិប្ដឹងអំពីធម្មនុញ្ញភាពនៃច្បាប់បាន តាមរយៈតំណាងរាស្ត្រ ឬប្រធានរដ្ឋសភា ឬសមាជិកព្រឹទ្ធសភា ឬប្រធានព្រឹទ្ធសភា ដូចមានចែងក្នុងវាក្យខ័ណ្ឌខាងលើ ។

**មាត្រា ១៤២ .- ថ្មី ( មាត្រា ១២៣ ចាស់ )**

បទប្បញ្ញត្តិក្នុងមាត្រាណាដែលក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថា មិនស្របនឹងរដ្ឋធម្មនុញ្ញ មិនអាចយកទៅប្រកាសឱ្យប្រើ ឬយកទៅអនុវត្តបានឡើយ ។

សេចក្ដីសំរេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញជាសេចក្ដីសំរេចបិទផ្លូវតវ៉ា ។

**មាត្រា ១៤៣ .- ថ្មី ( មាត្រា ១២៤ ចាស់ )**

ព្រះមហាក្សត្រ ទ្រង់ពិគ្រោះមតិក្រុមប្រឹក្សាធម្មនុញ្ញ ចំពោះសេចក្ដីស្នើទាំងឡាយ ដែលសុំធ្វើវិសោធនកម្មលើរដ្ឋធម្មនុញ្ញ ។

**មាត្រា ១៤៤ .- ថ្មី ( មាត្រា ១២៥ ចាស់ )**

ច្បាប់រៀបចំអង្គការមួយនឹងកំណត់ការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ។

## ជំពូកទី ១៣ ថ្មី

## អំពីការគ្រប់គ្រងរដ្ឋបាល

**មាត្រា ១៤៥ .- ថ្មី ( មួយ )**

ទឹកដីនៃព្រះរាជាណាចក្រកម្ពុជាចែកជា រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ។

**មាត្រា ១៤៦ .- ថ្មី ( មួយ )**

រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ត្រូវគ្រប់គ្រងតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងច្បាប់រៀបចំអង្គការ ។

## ជំពូកទី ១៤ ថ្មី
## អំពីសមាជជាតិ

### មាត្រា ១៤៧ .- ថ្មី ( មាត្រា ១២៨ ចាស់ )

សមាជជាតិបើកឱ្យប្រជារាស្ត្រជ្រាបដោយផ្ទាល់ អំពីកិច្ចការផ្សេងៗដែលជាប្រយោជន៍ជាតិ និងលើកបញ្ហា និងសំណូមពរជូនរដ្ឋអំណាចដោះស្រាយ ។

ប្រជារាស្ត្រខ្មែរទាំងពីរភេទ មានសិទ្ធិទៅចូលរួមក្នុងសមាជជាតិ ។

### មាត្រា ១៤៨ .- ថ្មី ( មាត្រា ១២៩ ចាស់ )

សមាជជាតិប្រជុំមួយដងក្នុងមួយឆ្នាំ នៅដើមខែធ្នូ តាមការកោះអញ្ជើញរបស់នាយករដ្ឋមន្ត្រី ។

សមាជជាតិ ប្រព្រឹត្តទៅក្រោមព្រះរាជាធិបតីភាពនៃព្រះមហាក្សត្រ ។

### មាត្រា ១៤៩ .- ថ្មី

សមាជជាតិអនុម័តសំណូមពរជូនព្រឹទ្ធសភា ជូនរដ្ឋសភា និង ជូនរដ្ឋអំណាចពិចារណា ។

ការរៀបចំ និង ការប្រព្រឹត្តទៅនៃសមាជជាតិនឹងត្រូវកំណត់ក្នុងច្បាប់មួយ ។

## ជំពូកទី ១៥ ថ្មី
## អំពីអានុភាព ការសើរើ និង វិសោធនកម្មរដ្ឋធម្មនុញ្ញ

### មាត្រា ១៥០ .- ថ្មី ( មាត្រា ១៣១ ចាស់ )

រដ្ឋធម្មនុញ្ញនេះជាច្បាប់កំពូលនៃព្រះរាជាណាចក្រកម្ពុជា ។

ច្បាប់ និង សេចក្តីសម្រេចទាំងឡាយនៃស្ថាប័ននានារបស់រដ្ឋ ត្រូវស្របនឹងរដ្ឋធម្មនុញ្ញជាដាច់ខាត ។

### មាត្រា ១៥១ .- ថ្មី ( មាត្រា ១៣២ ចាស់ )

ការផ្តើមគំនិតសើរើ ឬការផ្តើមគំនិតធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ជាសិទ្ធិរបស់ព្រះមហាក្សត្រ របស់នាយករដ្ឋមន្ត្រី និង របស់ប្រធានរដ្ឋសភាតាមសេចក្តីស្នើរបស់តំណាងរាស្ត្រមួយភាគបួននៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

ការសើរើ ឬវិសោធនកម្មរដ្ឋធម្មនុញ្ញ ត្រូវធ្វើឡើងដោយច្បាប់ធម្មនុញ្ញមួយដែលអនុម័តដោយរដ្ឋសភា តាមមតិភាគច្រើនពីរភាគបីនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

### មាត្រា ១៥២ .- ថ្មី ( មាត្រា ១៣៣ ចាស់ )

ការសើរើ ឬវិសោធនកម្មរដ្ឋធម្មនុញ្ញ ត្រូវហាមឃាត់មិនឱ្យធ្វើ នៅពេលប្រទេសជាតិឋិតក្នុងភាពអាសន្ន ដូចមានចែងក្នុងមាត្រា ៨៦ ។

### មាត្រា ១៥៣ .- ថ្មី ( មាត្រា ១៣៤ ចាស់ )

ការសើរើ ឬវិសោធនកម្មរដ្ឋធម្មនុញ្ញមិនអាចធ្វើបានឡើយ កាលបើប៉ះពាល់ដល់ប្រព័ន្ធប្រជាធិបតេយ្យ សេរីពហុបក្ស និង របបរាជានិយមអាស្រ័យដោយរដ្ឋធម្មនុញ្ញ។

# ជំពូកទី ១៦ ថ្មី
# អំពីអន្តរប្បញ្ញត្តិ

**មាត្រា ១៥៤ ._ ថ្មី**

រដ្ឋធម្មនុញ្ញនេះ ក្រោយពីបានទទួលការអនុម័ត ត្រូវបានប្រកាសឱ្យចូលជាធរមានភ្លាម ដោយព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ១៥៥ ._ ថ្មី ( មាត្រា ១៣៦ ចាស់ )**

ក្រោយពេលរដ្ឋធម្មនុញ្ញនេះចូលជាធរមាន សភាធម្មនុញ្ញត្រូវក្លាយទៅជារដ្ឋសភា ។

បទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភាត្រូវចូលជាធរមាន ក្រោយទទួលបានការអនុម័តពីរដ្ឋសភា ។

ក្នុងករណីដែលរដ្ឋសភាមិនទាន់ចាប់ដំណើរការបាន ប្រធាន អនុប្រធានទីមួយ និងអនុប្រធានទីពីរនៃសភាធម្មនុញ្ញនឹងចូលរួមបំពេញភារកិច្ចក្នុងក្រុមប្រឹក្សារាជសម្បត្តិ បើសភាពការណ៍ក្នុងប្រទេសទាមទារ ។

**មាត្រា ១៥៦ ._ ថ្មី**

ក្រោយរដ្ឋធម្មនុញ្ញនេះចូលជាធរមាន ព្រះមហាក្សត្រជ្រើសតាំងតាមល័ក្ខខ័ណ្ឌ ដែលមានចែងក្នុងមាត្រា ១៣ ថ្មី និង ១៤ ។

**មាត្រា ១៥៧ ._ ថ្មី**

នីតិកាលទី១ នៃព្រឹទ្ធសភាមានកំណត់ ៥ ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលព្រឹទ្ធសភាថ្មីចូលកាន់តំណែង ។

សំរាប់នីតិកាលទី១ នៃព្រឹទ្ធសភា :

- សមាជិកព្រឹទ្ធសភាមានចំនួនសរុបហុកសិបមួយរូប ។

- ព្រះមហាក្សត្រ ទ្រង់តែងតាំងសមាជិកព្រឹទ្ធសភាពីររូប ព្រមទាំងប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា ។

- សមាជិកដទៃទៀតនៃព្រឹទ្ធសភា ត្រូវបានតែងតាំងដោយព្រះមហាក្សត្រ តាមសំណើរបស់ប្រធានព្រឹទ្ធសភា និង ប្រធានរដ្ឋសភា ក្នុងចំណោមសមាជិកនៃគណបក្សដែលមានអាសនៈនៅក្នុងរដ្ឋសភា ។

- កិច្ចប្រជុំជាសមាជរដ្ឋសភា និង ព្រឹទ្ធសភា ត្រូវដឹកនាំដោយសហប្រធាន ។

**មាត្រា ១៥៨ ._ ថ្មី ( មាត្រា ១៣៩ ចាស់ )**

ច្បាប់ និង លិខិតបទដ្ឋានទាំងអស់នៅកម្ពុជា ដែលធានាការពារបាននូវទ្រព្យសម្បត្តិរដ្ឋ សិទ្ធិ សេរីភាព និង ទ្រព្យសម្បត្តិត្រឹមត្រូវតាមច្បាប់របស់បុគ្គល និងដែលសមស្របនឹងប្រយោជន៍ជាតិ ត្រូវមានអានុភាពអនុវត្តបន្តទៅមុខទៀត រហូតដល់មានអត្ថបទថ្មីមកកែប្រែ ឬលុបចោល លើកលែងតែបទប្បញ្ញត្តិណាដែលផ្ទុយនឹងស្មារតីនៃរដ្ឋធម្មនុញ្ញនេះ ។

រដ្ឋធម្មនុញ្ញនេះ ត្រូវបានសភាធម្មនុញ្ញអនុម័ត
នៅភ្នំពេញថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ១៩៩៣ នាសម័យប្រជុំពេញអង្គលើកទី២
ភ្នំពេញ ថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ១៩៩៣

**ប្រធាន**



**ស៊ីន សាន**

ឧបសម្ព័ន្ធទី១

# ទង់ជាតិ



## ភ្លេងជាតិ នគររាជ

១- សូមពួកទេព្តា រក្សា មហាក្សត្រយើង
ឱ្យ បានរុងរឿង ដោយជ័យមង្គល សិរីសួស្តី
យើងខ្ញុំព្រះអង្គ សូមជ្រកក្រោមម្លប់ព្រះបារមី
នៃព្រះនរបតី វង្សក្សត្រាដែលសាងប្រាសាទថ្ម
គ្រប់គ្រងដែនខ្មែរ បុរាណថ្កើងថ្កាន ៗ

២- ប្រាសាទសីលា កំបាំងកណ្ដាលព្រៃ
គួរឱ្យស្រមៃ នឹកដល់យសសក្តិ មហានគរ
ជាតិខ្មែរដូចថ្ម គង់វង្សនៅល្អ រឹងប៉ឹងជំហរ
យើងសង្ឃឹមពរ ភ័ព្វព្រេងសំណាងរបស់កម្ពុជា
មហារដ្ឋកើតមាន យូរអង្វែងហើយ ៗ

៣- គ្រប់វត្តអារាម ឮតែសូរស័ព្ទធម៌
សូត្រដោយអំណរ រំឭកគុណពុទ្ធសាសនា
ចូរយើងជាអ្នក ជឿជាក់ស្មោះស្ម័គ្រ តាមបែបដូនតា
គង់តែទេវតា នឹងជួយជ្រោមជ្រែងផ្គត់ផ្គង់ប្រយោជន៍ឱ្យ
ដល់ប្រទេសខ្មែរ ជាមហានគរ ៗ

# ភ្លេងជាតិ


Andante ♩ = 60
១.សូម ពួក ទេ - វតា រ - ក្សា មហា ក្សត្រ
លា កំ - បាំង ក - ណ្ដាល
រាម ឮ តែ សូរ សព្ទ
យើង ___ ឱ្យ ___ បាន រុង រឿង ដោយ ជ័យ ម - ង្គល ___ សិរី សួ -
ព្រៃ ___ គួរ ___ ឱ្យ ស្រ - មៃ នឹក ដល់ យស សក្តិ ___ ម - ហា ន -
ធម៌ ___ សូត្រ ___ ដោយ អំ ណរ រំ - លឹក គុណ ពុ - ទ្ធ សា - ស
ស្ដី យើង ខ្ញុំ ព្រះ អង្គ សូម ជ្រក ក្រោម ម្លប់ ព្រះ បា - រ -
គរ ជាតិ ខ្មែរ ដូច ថ្ម គង់ វង់ នៅ ល្អ រឹង ប៉ឹង ជំ -
នា ចូរ យើង ជា អ្នក ជឿ ជាក់ ស្មោះ ស្ម័គ្រ តាម បែប ដូន
- មី នៃ ___ ព្រះ នរប - តី វង្ស ក្ស - ត្រា ដែល សាង ប្រា - សាទ ថ្ម គ្រប់
- ហរ យើង ___ ស - ង្ឃឹម ពរ ភ័ព្វ ព្រេង សំ - ណាង - រ - បស់ កម្ពុ ជា មហា
តា គង់ ___ តែ ទេ - វតា នឹង ជួយ ជ្រោម ជ្រែង ផ្គត់ ផ្គង់ ប្រយោជន៍ ___ ឱ្យ ដល់
គ្រង ដែន ខ្មែរ បុ - រាណ ថ្កើង ថ្កាន។ ២.ប្រា - សាទ សី
រដ្ឋ កើត មាន យូរ អ - ង្វែង ហើយ។ ៣.គ្រប់ វត្ត អា
ប្រ ទេស ខ្មែរ ជា មហា ន - - - - - - - គរ

# សញ្ញាជាតិ



ឧបសម្ព័ន្ធទី៤

# សច្ចាប្រណិធាន

# នៃ

# ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា

**ខ្ញុំតាំងសច្ចាថានឹងប្រព្រឹត្តតាមរដ្ឋធម្មនុញ្ញ និង ច្បាប់**

**ទាំងឡាយនៃព្រះរាជាណាចក្រ ហើយនឹងតាំងចិត្តធ្វើផល**

**ប្រយោជន៍ដល់រដ្ឋ និង ប្រជារាស្ត្រ ។**

# សច្ចាប្រណិធាន

ទូលព្រះបង្គំ

យើងខ្ញុំ

ប្រធាន អនុប្រធាន និង សមាជិករដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា

សូមធ្វើសច្ចាប្រណិធាន

នៅចំពោះព្រះភ័ក្ត្រព្រះមហាក្សត្រ ព្រះភ័ក្ត្រនៃសម្តេចព្រះសង្ឃរាជ

និងទេវតារក្សាស្វេតច្ឆត្រ

ដូចតទៅ ÷

- ក្នុងពេលប្រតិបត្តិការ តាមមុខតំណែងខ្លួន និង ក្នុងការបំពេញបេសកកម្ម ដែលប្រជារាស្ត្រកម្ពុជាបានប្រគល់ជូនចំពោះទូលព្រះបង្គំយើងខ្ញុំគ្រប់ៗរូប ទូលព្រះបង្គំយើងខ្ញុំ សូមប្តេជ្ញាគោរពរដ្ឋធម្មនុញ្ញ បម្រើជានិច្ច ទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងអនាគត នូវផលប្រយោជន៍របស់ប្រជារាស្ត្រ ប្រជាជាតិ និង មាតុភូមិកម្ពុជា ។ ទូលព្រះបង្គំយើងខ្ញុំ សូមសច្ចាថា មិនកេងប្រវ័ញ្ចនូវផលប្រយោជន៍ជាតិ សម្រាប់ផ្ទាល់ខ្លួន ឬ សម្រាប់គ្រួសារ ឬ សម្រាប់បក្សពួក ឬ សម្រាប់ភាគីរៀងៗ ខ្លួនឡើយ ។

- ទូលព្រះបង្គំយើងខ្ញុំ សូមប្តេជ្ញាប្តូរផ្តាច់ហ៊ានបូជាជីវិត ដើម្បីការពារជានិច្ច ទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងអនាគត នូវ :

. ឯករាជ្យភាពទាំងស្រុងនៃមាតុភូមិកម្ពុជា

. អធិបតេយ្យភាពជាតិពេញបរិបូរណ៍

. បូរណភាពទឹកដីដ៏ត្រឹមត្រូវតាមច្បាប់ នៅក្នុងព្រំដែនដីគោក និង ព្រំដែនសមុទ្រ ដែលកម្ពុជាធ្លាប់មានក្នុងជំនាន់ឆ្នាំ១៩៦៣ ដល់ ឆ្នាំ១៩៦៩

. ឯកភាពជាតិ ហើយមិនអនុញ្ញាតឱ្យមានការបែងចែក ឬ ការធ្វើអបគមន៍ណាមួយឡើយ ។

- ទូលព្រះបង្គំយើងខ្ញុំ សូមប្តេជ្ញារក្សាទុកជានិច្ច ទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងអនាគត នូវអព្យាក្រឹតភាព និង ភាពមិនចូលបក្សសម្ព័ន្ធសម្រាប់កម្ពុជា ហើយមិនអនុញ្ញាតជាដាច់ខាតឱ្យជនណាក៏ដោយដែលចង់ជ្រៀតជ្រែកចូលក្នុងផ្ទៃក្នុងនៃកម្ពុជា ឬមកបង្គាប់បញ្ជា ចំពោះគោលនយោបាយជាតិ និង អន្តរជាតិរបស់កម្ពុជាបានឡើយ ។ ទូលព្រះបង្គំយើងខ្ញុំមិនបម្រើជាដាច់ខាតនូវផលប្រយោជន៍បរទេស ហើយធ្វើឱ្យខូចខាតដល់ផលប្រយោជន៍របស់ប្រជារាស្ត្រ ប្រជាជាតិ និង មាតុភូមិកម្ពុជាឡើយ ។

- ក្នុងការដោះស្រាយបញ្ហាទាំងឡាយលើផ្ទៃរាបជាតិ និង អន្តរជាតិ ទូលព្រះបង្គំយើងខ្ញុំ នឹងបំបាត់ចោលទាំងស្រុងនូវអំពើហឹង្សាគ្រប់បែបយ៉ាង ។

ប៉ុន្តែព្រះរាជាណាចក្រកម្ពុជា សូមរក្សាទុកនូវសិទ្ធិកាន់អាវុធតស៊ូប្រឆាំងនឹងការរំលោភឈ្លានពានមកពីក្រៅ ដើម្បីការពារជាតិមាតុភូមិខ្លួន ។

- ទូលព្រះបង្គំយើងខ្ញុំ សូមប្តេជ្ញាគោរពជានិច្ច ទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងអនាគត នូវលទ្ធិប្រជាធិបតេយ្យ សេរីនិយម ដែលមានរបបសភា និង ពហុបក្ស ព្រមទាំងមានការគោរព

យ៉ាងម៉ឺងម៉ាត់ចំពោះសិទ្ធិមនុស្ស ដូចមានចែងក្នុងសេចក្តីប្រកាសជាសកលស្តីអំពីសិទ្ធិមនុស្ស ។

- ទូលព្រះបង្គំយើងខ្ញុំ សូមប្តេជ្ញាតស៊ូប្រឆាំងអំពើពុករលួយគ្រប់បែបយ៉ាង ប្រឆាំងអយុត្តិធម៌សង្គម ហើយតស៊ូដើម្បីផ្សះផ្សាជាតិ ដើម្បីឯកភាពជាតិ ដើម្បីសន្តិភាពសង្គម និងសន្តិភាពជាតិ ដើម្បីភាពសម្បូរសប្បាយនៃប្រជារាស្ត្រកម្ពុជា និង ដើម្បីភាពរុងរឿងថ្កើងថ្កាននៃមាតុភូមិកម្ពុជា ជាទីគោរពសក្ការៈ និង ជាទីស្នេហានៃទូលព្រះបង្គំយើងខ្ញុំគ្រប់រូប ។

ឧបសម្ព័ន្ធ ៦

# សច្ចាប្រណិធាន

ទូលព្រះបង្គំ

យើងខ្ញុំ

នាយករដ្ឋមន្ត្រី និង សមាជិករាជរដ្ឋាភិបាល

សូមធ្វើសច្ចាប្រណិធាន

នៅចំពោះព្រះភ័ក្ត្រព្រះមហាក្សត្រ ព្រះភ័ក្ត្រនៃសម្តេចព្រះសង្ឃរាជ

និងទេវតារក្សាស្វេតច្ឆត្រ

ដូចតទៅ ÷

- ក្នុងពេលប្រតិបត្តិការ តាមមុខតំណែងខ្លួន និង ក្នុងការបំពេញបេសកកម្ម ដែលប្រជារាស្ត្រកម្ពុជាបានប្រគល់ជូនចំពោះទូលព្រះបង្គំយើងខ្ញុំគ្រប់ៗរូប ទូលព្រះបង្គំយើងខ្ញុំ សូមប្តេជ្ញាគោរពរដ្ឋធម្មនុញ្ញ បម្រើជានិច្ច ទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងអនាគត នូវផលប្រយោជន៍របស់ប្រជារាស្ត្រប្រជាជាតិ និង មាតុភូមិកម្ពុជា ។ ទូលព្រះបង្គំយើងខ្ញុំ សូមសច្ចាថា មិនកេងប្រវ័ញ្ច នូវផលប្រយោជន៍ជាតិ សម្រាប់ផ្ទាល់ខ្លួន ឬ សម្រាប់គ្រួសារ ឬ សម្រាប់បក្សពួក ឬ សម្រាប់ភាគីរៀងៗ ខ្លួនឡើយ ។

- ទូលព្រះបង្គំយើងខ្ញុំ សូមប្តេជ្ញាប្តូរផ្តាច់ហ៊ានបូជាជីវិត ដើម្បីការពារជានិច្ច ទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងអនាគត នូវ :

. ឯករាជ្យភាពទាំងស្រុងនៃមាតុភូមិកម្ពុជា

. អធិបតេយ្យភាពជាតិពេញបរិបូរណ៍

. បូរណភាពទឹកដីដ៏ត្រឹមត្រូវតាមច្បាប់ នៅក្នុងព្រំដែនដីគោក និង ព្រំដែនសមុទ្រ ដែលកម្ពុជាធ្លាប់មានក្នុងជំនាន់ឆ្នាំ១៩៦៣ ដល់ ឆ្នាំ១៩៦៩

. ឯកភាពជាតិ ហើយមិនអនុញ្ញាតឱ្យមានការបែងចែក ឬ ការធ្វើអបគមន៍ណាមួយឡើយ ។

- ទូលព្រះបង្គំយើងខ្ញុំ សូមប្តេជ្ញារក្សាទុកជានិច្ច ទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងអនាគត នូវអព្យាក្រឹតភាព និង ភាពមិនចូលបក្សសម្ព័ន្ធសម្រាប់កម្ពុជា ហើយមិនអនុញ្ញាតជាដាច់ខាត ឱ្យជនណាក៏ដោយដែលចង់ជ្រៀតជ្រែកចូលក្នុងផ្ទៃក្នុងនៃកម្ពុជា ឬមកបង្គាប់បញ្ជាចំពោះគោលនយោបាយជាតិ និង អន្តរជាតិរបស់កម្ពុជាបានឡើយ ។ ទូលព្រះបង្គំយើងខ្ញុំ មិនបម្រើជាដាច់ខាតនូវផលប្រយោជន៍បរទេស ហើយធ្វើឱ្យខូចខាតដល់ផលប្រយោជន៍របស់ប្រជារាស្ត្រ ប្រជាជាតិ និង មាតុភូមិកម្ពុជាឡើយ ។

- ក្នុងការដោះស្រាយបញ្ហាទាំងឡាយ លើផ្ទៃរាបជាតិ និង អន្តរជាតិ ទូលព្រះបង្គំយើងខ្ញុំ នឹងបំបាត់ចោលទាំងស្រុងនូវអំពើហឹង្សាគ្រប់បែបយ៉ាង ។

ប៉ុន្តែព្រះរាជាណាចក្រកម្ពុជា សូមរក្សាទុកនូវសិទ្ធិកាន់អាវុធតស៊ូ ប្រឆាំងនឹងការរំលោភឈ្លានពានមកពីក្រៅ ដើម្បីការពារជាតិមាតុភូមិខ្លួន ។

- ទូលព្រះបង្គំយើងខ្ញុំ សូមប្តេជ្ញាគោរពជានិច្ច ទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងអនាគត នូវលទ្ធិប្រជាធិបតេយ្យ សេរីនិយម ដែលមានរបបសភា និង ពហុបក្ស ព្រមទាំងមានការគោរព

យ៉ាងម៉ឹងម៉ាត់ចំពោះសិទ្ធិមនុស្ស ដូចមានចែងក្នុងសេចក្តីប្រកាសជាសកលស្តីអំពីសិទ្ធិមនុស្ស ។

ទូលព្រះបង្គំយើងខ្ញុំ សូមប្តេជ្ញាតស៊ូប្រឆាំងអំពើពុករលួយគ្រប់បែបយ៉ាង ប្រឆាំងអយុត្តិធម៌សង្គម ហើយតស៊ូដើម្បីផ្សះផ្សាជាតិ ដើម្បីឯកភាពជាតិ ដើម្បីសន្តិភាពសង្គម និងសន្តិភាពជាតិ ដើម្បីភាពសម្បូរសប្បាយនៃប្រជារាស្ត្រកម្ពុជា និង ដើម្បីភាពរុងរឿងថ្កើងថ្កាននៃមាតុភូមិកម្ពុជា ជាទីគោរពសក្ការៈ និង ជាទីស្នេហានៃទូលព្រះបង្គំយើងខ្ញុំគ្រប់រូប ។

ឧបសម្ព័ន្ធទី៧

# សច្ចាប្រណិធាន

ទូលព្រះបង្គំ

យើងខ្ញុំ

ប្រធាន អនុប្រធាន និង សមាជិកព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា

សូមធ្វើសច្ចាប្រណិធាន

នៅចំពោះព្រះភ័ក្ត្រព្រះមហាក្សត្រ ព្រះភ័ក្ត្រនៃសម្តេចព្រះសង្ឃរាជ

និងទេវតារក្សាស្វេតច្ឆត្រ

ដូចតទៅ ÷

- ក្នុងពេលប្រតិបត្តិការ តាមមុខតំណែងខ្លួន និង ក្នុងការបំពេញបេសកកម្ម ដែលប្រជារាស្ត្រកម្ពុជា បានប្រគល់ជូនចំពោះទូលព្រះបង្គំយើងខ្ញុំគ្រប់ៗរូប ទូលព្រះបង្គំយើងខ្ញុំ សូមប្តេជ្ញាគោរពរដ្ឋធម្មនុញ្ញ បម្រើជានិច្ច ទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងអនាគត នូវផលប្រយោជន៍របស់ប្រជារាស្ត្រ ប្រជាជាតិ និង មាតុភូមិកម្ពុជា ។ ទូលព្រះបង្គំយើងខ្ញុំ សូមសច្ចាថា មិនកេងប្រវ័ញ្ចនូវផលប្រយោជន៍ជាតិ សម្រាប់ផ្ទាល់ខ្លួន ឬ សម្រាប់គ្រួសារ ឬ សម្រាប់បក្សពួក ឬ សម្រាប់ភាគីរៀងៗ ខ្លួនឡើយ ។

- ទូលព្រះបង្គំយើងខ្ញុំ សូមប្តេជ្ញាប្តូរផ្តាច់ហ៊ានបូជាជីវិត ដើម្បីការពារជានិច្ច ទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងអនាគត នូវ :

. ឯករាជ្យភាពទាំងស្រុងនៃមាតុភូមិកម្ពុជា

. អធិបតេយ្យភាពជាតិពេញបរិបូរណ៍

. បូរណភាពទឹកដីដ៏ត្រឹមត្រូវតាមច្បាប់ នៅក្នុងព្រំដែនដីគោក និង ព្រំដែនសមុទ្រដែលកម្ពុជាធ្លាប់មានក្នុងជំនាន់ឆ្នាំ១៩៦៣ ដល់ ឆ្នាំ១៩៦៩

. ឯកភាពជាតិ ហើយមិនអនុញ្ញាតឱ្យមានការបែងចែក ឬ ការធ្វើអបគមន៍ណាមួយឡើយ ។

- ទូលព្រះបង្គំយើងខ្ញុំ សូមប្តេជ្ញារក្សាទុកជានិច្ច ទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងអនាគត នូវអព្យាក្រឹតភាព និង ភាពមិនចូលបក្សសម្ព័ន្ធសម្រាប់កម្ពុជា ហើយមិនអនុញ្ញាតជាដាច់ខាតឱ្យជនណាមួយក៏ដោយដែលចង់ជ្រៀតជ្រែកចូលក្នុងផ្ទៃក្នុងនៃកម្ពុជា ឬ មកបង្គាប់បញ្ជាចំពោះគោលនយោបាយជាតិ និង អន្តរជាតិរបស់កម្ពុជាបានឡើយ ។ ទូលព្រះបង្គំយើងខ្ញុំ មិនបម្រើជាដាច់ខាតនូវផលប្រយោជន៍បរទេស ហើយធ្វើឱ្យខូចខាតដល់ផលប្រយោជន៍របស់ប្រជារាស្ត្រ ប្រជាជាតិ និង មាតុភូមិកម្ពុជាឡើយ ។

- ក្នុងការដោះស្រាយបញ្ហាទាំងឡាយលើផ្ទៃរាបជាតិ និង អន្តរជាតិ ទូលព្រះបង្គំយើងខ្ញុំ នឹងបំបាត់ចោលទាំងស្រុងនូវអំពើហឹង្សាគ្រប់បែបយ៉ាង ។

ប៉ុន្តែព្រះរាជាណាចក្រកម្ពុជា សូមរក្សាទុកនូវសិទ្ធិកាន់អាវុធតស៊ូប្រឆាំងនឹងការរំលោភឈ្លានពានមកពីក្រៅ ដើម្បីការពារជាតិមាតុភូមិខ្លួន ។

- ទូលព្រះបង្គំយើងខ្ញុំ សូមប្តេជ្ញាគោរពជានិច្ច ទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងអនាគត នូវលទ្ធិប្រជាធិបតេយ្យ សេរីនិយម ដែលមានរបបសភា និង ពហុបក្ស ព្រមទាំងមានការគោរពយ៉ាងម៉ឺងម៉ាត់ចំពោះសិទ្ធិមនុស្ស ដូចមានចែងក្នុងសេចក្តីប្រកាសជាសកលស្តីអំពីសិទ្ធិមនុស្ស ។

- ទូលព្រះបង្គំយើងខ្ញុំ សូមប្តេជ្ញាតស៊ូប្រឆាំងអំពើពុករលួយគ្រប់បែបយ៉ាង ប្រឆាំងអយុត្តិធម៌សង្គម ហើយតស៊ូដើម្បីផ្សះផ្សាជាតិ ដើម្បីឯកភាពជាតិ ដើម្បីសន្តិភាពសង្គម និងសន្តិភាពជាតិ ដើម្បីភាពសម្បូរសប្បាយនៃប្រជារាស្ត្រកម្ពុជា និង ដើម្បីភាពរុងរឿងថ្កើងថ្កាននៃមាតុភូមិកម្ពុជា ជាទីគោរពសក្ការៈ និង ជាទីស្នេហានៃទូលព្រះបង្គំយើងខ្ញុំគ្រប់រូប ។

## គណៈកម្មការអចិន្ត្រៃយ៍រៀបរៀងរដ្ឋធម្មនុញ្ញបានអនុម័ត
## ដោយសភាធម្មនុញ្ញនាសម័យប្រជុំពេញអង្គលើកទី១
## ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ១៩៩៣

១-ឯកឧត្តមសម្តេចប្រធានសភាធម្មនុញ្ញ ឬ ឯកឧត្តម អនុប្រធាន សភាធម្មនុញ្ញ " ករណីសម្តេចប្រធានអវត្តមាន " ជាប្រធាន*

២-ឯកឧត្តម ចែម ស្ងួន ជាអនុប្រធាន

៣-ឯកឧត្តមបណ្ឌិត តាវ សេងហួរ ជាអ្នករាយការណ៍

៤-ឯកឧត្តម កាន់ ម៉ន ជាសមាជិក

៥-ឯកឧត្តម គាត ឈន់ ជាសមាជិក

៦-ឯកឧត្តម ឈួរ លាងហួត ជាសមាជិក

៧-ឯកឧត្តម ថៅ ប៉េងលាត ជាសមាជិក

៨-ឯកឧត្តម សម រង្ស៊ី ជាសមាជិក

៩-អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ ស៊ីរីរត្ន ជាសមាជិក

១០-ឯកឧត្តម សឺន ស៊ូប៊ែរ្ដិ៍ ជាសមាជិក

១១-ឯកឧត្តម សោម ចាន់បុត្រ ជាសមាជិក

១២-ឯកឧត្តម អ៊ុន នឹង ជាសមាជិក

| | | | |
|---|---|---|---|
| ១៣-ឯកឧត្តម | ឡូយ | ស៊ីមឈាង | ជាសមាជិក |
| ១៤-ឯកឧត្តម | ជាម | យៀប | ជាសមាជិកបម្រុង |
| ១៥-ឯកឧត្តម | ប៉ុល | ហំម | ជាសមាជិកបម្រុង |
| ១៦-ឯកឧត្តម | ពូ | សុធីរៈ | ជាសមាជិកបម្រុង |
| ១៧-ឯកឧត្តម | សរ | សារអាត | ជាសមាជិកបម្រុង |
| ១៨-ឯកឧត្តម | អ៊ឹង | គៀត | ជាសមាជិកបម្រុង |
| ១៩-ឯកឧត្តម | អ៊ុក | រ៉ាប៊ុន | ជាសមាជិកបម្រុង |
| ២០-ឯកឧត្តម | អ៊ុង | ផន | ជាសមាជិកបម្រុង |
| ២១-ឯកឧត្តម | ឯក | សំអុល | ជាសមាជិកបម្រុង |
| ២២-ឯកឧត្តម | សាយ | បូរី | ជាអ្នកជំនាញការ |
| ២៣-ឯកឧត្តម | ចាន់ | សុខ** | ជាអ្នកជំនាញការ |
| ២៤-ឯកឧត្តម | ឈន | អៀម | ជាអ្នកជំនាញការ |
| ២៥-ឯកឧត្តម | ហេង | វង្សប៊ុនឆាត | ជាអ្នកជំនាញការ |
| ២៦-ឯកឧត្តម | ខៀវ | រ៉ាដា | ជាអ្នកជំនាញការ |

កំណត់សម្គាល់ : *យោងជំពូក ៧ ប្រការ ១៨ ស្តីពីគណៈកម្មការ និង ប្រធានគណៈកម្មការសភាធម្មនុញ្ញ

**ឈ្មោះសរសេរត្រឹមត្រូវ ចាន់ សុក

# ព្រះរាជក្រម

**យើង**

**ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ វរ្ម័ន**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

យោងតាមមាត្រា ១៣៥ និង ១៣៦ នៃជំពូកទី១៤ ស្តីពីអន្តរប្បញ្ញត្តិនៃរដ្ឋធម្មនុញ្ញ ព្រះរាជាណាចក្រកម្ពុជា អនុម័តដោយសភាធម្មនុញ្ញ នៅថ្ងៃទី២១ ខែ កញ្ញា គ.ស ១៩៩៣ ។

**ត្រាស់បង្គាប់**

**មាត្រា ១ :** ប្រកាសឱ្យប្រើជាផ្លូវការភ្លាមនូវរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលសភាធម្មនុញ្ញបានអនុម័តនៅថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ១៩៩៣ ។

**មាត្រា ២ :** សភាធម្មនុញ្ញបានត្រឡប់ទៅជារដ្ឋសភានៃកម្ពុជាចាប់ពីពេលនេះ តទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ កញ្ញា គ.ស ១៩៩៣

**នរោត្តម សីហនុ**

# ច្បាប់ធម្មនុញ្ញបន្ថែម

# សំដៅ

# ធានានូវដំណើរការជាប្រក្រតីនៃ

# ស្ថាប័នជាតិ

# ព្រះរាជក្រម

នស/រកម/០៧០៤/០០១

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សម័យប្រជុំពេញអង្គលើកទី១ នីតិកាលទី៣ នៃរដ្ឋសភា នាថ្ងៃទី ៨ ខែ កក្កដា ឆ្នាំ២០០៤
- បានទ្រង់យល់សម័យប្រជុំពេញអង្គលើកទី៩ នីតិកាលទី១ នៃព្រឹទ្ធសភា នាថ្ងៃទី១២ ខែ កក្កដា ឆ្នាំ២០០៤

- យោងតាមសំណើចុះថ្ងៃទី១២ ខែ កក្កដា ឆ្នាំ២០០៤ របស់ព្រឹទ្ធសមាជិករដ្ឋសភា នីតិកាលទី៣

## ប្រកាសឱ្យប្រើ

ច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ២០០៤ នាសម័យប្រជុំពេញអង្គលើកទី១ នីតិកាលទី៣ ហើយដែលព្រឹទ្ធសភាបានឱ្យយោបល់យល់ព្រមកាលពីថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ២០០៤ នាសម័យប្រជុំពេញអង្គលើកទី៩ នីតិកាលទី១ ហើយដែលមានសេចក្ដីទាំងស្រុងដូចតទៅ ៖

## ច្បាប់ធម្មនុញ្ញបន្ថែម
## សំដៅ
## ធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ

**មាត្រា ១ .-**

ច្បាប់ធម្មនុញ្ញនេះ មានគោលដៅធានាក្នុងគ្រប់កាលៈទេសៈនូវដំណើរការល្អប្រសើរនៃស្ថាប័នជាតិ ដោយគោរពទៅតាមគោលការណ៍ជាមូលដ្ឋាន នៃលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស សមស្របតាមតម្រូវការនៃភាពចាំបាច់ ។

**មាត្រា ២ .-**

នៅដើមនីតិកាលថ្មីនីមួយៗ រដ្ឋសភា ក្រោមអធិបតីភាពព្រឹទ្ធសមាជិករដ្ឋសភា មុននឹងផ្តើមការងាររបស់ខ្លួន និង ក្រោយពេលសំរេចអំពីសុពលភាពនៃអាណត្តិរបស់សមាជិកម្នាក់ៗ អាចចាប់ផ្តើមអនុម័តអត្ថបទដែលមានចារិកជារដ្ឋធម្មនុញ្ញ ឬ ច្បាប់ ដើម្បីអនុវត្តបាននូវគោលដៅដូចមានចែងក្នុងមាត្រា ១ ។

អត្ថបទទាំងនេះ ក្រោយពីបានត្រូវទទួលការបោះឆ្នោតអនុម័តដោយរដ្ឋសភារួចហើយ ត្រូវតែបានទទួលជាបន្ទាន់នូវចំណាត់ការដោយរួសរាន់ពីសំណាក់ព្រឹទ្ធសមាជិករដ្ឋសភា តាមនីតិវិធីកំណត់សំរាប់អត្ថបទទាំងនោះ រហូតដល់ពេលដែលត្រូវបានប្រកាសអោយចូលជាធរមាន។

**មាត្រា ៣ .-**

ក្នុងករណីដែលឃើញថា នីតិវិធីនៃមាត្រា ៨២ និង ១១៩ ថ្មី នៃរដ្ឋធម្មនុញ្ញ មិនអាចសំរេចបាន រដ្ឋសភាតាមសំណើររបស់គណបក្សដែលមានអាសនៈច្រើនជាងគេនៅក្នុងរដ្ឋសភា អាចដំណើរការការបោះឆ្នោតជាកញ្ចប់ ដើម្បីជ្រើសតាំងប្រធាន អនុប្រធានរដ្ឋសភា ក៏ដូចជាប្រធាន និង អនុប្រធានគណៈកម្មការ ក្នុងពេលជាមួយគ្នា និង ការផ្តល់សេចក្តីទុកចិត្តចំពោះរាជរដ្ឋាភិបាល ។

**មាត្រា ៤ .-**

ការរៀបចំបញ្ជីរាយនាមបេក្ខជន ដើម្បីបោះឆ្នោតជ្រើសតាំង និង ផ្តល់សេចក្តីទុកចិត្តត្រូវអនុវត្តដូចតទៅ :

- បញ្ជីរាយនាមបេក្ខជនប្រធាន អនុប្រធាននៃរដ្ឋសភា ក៏ដូចជាប្រធាន និង អនុប្រធានគណៈកម្មការជំនាញទាំងអស់នៃរដ្ឋសភា ត្រូវរៀបចំ និង ស្នើដោយគណបក្សនយោបាយដែលព្រមព្រៀងគ្នា ដើម្បីបង្កើតរាជរដ្ឋាភិបាលចំរុះ ហើយត្រូវផ្ញើជូនព្រឹទ្ធសមាជិករដ្ឋសភា ។

- តាមសេចក្តីស្នើពីគណបក្សនយោបាយ ដែលមានចំនួនអាសនៈច្រើនជាងគេនៅក្នុងរដ្ឋសភា តាមរយៈព្រឹទ្ធសមាជិករដ្ឋសភា ព្រះមហាក្សត្រទ្រង់ចាត់តាំងវរជនមួយរូបក្នុងចំណោមតំណាងរាស្ត្រនៃគណបក្សនយោបាយដែលឈ្នះឆ្នោតអោយបង្កើតរាជរដ្ឋាភិបាល ។

វរជនដែលត្រូវបានចាត់តាំងនេះ ត្រូវរៀបចំផ្គូរផ្គងតំណែងផ្សេងៗ ក្នុងរាជរដ្ឋាភិបាល រួចផ្ញើបញ្ជីរាយនាមសមាជិកទាំងអស់នៃរាជរដ្ឋាភិបាលជូនព្រឹទ្ធសមាជិករដ្ឋសភា ។

- ព្រឹទ្ធសមាជិករដ្ឋសភា ត្រូវរៀបចំបញ្ជីរាយនាមជាកញ្ចប់មួយនូវបេក្ខជន ប្រធាន អនុប្រធាននៃរដ្ឋសភា ក៏ដូចជាប្រធាន និង អនុប្រធានគណៈកម្មការជំនាញទាំងអស់នៃរដ្ឋសភា ព្រមទាំងបេក្ខជននាយករដ្ឋមន្ត្រី និង សមាជិកទាំងអស់នៃរាជរដ្ឋាភិបាល ដើម្បីដាក់ជូនរដ្ឋសភាបោះឆ្នោត ។

**មាត្រា ៥ .-**

នៅក្នុងដំណើរការនៃការបោះឆ្នោតជាកញ្ចប់ មិនអាចជជែកពិភាក្សាអ្វីឡើយ ហើយក៏មិនអាចមានការពន្យល់អំពីការបោះឆ្នោតនេះ ក្រោយការប្រកាសលទ្ធផលនៃការបោះឆ្នោតជាកញ្ចប់នេះដែរ ។

សមាជិករដ្ឋសភា ត្រូវធ្វើការបោះឆ្នោតដោយបញ្ជាក់ថា ព្រម ឬ មិនព្រម ចំពោះបញ្ជីរាយនាមជាកញ្ចប់មួយ ដែលព្រឹទ្ធសមាជិករដ្ឋសភាបានដាក់ជូន ។ ការបោះឆ្នោតនេះត្រូវធ្វើឡើងដោយវិធីលើកដៃ ។

**មាត្រា ៦ .- ថ្មី នៃច្បាប់ធម្មនុញ្ញបន្ថែម**

ការបោះឆ្នោតជាកញ្ចប់ខាងលើនេះ ត្រូវយកតាមមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

ក្នុងករណីការបោះឆ្នោតជុំទីមួយមិនបានសម្រេច នីតិវិធីដដែលនេះនឹងត្រូវអនុវត្តចំពោះការបោះឆ្នោតជុំក្រោយៗទៀត ។

**មាត្រា ៧ .-**

ច្បាប់ធម្មនុញ្ញបន្ថែមនេះ ត្រូវបានប្រកាសជាការប្រញាប់ និង យកមកអនុវត្តចាប់តាំងពីដើមនីតិកាលបច្ចុប្បន្ននេះទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០០៤

**ក្នុងព្រះបរមនាម និង តាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និង ព្រះរាជលញ្ឆករ**

**ញឹក ប៊ុនឆៃ**

ពរល. ០៤.០៧.១១៧

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**ព្រឹទ្ធសមាជិក និង ជាប្រធានអង្គប្រជុំរដ្ឋសភា**

**ហត្ថលេខា**

**ជា សុទ្ធ**

លេខៈ ៩៧០ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កក្កដា ឆ្នាំ២០០៤

អគ្គលេខាធិការរាជរដ្ឋាភិបាល

# កំណត់សម្គាល់

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ នេះ បានធ្វើវិសោធនកម្ម ចំនួន ៦ លើកគឺ :

**១**-ច្បាប់ធម្មនុញ្ញស្តីពីការកែប្រែមាត្រា ២៨ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា អនុម័តនៅថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ១៩៩៤ នាសម័យប្រជុំវិសាមញ្ញរបស់រដ្ឋសភា នីតិកាលទី១ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ១៩៩៤ ។

**២**-ច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី៨ ដល់ជំពូកទី១៤ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា អនុម័តនៅថ្ងៃទី ០៤ ខែ មីនា ឆ្នាំ១៩៩៩ នាសម័យប្រជុំវិសាមញ្ញរបស់រដ្ឋសភា នីតិកាលទី២ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ១៩៩៩ ។

**៣**-ច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា ១៩ និង មាត្រា ២៩ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា អនុម័តនៅថ្ងៃទី ២ ខែ កក្កដា ឆ្នាំ២០០១ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី២ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០១/១១ ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ២០០១ ។

**៤**-ច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា ៨៨ និង មាត្រា ១១១ ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា អនុម័តនៅថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ២០០៥ នាសម័យប្រជុំពេញអង្គលើកទី២ នីតិកាលទី៣ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦០៥/០១៨ ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ២០០៥ ។

**៥**-ច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា ៨២ មាត្រា ៨៨ ថ្មី មាត្រា ៩០ ថ្មី មាត្រា ៩៨ មាត្រា ១០៦ ថ្មី មាត្រា ១១១ ថ្មី (មួយ) មាត្រា ១១៤ ថ្មី នៃរដ្ឋធម្មនុញ្ញ និងមាត្រា ៦ នៃច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ ដែលរដ្ឋសភាអនុម័តនៅថ្ងៃទី ០២ ខែ មីនា ឆ្នាំ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី៤ នីតិកាលទី៣ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣០៦/០០៦ ចុះថ្ងៃទី ០៩ ខែ មីនា ឆ្នាំ២០០៦ ។

**៦**-ច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា ១៤៥ ថ្មី និងមាត្រា ១៤៦ ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១៥ ខែ មករា ឆ្នាំ២០០៨ នាសម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៣ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២០៨/០០៨ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០០៨ ។

# ព្រះរាជក្រម

## យើង

## ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ វរ្ម័ន
## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
## ព្រះចៅក្រុងកម្ពុជាធិបតី

យោងតាមមាត្រា ១១ ជំពូកទី២ អំពីព្រះមហាក្សត្រ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានសភាធម្មនុញ្ញអនុម័ត នៅថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ១៩៩៣ ។

## បង្គាប់

**មាត្រា ១ :** ប្រកាសឱ្យប្រើជាផ្លូវការនូវច្បាប់ស្តីពីការកែប្រែមាត្រា ២៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ១៩៩៤ ។

**មាត្រា ២ :** ព្រះរាជក្រមនេះចូលជាធរមានច្បាប់ ចាប់ពីពេលចុះហត្ថលេខានេះតទៅ ។

ធ្វើនៅព្រះរាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ១៩៩៤

ក្នុងព្រះបរមនាម និង តាមព្រះរាជចំណារ

**ប្រមុខរដ្ឋស្តីទី**

**ជា ស៊ីម**

**ព្រះរាជក្រម**

នស/រកម/០៣៩៩/០១

## យើង

## ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣
- បានទ្រង់យល់សម័យប្រជុំវិសាមញ្ញពេញអង្គ នៃរដ្ឋសភា នៅថ្ងៃទី ២-៣-៤ ខែ មីនា ឆ្នាំ១៩៩៩
- យោងតាមសំណើរបស់ប្រធានរដ្ឋសភា ចុះថ្ងៃទី ៦ ខែ មីនា ឆ្នាំ១៩៩៩

## ត្រាស់បង្គាប់

**មាត្រា ១ :** ប្រកាសឱ្យប្រើជាផ្លូវការនូវច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣និងមាត្រាទាំងឡាយ

នៃជំពូកទី៨ ដល់ជំពូកទី១៤ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ៤ ខែ មីនា ឆ្នាំ១៩៩៩ ។

**មាត្រា ២ :** ព្រះរាជក្រមនេះចូលជាធរមានច្បាប់ ចាប់ពីពេលឡាយព្រះហស្ដលេខានេះតទៅ ។



**នរោត្តម សីហនុ**

ធ្វើនៅថ្ងៃទី ៨ ខែ មីនា ឆ្នាំ១៩៩៩

# ព្រះរាជក្រម

នស/រកម/០៧០១/១១

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- បានទ្រង់យល់លទ្ធផលសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី២ នៅថ្ងៃ ច័ន្ទ ទី ២ ខែ កក្កដា ឆ្នាំ២០០១
- បានទ្រង់យល់លទ្ធផលសម័យប្រជុំព្រឹទ្ធសភាលើកទី៥ នីតិកាលទី១ នៅថ្ងៃ ច័ន្ទ ទី ២៣ ខែ កក្កដា ឆ្នាំ២០០១
- បានទ្រង់យល់លិខិតស្នើសុំរបស់សម្តេចព្រះប្រធានរដ្ឋសភា ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ២០០១

## ត្រាស់បង្គាប់

**មាត្រា ១ :** ប្រកាសឱ្យប្រើជាផ្លូវការនូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១៩ និង មាត្រា ២៩ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័ត នៅថ្ងៃ ច័ន្ទ ទី ២ ខែ កក្កដា ឆ្នាំ២០០១ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ ស្របលើទម្រង់ និង គតិច្បាប់នេះទាំងស្រុង កាលពីថ្ងៃ ច័ន្ទ ទី ២៣ ខែ កក្កដា ឆ្នាំ២០០១ ។

**មាត្រា ២ :** ព្រះរាជក្រមនេះចូលជាធរមាន ចាប់ពីពេលឡាយព្រះហស្តលេខានេះតទៅ ។

**នរោត្តម សីហនុ**

ធ្វើនៅភ្នំពេញ ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ២០០១

# ព្រះរាជក្រម

នស/រកម/០៦០៥/០១៨

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**

**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**

**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**

**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា

# ប្រកាសឱ្យប្រើ

ច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា ៨៨ និង មាត្រា ១១១ ថ្មី នៃរដ្ឋធម្មនុញ្ញ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ២០០៥ នាសម័យប្រជុំរដ្ឋសភាលើកទី២ នីតិកាលទី៣ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របលើទម្រង់ និង គតិនៃច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ២០០៥ នាសម័យប្រជុំពេញអង្គលើកទី៩ នីតិកាលទី១ ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ២០០៥

**ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

# ព្រះរាជក្រម

នស/រកម/០៣០៦/០០៦

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**

**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**

**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**

**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សំណើរបស់តំណាងរាស្ត្រចំនួនលើសពីមួយភាគបួននៃចំនួនតំណាងរាស្ត្រទាំងមូល

- បានទ្រង់យល់លិខិតលេខ ៨២ លស ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ២០០៦ របស់សម្តេចនាយករដ្ឋមន្ត្រី
- បានទ្រង់យល់លិខិយលេខ ០០១/០១/២០០៦ កបធ ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ២០០៦ របស់ក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជសារព្រះមហាក្សត្រ ចុះថ្ងៃទី២៧ ខែ កុម្ភៈ ឆ្នាំ២០០៦
- បានទ្រង់យល់លិខិតលេខ ២៥៤ រស ចុះថ្ងៃទី ៩ ខែ មីនា ឆ្នាំ២០០៦ របស់រដ្ឋសភា
- បានទ្រង់យល់លិខិតលេខ ០១៣/០៣០៦/ពស/នវ ចុះថ្ងៃទី០៨ ខែ មីនាឆ្នាំ២០០៦ របស់ព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និង របស់ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## ប្រកាសឱ្យប្រើ

ច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា ៨២ មាត្រា ៨៨ ថ្មី មាត្រា ៩០ ថ្មី មាត្រា ៩៨ មាត្រា ១០៦ ថ្មី មាត្រា ១១១ ថ្មី ( មួយ ) មាត្រា ១១៤ ថ្មី នៃរដ្ឋធម្មនុញ្ញ និងមាត្រា ៦ នៃច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ ដែលរដ្ឋសភាអនុម័តនៅថ្ងៃទី ០២ ខែ មីនា ឆ្នាំ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី៤ នីតិកាលទី៣ និង

ដែលព្រឹទ្ធសភាពុំមានពេលវេលាគ្រប់គ្រាន់  ដើម្បីពិនិត្យច្បាប់នេះឱ្យទាន់តាមការកំណត់របស់មាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ ថ្ងៃទី ៩ ខែ មីនា ឆ្នាំ២០០៦

**ព្រះហស្ថលេខា និង ព្រះរាជលញ្ឆករ**

**នរោត្តម  សីហមុនី**

# ព្រះរាជក្រម

នស/រកម/០២០៨/០០៨

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

# ប្រកាសឱ្យប្រើ

ច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា ១៤៥ ថ្មី និង មាត្រា ១៤៦ ថ្មី នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១៥ ខែ មករា ឆ្នាំ២០០៨ នាសម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៣ និងដែលព្រឹទ្ធសភាពុំមានពេលវេលាគ្រប់គ្រាន់ អាចពិនិត្យនិងឱ្យយោបល់ តាមល័ក្ខខ័ណ្ឌកំណត់ក្នុងមាត្រា ១១៣ថ្មី នៃរដ្ឋធម្មនុញ្ញបានឡើយ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០០៨

**ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**